ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គរុកោសល្យ

សម្រាប់ការបណ្តុះបណ្តាលបរិញ្ញា+២

ឆ្នាំ២០២៤

# បុព្វកថា

ទស្សនៈវិស័យអប់រំនាសតវត្សទី២១ បានផ្ដោតលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចពិសេស គឺការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្ពោះទៅរកគំនិតនវានុវត្តន៍ថ្មីៗសម្រាប់បម្រើឱ្យសេចក្ដីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្ដុះបណ្ដាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។

ឈរលើស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់បានដាក់ចេញនូវគោលដៅជាអាទិភាពសម្រាប់ការធ្វើកំណែទម្រង់វិស័យអប់រំដោយផ្ដែកលើសសរស្ដម្ភទាំងប្រាំរួមមាន៖១.ការអនុវត្តគោលនយោបាយគ្រូបង្រៀន ២. ការវាយតម្លៃ ៣. ការងារអធិការកិច្ច ៤. កម្មវិធីសិក្សានិងបរិស្ថាន ៥.ឧត្ដមសិក្សា។ ដោយឡែក កំណែទម្រង់គ្រូបង្រៀន និងកម្មវិធីសិក្សា ធានាឱ្យកម្ពុជាមានធនធានមនុស្សដែលមានសមត្ថភាពសម្រាប់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា នៅគ្រប់កម្រិតគ្រប់ភូមិសិក្សារហូតដល់កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងកាន់តែធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវឌ្ឍរបស់ពិភពលោក និងគោលដៅយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល កម្ពុជា ។

កម្មវិធីបណ្ដុះបណ្ដាលលើវិធីសាស្ត្របង្រៀន សម្រាប់ការកសាងឧត្ដមភាពគុណវុឌ្ឍិគ្រូបង្រៀននេះត្រូវបានរៀបចំឡើងទៅតាមទស្សនៈ និងចក្ខុវិស័យថ្មី ដោយធ្វើការសំយោគចំណេះដឹងពីកម្រិតរបស់*ប្លូមតាក់សូណូមី* រួមជាមួយនឹងខ្លឹមសារកម្មវិធីបណ្ដុះបណ្ដាលវិធីសាស្ត្របច្ចុប្បន្ន និងវិធីសាស្ត្របង្រៀនថ្មីៗ របស់ប្រទេសក្នុងតំបន់ និងពិភពលោក ដែលកំពុងនិយមប្រើប្រាស់ ការរួមបញ្ចូលទាំងបញ្ញត្តិតាមបែបវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា(STEM) ជាមួយនឹងការបញ្ជ្រាបខ្លឹមសារ " *ការអប់រំប្រកបដោយបរិយាបន្ន* " ក្នុងការបង្រៀន ដើម្បីធ្វើឱ្យសិស្សានុសិស្ស ទទួលបានចំណេះដឹង ជំនាញក្នុងជីវភាពរស់ នៅព្រមទាំងអាចចូលរួមប្រកួតប្រជែងនៅក្នុងសហគមន៍សេដ្ឋកិច្ចប្រជាជាតិអាស៊ានបាន។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា គ្រប់ស្ថាប័នអប់រំ ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ចូលរួមគាំទ្រ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តលើកម្មវិធីបណ្ដុះបណ្ដាលវិធីសាស្ត្របង្រៀននេះ ដើម្បីពង្រឹងសក្ដានុពលរបស់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះគណៈកម្មការអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាលវិធីសាស្ត្របង្រៀន អ្នកបច្ចេកទេស លោកគ្រូ អ្នកគ្រូ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាធ្វើឱ្យស្នាដៃដ៏មានសារៈសំខាន់នេះ សម្រេចបានដើម្បីជាប្រយោជន៍ដល់សង្គមជាតិយើង ។

ថ្ងៃ ខែ ឆ្នាំរោង ខែ ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**នាយកវិទ្យាស្ថានជាតិអប់រំ**

# អារម្ភកថា

ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងយកចិត្តទុកដាក់ដល់ការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច ទាំងក្នុងពេលចំពោះមុខ និងអនាគត ។

ការអប់រំគឺជាកូនសោរដ៏សំខាន់ ដើម្បីសម្រេចចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជាក្នុងការកសាងសង្គមដែលមានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋក្នុងសង្គម។ ហេតុនេះហើយ ការវិនិយោគវិស័យអប់រំ ចាំបាច់ត្រូវយកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស ចាប់ពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា ។

សៀវភៅគរុកោសល្យទូទៅនេះ ជាសៀវភៅស្តីពីនិយាម វិធីសាស្ត្រ ការអនុវត្តការបង្រៀនឱ្យមានប្រសិទ្ធភាពខ្ពស់។

ដើម្បីលើកកម្ពស់សមត្ថភាពអប់រំ និងការបង្រៀនបានល្អ គ្រូបង្រៀនត្រូវមានចំណេះដឹងផ្នែកគរុកោសល្យ ដើម្បីងាយស្រួលក្នុងការស្វែងយល់ពីលំនាំ និងដំណើរការបង្រៀន និងការសិក្សារបស់សិស្ស និស្សិត។ សៀវភៅនេះ យើងខ្ញុំសង្ឃឹមថា នឹងក្លាយជាឯកសារដ៏មានប្រយោជន៍ចំពោះគ្រូ និងគរុនិស្សិត សម្រាប់ជាជំនួយក្នុងការបង្កើនគំនិត ដើម្បីស្រាវជ្រាវបន្ថែម លើជំនាញរបស់ខ្លួន ។

ជាទីបញ្ចប់ យើងរង់ចាំទទួលជានិច្ចនូវការរិះគន់ស្ថាបនា ដើម្បីឱ្យសៀវភៅនេះកាន់តែមានគុណភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២៤

**រៀបរៀងដោយ**

**ក្រុមគ្រូឧទ្ទេសចិត្ត-គរុកោសល្យ**

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ

លោក **ឌី បុណ្ណា** នាយករងវិទ្យាស្ថានជាតិអប់រំ

លោកបណ្ឌិត **នួច ចរ៉ា** នាយករងវិទ្យាស្ថានជាតិអប់រំ

លោកស្រី **ប៊ុន សុផានី** នាយិការងវិទ្យាស្ថានជាតិអប់រំ

## គណៈកម្មការនិពន្ធ និងរៀបចំ

លោកស្រី **ឡាច ប៊ុនហ៊ាន**

លោកស្រី **តូ សុភ**

លោក **វន សុខលឿង**

លោក **ម៉ក់ ចន្ធា**

លោកស្រី **ហុង ណៃស៊ីម**

លោកស្រី **កែវ សុបូរិន្ទ**

លោក **ប៉ែន សុម៉ានីន**

លោកស្រី **សាន សោយរុក្ខា**

លោកស្រី **ហាក់ វឌ្ឍនី**

លោកស្រី **ប្រាក់ សាឈួន**

## គណៈកម្មការត្រួតពិនិត្យ

លោក **ម៉ៅ សារឿន** អនុប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

លោក **ចេង ថុន** អនុប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

លោក **អ៊ុក ញ៉ាល់** មន្ត្រីដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

លោក **អ៊ូ វណ្ណឌី** មន្ត្រីដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

លោក **សេង ឡាង** មន្ត្រីដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

# មាតិកាមេរៀន

**បុព្វកថា** ... i

**អារម្ភកថា** ... iii

**ជំពូក I បញ្ហាទូទៅនៃគរុកោសល្យ និង ទស្សនៈនៃការអប់រំសតវត្សទី២១** ... 7

**មេរៀនទី ១បញ្ហាទូទៅនៃគរុកោសល្យ** ... 7

**១.១. វត្ថុបំណងមេរៀន** ... 7

**១.២. វត្ថុបំណងនៃគរុកោសល្យទូទៅ** ... 7

**១.២.១ និយមន័យ** ... 7

**១.២.២. ធម្មជាតិពិតប្រាកដរបស់ការអប់រំ** ... 8

**១.៣.អំពើអប់រំដែលជះឥទ្ធិពលលើការអភិវឌ្ឍសង្គម** ... 9

**១.៤. ទំនាក់ទំនងរវាងការអប់រំ និងនយោបាយ** ... 11

**១.៥. កម្មវត្ថុរបស់គរុកោសល្យទូទៅ** ... 12

**១.៦. ទំនាក់ទំនងរវាងចិត្តវិទ្យា និងគរុកោសល្យ** ... 13

**១.៧. តួនាទីរបស់គរុកោសល្យក្នុងការបង្ហាត់បង្រៀន** ... 13

**មេរៀនទី២ ទស្សនៈនៃការអប់រំសតវត្សទី២១** ... 15

**២.១. វត្ថុបំណងមេរៀន** ... 15

**២.២. ការសិក្សានៅសតវត្សទី២១** ... 15

**២.៣. ជំនាញនៃការសិក្សាសតវត្សទី២១** ( Learning Skills in the 21st Century ) ... 18

**២.៣.១ ការត្រិះរិះពិចារណា** ... 19

**២.៣.២ គំនិតច្នៃប្រឌិត** ... 19

**២.៣.៣ ការប្រាស្រ័យទាក់ទង** ... 20

**២.៣.៤ កិច្ចសហការ** ... 21

**២.៤. ការអប់រំបរិយាបន្ន** ... 22

**២.៤.១ និយមន័យៈ** ... 23

**២.៤.២ ឥរិយាបថបណ្ដាលឱ្យមាន ឬមិនមានលក្ខណៈអប់រំបរិយាបន្ន** ... 23

**២.៤.៣ បញ្ញត្តិនៃជនមានពិការភាព** ... 25

២.៥. ការអប់រំភាពជាពលរដ្ឋសកល ..... 26

២.៥.១. និយមន័យ ..... 26

២.៥.២. កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណកម្មបុគ្គល ..... 26

២.៥.៣. សហគមន៍មនុស្សនានា និងទំនាក់ទំនងរវាងសហគមន៍ទាំងនោះ ..... 27

២.៥.៤. អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌ ..... 28

២.៦. ក្របខ័ណ្ឌគុណវុឌ្ឍិគ្រូ (TPACK) ក្នុងយុគសម័យឌីជីថល ..... 28

២.៧. លក្ខណសម្បត្តិគ្រូក្នុងយុគសម័យឌីជីថល ..... 30

ជំពូក II លំនាំនៃការបង្រៀន និង រៀន ..... 31

មេរៀនទី ៣ វិធីបង្រៀន ..... 31

៣.១ វត្ថុបំណងមេរៀន ..... 31

៣.២.សញ្ញាណទូទៅ ..... 31

៣.៣.ប្រព័ន្ធវិធីបង្រៀន ឬគោលវិធីបង្រៀន ..... 34

៣.៣.១.ប្រព័ន្ធវិធីបង្រៀនត្រូវបានបែងចែកជាប្រភេទទៅតាមធម្មជាតិរបស់វា ..... 34

៣.៣.២.ប្រព័ន្ធវិធីបង្រៀនត្រូវបានកសាងឡើងដោយឈរលើមូលដ្ឋាននៃសារជាតិរបស់វិធីសិក្សា ..... 35

៣.៤.វិធីបង្រៀននានា ..... 35

៣.៤.១.វិធីឧទ្ទេស ..... 35

៣.៤.២.វិធីចោទ-ឆ្លើយ (សន្ទនា) ..... 38

៣.៤.៣ វិធីប្រើប្រាស់សៀវភៅសិក្សា និងឯកសារសិក្សាផ្សេងទៀត ..... 42

៣.៤.៤ វិធីអព្ភន្តរញ្ញាណ (អព្ភន្តរញ្ញាណវិធី) ..... 44

៣.៤.៥. វិធីធ្វើពិសោធន៍ ..... 49

៣.៤.៦.វិធីហ្វឹកហ្វឺន ..... 51

៣.៤.៧. វិធីសិក្សាសារឡើងវិញ ..... 55

៣.៤.៨ វិធីធ្វើកិច្ចការត្រួតពិនិត្យវាយតម្លៃចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ ..... 60

មេរៀនទី ៤ ខ្លឹមសារ និង លំនាំនៃការបង្រៀន ......67
៤.១ វត្ថុបំណងមេរៀន ......67
៤.២.សញ្ញាណស្តីពីការបង្រៀន ......67
៤.៣ ធាតុទី១ ជាមូលដ្ឋាននៃចំណេះដឹង ៖ ......67
៤.៣.១ ចំណេះដឹងមានលក្ខណៈជាបទពិសោធន៍ ......68
៤.៣.២ ចំណេះដឹងជាទ្រឹស្តី ......68
៤.៣.៣ ចំណេះដឹងក្នុងការអនុវត្ត ......68
៤.៣.៤ ចំណេះដឹងក្នុងសកម្មភាពច្នៃប្រឌិត ......69
៤.៤ ធាតុទី២ គឺជាបទពិសោធន៍ក្នុងសកម្មភាព ៖ ......69
៤.៥ ធាតុទី៣ គឺជាបទពិសោធន៍នៃសកម្មភាពច្នៃប្រឌិត ៖ ......70
៤.៦ ធាតុទី៤ គឺជាឥរិយាបថរបស់មនុស្សចំពោះធម្មជាតិ សង្គម និងមនុស្សផ្សេងគ្នា៖ ......70
៤.៧ ចរិតប្រវត្តិសាស្ត្ររបស់ខ្លឹមសារនៃការបង្រៀន ......71
៤.៨ គោលការណ៍ជាមូលដ្ឋាន ក្នុងការតាក់តែងខ្លឹមសារនៃការបង្រៀន ......71
៤.៨.១ ខ្លឹមសារនៃការបង្រៀនត្រូវធានាបាននូវចរិតសាកល និងភាពមានលំនឹង៖ ......72
៤.៨.២ ខ្លឹមសារនៃការបង្រៀនត្រូវធានាបាននូវការផ្តល់ដល់សិស្សនូវចំណេះដឹងវិទ្យាសាស្ត្រទូទៅជាមូលដ្ឋាន ហើយទំនើប៖ ......73
៤.៨.៣ ខ្លឹមសារនៃការបង្រៀនត្រូវធានាឱ្យបានដល់ការសិក្សាទ្រឹស្តីផ្សារភ្ជាប់នឹងការប្រតិបត្តិ៖ ......75
៤.៨.៤ ខ្លឹមសារនៃការបង្រៀនត្រូវធានាឱ្យបានឯកភាពគ្នាទូទាំងប្រទេស៖ ......76
៤.៩ ផែនការបង្រៀន កម្មវិធីសិក្សា សៀវភៅសិក្សា និងឯកសារសិក្សាដ៏ទៃទៀត ......77
៤.៩.១. ផែនការបង្រៀន ......77
៤.៩.២.កម្មវិធីសិក្សា ......78
៤.៩.៣ សៀវភៅសិក្សា និងឯកសារសិក្សាផ្សេងទៀត ......79
៤.១០.លំនាំនៃការបង្រៀន ......80
៤.១០.១.កត្តាជាមូលដ្ឋានរបស់លំនាំនៃការបង្រៀន ......81

៤.១០.២ លំនាំនៃការបង្រៀន គឺជាលំនាំនៃសកម្មភាពរបស់គ្រូបង្រៀន និង សិស្ស ....... 82
៤.១០.៣ សារជាតិរបស់លំនាំនៃការបង្រៀន ....... 84
៤.១០.៤ ភាពសមហេតុផលនៅក្នុងលំនាំនៃការបង្រៀន ....... 85
៤.១០.៥ កម្លាំងចលកររបស់លំនាំនៃការបង្រៀន ....... 89
មេរៀនទី ៥ គោលការណ៍នៃការបង្រៀន ....... 93
៥.១. វត្ថុបំណងមេរៀន ....... 93
៥.២. សញ្ញាណទូទៅស្តីពីគោលការណ៍នៃការបង្រៀន ....... 93
៥.៣. លក្ខណៈប្រវត្តិសាស្ត្ររបស់គោលការណ៍នៃការបង្រៀន ....... 93
៥.៤. ប្រព័ន្ធគោលការណ៍នៃការបង្រៀនសម្រាប់សាលារៀនមធ្យមសិក្សាចំណេះទូទៅកម្ពុជា ....... 95
៥.៤.១. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតអប់រំ ....... 95
៥.៤.២. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតវិទ្យាសាស្ត្រ ....... 98
៥.៤.៣. គោលការណ៍នៃការបង្រៀនត្រូវធានាបាននូវចរិតប្រតិបត្តិ ....... 100
៥.៤.៤. គោលការណ៍នៃការបង្រៀន ត្រូវពង្រឹងពង្រីកចរិតភ្ញាក់រលឹក ចរិតសកម្មម្ចាស់ការច្នៃប្រឌិតរបស់សិស្ស ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ ....... 103
៥.៤.៥ គោលការណ៍នៃការបង្រៀន ត្រូវធានាឱ្យបាននូវចរិតអព្ភន្តរញាណ 106
៥.៤.៦.គោលការណ៍នៃការបង្រៀនត្រូវធានាបាននូវការពង្រឹងចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ ....... 107
៥.៤.៧.គោលការណ៍នៃការបង្រៀនត្រូវយកចិត្តទុកដាក់ដល់ភាពដោយឡែករបស់សិស្សម្នាក់ៗ ....... 110
មេរៀនទី ៦ បំណិននៃការគិតលំដាប់ខ្ពស់ និងការដោះស្រាយបញ្ហា ....... 113
៦.១. វត្ថុបំណងមេរៀន ....... 113
៦.២. ការគិតកម្រិតខ្ពស់ និងអំណះអំណាង ( Critical Thinking and Argumentation ) 113
៦.៣. ការពិពណ៌នាអំពីលក្ខណៈរបស់អ្នកគិតកម្រិតខ្ពស់ ....... 113
៦.៤. អំណះអំណាង ( Argumentation ) ....... 115
៦.៥. ចំណុចស្រប និងចំណុចប្រឆាំង ....... 117

៦.៦. ទិដ្ឋភាពជាច្រើននៃការផ្ទេរ ........ 118
៦.៧. ពហុបញ្ញារបស់មនុស្ស ( Multiple Intelligences ) ........ 123
៦.៧.១. ការអភិវឌ្ឍពុទ្ធិ និងខួរក្បាល ........ 123
៦.៧.២. គោលទូទៅនៃការអភិវឌ្ឍពុទ្ធិ ........ 123
៦.៧.៣. សរីរវិទ្យានៃខួរក្បាល ( Physiology of the Brain ) ........ 124
៦.៧.៤. សរសៃខួរក្បាលគ័រតិក ( The Cerebral Cortex ) ........ 125
៦.៧.៥. ការរៀន និងបង្រៀនផ្អែកលើខួរក្បាល ........ 127
៦.៧.៦. ទ្រឹស្តីបញ្ញា Triarchic របស់លោក Sternberg ........ 131
៧.៧.៧. ទ្រឹស្តីពហុបញ្ញារបស់លោក Howard Gardner ........ 133
៧.៧.៨. វិធីបង្រៀនដោយប្រើពហុបញ្ញា ........ 135
ជំពូកទី III 137
មេរៀនទី៧ ការគ្រប់គ្រងថ្នាក់រៀន ( Classroom Management ) ........ 137
៧.១. វត្ថុបំណងមេរៀន ........ 137
៧.២. គោលដៅនៃការគ្រប់គ្រងថ្នាក់រៀន ........ 137
៧.៣. ការបង្កើតបរិយាកាសសិក្សាវិជ្ជមាន ........ 138
៧.៤. ការរក្សាបរិយាកាសល្អសម្រាប់ការសិក្សា ........ 141
៧.៥. ដំណោះស្រាយបញ្ហាវិន័យ ........ 143
មេរៀនទី៨វិធីសាស្ត្រក្នុងការលើកទឹកចិត្តសិស្ស ( Methods for motivating students )148
៨.១. វត្ថុបំណងមេរៀន ? ? ? ........ 148
៨.២. និយមន័យ និងគោលបំណងនៃការលើកទឹកចិត្ត ........ 148
៨.២.១. និយមន័យ: ........ 148
៨.២.២. គោលបំណងនៃការលើកចិត្ត: ........ 148
៨.៣. ទ្រឹស្តីកម្លាំងជំរុញតាមបែបប្រពៃណី ( Traditional Motivational Theories ) ........ 148
៨.៤. វិធីសាស្ត្រក្នុងការជំរុញទឹកចិត្តសិស្ស ........ 149
៨.៥. ការបំផុសគំនិតសិស្សអោយចង់រៀន : Motivation ........ 150

**៨.៦.គោលការណ៍ណែនាំះ ពីការលើកទឹកចិត្តដើម្បីរៀនសូត្រតាមជាដៃគូក្នុងគ្រួសារ និងសហគមន៍** ........ 154

**៨.៧. ការលើកទឹកចិត្តនៅក្នុងថ្នាក់រៀន**( Motivation in the classroom ) ........ 156

**ឯកសារយោង** ........ 157

# ជំពូក I សញ្ញាណទូទៅនៃគរុកោសល្យ និង ទស្សនៈនៃការអប់រំសតវត្សទី២១

## មេរៀនទី ១ សញ្ញាណទូទៅនៃគរុកោសល្យ

### ១.១ វត្ថុបំណងមេរៀន

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

- បកស្រាយពីកម្មវត្ថុ និងតួនាទីរបស់គរុសល្យទូទៅ
- សរសេរសង្ខេបអំពីទំនាក់ទំនងរវាងគរុកោសល្យទូទៅ និងចិត្តវិទ្យា និង គរុកោសល្យនិងសង្គមវិជ្ជា
- ចូលរួមក្នុងការអប់រំ និងបង្រៀនដោយឈរលើមូលដ្ឋានគ្រឹះចិត្ត-គរុកោសល្យប្រកបដោយគុណភាព។

### ១.២ វត្ថុបំណងនៃគរុកោសល្យទូទៅ

#### ១.២.១ និយមន័យ

គរុកោសល្យទូទៅ ជាវិទ្យាសាស្ត្រមួយដែលសិក្សាអំពីសកម្មភាពនៃការអប់រំ និងច្បាប់របស់ការអប់រំ (**មានកម្មវត្ថុសិក្សា កម្មវិធីសិក្សា ច្បាប់ជាសត្យានុម័ត**)។ តើការអប់រំស្ថិតនៅលើអ្វី? តើការអប់រំកើតចេញពីប្រភពណា?

ការងាររបស់មនុស្សខុសប្លែកគ្នាពីសកម្មភាពរបស់សត្វ។ ការងាររបស់មនុស្សជាការងារដែលប្រកបដោយមនសិការ។ មុននឹងធ្វើការងារអ្វីមួយ មនុស្សមានរូបភាពការងារនៅក្នុងខួរក្បាលជាស្រេចហើយ។

*ឧទាហរណ៍៖* បើមនុស្សចង់សង់ផ្ទះ នោះរូបភាពរបស់ផ្ទះមាននៅក្នុងខួរក្បាលមនុស្សជាស្រេច ដូចជាតើសម្ភារៈអ្វីខ្លះដែលគេត្រូវយកមកសាងសង់ ឱ្យបានជាផ្ទះទៅតាមបំណងដែលគេបានគ្រោងទុក? រីឯសកម្មភាពរបស់សត្វវិញមានលក្ខណៈជាសភាវគតិ។

*ឧទាហរណ៍៖* ក្តាម ឬកណ្តុរដែលកាយរន្ធនៅតាម ភ្លឺស្រែ ជាសកម្មភាពដែលលក្ខណៈ សភាវគតិរបស់សត្វព្រោះសត្វគ្មានការពិចារណា គ្មានគម្រោងផែនការការងាររបស់វាដូចមនុស្សទេ។

អ្នកនិពន្ធឈ្មោះ Mouroe បានសរសេរថា៖ ធម្មជាតិរបស់ការអប់រំ គឺការត្រាប់តាមគ្នា។

*ឧទាហរណ៍៖* កុមារត្រាប់តាមមនុស្សចាស់។ ការត្រាប់តាមគ្នានេះមានឥទ្ធិពលខ្លាំងណាស់នៅក្នុងការអប់រំ។

*ឧទាហរណ៍៖* សិស្សរៀនស្លៀកពាក់ និងធ្វើកាយវិការតាមគ្រូបង្រៀននិងតាមឪពុកម្តាយ។

**នៅក្នុងការងារអប់រំមាន :**

១.ការផ្ទេរចំណេះដឹង។ គ្រូបង្រៀនគប្បីមានលក្ខណៈវិនិច្ឆ័យឱ្យបានច្បាស់ក្នុងការវែកញែកអំពើល្អ និងអំពើអាក្រក់។ តាមទស្សនៈនៃការផ្តល់ចំណេះដឹងឱ្យដល់សិស្ស គ្រូបង្រៀនគប្បីបង្ហាត់សិស្សឱ្យចេះវែកញែក អំពើល្អ និងអំពើអាក្រក់។

២.គេគប្បីមានជំនឿនិងសញ្ចេតនានៅចំពោះមុខអំពើល្អ។គេត្រូវសម្តែងសេចក្តីពេញចិត្តចំពោះអ្នកដែលបានធ្វើអំពើល្អ។ ក៏ប៉ុន្តែនៅចំពោះមុខអំពើអាក្រក់វិញ គេត្រូវតែសម្តែងសេចក្តីស្អប់ខ្ពើមការទិទៀន និងការថ្កោលទោស។

៣.ការប្រកាន់យកទង្វើ ៖ក្នុងសកម្មភាពប្រតិបត្តិគេគប្បីចៀសវាង អំពើអាក្រក់ហើយប្រកាន់យកអំពើល្អ

## ១.២.២. ធម្មជាតិពិតប្រាកដរបស់ការអប់រំ

ការអប់រំមានប្រភពចេញមកពីសង្គមបុព្វកាល។ នៅក្នុងសម័យសង្គមបុព្វកាលដើម្បីរស់នៅបាន មនុស្សត្រូវស្វែងរកចំណីអាហារសម្រាប់ហូប។ គេរស់នៅក្នុងព្រៃព្រឹក្សាដែលសម្បូរដោយសត្វកាចសាហាវ។

តើគេមានតម្រូវការខាងសម្លៀកបំពាក់ឬទេ? តម្រូវការរបស់មនុស្សក្នុងសម័យសង្គមបុព្វកាល មាន៖

-ហូបចុក

-ស្លៀកពាក់

-មានជម្រក

-ការងារផលិតកម្ម

គេត្រូវចំណាយកម្លាំង ក្នុងការងារពលកម្ម។ ដើម្បីបានផ្លែឈើយកមកហូប គេត្រូវដើររកបេះផ្លែឈើ" **ឡើងដើមឈើ** "។ ដើម្បីងាយស្រួលក្នុងការមានផ្លែឈើហូប គេត្រូវដាំដើមឈើស៊ីផ្លែ។ ដើម្បីដោះស្រាយបញ្ហាហូប គេត្រូវធ្វើការប្រមាញ់សត្វ។ គេប្រើដុំថ្ម ដើម្បីចោលសត្វ។គេចាប់ត្រីយកមកចំអិនបរិភោគ។ ដូច្នេះមនុស្សក្នុង សង្គមបុព្វកាល ដោះស្រាយបញ្ហារស់នៅដោយ៖

-ការបេះផ្លែឈើ

-ការដាំដើមឈើ

-ការប្រមាញ់សត្វ

-ការនេសាទ

ការងាររបស់មនុស្ស និង ការងាររបស់សត្វមានលក្ខណៈខុសប្លែកគ្នាត្រង់ដែលមនុស្សបានបង្កើតឧបករណ៍ សម្រាប់ការងារដូចជាពូថៅធ្វើអំពីថ្ម។ដើមឡើយមនុស្សដើរជើងបួនដូចសត្វ ដោយសារការងារពលកម្មមនុស្សអាចដើរជើងពីរហើយឈរត្រង់បាន។ ពេលនោះមនុស្សផ្តាច់ខ្លួនស្រឡះពីការរស់នៅតាមរបៀបជាសត្វ។ ដោយសារការងារពលកម្ម មនុស្សមានភាសាដែលអាចនិយាយយល់គ្នាបានទៅវិញទៅមក។ ឧបករណ៍សម្រាប់ការងាររបស់មនុស្សក្នុងសង្គមបុព្វកាលមានភាពសាមញ្ញណាស់។ មនុស្សមានសម្ភារៈសម្បូរបែប តែពិបាកនឹងយកមកប្រើការដើម្បីប្រកបរបរចិញ្ចឹមជីវិត ហើយសម័យនោះមនុស្សមានតម្រូវការផ្នែកសម្ភារៈខ្លាំងណាស់ មនុស្សគ្រប់រូបត្រូវធ្វើការ ត្រូវតែចំណាយពេលធ្វើការងារផលិតកម្មចាំបាច់ខានមិនបាន។ ក្នុងសម័យនោះ បើគេក្តាប់បាននូវបទពិសោធន៍ល្អក្នុងការ ងារ គេចាំបាច់ត្រូវផ្ទេរបទពិសោធន៍ល្អឱ្យដល់មនុស្សទាំងអស់ក្នុងសង្គម។ នេះហៅថា **រូបភាពអប់រំក្នុងសម័យសង្គមបុព្វកាល**។

ដូច្នេះយើងឃើញថា ធម្មជាតិដ៏ពិតប្រាកដរបស់ការអប់រំគឺស្ថិតនៅត្រង់៖

-ផ្ទេរបទពិសោធន៍ក្នុងការងារផលិតកម្មឱ្យមនុស្សពីជំនាន់មួយទៅជំនាន់មួយតៗគ្នា

-បទពិសោធន៍ទាំងនោះកាន់តែមានលក្ខណៈទូទៅកម្មនិងប្រព័ន្ធកម្មកាន់តែប្រសើរឡើងទៅតាមសំណូមពរនៃផលិតកម្មរហូតទាល់តែលេចធ្លោរឡើងនូវអ្វីមួយដែលគេហៅថាវិទ្យាសាស្ត្រ។បពិសោធន៍និងចំណេះដឹងទាំងនោះគេហៅថា ចំណេះដឹងវិទ្យាសាស្ត្រ។

- ចំណេះដឹងដែលគេយកមកបង្រៀនសិស្សក្នុងសាលារៀន មានប្រភពចេញមកពីចំណេះដឹងក្នុងការងារពលកម្មនេះឯង។ ការផ្ទេរបទពិសោធន៍ឱ្យដល់សិស្សនេះគេហៅថាការបង្រៀន និងការរៀន។ នេះជា **ទិដ្ឋភាពទី១** របស់ការអប់រំ ។

**ទិដ្ឋភាពទី២**របស់ការអប់រំ៖ ដោយឧបករណ៍សម្រាប់ការងារពលកម្មមានលក្ខណៈចេះតែហួសសម័យ ហើយដោយមនុស្សចំណាយពេលធ្វើពលកម្មច្រើន ពេលនោះទំនាក់ទំនងរវាងមនុស្ស និងមនុស្សកាន់តែកើតមានជិតស្និទ្ធនិងគ្នាខ្លាំងឡើងៗ ។ ប៉ុន្តែនៅក្នុងសង្គម គឺមនុស្សចាស់ដែលមានបទពិសោធន៍ច្រើននៅក្នុងការងារផលិតកម្ម។ ដោយការងារផលិតកម្មជាបញ្ហាស្លាប់រស់នៅក្នុងសង្គម មនុស្សចាស់ត្រូវបានគោរពជាងគេក្នុងសង្គម។ បើមានបញ្ហាអ្វីដែលគេទាល់ច្រកដោះស្រាយមិនបាន ឬងឿងឆ្ងល់គេតែងតែសួរមនុស្សចាស់។ នេះហៅថាលក្ខណៈវិនិច្ឆ័យខាងផ្នែកសីលធម៌ក្នុងសង្គម។

ទន្ទឹមនឹងនេះផងដែរមានទស្សនៈសាសនាសិល្បៈនិងវិទ្យាសាស្ត្រកើតឡើងក្នុងសង្គម។ រីឯប្រពៃណីនិងទំនៀមទម្លាប់ក៏កើតមានជាក្រឹត្យក្រមក្នុងសង្គមដែរ ដែលតម្រូវឱ្យមនុស្សគ្រប់រូបត្រូវជឿ និងចេះគោរពទៅតាមបែបបទដ៏ ត្រឹមត្រូវផង។ ប្រពៃណីទំនៀមទម្លាប់ សាសនា និងការគោរពបូជាក៏ត្រូវបានផ្ទេរឱ្យជំនាន់មនុស្សតៗគ្នាមកដែរ។ នេះហៅថាការផ្ទេរបទពិសោធន៍ក្នុងការងារផលិតកម្មក្នុងទស្សនៈ សាសនា សិល្បៈ សីលធម៌ ទស្សនវិជ្ជា និងការផ្ទេរទំនៀមទម្លាប់ប្រពៃណីក្បួនច្បាប់សង្គមឱ្យដល់មនុស្សជំនាន់ ក្រោយ សំដៅឱ្យគេម្នាក់ៗរស់នៅប្រកបដោយសុខដុមរមនានៅក្នុងជីវភាពសង្គមរហូតដល់គេមានវ័យចាស់ជរា។ នេះគេហៅថាការអប់រំក្នុងន័យចង្អៀតនៅក្នុងសាលារៀន។

## ១.៣.អំពើអប់រំដែលជះឥទ្ធិពលលើការអភិវឌ្ឍសង្គម

បដិវត្តន៍វិទ្យាសាស្ត្រ និងបច្ចេកទេសធ្វើឱ្យសង្គមមនុស្សអភិវឌ្ឍឡើងឥតឈប់ឈរ។ ទន្ទឹមនឹងនេះផងដែរ សមិទ្ធិផលនៃរបកគំហើញថ្មីក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេសចេះតែអភិវឌ្ឍឡើងជានិច្ច។ សមិទ្ធិផលនៃរបក គំហើញថ្មីៗត្រូវបានគេយកទៅអនុវត្តនៅក្នុងការងារផលិតកម្មសំដៅទទួលបាននូវទិន្នផលខ្ពស់។ ដើមឡើយ គេយករបកគំហើញក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេសមកអនុវត្តក្នុងខឿនផលិតកម្មគ្រាន់តែជាជំហានសាកល្បងប៉ុណ្ណោះ។ មនុស្សកែច្នៃរបកគំហើញវិទ្យាសាស្ត្រនិងបច្ចេកទេសសំដៅឱ្យផលិតផលនៃការងារផលិតកម្មមានគុណភាពខ្ពស់។

លំនាំផលិតកម្មក្នុងសង្គមមនុស្សចេះតែផ្លាស់ប្តូរទៅរកគុណភាពតាមតម្រូវការដ៏ទាន់ សម័យរបស់មនុស្ស។ គេផលិតបានម៉ាស៊ីនថ្មីៗហើយទំនើបបំផុតក្នុងខឿនផលិតកម្ម សម្រាប់បម្រើសេចក្តីត្រូវការដ៏ទាន់ចិត្តក្នុងជីវភាពរស់នៅនិងក្នុងការងារ។

*ឧទាហរណ៍៖* ការផលិតឧបករណ៍ប្រើប្រាស់ក្នុងគ្រួសារ និង ក្នុងការិយាល័យ ដូចជាទូរទស្សន៍ វីដេអូ ម៉ាស៊ីនច្រូតកាត់ ម៉ូតូ រថយន្ត កុំព្យូទ័រ... ដ៏ទំនើប និងទាន់សម័យសម្រាប់តម្រូវការរបស់មនុស្សជាតិ ។

ដើម្បីផលិតឧបករណ៍ទាំងនេះគេប្រើប្រាស់កម្លាំងមួយហៅថាកម្លាំងផលិតកម្មឯកទេស។ គេមិនត្រូវការពេលវេលាច្រើន ដើម្បីបណ្តុះបណ្តាលកម្លាំងផលិតកម្មធម្មតានេះឡើយ។ គេត្រូវបណ្តុះបណ្តាលកម្លាំងនេះតាមមធ្យោបាយអប់រំ ។

**ការអប់រំមានមុខងារ ៣ យ៉ាង៖**

- អប់រំជំនាន់យុវវ័យ
- លើកកម្ពស់កម្រិតបញ្ញារបស់មហាជន
- បណ្តុះបណ្តាលមន្ត្រីរាជការសម្រាប់គ្រប់គ្រងស្ថាប័នសង្គម

ដើម្បីឱ្យការអប់រំអាចបំពេញបាននូវភារកិច្ចល្អប្រសើរ ចាំបាច់ត្រូវមានលក្ខខណ្ឌ។តើមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ ?

១. ត្រូវមានមនុស្ស (សិស្សានុសិស្ស)

២. ត្រូវមានថវិកាសម្រាប់ចំណាយ

៣. ត្រូវមានមូលដ្ឋានសម្ភារ(គឺសម្ភារឧបទ្ទេសសិក្សា)

៤. ត្រូវមានពេលវេលា (កាលណាគេបណ្តុះបណ្តាលអ្នកឯកទេសគេត្រូវការពេលវេលាយូរ)

មូលដ្ឋានអប់រំនិងមូលដ្ឋានសេដ្ឋកិច្ចត្រូវមានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។ តើផែនការអភិវឌ្ឍសេដ្ឋកិច្ច នៅឆ្នាំបន្តត្រូវស្ថិតនៅក្នុងកម្រិតណា ?

**វិស័យកសិ កម្ម** ៖ ប្រើត្រាក់ទ័រដើម្បីកាត់បន្ថយ កម្លាំងពលកម្មម នុស្សនិងសត្វព្រមទាំងពង្រីកប្រព័ន្ធធារាសាស្ត្រ។

**ឧស្សាហកម្ម**៖ ផលិតសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងស្រុក និងនាំចេញក្រៅប្រទេស ថាមពលអគ្គិសនីមានគ្រប់គ្រាន់។

**គមនាគមន៍៖** វិថីក្នុងក្រុងនិងផ្លូវជាតិទូទាំងប្រទេសត្រូវបានពង្រីក និងក្រាលកៅស៊ូបានទាំងអស់។

**សុខាភិបាល**៖ ពង្រីកសុខាភិបាល (មន្ទីរពេទ្យ) ដល់ជនបទដាច់ស្រយាល ។

អ្នកអប់រំត្រូវតែដឹងស្គាល់ផែនការអភិវឌ្ឍសេដ្ឋកិច្ច និងវិស័យឯទៀតៗជាមុន ហើយក្រសួងអប់រំត្រូវបណ្តុះបណ្តាលមនុស្សទៅតាមកម្មវិធី ដែលឆ្លើយតបបានទៅនឹងផែនការអភិវឌ្ឍនេះជាមុនសិន។ តម្រូវការមនុស្សសម្រាប់ក្រុមហ៊ុនវិនិយោគទុន និងស្ថាប័នរដ្ឋនានាត្រូវឱ្យព័ត៌មានមកអ្នកអប់រំដឹងជាមុនដើម្បីរៀបចំការបណ្តុះបណ្តាលមនុស្សឱ្យបានសមស្រប។ ការបណ្តុះបណ្តាលអ្នកឯកទេសល្អ ត្រូវផ្សារភ្ជាប់និងមូលដ្ឋានសម្ភារមន្ទីរពិសោធន៍គ្រប់គ្រាន់ ហើយនិងកម្មសិក្សាប្រតិបត្តិជាក់ស្តែង។ បើខ្វះមូលដ្ឋានសម្ភារៈ ខ្វះមន្ទីរពិសោធន៍ ធ្វើកម្មសិក្សាមិនបានគ្រប់គ្រាន់នាំឱ្យលទ្ធផលនៃការអប់រំចុះខ្សោយ និងទិន្នផលផលិតកម្មក៏គ្មាន គុណភាពដែរ។ ដូច្នេះដើម្បីឱ្យវិស័យអប់រំអភិវឌ្ឍឡើងប្រកបដោយគុណភាពល្អមែនទែននោះគេត្រូវឈរលើ មូលដ្ឋានសេដ្ឋកិច្ច។

*ឧទាហរណ៍៖*

-ដើម្បីគ្រប់គ្រងសេដ្ឋកិច្ចគេត្រូវបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងសេដ្ឋកិច្ច។

-ដើម្បីថែរក្សាឯករាជ្យ និងបូរណភាពទឹកដីគេត្រូវបណ្តុះបណ្តាលនាយទាហាន និងកងទ័ព។

-ដើម្បីគ្រប់គ្រងវិស័យណាមួយ ឬស្ថាប័នរដ្ឋណាមួយ គេត្រូវតែបណ្តុះបណ្តាលមន្ត្រីនិងបុគ្គលិកឱ្យបាន គ្រប់គ្រាន់ និងសមស្របតាមវិស័យ ឬស្ថាប័ននោះ។

សរុបសេចក្តីមក ពាក្យថាបណ្តុះបណ្តាលក្នុងន័យនេះ ស្ថិតនៅក្នុងអត្ថន័យរបស់ពាក្យថា **អប់រំ** ។

យើងឃើញថា ពាក្យបណ្តុះបណ្តាលហាក់ដូចមានវេចនសព្ទ័និងពាក្យ(អប់រំ)។ រូបភាពនៃការអប់រំ ឬការបណ្តុះបណ្តាលសុទ្ធតែទាមទារផ្នែកថវិកាទាំងអស់។ គ្មានថវិកា គ្មានកម្លាំង គ្មានពេលវេលា គឺគេមិនអាចបណ្តុះបណ្តាល ឬអប់រំមនុស្សបានទេ។ ដូច្នេះយើងឃើញថា៖

- សេដ្ឋកិច្ចកំណត់ឱ្យដំណើរការអភិវឌ្ឍនៃវិស័យអប់រំ។
- វិស័យអប់រំជាមូលដ្ឋានគ្រឹះសម្រាប់វិស័យសេដ្ឋកិច្ចនិងវិស័យឯទៀត។
- ក្រឹត្យក្រម ជាសត្យានុម័តក្នុងសង្គមមនុស្ស តម្រូវឱ្យមនុស្សរស់នៅដ៏សុខដុមរមនានៅក្នុងការអភិវឌ្ឍខាងវិស័យអប់រំ និងវិស័យសេដ្ឋកិច្ចក្នុងពេលដំណាលគ្នា។

ដូច្នេះវិស័យអប់រំ និងវិស័យសេដ្ឋកិច្ចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិនឹងគ្នា ហើយមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ។ ហើយទំនាក់ទំនងគ្នារវាងវិស័យទាំងពីរនេះជាក្រឹត្យក្រមសត្យានុម័តរបស់សង្គមមនុស្សដែល បោះជំហានទៅរកភាពជឿនលឿនទាន់សម័យនេះជាក្រឹត្យក្រមដ៏សំខាន់របស់មនុស្សជាតិ។

ទំនាក់ទំនងរវាងវិស័យសេដ្ឋកិច្ច និងវិស័យអប់រំស្រេចតែនឹងចរិតនៃរបបគ្រប់គ្រងសង្គមដែរ។ របបសង្គមយ៉ាងណាទំនាក់ទំនងគ្នារវាងវិស័យទាំងពីរក៏យ៉ាងនោះដែរ ។ ប្រទេសជាតិនីមួយៗរីកចម្រើនបានក៏ទាល់តែរបបសង្គមយល់ច្បាស់ពីបញ្ហានេះដែរ។ ជួនកាលគេមិនបានចាប់ភ្លឹក នឹងបញ្ហាទំនាក់ទំនងគ្នារវាងវិស័យទាំងពីរនេះផង។ កាលណាការបណ្តុះបណ្តាលខ្វះអ្នកជំនាញ ឬអ្នកឯកទេសគ្រប់គ្រង ឬខ្វះកម្មវិធីបណ្តុះបណ្តាល ឬក៏កម្មវិធីបណ្តុះបណ្តាលមិនច្បាស់លាស់នាំឱ្យសេដ្ឋកិច្ច និងវិស័យឯទៀតៗរបស់ប្រទេសជាតិ មិនបោះជំហាន ទៅមុខ ហើយចេះតែដុនដាបទៅ ។ ផ្ទុយទៅវិញបើតម្រូវការសម្ភារៈ និងថវិកា សម្រាប់បម្រើឱ្យវិស័យអប់រំ ឬការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ទេនោះ គុណភាពអប់រំ ឬគុណភាព បណ្តុះបណ្តាលមនុស្ស ធ្វើឱ្យវិស័យសេដ្ឋកិច្ចនិងវិស័យឯទៀតក៏ចុះខ្សោយដែរ។ ដូច្នេះមូលដ្ឋានសាលារៀន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលទាមទារឱ្យមានមូលដ្ឋានសម្ភារៈបច្ចេកទេស និងមូលដ្ឋានសម្ភារៈឧបទ្ទេសសិក្សាដ៏គ្រប់គ្រាន់ទើបសម្រេចបានតាមបំណងដ៏ល្អនេះ។ មានន័យថាកម្លាំងអប់រំច្បាស់ជាទាមទារថវិកាគ្រប់គ្រាន់ សម្ភារៈបច្ចេកទេស និងសម្ភារៈឧបទ្ទេសសិក្សាដ៏សម្បូរបែប និងពេលវេលាឱ្យបានគ្រប់គ្រាន់ ប្រកបដោយកម្មវិធីសិក្សាដ៏សមស្រប។

-ក្នុងសង្គមបុព្វកាលកម្លាំងផលិតកម្មខ្សោយការអប់រំបម្រើកឱ្យផលប្រយោជន៍សង្គម

-ក្នុងសង្គមទាសភាព សង្គមមនុស្សចាប់ផ្តើមបែងចែកជាវណ្ណៈ វណ្ណៈជិះជាន់គេទទួលការអប់រំពេញសមត្ថភាពក្នុងសាលារៀន រីឯកូនចៅវណ្ណៈត្រូវគេជិះជាន់ មិនមានសិទ្ធិទៅសាលារៀនឡើយ។

-ក្នុងសង្គមសក្តិភូមិការអប់រំក៏មានលក្ខណៈវណ្ណៈដែរ គឺបម្រើផលប្រយោជន៍ ឱ្យវណ្ណៈជិះជាន់កូនចៅ វណ្ណៈកសិករក្រីក្រ ទទួលការអប់រំបានតិចតួចក្នុងសាលារៀន។

-ក្នុងរបបមូលធន កូនចៅវណ្ណៈអភិជន ទទួលការអប់រំបានខ្ពង់ខ្ពស់សម្រាប់បម្រើផល ប្រយោជន៍ឱ្យ វណ្ណៈអភិជនក្នុងការគ្រប់គ្រងសង្គម។

ដូច្នេះ យើងឃើញថាកាលណារបបគ្រប់គ្រងសង្គមត្រូវផ្លាស់ប្តូរ នោះវិស័យនិងគោលបំណងអប់រំក៏ ផ្លាស់ប្តូរដែរ ពោលគឺការអប់រំមានលក្ខណៈប្រវត្តិសាស្ត្រទៅតាមសម័យកាលនៃសង្គម។ គ្មានការអប់រំណាមួយមួយដែលមានលក្ខណៈរួម សម្រាប់សង្គមមនុស្សឡើយ។

## ១.៤ ទំនាក់ទំនងរវាងការអប់រំ និងនយោបាយ

ពាក្យថានយោបាយ គឺជាការសម្តែងចេញរួមគ្នាក្នុងន័យសេដ្ឋកិច្ចទូទៅកម្ម និងសមិទ្ធផល។ ដោយការអប់រំមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងសេដ្ឋកិច្ច ដូច្នេះវាជាការពិតណាស់ដែលការអប់រំមានទំនាក់ទំនងជាមួយនិងនយោបាយ។ ការអប់រំត្រូវបម្រើឱ្យនយោបាយដូចដែលការអប់រំបម្រើឱ្យសេដ្ឋកិច្ចផងដែរ។ ដូច្នេះ ហើយបានជាគោលមាគ៌ានយោបាយ ដឹកនាំរបស់ប្រទេសនីមួយៗ ត្រូវជ្រួតជ្រាបនៅក្នុងវិស័យអប់រំ។ បានន័យថាការអប់រំត្រូវបម្រើឱ្យសេដ្ឋកិច្ចផងនយោបាយផង។ នេះជាក្រឹត្យក្រមនៃការអប់រំ។ ក្រឹត្យក្រមនេះត្រូវបានប្រកាន់យកជាមូលដ្ឋានអប់រំនៅប្រទេសក្នុងសកលលោក។

សរុបសេចក្តីមក ដោយការអប់រំបម្រើឱ្យសេដ្ឋកិច្ចផង នយោបាយផង ទើបធ្វើឱ្យការអប់រំមានទង្វើយ៉ាងសំខាន់មកលើការអភិវឌ្ឍក្នុងសង្គម។ ដើម្បីសម្រេចតាមគោលបំណងអប់រំនៅក្នុងរដ្ឋធម្មនុញ្ញ និង

គោលមាគ៌ា នយោបាយដឹកនាំរបស់រដ្ឋាភិបាល ប្រព័ន្ធអប់រំត្រូវឈរលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យដូចតទៅ៖

ក. ផ្សារភ្ជាប់ការអប់រំសីលធម៌ទៅនឹងការអប់រំវប្បធម៌ និងវិទ្យាសាស្ត្រ

ខ. ផ្សារភ្ជាប់ការសិក្សាផ្នែកទ្រឹស្តីទៅនឹងការប្រតិបត្តិជាក់ស្តែង ការសិក្សាទៅនឹងទង្វើជាក់ស្តែងរបស់សិស្ស ការបង្ហាត់បង្រៀនទៅនិងផលិតកម្មក្នុងសង្គម

គ. ផ្សារភ្ជាប់ការអប់រំក្នុងសាលារៀនទៅនឹងការអប់រំក្នុងសង្គម

ឃ. ផ្សារភ្ជាប់តួនាទីដឹកនាំរបស់គ្រូទៅនឹងគំនិតផ្តួចផ្តើមជឿនលឿនរបស់សិស្ស

ដូច្នេះ បានន័យថាការអប់រំបំពេញតួនាទីមួយយ៉ាងសំខាន់ឱ្យនយោបាយ។

## ១.៥ កម្មវត្ថុរបស់គរុកោសល្យទូទៅ

បទពិសោធន៍ សម្រាប់ផ្ទេរឱ្យមនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត ត្រូវបានចងក្រងជាឯកសារសម្រាប់សិក្សា ពីមួយថ្ងៃទៅមួយថ្ងៃ ហើយមានលក្ខណៈកាន់តែស្មុគស្មាញឡើង។ ទន្ទឹមនឹងនេះ ការអប់រំក៏កាន់តែមានលក្ខណៈស្មុគស្មាញផងដែរ។ ការអប់រំត្រូវធ្វើឱ្យបទពិសោធន៍មានតុល្យភាពទៅនឹង ចំណេះដឹង ដែលមនុស្សអាចទទួលបាន។ ដោយសារបញ្ហានេះ ដែលធ្វើឱ្យគរុកោសល្យទូទៅដែលជាវិទ្យាសាស្ត្រស្តីពី ការអប់រំ ចាប់បដិសន្ធិឡើងហើយមានកម្មវត្ថុសិក្សាដូចតទៅ៖

-ហេតុការណ៍ បាតុភូត លំនាំរបស់ការអប់រំទូទៅ និងដោយឡែកស្នាដៃអប់រំសម្រាប់យុវវ័យដែលសម្តែងចេញបានជាក្រឹត្យក្រមសត្យានុម័ត

-ឈរលើមូលដ្ឋាននៃក្រឹត្យក្រមទាំងនេះ គេបានតម្រង់ទិសដំណើរការអភិវឌ្ឍរបស់វិស័យអប់រំដោយ អនុលោមតាមសំណូមពររបស់សង្គមសម្រាប់សម័យកាលនីមួយៗនៃប្រវត្តិសាស្ត្រ

-ពិសេសណាស់ទៅទៀត គឺការអប់រំនេះហើយដែលជាវិទ្យាសាស្ត្រសិក្សានិងធ្វើឱ្យមានតុល្យភាពលើ បទពិសោធន៍ ក្នុងការបណ្តុះបណ្តាលមនុស្ស សម្រាប់ជីវភាពរស់នៅរបស់សង្គម ការងារផលិតកម្មនិងវិស័យ ការពារប្រទេស ។

*ឧទាហរណ៍:* ការបណ្តុះបណ្តាលវិជ្ជាជី វៈសម្រាប់កម្រិតមធ្យមសិក្សា និងកម្រិតឧត្តមសិក្សា ដើម្បីយក មនុស្ស ទៅបម្រើការតាមស្ថាប័នរដ្ឋនានា ទាមទារឱ្យមានមន្ទីរពិសោធន៍ការងារប្រតិបត្តិ និងកម្មសិក្សាពេញសមត្ថភាព។ ការបណ្តុះបណ្តាលអ្នកឯកទេសនេះ ត្រូវធ្វើឡើងទៅតាមផែនការ តម្រូវការមនុស្សរបស់រដ្ឋាភិបាល និង ក្រុមហ៊ុនវិនិយោគទុនបរទេស។ ទន្ទឹមនឹងនេះ គេត្រូវពឹងផ្អែកលើលក្ខខណ្ឌសង្គមប្រវត្តិទៀតផងកម្មវិធីបណ្តុះ បណ្តាល រយៈពេលបណ្តុះបណ្តាលកម្លាំង ជួយក្នុងការបណ្តុះបណ្តាលមូលដ្ឋាន សម្ភារៈថវិកាសម្រាប់ចំណាយមូលដ្ឋាន សម្រាប់ធ្វើកម្មសិក្សា និងមន្ទីរពិសោធន៍ ឬវាសនដ្ឋានសិក្សាជាកត្តា ដែលញ៉ាំងឱ្យការបណ្តុះបណ្តាលមុខជំនាញបែបណានេះ មានប្រសិទ្ធិភាពខ្ពស់និងទទួលបានគុណភាពល្អប្រសើរ។ ដូច្នេះការបង្ហាត់បង្រៀនសិស្ស និងយុវសិស្សគ្រប់វ័យ គ្រប់កម្រិតសិក្សា និងគ្រប់មុខវិជ្ជាឯកទេសទាមទារឱ្យគ្រូបង្រៀន និងសាស្ត្រាចារ្យប្រើអស់ពីសមត្ថភាពខាងផ្នែកសម្ភារៈឧបទ្ទេសសិក្សា។ ការបង្រៀនគ្មាន ប្រើសម្ភារៈឧបទ្ទេស និងការបណ្តុះ បណ្តាលគ្មានមន្ទីរពិសោធន៍ និងគ្មានកម្មសិក្សាប្រតិបត្តិស៊ីជម្រៅជាក់ស្តែង ប្រៀបបានទៅនឹងពេលអាហារ ដ៏សោះកក្រោះ គ្មានម្ហូបគ្រប់គ្រាន់ដើម្បីឆ្ងាញ់បាយ។ បញ្ហាទាំងនេះ ជាបញ្ហាដែលគេអាចដោះស្រាយបានទាំងអស់ ប្រសិនណាជាគេគិតគូរ ឬចង់ធ្វើឱ្យមានគ្រប់គ្រាន់។ កសិករម្នាក់ ដែលស្ទូងស្រូវហើយ មិនបាន ទទួលនូវទិន្នផលល្អដូចអ្នកជិតខាង មកពីកសិករនោះ មិនគិត

គួរយកចិត្តទុកដាក់មើលថែទាំទឹកបញ្ចូលស្រែ ដាក់ជីឱ្យគ្រប់គ្រាន់និងបោចស្មៅ។ យ៉ាងណាមិញ ការអប់រំ និងការបណ្តុះបណ្តាល ក៏ទាមទារឱ្យគ្រូបង្រៀន សាស្ត្រាចារ្យយកចិត្តទុកដាក់នឹងសិស្ស ឬយុវសិស្សដែរ។

គោលដៅរបស់ការអប់រំ គឺសំដៅប្រើប្រាស់លំនាំអប់រំទៅតាមកម្រិតសិក្សានីមួយៗ សម្រាប់ធ្វើឱ្យកុមារ ជំទង់យុវជន និងនិស្សិតក្លាយទៅជាពលរដ្ឋល្អ បញ្ញវន្តប្រកបដោយសីលធម៌ស្អាតស្អំ ដើម្បីចូលរួម និងបន្តវេនក្នុងការសម្រេចបាននូវសមិទ្ធិផលគ្រប់វិស័យកសាង និងការពារមាតុប្រទេស ព្រមទាំងញ៉ាំងខឿនសេដ្ឋកិច្ច ជាតិឱ្យឈានដល់ភាពសម្បូរបែប ដើម្បីបម្រើតម្រូវការរបស់ប្រជាពលរដ្ឋ។ ការបណ្តុះបណ្តាលគ្រូបង្រៀន និងសាស្ត្រាចារ្យសម្រាប់ប្រព័ន្ធអប់រំមិនអាចកាត់ផ្តាច់ពីទស្សនវិជ្ជា និងគរុកោសល្យបានឡើយ។

## ១.៦ ទំនាក់ទំនងរវាងចិត្តវិទ្យា និងគរុកោសល្យ

មនុស្សគឺជាកម្មវត្ថុរបស់ការបង្រៀននិងការអប់រំ។ ដូច្នេះហើយបានជាគេត្រូវសិក្សាទៅលើធម្មជាតិ និង ច្បាប់ដែលជះឥទ្ធិពលមកលើការអភិវឌ្ឍខាងរូបកាយ និងផ្លូវចិត្តរបស់មនុស្ស។ សរីរវិទ្យា និងចិត្តវិទ្យាមាន ភារកិច្ច សិក្សាទៅលើបាតុភូតទាំងនេះ។ សរីរវិទ្យា និងចិត្តវិទ្យានេះ សម្រាប់ យកធ្វើជាមូ លដ្ឋាន ក្នុងការអនុវត្ត វិធីសាស្ត្របង្រៀន និងអប់រំតាមគរុកោសល្យទូទៅ។ ដើម្បីបង្រៀនមនុស្សបានទាល់តែស្គាល់ពីច្បាប់ធម្មជាតិ របស់មនុស្សសិន។ ដើម្បីអាចតាក់តែងបាននូវវិធីបង្រៀន និងអប់រំគ្រូបង្រៀនគប្បីឈរលើមូលដ្ឋានរបស់សរីរវិទ្យា និងចិត្តវិទ្យានេះឯង។ គ្រូបង្រៀនត្រូវប៉ិនប្រសប់ក្នុងការតាក់តែងវិធីបង្រៀនទាំងឡាយដែល ផ្តល់នូវលទ្ធផលក្នុងការបង្រៀន និងការអប់រំ។

*ឧទាហរណ៍៖*

-សកម្មភាពដ៏សំខាន់របស់កុមារតូចៗ គឺល្បែងកំសាន្ត។ ដើម្បីបង្រៀនកុមារទាំងនេះគ្រូត្រូវរៀបចំឱ្យ មានល្បែងកំសាន្ត

-ក្នុងការបង្រៀនអក្ខរក្រម ឱ្យដល់កុមារមត្តេយ្យ អ្នកគ្រូត្រូវចេះបង្គាប់ឱ្យកុមារតូចៗរកអក្សរ "ក" ដែលស្ថិតនៅក្នុងចំណោមអក្សរឯទៀតក្នុងប្រអប់មួយ។

គរុកោសល្យជាវិទ្យាសាស្ត្រស្តីពីការអប់រំ។គរុកោសល្យផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលក្ខខណ្ឌប្រវត្តិសាស្ត្រក្នុងសង្គមដោយយកចិត្តវិទ្យា ធ្វើជាមូលដ្ឋានក្នុងការអប់រំមនុស្ស។ គរុកោសល្យប្រើប្រាស់មូលដ្ឋាន ចិត្តវិទ្យានៅក្នុងការអប់រំ និងបកស្រាយបំភ្លឺពីលំនាំនៃបាតុភូតអប់រំក្នុងសាលារៀន។

គរុកោសល្យបកស្រាយពីសច្ចធម៌នៃធម្មជាតិក្នុងវិស័យអប់រំ។គរុកោសល្យផ្សារភ្ជាប់ជានិច្ចទៅនឹងលំនាំអភិវឌ្ឍផ្នែកចំណេះដឹង ផ្នែកបុគ្គលិកលក្ខណៈ និងការអភិវឌ្ឍរបស់សង្គមមនុស្ស។ គរុកោសល្យផ្សារភ្ជាប់ទៅនឹងដំណើរការ អភិវឌ្ឍរបស់វិទ្យាសាស្ត្រ និងបច្ចេកទេសទៅតាមសម័យកាលដ៏ជឿនលឿន របស់មនុស្សជាតិ។

## ១.៧ តួនាទីរបស់គរុកោសល្យក្នុងការបង្ហាត់បង្រៀន

គរុកោសល្យ បកស្រាយពន្យល់បានពីក្រឹត្យក្រមសត្យានុម័តស្តីពីចរិតប្រវត្តិសាស្ត្រ និងគំនិតណែនាំក្នុងការអប់រំមនុស្ស ក្នុងការក្តាប់យកចំណេះដឹង តាមលំនាំញាណសត្តិ។ បំណកស្រាយពន្យល់ តាមលក្ខណៈ គរុកោសល្យមានភាពចាំបាច់ណាស់នៅក្នុងការតាក់តែងវិធីសាស្ត្របង្រៀនការរៀបចំ និងការប្រើប្រាស់សម្ភារៈ ឧបទ្ទេសសិក្សា សំដៅឱ្យសិស្សងាយចេះ ងាយចាំ និងងាយយល់និងជួយឱ្យចិត្តវិទ្យា ជាមូល

ដ្ឋានគ្រឹះក្នុងការ អនុវត្តគរុកោសល្យមានតួនាទីដូចតទៅ៖

- ផ្តើមចេញពីហេតុការណ៍ជាក់ស្តែងនៃការអប់រំ និងតម្រូវការរបស់សង្គមគរុកោសល្យ ស្រាយបំភ្លឺពីគោលការណ៍ និងក្បួនច្បាប់នៅក្នុងការប្រតិបត្តិរបស់ការអប់រំ
- បន្សល់ទុកជាកេរ្តិ៍មរតកនូវប្រពៃណីដ៏ល្អរបស់សាលារៀនពីសម័យដើម ដោយលើកឡើងជាការទិទៀន ទៅលើចំណុចខ្វះខាត និងធ្វើឱ្យសម្បូរបែបនូវលទ្ធកម្មថ្មីៗនៃចំណេះដឹងរបស់សិស្ស
- ប្រឆាំងជានិច្ចនឹងភាពអន់ខ្សោយហួសសម័យ ក្នុងការផ្តល់ចំនេះដឹងឱ្យដល់សិស្ស
- ធ្វើតុល្យការ និងវាយតម្លៃទៅលើជោគជ័យដែលសម្រេចបាន ពីការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្ស
- ធ្វើវិភាគ ណែនាំបង្ហាញពីបទពិសោធន៍ លើការបង្រៀនគ្រប់មុខវិជ្ជាឯកទេស ដល់គ្រូបង្រៀន និងសាស្ត្រា ចារ្យដែលទើបចេញពីមហាវិទ្យាល័យគរុកោសល្យ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលគរុកោសល្យ។

## សន្និដ្ឋាន

សរុបសេចក្តីមក គរុកោសល្យ គឺជាវិទ្យាសាស្ត្រដ៏ប្រសើរថ្លៃថ្លាសម្រាប់ជួយគ្រូបង្រៀន និងសាស្ត្រាចារ្យ ឱ្យបំពេញបាននូវភារកិច្ចដ៏ថ្លៃថ្លារបស់ខ្លួន ក្នុងការបង្ហាត់បង្រៀន ការអប់រំ ការបណ្តុះបណ្តាលជំនាន់យុវវ័យ ឱ្យក្លាយទៅជាស្ថាបនិករបស់ប្រទេសជាតិទៅថ្ងៃអនាគត លើគ្រប់វិស័យទាំងអស់។

### សំណួរ

១. ការអបរំចាប់បដិសន្ធិតាំងពីសម័យណាមក?

២. ដូចម្តេចហៅថាការ អប់រំក្នុងន័យចង្អៀតនិងការអប់រំក្នុងន័យទូលាយ?

៣. ការអប់រំជះឥទ្ធិពលលើការអភិវឌ្ឍសង្គមយ៉ាងណាខ្លះ?

៤.កត្តាអ្វីខ្លះដែលនាំឱ្យខឿនអប់រំកម្ពុជាក្នុងសម័យសង្គមរាស្ត្រនិយមឱ្យមានដំណើរការអភិវឌ្ឍខ្លាំង?

៥. កម្មវត្ថុសិក្សារបស់គរុកោសល្យមានអ្វីខ្លះ?

៦. គរុកោសល្យមានតួនាទីអ្វីខ្លះ ក្នុងការបង្រៀន?

៧. លើកឡើង និងទាញឧទាហរណ៍ អំពីការអប់រំក្នុងន័យទូលាយ និងន័យចង្អៀត។

# មេរៀនទី២ ទស្សនៈនៃការអប់រំសតវត្សទី២១
( Educational Concept in the 21 Century )

## ២.១ វត្ថុបំណងមេរៀន

នៅចុងបញ្ចប់នៃមេរៀននេះ គរុនិស្សិតនឹងមានសមត្ថភាព៖

- កំណត់បានជំនាញនៃការសិក្សាសំខាន់ៗក្នុងសតវត្សទី២១ អត្ថន័យនៃការអប់រំបរិយាបន្ន និងការអប់រំភាពជាពលរដ្ឋសកល ព្រមទាំងស្វែងយល់ពីបញ្ហា និងដំណោះស្រាយជាបឋម។
- បង្ហាញពីលក្ខណៈសម្បត្តិគ្រូក្នុងយុគសម័យឌីជីថល
- ឆ្លុះបញ្ចាំងពីជំនាញ និងលក្ខណៈសម្បត្តិផ្ទាល់ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន
- ប្រើប្រាស់ជំនាញ និងសមត្ថភាពរបស់ខ្លួនក្នុងការបង្ហាត់បង្រៀនសិស្ស

## ២.២ ការសិក្សានៅសតវត្សទី២១

សតវត្សន៍ទី21 គឺជាសហស្សវត្សរ៏ដែលកំណត់ដោយរបកគំហើញនៃចំណេះដឹង និងបច្ចេកវិទ្យាដែលមិនធ្លាប់មានពីមុនមក និងដោយសេដ្ឋកិច្ចផ្អែកលើចំណេះដឹង ដែលជំរុញដោយសាកលភាវូបនីយកម្ម លទ្ធភាពទទួលបានព័ត៌មាន និងការរីកសាយយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា។ នេះទាមទារនូវសមត្ថភាពថ្មីដែលទាមទារនូវគំរូផ្សេងៗ និងការលើកកម្ពស់គរុកោសល្យ (Tan, 2004)។ អ្នកចាកចេញពីសាលាត្រូវតែបំពាក់មិនត្រឹមតែជាមួយអក្ខរកម្មជាមូលដ្ឋាននៃការអាន ការរែកញែក ការសរសេរ សមត្ថភាពលេខប៉ុណ្ណោះទេ ប៉ុន្តែក៏មានសមត្ថភាពក្នុងការសម្របខ្លួន ផ្សងព្រេងទៅក្នុងវិស័យចំណេះដឹងថ្មីៗ និងរៀនជំនាញថ្មីៗផងដែរ។ បច្ចេកវិទ្យាកំពុងផ្លាស់ប្តូររបៀបដែលយើងរៀនរស់នៅ និងធ្វើការ។ Frey and Osborne (2013) មកពីសាកលវិទ្យាល័យ Oxford បានប្រកាសថា 47% នៃការងារនាពេលបច្ចុប្បន្ននេះអាចត្រូវបានស្វ័យប្រវត្តិក្នុងរយៈពេលពីរទសវត្សរ៍ខាងមុខ។ ស្វ័យប្រវត្តិកម្មឆ្លាតវៃ ដូចជារថយន្តគ្មានអ្នកបើកបរ បានក្លាយជាការពិតហើយនៅកន្លែងខ្លះ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការពិចារណាឱ្យស៊ីជម្រៅ មិនត្រឹមតែអ្វីដែលយើងចង់ឱ្យសិស្សរៀនប៉ុណ្ណោះទេ ប៉ុន្តែវិធីដែលពួកគេរៀន។

យើងអាចពិចារណាពីនិន្នាការខាងក្រោម ហើយគិតពីរបៀបដែលពួកគេអាចមានឥទ្ធិពលលើការរៀបចំសិស្សរបស់យើងសម្រាប់អនាគត៖

- បង្កើនការប្រកួតប្រជែងសេដ្ឋកិច្ចសកលជាសកល
- ការផ្លាស់ប្តូរបរិយាកាសនៅកន្លែងធ្វើការ
- បង្កើនភាពចម្រុះនៅក្នុងសង្គម និងពិភពពហុមុខ
- ការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម
- ការផ្លាស់ប្តូរការរំពឹងទុករបស់អ្នកសិក្សា
- ការផ្លាស់ប្តូរការរំពឹងទុករបស់ឪពុកម្តាយ
- ឱកាសសម្រាប់ការសិក្សាក្រៅថ្នាក់
- អនុវត្តការរៀនសូត្រទៅកាន់ពិភពពិត

- គំរូថ្មីនៃការចូលរួមសហគមន៍ជាមួយការអប់រំ
- ឧបករណ៍ និងលទ្ធភាពថ្មីៗសម្រាប់ការរៀនសូត្រ

ដើម្បីទប់ទល់នឹងការផ្លាស់ប្តូរដែលបានរៀបរាប់ខាងលើ យើងត្រូវរៀបចំសិស្សជាមួយនឹងសំណុំជំនាញផ្សេងៗ ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាពនៅក្នុងពិភពលោកថ្មី។ សញ្ញាណប្រពៃណីនៃការបញ្ជូនចំណេះដឹង ជំនាញ និងអាកប្បកិរិយាហាក់ដូចជាមិនគ្រប់គ្រាន់ដើម្បីដោះស្រាយតម្រូវការនេះ។ មានតម្រូវការបន្ទាន់សម្រាប់អ្នកអប់រំដើម្បីទទួលស្គាល់ផលប៉ះពាល់នៃការផ្លាស់ប្តូរថាមវន្តទាំងនេះ។ ធម្មជាតិនៃការអប់រំ និងកម្មវិធីសិក្សារបស់វាមិនត្រឹមតែមានផលប៉ះពាល់ដល់គុណភាពជីវិតប៉ុណ្ណោះទេ ថែមទាំងសម្រាប់ភាពជោគជ័យផ្នែកវប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសជាតិផងដែរ។ សេដ្ឋកិច្ចពិភពលោកត្រូវបានជំរុញដោយចំណេះដឹង ដើមទុន និងការបណ្តាក់ទុនប្រកបដោយការច្នៃប្រឌិត។ លក្ខណៈនៃចំណេះដឹងផ្អែកលើសតវត្សន៍ទី ២១ អំពាវនាវឱ្យមានការវិវឌ្ឍន៍នៃភាពវៃឆ្លាតក្នុងពហុវិមាត្រ (Tan & Seng, 2005)។ ម្យ៉ាងវិញទៀត លើសពីការគិតលើភាពវៃឆ្លាតដែលបានសង្កត់ធ្ងន់ជាប្រពៃណីនៅក្នុងប្រព័ន្ធប្រឡង ត្រូវតែមានការសង្កត់ធ្ងន់បន្ថែមទៀតលើវិធីនៃការគិតផ្សេងៗ ដូចជាការគិតទូទៅ និងការគិតតាមប្រព័ន្ធនៅទូទាំងបរិបទវិន័យផងដែរ។ នេះមានន័យថាមិនត្រឹមតែរៀនពីរបៀបធ្វើប៉ុណ្ណោះទេ ថែមទាំងមានសមត្ថភាពក្នុងការដោះស្រាយជាមួយនឹងភាពថ្មីថ្មោង អភិវឌ្ឍសមត្ថភាពសម្របខ្លួន និងជ្រើសរើសអន្តរកម្មជាមួយបរិកាសជុំវិញទៀតផង។ គុណលក្ខណៈផ្លូវចិត្តដូចជាការបដិសេធពីការបិទមុនពេលកំណត់ ឧបសគ្គដែលមិនមានការជានា ការអត់ឱនចំពោះភាពមិនច្បាស់លាស់ និងឆន្ទៈក្នុងការទទួលយកហានិភ័យគឺ មានសារៈសំខាន់ដូចគ្នានឹងការទទួលបានការសិក្សាដែរ។ គុណលក្ខណៈសង្គម-អារម្មណ៍នៃការយល់ដឹងដោយខ្លួនឯង ការគ្រប់គ្រងអារម្មណ៍ ការលើកទឹកចិត្តខ្លួនឯង ជំនាញអន្តរបុគ្គល និងជំនាញទំនាក់ទំនងមានសារៈសំខាន់ដូចគ្នា។ សារៈសំខាន់ខ្លាំងជាងនេះគឺគុណតម្លៃ និងចរិតលក្ខណៈរបស់មនុស្សជំនាន់ក្រោយរបស់យើង សមត្ថភាពរបស់ពួកគេសម្រាប់ការរួមចំណែកដោយស្មោះស្ម័គ្រ និងការកសាងសង្គមដោយយកចិត្តទុកដាក់ និងអនាគតប្រកបដោយចីរភាព។

ក្រៅពីការយល់ដឹងអំពីបរិស្ថាន យើងក៏ត្រូវការ ការយល់ដឹងជាថ្មីអំពីការផ្លាស់ប្តូរទម្រង់របស់អ្នកសិក្សាផងដែរ។ ជំនាន់ថ្មីនៃអ្នកសិក្សាតាមអ៊ីនធឺណិតកំពុងលេចឡើងជាមួយនឹងមធ្យោបាយសិក្សាខុសៗគ្នា។ ចិត្តវិទ្យាអប់រំត្រូវតែអនុវត្តក្នុងបរិបទបែបនេះដែលមិនត្រូវបានរាប់បញ្ចូលពីមុនមក។ ការអប់រំល្អត្រូវគិតគូរពីរចនាបទសិក្សាចម្រុះ និងយុទ្ធសាស្ត្រសិក្សារបស់បុគ្គលផ្សេងៗ។

គ្រូបង្រៀនត្រូវសួរខ្លួនឯងនូវសំណួរដូចតទៅ៖

- តើការអនុវត្តការអប់រំរបស់យើងកំពុងអភិវឌ្ឍសិស្សឱ្យមានភាពវៃឆ្លាត និងសមត្ថភាពចាំបាច់សម្រាប់សតវត្សទី 21 ដែរឬទេ?
- តើខ្លឹមសារដែលយើងបង្រៀននឹងលែងមានអត្ថន័យទៀតហើយឬ?
- តើយើងកំពុងធ្វើកិច្ចការដដែលៗ ដែលគ្រាន់តែរៀបចំសិស្សសម្រាប់ការប្រឡងជាជាងជីវិតរបស់ពួកគឬទេ?
- តើយើងកំពុងប្រើដំណើរការ ដែលមិនប៉ះពាល់ដល់ការសិក្សាជីវិតពិតឬ?
- តើយើងយកគំរូតាមការគិត និងការចាត់ចែងដែលបង្កើតឧបសគ្គ ដែលមិនអាចជានាបានក្នុងការរៀន និងហេតុផលមែនទេ?

- តើយើងលើកទឹកចិត្តសិស្សឱ្យមានការចង់ដឹង ចង់ឃើញ និងការលើកទឹកចិត្តតាមរយៈបរិយាកាសសិក្សាដែលយើងបង្កើតទេ ?
- តើយើងកំពុងជួយអ្នកសិក្សាឱ្យក្លាយជាអ្នកដឹកនាំដោយខ្លួនឯង ដើម្បីឱ្យពួកគេអាចប្រឈមមុខនឹងចំណេះដឹងថ្មីៗនាពេលអនាគត ហើយមានទំនុកចិត្តក្នុងការដោះស្រាយខ្សែកោងការរៀនសូត្រដ៏ចោតទេ ?
- តើយើងកំពុងដាក់មូលដ្ឋានគ្រឹះសម្រាប់ការសិក្សារួមគ្នា និងការរៀនដោយសហការឬទេ ?
- តើយើងបំពាក់ឱ្យពួកគេនូវជំនាញ និងតម្លៃនៃចិត្ត-សង្គមដែលជះឥទ្ធិពលលើបុគ្គលិកលក្ខណៈ និងភាពជាអ្នកដឹកនាំក្នុងសេវាកម្មពេញមួយជីវិតដែរឬទេ ?



## ២.៣ ជំនាញនៃការសិក្សាសតវត្សទី២១ ( Learning Skills in the 21st Century )




ការអប់រំសតវត្សរ៍ទី២១ គឺអំពីការផ្តល់ឱ្យសិស្សនូវជំនាញដែលពួកគេត្រូវការដើម្បីទទួលបានជោគជ័យក្នុងពិភពលោកថ្មីនេះ និងជួយពួកគេបង្កើនទំនុកចិត្តក្នុងការអនុវត្តជំនាញទាំងនោះ។ ជាមួយនឹងព័ត៌មានជាច្រើនដែលអាចរកបានសម្រាប់ពួកគេ ជំនាញសតវត្សរ៍ទី២១ ផ្តោតលើការធ្វើឱ្យយល់អំពីព័ត៌មាននោះ ចែករំលែក និងប្រើប្រាស់វាតាមរបៀបឆ្លាតវៃ។

ភាពជាដៃគូសម្រាប់ការរៀនសតវត្សរ៍ទី 21 បានកំណត់ «ជំនាញសម្រាប់ថ្ងៃនេះ» ចំនួនបួន៖

(១) ភាពច្នៃប្រឌិត ( Creativity )

(២) ការត្រិះរិះពិចារណា ( Critical Thinking )

(៣) ការទំនាក់ទំនង ( Communications )

(៤) កិច្ចសហការ ( Collaboration )

## ២.៣.១ ការត្រិះរិះពិចារណា

ការគិតបែបត្រិះរិះពិចារណា គឺអំពីការវិភាគព័ត៌មាន និងការរិះគន់ការទាមទារ។ ការត្រិះរិះពិចារណា គឺផ្ដោតការយកចិត្តទុកដាក់ ការវិភាគដោយប្រុងប្រយ័ត្នលើអ្វីមួយ ដើម្បីយល់កាន់តែច្បាស់ នៅពេលដែលមនុស្សនិយាយអំពីសកម្មភាពអ្វីមួយ។ "ខួរក្បាលខាងឆ្វេង" ពួកគេតែងតែសំដៅទៅលើការគិតបែបរិះគន់។ ខាងក្រោមនេះជាសមត្ថភាពគិតវិភាគសំខាន់ៗមួយចំនួនៈ

- ការវិភាគ គឺការបំបែកអ្វីមួយចូលទៅក្នុងផ្នែករបស់វា ពិនិត្យផ្នែកនីមួយៗ និងកត់សម្គាល់ពីរបៀបដែលផ្នែកត្រូវគ្នា
- ការជជែកវែកញែកប្រើសេចក្ដីថ្លែងការណ៍ជាច្រើនដែលតភ្ជាប់គ្នាយ៉ាងច្បាស់លាស់ គាំទ្រដោយភស្តុតាង ដើម្បីឈានដល់ការសន្និដ្ឋានមួយ។
- ការចាត់ថ្នាក់ គឺជាការកំណត់ប្រភេទ ឬក្រុមនៃអ្វីមួយ ដោយបង្ហាញពីរបៀបដែលប្រភេទនីមួយៗមានភាពខុសប្លែកពីអ្នកដទៃ។
- ការប្រៀបធៀប និងភាពផ្ទុយគ្នា គឺជាការចង្អុលបង្ហាញពីភាពស្រដៀងគ្នា និងភាពខុសគ្នារវាងមុខវិជ្ជាពីរ ឬច្រើន។
- និយមន័យគឺការពន្យល់ពីអត្ថន័យនៃពាក្យដោយប្រើប្រាស់អត្ថន័យ ខ្លឹមសារ ឧទាហរណ៍ និរុត្តិសាស្ត្រ សទិសន័យ និងពាក្យផ្ទុយ។
- ការពិពណ៌នា គឺការពន្យល់ពីលក្ខណៈនៃអ្វីមួយដូចជា ទំហំ រូបរាង ទម្ងន់ ពណ៌ ការប្រើប្រាស់ ប្រភពដើម តម្លៃ លក្ខខណ្ឌ ទីតាំង ។ល។
- ការវាយតម្លៃ គឺជាការសម្រេចចិត្តលើតម្លៃនៃអ្វីមួយដោយប្រៀបធៀបវាទៅនឹងស្តង់ដារនៃតម្លៃដែលទទួលយកបាន។
- ការពន្យល់ គឺប្រាប់ពីអ្វីដែលជារបស់អ្វីមួយ ឬរបៀបដែលវាដំណើរការដើម្បីឱ្យអ្នកដទៃយល់អំពីវា។
- ការដោះស្រាយបញ្ហា គឺការវិភាគពីមូលហេតុ និងផលប៉ះពាល់នៃបញ្ហា ហើយស្វែងរកវិធីបញ្ឈប់មូលហេតុ ឬផលប៉ះពាល់។
- ការតាមដានមូលហេតុ និងឥទ្ធិពល គឺកំណត់ថា ហេតុអ្វីបានជាមានអ្វីមួយកើតឡើង និងលទ្ធផលអ្វីពីវា។

## ២.៣.២ គំនិតច្នៃប្រឌិត

ការច្នៃប្រឌិត គឺនិយាយអំពីការគិតតាមរយៈព័ត៌មានក្នុងវិធីថ្មី បង្កើតទំនាក់ទំនងថ្មី និងបង្កើតដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតចំពោះបញ្ហា។ ការគិតប្រកបដោយការច្នៃប្រឌិត គឺជាការពង្រីកការច្នៃប្រឌិតបើកចំហ និងការរកឃើញនូវលទ្ធភាព។ នៅពេលដែលមនុស្សនិយាយអំពីសកម្មភាព "ខួរក្បាលខាងស្តាំ" ពួកគេច្រើនតែមានន័យថា ការគិតប្រកបដោយភាពច្នៃប្រឌិត។ ខាងក្រោមនេះ គឺជាសមត្ថភាពគិតប្រកបដោយភាពច្នៃប្រឌិតទូទៅមួយចំនួនៈ

- គំនិតបំផុស គំនិតពាក់ព័ន្ធនឹងការសួរសំណួរមួយ ហើយរាយបញ្ជីចម្លើយទាំងអស់យ៉ាងឆាប់ រហ័ស សូម្បីតែចម្លើយដែលវែងឆ្ងាយ មិនអាចអនុវត្តបាន ឬមិនអាចទៅរួចក៏ដោយ។
- ការបង្កើតអ្វីមួយតម្រូវឱ្យបង្កើតវាឡើងដោយការបញ្ចូលគ្នារវាងសម្ភារៈ ប្រហែលជាយោងទៅតាមផែនការ ឬប្រហែលជាផ្អែកលើកម្លាំងជំរុញនៃពេលបច្ចុប្បន្ន។
- ការរចនាអ្វីមួយ មានន័យថា ការស្វែងរកការភ្ជាប់គ្នារវាងទម្រង់ និងមុខងារ និងសម្ភារៈទម្រង់សម្រាប់ គោលបំណងជាក់លាក់មួយ។
- ការកម្សាន្តអ្នកដទៃពាក់ព័ន្ធនឹងការនិទានរឿង បង្កើតរឿងកំប្លែង ច្រៀងចម្រៀង លេងហ្គេម សម្ដែងជាផ្នែក និងបង្កើតការសន្ទនា។
- គំនិតស្រមើស្រមៃពាក់ព័ន្ធនឹងការឈានទៅដល់អ្វីដែលមិនស្គាល់ និងមិនអាចទៅរួច ប្រហែលជាដោយឥលាក់លៀម ឬដោយផ្ដោតអារម្មណ៍ខ្លាំង ដូចលោកអែងស្តែងបានធ្វើជាមួយការពិសោធន៍គំនិតរបស់គាត់
- ការកែលម្អដំណោះស្រាយពាក់ព័ន្ធនឹងការប្រើប្រាស់អ្វីមួយតាមរបៀបថ្មីដើម្បីដោះស្រាយបញ្ហា។
- ការច្នៃប្រឌិត គឺបង្កើតអ្វីមួយដែលមិនមានពីមុនមក មិនថាវត្ថុ នីតិវិធី ឬគំនិតមួយ។
- ការបដិសេធអ្វីមួយមានន័យថា ត្រឡប់វា ដើម្បីទទួលបានទស្សនៈថ្មី ប្រហែលជាដោយកំណត់ឡើងវិញនូវអ្វីដែលផ្តល់ឱ្យ បញ្ច្រាសមូលហេតុ និងឥទ្ធិពល ឬសម្លឹងមើលអ្វីមួយតាមរបៀបថ្មី។
- ការដោះស្រាយបញ្ហាតម្រូវឱ្យប្រើប្រាស់សមត្ថភាពច្នៃប្រឌិតជាច្រើនដែលបានរាយបញ្ជីនៅទីនេះ ដើម្បីស្វែងរកដំណោះស្រាយដែលអាចកើតមាន និងដាក់ឱ្យដំណើរការមួយ ឬច្រើន។
- ការសាកសួរយ៉ាងសកម្មឈានដល់អ្វីដែលមិនស្គាល់ ដើម្បីធ្វើឱ្យវាស្គាល់ ស្វែងរកព័ត៌មាន ឬវិធីថ្មីដើម្បីធ្វើអ្វីមួយ។

## ២.៣.៣ ការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទងគ្នា គឺការយល់ដឹងអំពីអ្វីៗឱ្យបានគ្រប់គ្រាន់ដើម្បីចែករំលែកយ៉ាងច្បាស់ជាមួយមនុស្សផ្សេងទៀត។

- ការវិភាគស្ថានភាពមានន័យថា គិតអំពីប្រធានបទ គោលបំណង អ្នកផ្ញើ អ្នកទទួល ឧបករណ៍ផ្ទុក និងបរិបទនៃសារ។
- ការវាយតម្លៃសារ មានន័យថា ការសម្រេចចិត្តថា តើវាត្រឹមត្រូវ ពេញលេញ អាចទុកចិត្តបាន អនុញ្ញាត និងទាន់សម័យ។
- ការធ្វើតាមអនុសញ្ញាមានន័យថា ការប្រាស្រ័យទាក់ទងគ្នាដោយប្រើបទដ្ឋានដែលរំពឹងទុកសម្រាប់ឧបករណ៍ផ្ទុកដែលបានជ្រើសរើស។
- ការស្តាប់យ៉ាងសកម្ម តម្រូវឱ្យមានការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន កត់ត្រា សួរសំណួរ និងបើមិនដូច្នេះទេ អាចចូលរួមនៅក្នុងគំនិតដែលកំពុងទាក់ទង។
- ការអាន គឺការសម្រង់ពាក្យ និងរូបភាពជាលាយលក្ខណ៍អក្សរ ដើម្បីយល់ពីអ្វីដែលប្រភពដើមរបស់ពួកគេកំពុងព្យាយាមទំនាក់ទំនង។
- ការនិយាយ គឺពាក់ព័ន្ធនឹងការប្រើពាក្យសំដី សម្លេង ភាសាកាយវិការ ទឹកមុខ និងជំនួយការមើលឃើញ ដើម្បីបង្ហាញគំនិត។

- ការផ្លាស់ប្តូរគំនិត (Turn taking) មានន័យថាការផ្លាស់ប្តូរយ៉ាងមានប្រសិទ្ធភាពពីការទទួលគំនិតទៅជាការផ្តល់គំនិត ទៅវិញទៅមករវាងអ្នកនៅក្នុងស្ថានភាពទំនាក់ទំនង។
- ការប្រើប្រាស់បច្ចេកវិទ្យា គឺទាមទារការយល់ដឹងអំពីសមត្ថភាព និងដែនកំណត់នៃការទំនាក់ទំនងបច្ចេកវិទ្យាណាមួយ ចាប់ពីការហៅទូរសព្ទទៅអ៊ីមែល រហូតដល់សារភ្លាមៗ។
- ការសរសេរ គឺពាក់ព័ន្ធនឹងការបំប្លែងសារទៅជាពាក្យ ប្រយោគ និងកថាខណ្ឌ ក្នុងគោលបំណងទំនាក់ទំនងទៅកាន់បុគ្គលដែលនៅឆ្ងាយ ឬអាចប្រើពេលវេលាយូរ។

## ២.៣.៤ កិច្ចសហការ

- ការបែងចែកធនធាន និងទំនួលខុសត្រូវជានាថា សមាជិកទាំងអស់នៃក្រុមអាចធ្វើការប្រកបដោយប្រសិទ្ធភាព។
- ការបំផុសគំនិតក្នុងក្រុមពាក់ព័ន្ធនឹងការផ្តល់យោបល់យ៉ាងឆាប់រហ័ស និងសរសេរបញ្ចូលគំនិតដោយមិនគិតពីការរិះគន់។
- ការសម្រេចចិត្តតម្រូវឱ្យតម្រៀបតាមជម្រើសជាច្រើនដែលបានផ្តល់ដល់ក្រុម ហើយមកដល់ជម្រើសតែមួយដើម្បីឆ្ពោះទៅមុខ។
- ការធ្វើប្រតិភូកម្ម (Delegating) មានន័យថា ប្រគល់ភារកិច្ចដល់សមាជិកក្រុម ហើយរំពឹងថាពួកគេបំពេញផ្នែកនៃភារកិច្ចរបស់ពួកគេ។
- ការវាយតម្លៃផលិតផល ដំណើរការ និងសមាជិកនៃក្រុម ផ្តល់នូវអារម្មណ៍ច្បាស់លាស់អំពីអ្វីដែលកំពុងដំណើរការល្អ និងអ្វីដែលអាចធ្វើឱ្យប្រសើរឡើង។
- ការកំណត់គោលដៅ តម្រូវឱ្យក្រុមវិភាគស្ថានភាពសម្រេចថា តើលទ្ធផលអ្វីដែលចង់បាន និងបញ្ជាក់យ៉ាងច្បាស់អំពីគោលដៅដែលអាចសម្រេចបាន។
- ការដឹកនាំក្រុមមានន័យថា បង្កើតបរិយាកាសមួយដែលសមាជិកទាំងអស់អាចចូលរួមចំណែកតាមសមត្ថភាពរបស់ពួកគេ។
- ការគ្រប់គ្រងពេលវេលា ពាក់ព័ន្ធនឹងការផ្គូផ្គងបញ្ជីកិច្ចការទៅនឹងកាលវិភាគ និងតាមដានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅ។
- ការដោះស្រាយជម្លោះកើតឡើងពីការប្រើប្រាស់យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រខាងក្រោម៖ ការអះអាង សហការ ការសម្របសម្រួល ការប្រកួតប្រជែង ឬការពន្យាពេល។
- ការកសាងក្រុមមានន័យថា សហការគ្នាធ្វើការទោះជាលើសម៉ោង ដើម្បីសម្រេចបាននូវគោលដៅរួម។

អាស្រ័យហេតុនេះគ្រូបង្រៀនសតវត្សរ៍ទី២១ ត្រូវការធ្វើជាមគ្គុទ្ទេសក៍ ឬអ្នកណែនាំសម្រាប់សិស្សរបស់ពួកគេ មិនមែនជាអ្នកចេះដឹងទាំងអស់ដែលផ្តល់ព័ត៌មានទាំងអស់ដល់ពួកគេនោះទេ។ ជាមួយនឹងការចូលប្រើប្រាស់ធនធានគ្រប់ប្រភេទ ឧទាហរណ៍ កុមារតែងតែអាចដឹងច្រើនជាងគ្រូលើប្រធានបទផ្សេងគ្នា ហើយឈានមុខគេនៃបច្ចេកវិទ្យាដែលកំពុងប្រើប្រាស់។ គ្រូត្រូវផ្តល់សិទ្ធិអំណាចជាអ្នកសម្របសម្រួល និងអ្នកលើកទឹកចិត្តសម្រាប់ការរៀនសូត្រ ដូច្នេះពួកគេអាចផ្តល់អំណាចដល់សិស្សរបស់ពួកគេជាវេន។

ការផ្លាស់ប្តូរនេះគឺជាដំណឹងដ៏ល្អសម្រាប់គ្រូបង្រៀន។ ជំនួសឱ្យការតស៊ូដើម្បីផ្តល់ឱ្យកុមារនូវព័ត៌មានទាំងអស់ដែលពួកគេត្រូវការដើម្បីទទួលបានជោគជ័យនៅក្នុងផ្នែកដែលគ្រូដឹងតិចតួច ពួកគេអាច

គាំទ្រសិស្សនៅពេលពួកគេធ្វើជំហានផ្ទាល់ខ្លួនរបស់ពួកគេទៅក្នុងវិស័យផ្សេងៗ។ វានិយាយអំពីការរៀបចំកុមារឱ្យទៅហួសពីឪពុកម្តាយ និងគ្រូបង្រៀនរបស់ពួកគេ ដោយធ្វើឱ្យប្រាកដថា ពួកគេមានជំនាញដើម្បីធ្វើវា ហើយបន្ទាប់មកជួយតាមផ្លូវនៅពេលពួកគេបង្កើតទំនុកចិត្តដើម្បីសម្រេចបាន។ នេះមានន័យថា គ្រូបង្រៀនត្រូវមានការគិតទៅមុខ ចង់ដឹង ចង់ឃើញ និងអាចបត់បែនបាន។ គ្រូបង្រៀនត្រូវតែជាអ្នកសិក្សារៀនវិធីថ្មីនៃការបង្រៀន និងរៀនជាមួយសិស្សរបស់ពួកគេ។ គ្រាន់តែសួរសំណួរដូចជា "តើសិស្សរបស់ខ្ញុំនឹងត្រូវការអ្វីខ្លះ ឬហាសិបឆ្នាំចាប់ពីពេលនេះទៅ? តើខ្ញុំអាចជួយឱ្យពួកគេនូវជំនាញទាំងនោះដោយរបៀបណា?» អាចផ្លាស់ប្តូរផ្នត់គំនិតរបស់អ្នក ធ្វើឱ្យអ្នកក្លាយជាអ្នកដឹកនាំ និងជួយអ្នកនាំមកនូវការផ្លាស់ប្តូរនៅក្នុងថ្នាក់រៀន សាលារៀន និងសហគមន៍របស់អ្នក។

- ចាប់ផ្តើមថ្ងៃនេះ៖ គន្លឹះជាក់ស្តែងសម្រាប់សាលាសតវត្សរ៍ទី ២១
- អញ្ជើញសិស្សឱ្យចូលរួមចំណែកក្នុងកិច្ចប្រជុំយុទ្ធសាស្ត្រ និងការសម្រេចចិត្ត
- បង្កើតបរិយាកាសសិក្សាដែលអាចសម្របខ្លួនបាន សមស្របទៅនឹងប្រភេទផ្សេងៗនៃការសហការ និងការងារជាក្រុម
- លើកទឹកចិត្តសិស្សឱ្យធ្វើជាម្ចាស់នៃកម្មវិធីសេវាសហគមន៍
- ស្វែងរកវិធីដើម្បីភ្ជាប់សិស្សទៅនឹងមនុស្សដែលមានអាយុរបស់ពួកគេនៅក្នុងផ្នែកផ្សេងទៀតនៃពិភពលោក
- ពិនិត្យមើលការប្រើប្រាស់បច្ចេកវិទ្យារបស់អ្នកនៅក្នុងថ្នាក់រៀន៖ តើវាអាចធ្វើឱ្យមានប្រសិទ្ធភាពជាងមុនដោយរបៀបណា?

ជំនាញដូចជាការប្រាស្រ័យទាក់ទង ការគិតត្រិះរិះពិចារណា និង EQ ហួសពីកន្លែងធ្វើការ៖ ពួកគេអាចជួយមនុស្សឆ្លងកាត់គ្រាលំបាកបំផុតនៃជីវិតរបស់ពួកគេ។ ការស្វែងរកចំណង់ចំណូលចិត្តរបស់អ្នក ធ្វើវាឱ្យបានល្អ ការយល់ដឹងអំពីគោលបំណង និងការផ្តោតអារម្មណ៍ និងអាចគ្រប់គ្រងការងារ និងជីវិតរបស់អ្នក គឺជាជំហានដ៏សំខាន់នៅលើផ្លូវទៅកាន់សុខុមាលភាព។

សមត្ថភាពក្នុងការគិតពិចារណា និងប្រកបដោយភាពច្នៃប្រឌិត សហការជាមួយអ្នកដទៃ និងការប្រាស្រ័យទាក់ទងយ៉ាងច្បាស់លាស់ កំណត់សិស្សឱ្យទទួលបានជោគជ័យក្នុងអាជីពរបស់ពួកគេ ប៉ុន្តែថែមទាំងផ្តល់អំណាចឱ្យពួកគេដឹកនាំជីវិតកាន់តែសប្បាយរីករាយ និងមានសុខភាពល្អ។

ការនាំសាលារៀនរបស់អ្នកចូលទៅក្នុងសតវត្សទី 21 ទាមទារឱ្យមានការនាំមុខជំនួសឱ្យការដើរពីក្រោយដោយសកម្មស្វែងរកវិធីថ្មីនៃការធ្វើកិច្ចការ និងរក្សាទំនាក់ទំនងជាមួយពិភពលោកនៅខាងក្រៅប្រព័ន្ធអប់រំ។ ការផ្លាស់ប្តូរក្នុងកម្រិតទូលំទូលាយទាមទារភាពជាអ្នកដឹកនាំនៅក្នុងថ្នាក់រៀន និងទូទាំងសហគមន៍សាលា ប៉ុន្តែគ្រូបង្រៀនគ្រប់រូបអាចចាត់វិធានការភ្លាមៗដើម្បីជួយសិស្សរបស់ពួកគេឱ្យទទួលបានជោគជ័យ។

ពាក្យថា "ការអប់រំសម្រាប់សតវត្សរ៍ទី២១" ទទួលស្គាល់ថាយើងកំពុងរស់នៅតាមរយៈការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងបរិយាកាសសកលភាវូបនីយកម្មដែលកាន់តែខ្លាំងឡើង ដែលប្រព័ន្ធអប់រំត្រូវសម្របខ្លួន មិនមែនតាមរយៈកំណែទម្រង់តែមួយប៉ុណ្ណោះទេ ប៉ុន្តែជាបន្ត។

## ២.៤ ការអប់រំបរិយាបន្ន

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើនរួមទាំងជនមានពិការភាពផងដែរ។ ប្រជាជនកម្ពុជាក៏ប្រឈមនឹងការធ្លាក់ទៅក្នុងពិការភាពដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះដែលសេសសល់ពីសង្គ្រាម។ ក្រៅពីនេះ ពិការភាពផ្សេងទៀតបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា និងមូលហេតុផ្សេងទៀត។ ដូចនេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរកដំណោះស្រាយឱ្យទាន់ពេលវេលា ។ ដើម្បីធានាបាននូវនិរន្តរភាព ក្នុងការអភិវឌ្ឍធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញ គុណភាព ស្មារតីទទួលខុសត្រូវស្របតាមសីលធម៌វិជ្ជាជីវៈទទួលបានលក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ និងមានការទទួលស្គាល់ពីសង្គម។ ជាមួយគ្នានេះគ្រូបង្រៀនត្រូវអភិវឌ្ឍសមត្ថភាពជំនាញឱ្យស្របទៅតាមតម្រូវការពិសេសរបស់សិស្សមានពិការភាព ដើម្បីឆ្លើយតបនឹងគោលនយោបាយស្តីពីការអប់រំបរិយាបន្នក្នុងយុគសម័យឌីជីថល។

### ២.៤.១ និយមន័យ៖

- ការអប់រំបរិយាបន្ន មានន័យថា ការបង្កើតបរិយាកាសសាលារៀន និងបង្រៀនសមស្របសម្រាប់សិស្សទាំងអស់នៅក្នុងសាលាទូទៅដោយមិនគិតពីភាពខុសគ្នារវាង ប្រវត្តិសេដ្ឋកិច្ចសង្គម មានពិការភាព ឬមិនមានពិការភាព ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា និងជាតិពន្ធុ (ជនជាតិដើមភាគតិច)។ (UNICEF)
- ការអប់រំបរិយាបន្ន គឺសំដៅដល់ដំណើរការដោះស្រាយ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗគ្នារបស់បុគ្គល និងក្រុមនានាតាមរយៈការលើកកម្ពស់ការចូលរួមក្នុងការសិក្សា វប្បធម៌ និងសហគមន៍ ការកាត់បន្ថយ និងលុបបំបាត់ការបំភ្លេចចោល ឬផាត់ចេញពីប្រព័ន្ធអប់រំ។ ការអប់រំបរិយាប័ន្នទាមទារឱ្យមានការផ្លាស់ប្តូរ និងកែសម្រួលខ្លឹមសារមេរៀន យុទ្ធវិធី ទម្រង់ និងយុទ្ធសាស្ត្រ ដើម្បីបញ្ចូលជនគ្រប់រូបទៅក្នុងប្រព័ន្ធអប់រំ។ ការអប់រំបរិយាបន្ន គឺជាការដំណើរការពង្រីកសមត្ថភាពរបស់ប្រព័ន្ធអប់រំក្នុងផ្តល់សេវាកម្មដល់អ្នកសិក្សាគ្រប់រូប។ (UNESCO, ២០០៥)
- ការអប់រំបរិយាបន្ន គឺជា «វិធីសាស្ត្រសកម្មនៃការឆ្លើយតបដោយវិជ្ជមានទៅកាន់ភាពចម្រុះគ្នានៃសិស្ស និងការមើលឃើញភាពខុសគ្នារបស់សិស្សមិនមែនជាបញ្ហា ប៉ុន្តែជាឱកាសសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង»។

### ២.៤.២ ឥរិយាបថបណ្តាលឱ្យមាន ឬមិនមានលក្ខណៈអប់រំបរិយាបន្ន

### ក. មើលឃើញសិស្សជាបញ្ហា

នៅពេលសង្គមគិតថា សិស្សគឺជាបញ្ហាសម្រាប់ការមិនទទួលបានការអប់រំ សង្គមនោះដាក់កំហុសទៅលើ សិស្ស។ បន្ទាប់មកសហគមន៍ ឪពុកម្តាយ នាយកសាលា និងគ្រូបង្រៀនគិតថា ពួកគេមិនមានការទទួលខុសត្រូវអ្វីទាំងអស់ ដើម្បីធ្វើការផ្លាស់ប្តូរអាកប្បកិរិយា និងសកម្មភាពរបស់ពួកគេ។ ការធ្វើបែបនេះបណ្តាលឱ្យមានការផាត់ចេញ ហើយសិស្សត្រូវបានបោះបង់ដោយគ្រួសារ សហគមន៍ ប្រព័ន្ធអប់រំ និងមិនអាចក្លាយជាសមាជិកសកម្មដើម្បីចូលរួមជាមួយគ្រួសារ សហគមន៍ សាលារៀន និងសង្គម។

## ខ. មើលឃើញថាប្រព័ន្ធអប់រំគឺជាបញ្ហា

នៅពេលសង្គមគិតថា ប្រព័ន្ធអប់រំគឺជាបញ្ហា សង្គមនោះដាក់ការទទួលខុសត្រូវលើប្រព័ន្ធអប់រំ និងអ្នកពាក់ព័ន្ធទាំងឡាយដើម្បីធ្វើការផ្លាស់ប្តូរ និងដាក់បញ្ចូលសិស្សទាំងអស់នៅក្នុងការអប់រំ។ ការធ្វើបែបនេះជួយដល់ការដាក់បញ្ចូលសិស្សដែលងាយបាត់បង់ឱកាស។ នៅក្នុងសាលារៀន គ្រូបង្រៀនយល់ថាពួកគេត្រូវធ្វើការផ្លាស់ប្តូរវិធីបង្រៀន ដើម្បីឱ្យសិស្សទាំងអស់អាចរៀន និងទទួលបានការអប់រំប្រកបដោយគុណភាព។

### ការកំណត់បញ្ហា និងការផ្លាស់ប្តូរការគិត







ពេលយើងពន្យល់ ឬនិយាយទៅកាន់ជនពិការភាពដោយប្រើពាក្យគួរសម នោះយើងបង្ហាញពីការគោរព និងជួយបង្កើនឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាសង្គម។

## រូបភាពបង្ហាញពីឧបសគ្គ និងដំណោះស្រាយចំពោះជនមានពិការភាព




ការស្តារកាយសម្បទានិងគ្រឿងបរិក្ខារ ការបង្ករភាពងាយស្រួល ការផ្លាស់ប្តូរអាកប្បកិរិយា

adopted from WVC presentation




- ការយល់ដឹង
- សមាហរណកម្ម
- ការឆ្លើយតប

### ២.៤.៣ បញ្ញាត្តិនៃជនមានពិការភាព

**និយមន័យទី១៖** «ជនពិការ» ត្រូវបានជំនួសដោយពាក្យ «ជនមានពិការភាព» សំដៅលើអ្នកទាំងឡាយណាដែលមានភាពអន់ខ្សោយរយៈពេលយូរផ្នែកកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញាណដឹង ដែលនៅពេលជួបប្រទះជាមួយ ឧបសគ្គនានាអាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គមដោយភាពស្មើគ្នាជាមួយអ្នកដទៃបាន។ (អនុសញ្ញាស្តីពីសិទ្ធិជនពិការ)

**និយមន័យទី២៖** ជនពិការសំដៅទៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញាបណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិបាកក្នុងការស្តាប់ ខ្សោយសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងទៀតដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។ (ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ)

## ២.៥ ការអប់រំភាពជាពលរដ្ឋសកល

### ២.៥.១. និយមន័យ

ពលរដ្ឋសកល គឺជាពលរដ្ឋដែលជាសមាជិកនៃសកលលោកទាំងមូលដោយមិនមានការរើសអើង និងជាពលរដ្ឋដែលប្រកាន់ខ្ជាប់នូវការចែករំលែកវប្បធម៌ ការទទួលស្គាល់ និងការឱ្យតម្លៃវប្បធម៌ចម្រុះនៃជាតិសាសន៍ដទៃ ព្រមទាំងមានការទទួលខុសត្រូវ ខ្វាយខ្វល់ទៅលើបញ្ហានយោបាយ បញ្ហាសេដ្ឋកិច្ច បញ្ហាបរិស្ថាន និងបញ្ហាសង្គម។

ការអប់រំអំពីភាពជាពលរដ្ឋសកល ជួយអ្នកសិក្សាយល់ច្បាស់ពីការវែកញែកអំពីអំណាចដែលនៅពីក្រោយពីបញ្ហាទាំងក្នុង និងខាងក្រៅប្រទេស ហើយលើកទឹកចិត្តឱ្យអ្នកសិក្សាចូលរួមស្វែងរកឬសគល់នៃបញ្ហាទាំងនោះ ដើម្បីឈានទៅរកការអភិវឌ្ឍជាវិជ្ជមាននៅក្នុងសង្គម។ ការអប់រំអំពីភាពជាពលរដ្ឋសកលមានគោលបំណងជំរុញអ្នកសិក្សាឱ្យក្លាយជាភ្នាក់ងារនៃការអភិវឌ្ឍសង្គម ដោយការលើកកម្ពស់ចំណេះដឹង ជំនាញ និងបទពិសោធ ព្រមទាំងការផ្លាស់ប្តូរជាវិជ្ជមាននូវអាកប្បកិរិយា ឬទម្លាប់មិនល្អ។

### ២.៥.២. កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណកម្មបុគ្គល

តាមន័យទូទៅយើងអាចកំណត់អត្តសញ្ញាណកម្មថា ជាសតិអារម្មណ៍ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗដែលបានបង្កើតឡើងដោយចរិកលក្ខណៈពិសេសភាពជាប់ទាក់ទងគ្នា និងតួនាទីក្នុងសង្គមរបស់ពួកគេ។ លើសពីនេះអត្តសញ្ញាណកម្មមាននិរន្តភាព ដោយមនុស្សម្នាក់មានសតិអារម្មណ៍ស្រដៀងគ្នាទៅនឹងមនុស្សម្នាក់ទៀត ហើយបន្តបន្ទាប់នឹងក្លាយជាមនុស្សតែមួយ ទោះបីជាមានការផ្លាស់ប្តូរច្រើនក្នុងស្ថានភាពរបស់ពួកគេយ៉ាងណាក៏ដោយ។ គ្រាប់ពូជនៃអត្តសញ្ញាណកម្មត្រូវបានបណ្តុះក្នុងវ័យកុមារ ដែលអ្នកមើលថែមានឥទ្ធិពលទៅលើពួកគេជាទីបំផុត។ ប៉ុន្តែការផ្លាស់ប្តូរបុគ្គលពីវ័យកុមាររហូតដល់វ័យជំទង់នាពេលនោះ ពួកគេចាប់ផ្តើមចេះសួរសំណួរថា៖ តើពួកគេជាអ្នកណា និងតើពួកគេសម្របសម្រួលខ្លួនទៅក្នុងសង្គមដោយរបៀបណាដែរ? ដូច្នេះមនុស្សវ័យជំទង់ត្រូវចាកចេញដើម្បីរកឱ្យឃើញពីអារម្មណ៍ផ្ទាល់ខ្លួនពួកគេ ដោយមានការធ្វើពិសោធជាមួយនឹងតួនាទី និងអត្តចរិកខុសៗគ្នា (Erikson, 1956)។ ទោះបីជាមនុស្សពេញវ័យ បន្តវាយតម្លៃអត្តសញ្ញាណក្នុងជីវិតពួកគេយ៉ាងណាក៏ដោយភាពផ្លាស់ប្តូរនៃអត្តសញ្ញាណគឺនៅមានតិចតួចនៅឡើយ។ ដូចនេះយោងតាមអ្នកចិត្តសាស្ត្រដ៏ល្បីល្បាញ គឺលោក អ៊ីរិក អ៊ីរិកសុន ការអភិវឌ្ឍន៍អត្តសញ្ញាណកម្មនៅអំឡុងពេលពេញវ័យ គឺមានសារៈសំខាន់ដើម្បីឱ្យមនុស្សម្នាក់ៗអាចបង្កើតគោលគំនិតផ្ទាល់ខ្លួនមួយដ៏រឹងមាំ ហើយអាចអភិវឌ្ឍទិសដៅក្នុងជីវិតបាន (Erikson, 1956)។ ការបង្កើតអត្តសញ្ញាណកម្ម ឬអាចហៅថា ការអភិវឌ្ឍន៍អត្តសញ្ញាណកម្ម ឬការកសាងអត្តសញ្ញាណកម្ម គឺជាដំណើរ

ការស្មុគ្រស្មាញមួយដែលមនុស្សទូទៅអាចអភិវឌ្ឍទិដ្ឋភាព និងអត្តសញ្ញាណពួកគេដោយច្បាស់លាស់ និងមានលក្ខណៈពិសេស។ អត្តសញ្ញាណច្រើនប្រភេទស្ថិតនៅក្នុងបុគ្គលម្នាក់ៗរួមគ្នា ហើយអាចបែងចែកជាៈ អត្តសញ្ញាណវប្បធម៌ អត្តសញ្ញាណវិជ្ជាជីវៈ អត្តសញ្ញាណជនជាតិ និងសញ្ជាតិ អត្តសញ្ញាណសាសនា អត្តសញ្ញាណយេនឌ័រ និងអត្តសញ្ញាណពិការភាព។

នៅក្នុងការអនុវត្តជាក់ស្តែង មនុស្សត្រូវយល់ដឹងពីអត្តសញ្ញាណរបស់ពួកគេ ដើម្បីជៀសវាងការកើតមាននូវវិបត្តិអត្តសញ្ញាណ។ ចំណេះដឹងអំពីអត្តសញ្ញាណរបស់ពួកគេមានសារៈសំខាន់ក្នុងការកំណត់អត្តសញ្ញាណរបស់ពួកគេ ដោយសារមានកម្រិតនៃអត្តសញ្ញាណខុសៗគ្នានៅក្នុងសង្គមនីមួយៗ។ ការដឹងពីអត្តសញ្ញាណធ្វើឱ្យពួកគេចេះរៀន និងឱ្យតម្លៃចំពោះអត្តសញ្ញាណគ្នាទៅវិញទៅមក ហើយជាលទ្ធផលពួកគេអាចរស់នៅជាមួយគ្នាដោយសុខដុមរមនា ព្រមទាំងអាចផ្លាស់ប្តូរខ្លួនឯងដើម្បីបំពេញតម្រូវការរបស់ពលរដ្ឋក្នុងពិភពលោក។ ម្យ៉ាងវិញទៀត ភាពចម្រុះនៃអត្តសញ្ញាណក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ ចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងបញ្ហាដែលបានជួបប្រទះនឹងអំពើហិង្សា ដោយទាំងនេះត្រូវមានភាពចាំបាច់ និងចេះសម្របខ្លួនក្នុងសង្គម ព្រមទាំងដឹងពីរបៀបគោរពគ្នាទៅវិញទៅមកក្នុងសហគមន៍។

### ២.៥.៣. សហគមន៍មនុស្សនានា និងទំនាក់ទំនងរវាងសហគមន៍ទាំងនោះ

មនុស្សជាតិមានតម្រូវការមូលដ្ឋានដូចគ្នា ប៉ុន្តែមានវិធីផ្សេងគ្នាជាច្រើនក្នុងការបំពេញតម្រូវការទាំងនោះ។ ភាពខុសគ្នានៃយេនឌ័រ វប្បធម៌ វណ្ណៈ ជាតិសាសន៍ សាសនា ជាតិពិន្ទុ ភាសា និងឋានៈ អាចមានសារៈសំខាន់ក្នុងការពន្យល់ពីការភាពខុសគ្នានានា និងការកំណត់អត្តសញ្ញាណ។ ទោះបីជាយើងទាំងអស់គ្នារស់នៅជាមួយនឹងគោលបំណងធ្វើឱ្យជីវិតមានសុភមង្គល ក៏ជីវិតរបស់យើងមិនដូចគ្នាដែរ។ ហើយនៅតែរស់នៅក្នុងសហគមន៍នៃពិភពលោក។ ហេតុនេះហើយយើងត្រូវការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកតាមគោលបំណង និងវិធីផ្សេងៗ ដូចជាការគាំទ្រពីសង្គមទាំងផ្នែកហិរញ្ញវត្ថុ និងការថែទាំសុខភាពផ្លូវចិត្ត។

បច្ចុប្បន្ន និន្នាការនៃការអប់រំពិភពលោក សង្កត់ធ្ងន់លើគោលបំណង នៃការផ្តល់ដល់អ្នកសិក្សាមិនត្រឹមតែចំណេះដឹងមូលដ្ឋានដែលផ្តោតលើបុគ្គលមានសមត្ថភាពអាន សរសេរ និងលេខនព្វន្ធ និងជំនាញប៉ុណ្ណោះទេ ថែមទាំងដើម្បីជួយមនុស្សរស់នៅដោយយុត្តិធម៌ សុវត្ថិភាព អព្យាក្រិត សន្តិភាពក្នុងជីវិតរស់ និងផ្តល់អត្ថប្រយោជន៍ដលបរិស្ថានរបស់យើង (UNESCO, 2016)។ ការអប់រំតែងតែរួមចំណែកក្នុងការរៀបចំយុវជនសម្រាប់សង្គម។ ការអប់រំអាចផ្លាស់ប្តូររបៀបដែលយើងគិត និងធ្វើសកម្មភាព ដើម្បីកសាងសង្គមកាន់តែយុត្តិធម៌ សន្តិភាព អធ្យាស្រ័យ ការអត់ឱន និងសង្គមបរិយាបន្ន ដើម្បីកាត់បន្ថយបញ្ហាប្រឈមជាសកលក្នុងយុគសម័យសកលភាវូបនីយកម្ម (Wiel Veugelers, 2011)។ ដូច្នេះ ខ្លឹមសារនៃការអប់រំសម្រាប់ភាពជាពលរដ្ឋសកល គឺជាការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យអ្នកសិក្សានាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីឱ្យមនុស្សរស់នៅចុះសម្រុងគ្នាក្នុងសហគមន៍ និងមានទំនាក់ទំនងគ្នារវាងបុគ្គលក្នុងសហគមន៍ សង្គមជាតិ ក៏ដូចជាពិភពលោក។

ការឈ្វេងយល់និងការឱ្យតម្លៃនូវភាពផ្ទុយគ្នានៃការគិត ទស្សនៈ ឬមតិយោបល់ ភាពខុសគ្នានៃសង្គមវប្បធម៌ និងបទដ្ឋានច្បាប់ចាប់ពីកម្រិតបុគ្គល ក្រុម សហគមន៍ ប្រទេស និងសកល នាំមកនូវការគោរពបុគ្គលភាព និងចម្រុះនៃវប្បធម៌ ក្នុងទំនាកទំនងរវាងសង្គមមូលដ្ឋាន និងសាកល។ ការអប់រំភាពជាពលរដ្ឋសកល បានបើកចំហព្រំដែននៃទំនាក់ទំនងដែលធ្វើឱ្យប្រជាជាតិទាំងមូលទទួលស្គាល់ថា ពិភពលោកកាន់តែតូចទៅៗ តាមរយៈការប្រាស្រ័យមធ្យោបាយទំនាក់ទំនងកាន់តែឆាប់រហ័ស ងាយស្រួល និងមានប្រសិទ្ធភាពខ្ពស់។ ដូច្នេះទំនាក់ទំនងរបស់សហគមន៍ក្នុងភាពជាពលរដ្ឋសកលដែលប្រកបដោយសីលធម៌ សមធម៌ សមភាព មនុស្សធម៌ ដោយឈរលើគោលការណ៍សិទ្ធិមនុស្សជាសកលបង្ហាញនូវការទទួលស្គាល់ និងការទទួលខុសត្រូវសម្រាប់សកលលោកទាំងមូល។

### ២.៥.៤. អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌

គោលការណ៍នៃឥរិយាបថទទួលខុសត្រូវជាសកល បានផ្តល់និយមន័យថា៖ ការអប់រំពលរដ្ឋជាសកលភ្ជាប់ទៅនឹងគោលការណ៍នៃការទទួលខុសត្រូវជាសកល ពីព្រោះវាជាឥរិយាបថទទួលខុសត្រូវដែលកំណត់ និងធ្វើឱ្យក្លាយជាពលរដ្ឋស្របច្បាប់នៃពិភពលោក។ អាស្រ័យហេតុនេះ បញ្ហានៃការទទួលខុសត្រូវរបស់គេម្នាក់ៗ គឺជាការបង្ហាញនូវសេរីភាព និងកិត្តិយសរបស់គេម្នាក់ៗក្នុងនាមជាពលរដ្ឋនៃសហគមន៍ពិភពលោក។ ការអប់រំពលរដ្ឋសកលបង្រៀន និងធ្វើឱ្យបុគ្គលម្នាក់ៗអាចអនុវត្តសេរីភាព និងសេចក្តីថ្លៃថ្នូររបស់គេប្រកបដោយការទទួលខុសត្រូវ។ (http://www.charter-human-responsibilities.net)

យោងតាមនិយមន័យដែលបានផ្តល់ដោយអង្គការ Oxfam បានកំណត់ភាពជាពលរដ្ឋសកល គឺជាជនទាំងឡាយណាដែលមានលក្ខខ័ណ្ឌដូចខាងក្រោម៖

- យល់ដឹងអំពីពិភពលោកកាន់តែទូលំទូលាយ និងមានអារម្មណ៍ថា តួនាទីរបស់ពួកគេម្នាក់ៗ គឺជាពលរដ្ឋសកល
- គោរព និងផ្តល់តម្លៃនូវភាពចម្រុះ
- មានការយល់ដឹងអំពីពិភពលោកធ្វើការ
- ប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីយុត្តិធម៌សង្គម
- ចូលរួមនៅក្នុងសហគមន៍គ្រប់កម្រិតតាំងពីកម្រិតតំបន់រហូតដល់កម្រិតពិភពលោក
- ធ្វើការជាមួយអ្នកដទៃដើម្បីធ្វើឱ្យពិភពលោកមានសមធម៌ និងជាកន្លែងដែលមានចីរភាព
- ទទួលខុសត្រូវលើអំពើរបស់ខ្លួន។

## ២.៦ ក្របខ័ណ្ឌគុណវុឌ្ឍិគ្រូ (TPACK) ក្នុងយុគសម័យឌីជីថល

នៅក្នុងយុគសម័យឌីជីថល គ្រូត្រូវមានចំណេះដឹងបច្ចេកវិទ្យា គរុកោសល្យ និងមុខវិជ្ជាឯកទេស (Technological Pedagogical and Content knowledge TPACK; Koehler, & Mishra, 2009)។

ក្របខ័ណ្ឌគុណវុឌ្ឍិគ្រូក្នុងយុគសម័យឌីជីថល ដែលមានឈ្មោះថា ក្របខ័ណ្ឌ (Technological Pedagogical and Control Knowledge: TPACK) ដែលជាចំណេះដឹងដែលគ្រូត្រូវមានដើម្បីបញ្ចូល

បច្ចេកវិទ្យា ក្នុងការបង្រៀនខ្លឹមសារមេរៀនតាមក្បួនគរុកោសល្យ៖ គ្រូត្រូវយល់ដឹងពីការប្រចាប់បញ្ចូលគ្នានូវសមាសភាគ ៣ នៃចំណេះដឹង៖

១. ចំណេះដឹងពីខ្លឹមសារមេរៀន (CK)

២. ចំណេះដឹងពីចិត្ត-គរុកោសល្យ (PK) និង

៣. ចំណេះដឹងពីបច្ចេកវិទ្យា (TK)

ដោយគ្រូបង្រៀនពីខ្លឹមសារមេរៀន ដោយប្រើប្រាស់វិធីសាស្រ្តបង្រៀន និងបច្ចេកវិទ្យា សមស្របទៅតាមបរិបទនៃយុគសម័យឌីជីថល។

ដូចនេះក្របខ័ណ្ឌនេះផ្តោតលើសមាសភាគចំនួនបីគឺ ៖

(១) ចំណេះដឹងលើខ្លឹមសារមេរៀនមុខវិជ្ជា (Content Knowledge: CK) ៖ ដែលគ្រូត្រូវបង្រៀនទៅតាមមុខវិជ្ជា និងកម្រិតភូមិសិក្សានីមួយៗ។

(២) ចំណេះដឹងចិត្តគរុកោសល្យ (Pedagogical Knowledge: PK) ៖ ដែលជាចំណេះដឹងស្តីពីដំណើរការ ការអនុវត្ត និងវិធីសាស្រ្តរៀន និងបង្រៀន — ដូចជា ការរៀនផ្តោតលើបញ្ហា (Problem-Based Learning: PBL) ការរៀនផ្តោតលើការចងចាំនៃខួរក្បាល (Brain-Based Learning) ការរៀនតាមបែបគម្រោង (Project Method) វិធីសាស្រ្តស្វែងរកដោយខ្លួនឯង (Discovery Method) ការសិក្សាដោយខ្លួនឯង (Self-Study Method) ការរៀនតាមបែបរិះរក (Inquiry-Based Learning) ការគ្រប់គ្រងថ្នាក់រៀន វង្វាយតម្លៃ ការរៀបចំកិច្ចតែងការបង្រៀន និងវិធីរៀនរបស់សិស្ស។ និង

(៣) ចំណេះដឹងបច្ចេកវិទ្យា (Technological Knowledge: TK)៖ ដែលមានមិនត្រឹមតែអក្ខរកម្មឌីជីថលប៉ុណ្ណោះទេ តែត្រូវផ្តោតលើការយល់ដឹង និងការចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានស៊ីជម្រៅ និងចេះប្រើប្រាស់ក្នុងការបង្រៀន ការដោះស្រាយបញ្ហា និងការវិភាគទិន្នន័យ ជាពិសេសចំណេះដឹងពីអក្ខរកម្មកុំព្យូទ័រ អ៊ីនធើណែត វីដេអូឌីជីថល ក្តារខៀនវៃឆ្លាត និងកម្មវិធីកុំព្យូទ័រ។

គុណវុឌ្ឍិTPACK នេះផ្តោតលើផងដែរលើអន្តរសកម្មរវាងសមាសភាពទាំងបីនៅក្នុងម៉ូដែល៖

ទីមួយ-ចំណេះដឹងចិត្ត-គរុកោសល្យ និងមុខវិជ្ជា (Pedagogical Content Knowledge: **PCK**)៖ គឺជាការបន្សាំចំណេះដឹងខាងផ្នែកមុខវិជ្ជា ដើម្បីយោទៅបង្រៀនដោយប្រចាប់បញ្ចូគ្នានូវវិធីសាស្រ្តបង្រៀន និងខ្លឹមសារមេរៀន ដើម្បីបង្រៀនឱ្យកាន់តែល្អ។ ក្នុងន័យនេះ គ្រូត្រូវចេះខ្លឹមសារមេរៀន របៀបរៀនរបស់សិស្ស បរិបទ គោលដៅនៃកម្មវិធីសិក្សា យុទ្ធសាស្រ្តបង្រៀន និងវង្វាយតម្លៃ។

ទីពីរ-ចំណេះដឹងបច្ចេកវិទ្យា និងមុខវិជ្ជា (Technological Content Knowledge: TCK)៖ ជាការប្រើប្រាស់ចំណេះដឹងពីការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្ហាញខ្លឹមសារតាមបែបថ្មី ដោយគ្រូត្រូវដឹងថា គេអាចប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្រៀនឱ្យសិស្សយល់ពីបញ្ញត្តិនៅក្នុងខ្លឹមសារនៃមេរៀន។ ការប្រើប្រាស់បច្ចេកវិទ្យាណាមួយក្នុងការបង្រៀនអាចផ្លាស់ប្តូរវិធីរៀនរបស់សិស្សក្នុងមុខវិជ្ជានីមួយៗ។ ដូចនេះគ្រូបង្រៀនត្រូវកំណត់ឱ្យបានច្បាស់នូវបច្ចេកវិទ្យាដែលសមស្របបំផុតក្នុងការបង្រៀនតាមមុខវិជ្ជានីមួយៗ។

ទីបី-ចំណេះដឹងស្តីពីការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន (Technological Pedagogical Knowledge: TPK)៖ ការប្រើប្រាស់បច្ចេកវិទ្យា និងផ្លាស់ប្តូររបៀបបង្រៀនរបស់គ្រូ។ ដូចនេះគ្រូត្រូវដឹងថា ការជ្រើសរើសកម្មវិធីបច្ចេកវិទ្យា ឬបច្ចេកវិទ្យាណាមួយមកប្រើប្រាស់ក្នុងការបង្រៀន និងត្រូវផ្លាស់ប្តូរវិធីសាស្រ្តនៃការបង្រៀនសិស្ស ដូចជាការប្រើប្រាស់ ការខៀនវៃឆ្លាតទាមទារនូវអន្តរសកម្មរវាងគ្រូ និងសិស្ស។

វិធីសាស្ត្របង្រៀនកំពុងពេញនិយម ក្នុងការប្រើប្រាស់បច្ចេកវិទ្យា គឺវិធីសាស្ត្របង្រៀនតាមបែបចម្រុះ (Blended Learning) និងវិធីសាស្ត្របង្រៀនតាមបែបបញ្ច្រាស (Flipped Classroom)។

(បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ២០២០ *កំណែទម្រង់សាលារៀននៅកម្ពុជា*)

## ២.៧ លក្ខណសម្បត្តិគ្រូក្នុងយុគសម័យឌីជីថល

គ្រូបង្រៀនក្នុងយុគសម័យឌីជីថលត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម (Marc, 2010: 20-22; Sukanya Chaemchoy, 2018) ៖

1) គ្រូជាអ្នកបង្ហាត់បង្រៀន និងជាមគ្គុទ្ទេសក៍ដែលជួយគាំទ្រ និងបង្ហាញផ្លូវសិស្ស (Teacher as coach and guide)
2) គ្រូកំណត់គោលដៅនៃការរៀន និងសួរសំណួរឱ្យសិស្សចេះគិត ធ្វើអត្ថាធិប្បាយ និងរកចម្លើយ (Teacher as goal setter and questioner) ហើយបង្រៀនតាមបែបការរៀនដោះស្រាយបញ្ហា (Problem-Based Learning) និងការរៀនតាមបែបត្រិះរិះ (Inquiry-Based Learning)
3) គ្រូរៀបចំដំណើរការរៀន (Teacher as learning designer) ៖
   ដោយឈរលើមូលដ្ឋាននៃការយល់ដឹងរបស់សិស្ស ដើម្បីឱ្យសិស្សកាន់តែយល់ច្បាស់ គ្រូត្រូវរៀបចំសកម្មភាពឱ្យសិស្សរៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
4) គ្រូជាអ្នករៀបចំបរិបទ (Teacher as context provider) ៖
   ដើម្បីឱ្យសិស្សមានសមត្ថភាពយល់
5) គ្រូជាអ្នកត្រួតពិនិត្យការរៀនសូត្រ និងធានាគុណភាព នៃការរៀន (Teacher as rigor provider and quality assurer)។

(បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ២០២០ *កំណែទម្រង់សាលារៀននៅកម្ពុជា*)

## ជំពូក II លំនាំនៃការបង្រៀន និង រៀន

## មេរៀនទី ៣ វិធីបង្រៀន

### ៣.១ វត្ថុបំណងមេរៀន

- ក្ដាប់បានសញ្ញាណ និងចរិតប្រវត្តិសាស្ត្ររបស់វិធីបង្រៀន
- ក្ដាប់បានចំណុចខ្លាំង ចំណុចខ្សោយ ក្នុងវិធីបង្រៀនដោយឈរលើមូលដ្ឋានជាក់ស្ដែង គឺចេះជ្រើសរើសចេះគួបផ្សំ និងចេះប្រើប្រាស់ វិធីបង្រៀនទាំងអស់បានយ៉ាងប៉ិនប្រសប់ និងត្រឹមត្រូវផង។

### ៣.២.សញ្ញាណទូទៅ

**ក.** គរុវិទូជាច្រើនបានឱ្យនិយមន័យផ្សេងៗគ្នាពីវិធីបង្រៀន។ ប៉ុន្តែសង្ខេបសេចក្ដីមកយើងលើកមកសិក្សាស្រាវជ្រាវនូវមតិពីរជាមូលដ្ឋាន។

- គរុវិទូមួយចំនួនបានកំណត់វិធីបង្រៀនថាជារបៀប ជាមធ្យោបាយ ជាសកម្មភាព ជាល្បិច ដែលសាស្ត្រាចារ្យម្នាក់ៗបានប្រើប្រាស់ ដើម្បីដឹកនាំសកម្មភាពយល់ជ្រួតជ្រាបនិងក្ដាប់ចំណេះដឹងរបស់សិស្ស។ ទស្សនៈនេះសង្កត់ធ្ងន់តែលើផ្នែកៈ យកចិត្តទុកដាក់តែពីសកម្មភាពបង្រៀនរបស់សាស្ត្រចារ្យ និងលើកឡើងតែពីអត្ថន័យ នៃការផ្ដល់ចំណេះដឹងតាមរយៈ វិធីបង្រៀនរបស់សាស្ត្រចារ្យ
- គរុវិទូមួយចំនួនទៀតបានលើកឡើងពីនិយមន័យនៃវិធីបង្រៀនថាជារបៀបឬជាមធ្យោបាយធ្វើការ ងាររបស់សាស្ត្រចារ្យនិងសិស្ស។ ផ្អែកលើមធ្យោបាយនេះ សិស្សក្ដាប់បាន ចំណេះដឹង ចំណេះធ្វើ និង បំណិនប្រសប់ហើយបណ្ដុះបណ្ដាលបាននូវលោកទស្សនៈ ហើយព្រមទាំងអភិវឌ្ឍបាននូវសតិបញ្ញាទៀតផង។ ក្នុងចំណោមមតិទាំងនេះមានគរុកោសល្យវិទូខ្លះដូចជា៖
  - លោកដានីឡូសនិងអេស៊ីប៉ូសង្កត់ធ្ងន់តែប្រើការអភិវឌ្ឍខាងសតិបញ្ញារបស់សិស្ស
  - លោកស្រី លុនដាបានយកចិត្តទុកដាក់តែលើការអភិវឌ្ឍខាងសមត្ថភាពយល់ជ្រួតជ្រាបចំណេះ ដឹងនិងចេះយកចំណេះដឹងនោះទៅអនុវត្តនៅក្នុងការប្រតិបត្តិដោយភាពម្ចាស់ការច្នៃប្រឌិត។
- គរុកោសល្យវិទូខ្លះទៀតបានយកចិត្តទុកដាក់ដល់ការអភិវឌ្ឍខាងសតិបញ្ញានិងសកម្មភាពប្រតិបត្តិហើយជាពិសេសបានយកចិត្តទុកដាក់អត្ថន័យនៃការអប់រំ តាមរយៈវិធីបង្រៀនថាជាវិធីមួយដែល ជួយសិស្សានុសិស្សឱ្យបណ្ដុះបាននូវសីលធម៌ល្អក្នុងសង្គម។

តាមមតិអស់ទាំងនេះ យើងអាចកំណត់បាននូវនិយមន័យរបស់វិធីបង្រៀនដូចតទៅ៖ **"វិធីបង្រៀនគឺជាការគួបផ្សំនៃរបៀ បធ្វើ ការ រួមរបស់សាស្ត្រចារ្យ និងសិស្សក្រោម តួនាទីដឹកនាំរបស់ សាស្ត្រាចារ្យ សំដៅប្រតិបត្តិឱ្យបានល្អលើ គ្រប់ភារកិច្ចនៃ ការបង្រៀន"** ។

និយមន័យនេះមានអត្ថន័យ៖

• ជានាប៉ាប់រងបាននូវវិធីបង្រៀនពោលគឺមិនត្រឹមតែយកចិត្តទុកដាក់តែលើរបៀបធ្វើការរបស់សាស្ត្រាចារ្យប៉ុណ្ណោះទេ (ចាត់តាំង ដឹកនាំ គ្រប់គ្រង) ប៉ុន្តែថែមទាំងយកចិត្តទុកដាក់របៀបធ្វើការរបស់សិស្សទៀតផង (ស្វ័យចាត់តាំង ស្វ័យគ្រប់គ្រងសកម្មភាពសិស្ស) ។

• លើកឡើងច្បាស់លាស់ពីវិធីបង្រៀន គឺសំដៅជួយសាស្ត្រាចារ្យ និងសិស្ស ឱ្យឈាន ដល់គោលដៅនៃ ការសិក្សា ដែលបានកំណត់ហើយមើលឃើញច្បាស់ ទៅលើលំនាំនិងគោលដៅនៃការបង្រៀន ដែលស្ដែង ឡើងគឺសំដៅបណ្ដុះបណ្ដាលសិស្សឱ្យបានល្អលើរាល់ភារកិច្ចនៃការបង្រៀន។

• ឆ្លងកាត់តាមនិយមន័យនេះ យើងជាសាស្ត្រាចារ្យ អាចឆ្លុះបញ្ចាំងឃើញកាន់តែច្បាស់លាស់ពីអត្ថន័យនៃការបង្រៀន និងការអប់រំនៅក្នុងវិធីបង្រៀន។

• ចរិតជាសារជាតិរបស់លំនាំនៃការបង្រៀន និងចំណងទាក់ទងគ្នាយ៉ាងជិតស្និតរវាងសកម្មភាពបង្រៀនរបស់សាស្ត្រាចារ្យ និងសកម្មភាពសិក្សារបស់សិស្ស។

• ចំណងទាក់ទងគ្នាយ៉ាងជិតស្និតរវាងវិធីបង្រៀន និងភារកិច្ចនៃការបង្រៀនរវាងរបៀបធ្វើសកម្មភាព និង ការកំណត់បាននូវគោលដៅនៃសកម្មភាពនៅក្នុងវិស័យបង្រៀន។

• ការឆ្លងកាត់តាមនិយមន័យនេះ អត្ថន័យនៃការផ្ដល់ចំណេះដឹង និងការអប់រំក្នុងវិធីបង្រៀន បានឆ្លុះបញ្ចាំងឱ្យឃើញសកម្មភាពរបស់សាស្ត្រាចារ្យ និងសិស្សកាន់តែច្បាស់លាស់ហើយងាយយល់។

ខ. វិធីបង្រៀនទាំងអស់ បានត្រូវយកមកប្រើប្រាស់តាមបែបសត្យានុម័ត ទៅតាមគោលដៅភារកិច្ច និងខ្លឹមសារនៃការបង្រៀន ហើយត្រូវបានផ្លាស់ប្ដូរទៅតាមលក្ខខណ្ឌសង្គម-នយោបាយ និងការអភិវឌ្ឍរបស់វិទ្យាសាស្ត្របច្ចេកទេស។

• សាលារៀន ក្នុងមជ្ឈឹមសម័យ អប់រំពីស្មារតីខ្មៅងងឹតនៅក្នុងវិហារកាតូលិកឱ្យដល់សិស្ស។ គេបានរៀបចំកូនចៅរបស់វណ្ណៈ ជិះជាន់ ឱ្យមាន ជីវភាពមួយដ៏ប្រសើរថ្លៃថ្នូរ ហើយសម្បូរបែបផ្ទុយពីជីវភាព របស់មនុស្ស ក្នុងពលកម្ម។ អាស្រ័យហេតុនេះ សិស្សត្រូវ រៀនចាំមាត់នូវឯកសារដែលត្រូវរៀន តាមក្បួនច្បាប់ គម្ពីរសាសនា។ វិធីបង្រៀនតាមបែបគម្ពីរនិយមរបស់វណ្ណៈ ជិះជាន់នៅក្នុងសាលារៀន បានធ្វើឱ្យសិស្សមិនអាចយល់បានច្បាស់ពីប្រការដែលបានរៀនហើយ មិនអាចធ្វើឱ្យស្មារតីសកម្ម ក្នុងការទទួលយល់ជ្រួតជ្រាបចំណេះដឹង អភិវឌ្ឍឡើងបាន គឺមានតែស្មារតីទាសភាពបម្រើសាសនាប៉ុណ្ណោះ។

• ក្រោយមកដោយសារតម្រូវការនៃជីវភាពរស់នៅ និងដោយសារការសិក្សាស្រាវជ្រាវនិងការច្នៃប្រ ឌិតជាពិសេសគឺតម្រូវការជាចាំបាច់ក្នុងការបណ្ដុះបណ្ដាលពលករស៊ីឈ្នួលឱ្យមានកម្រិតវប្បធម៌និងបច្ចេកទេសខ្ពស់ដើម្បីបម្រើវណ្ណៈនាយទុន ដែលកំពុងអភិវឌ្ឍឡើងនោះ វិធីបង្រៀនថ្មីៗជាច្រើនបានកើតមានឡើង។ ឈរលើមូលដ្ឋាននៃទស្សនៈនេះ នៅសតវត្សទី១៨ និង១៩ វិធីបង្រៀនតាមបែបអព្ភន្តរញ្ញាណ ដ៏ត្រឹមត្រូវនោះបានកើតឡើង។ រីឯវិធីបង្រៀនតាមបែបសួរ-ឆ្លើយ បានត្រូវធ្វើឱ្យកាន់តែសុក្រឹតឡើងដែរ។ ក៏ប៉ុន្តែវិធីបង្រៀនទាំងនេះ ធ្វើឱ្យសិស្សអសកម្មក្នុងការយល់ជ្រួតជ្រាប និងក្ដាប់យកចំណេះដឹងដោយសារសាស្ត្រាចារ្យ ឬសៀវភៅសិក្សា។ ក្រោយមក ដោយសារតម្រូវការនៃការអនុវត្តចំណេះដឹង វិធីអនុវត្ត និងវិធីពិសោធន៍ក៏បានកើតឡើង ហើយបានជំរុញឱ្យវិធីទាំងឡាយដទៃទៀតកាន់តែមាន សុក្រឹតភាពឡើង ដែរ ដូចជា វិធីពិពណ៌នា វិធីសន្ទនា និងវិធីប្រើប្រាស់សៀវភៅសិក្សាជាដើម។ ប៉ុន្តែទោះជាយ៉ាងណា ក៏ដោយ វិធីបង្រៀននៅក្នុងសាលារៀនមូលធនបានត្រូវកាត់ផ្ដាច់ចេញស្រលះពីជីវភាពរស់នៅ។ ឯវិធីបង្រៀនតាមបែបគម្ពីរនិយមបានកម្រិតព្រំដែនចំពោះការអភិវឌ្ឍនៃចរិតសកម្ម ចរិតម្ចាស់ការ និងការគិតរបស់សិស្ស។

គ. នៅប្រទេសកម្ពុជាយើង ក្នុងសាលារៀនសម័យសក្ដិភូមិមុនគ.ស១៨៦៣ វិធីបង្រៀនតាមបែបគម្ពីរនិយម

ត្រូវបានគេចាត់ទុកថាមានភាពប្រសើរ និងមានរបៀបបំផុត។ សិស្សត្រូវរៀនទន្ទេញចាំមាត់ ដូចសត្វសេក។ សាលារៀនច្រើនមានតែនៅក្នុងវត្តអារាម ដែលជាទីសក្ការៈបូជាសម្រាប់ព្រះពុទ្ធសាសនា។ គ្រូបង្រៀន ជាព្រះសង្ឃ។ កាលណារៀនល្មម អាន និងសរសេរបាន សិស្សត្រូវបួសជាព្រះ សង្ឃ ឬវិលត្រលប់មក ជួយប្រកបការងារស្រែចាំការវិញ។ គេមិនមានលទ្ធភាព បន្តការ សិក្សាទៅទៀ តបានឡើយ។ ឯសិស្ស ដែលបួស ជាព្រះសង្ឃហើ យ បានសិក្សាធម៌អាថ៌ តាមគម្ពីរព្រះពុទ្ធសាសនាអស់រយៈពេលច្រើនឆ្នាំហើយ បានលាចាក សិក្ខាបទមកជាគ្រហស្ថធម្មតាវិ ញ។ គេចាត់ទុកអ្នកនោះឯង ជាអ្នកមានចំណេះវិជ្ជាជ្រៅជ្រះ គួរជាទីគោរពដល់ អ្នកផង។សិស្សម្នាក់ៗ ដែលចាប់ផ្តើមចូលរៀនជាមួយគ្រូបង្រៀនជាព្រះសង្ឃ នោះត្រូវរៀនធម៌អាថ៌ខាងផ្លូវសាសនាផង និងរៀនអក្សរសាស្ត្រ លេខនិពន្ធ សម្រាប់តម្រូវការក្នុងជីវភាពរស់នៅផង។ គ្រូប្រើអំណាចផ្តាច់ការ។ សិស្សគោរ ព និងកោតខ្លាចគ្រូ ជាងឪពុកម្តាយ។

ក្នុងសម័យអាណានិគមនិយមបារាំង ក្រោយឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ វិធីបង្រៀននៅក្នុងសាលារៀនប្រកាន់យកនូវចរិតសិក្សាតាមបែបគម្ពីរនិយមផង និងតាមអរូបិយ៍កម្មផង។ក៏ប៉ុន្តែការបង្រៀននៅតែផ្តាច់ចេញពីជីវភាពរបស់នៅដដែល។ គ្រូបង្រៀន បញ្ច្រកចំណេះដឹងឱ្យដល់សិស្ស។ នៅថ្នាកទី២ នៃសាលាបឋមសិក្សា តម្រូវឱ្យរៀនភាសាបារាំង ហើយសាលារៀនមិនអាចកាត់ផ្តាច់ចេញពីវត្តអារាម បានឡើយ។ចៅអធិការដែលគ្រប់គ្រងវត្តអារាមនីមួយៗជាអ្នកបង្រៀនប្រដៅប្រជាជនខាងផ្លូវសាសនាផងនិង ជាអ្នកដឹកនាំប្រជាជនកសាងសាលារៀនផង។

ក្រោយសម័យឆ្នាំ១៩៥៥ សាលារៀន បានចាប់ផ្តើមរីកដុះដាលពាសពេញប្រទេស។ចំនួនសិស្ស និងគ្រូក៏កើនឡើង។តែការសិក្សារបស់សិស្ស នៅតែមានចរិតអសកម្ម។ សិស្សគ្រាន់តែស្តាប់គ្រូពន្យល់ និងកត់ត្រាប៉ុណ្ណោះ ហើយខ្វះខាតទៅលើការអនុវត្ត និងការធ្វើពិសោធ។ មិនតែប៉ុណ្ណោះសោតសិស្ស ត្រូវរៀនទន្ទេញចាំមាត់តាមសៀវភៅសិក្សាឬតាមវចនានុក្រមទៀតផង។សិស្សមានលទ្ធភាពបន្តការសិក្សា ទៅថ្នាក់ខ្ពស់ៗបាន។ឯសាលារៀនមួយចំនួន ក៏ត្រូវបានកាត់ចេញពីវត្តអារាមដែរ។ឥទ្ធិពលរបស់វិទ្យាសាស្ត្រ និងបច្ចេកទេស ក៏បានចូលជ្រួតជ្រាបនៅក្នុងវិធីបង្រៀន និងឯកសារសម្រាប់សិក្សាផងដែរ។

ក្រោយឆ្នាំ១៩៥៧ វិធីបង្រៀន ត្រូវបានចាប់ផ្តើមកែលំអទៅតាមទិសដៅអភិវឌ្ឍរបស់វិទ្យាសាស្ត្រ និងបច្ចេកទេស។អនុវិទ្យាល័យ និងវិទ្យាល័យច្រើនធ្វើឡើងទៅតាមកម្មវិធីស្មើគ្រប់ខេត្តនិងស្រុកការសិក្សានៅក្នុង អនុវិទ្យាល័យនិងវិទ្យាល័យច្រើនធ្វើឡើងទៅតាមកម្មវិធីសិក្សារបស់ប្រទេសបារាំងហើយយកភាសាបារាំងជាមូលដ្ឋានសម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់រហូតដល់ឆ្នាំ១៩៧០។ ចាប់តាំងពីឆ្នាំ១៩៥៩ មកការសិក្សា ភាសាបារាំងថ្នាក់ដំបូងត្រូវបន្ថយមកនៅថ្នាក់ឆ្នាំទី៤នៃសាលាបឋមសិក្សាវិញ។

ក្រោយឆ្នាំ១៩៧០ ការសិក្សាត្រូវបានកែទម្រង់មកជាភាសាជាតិវិញ។ ឯកម្មវិធីសិក្សាគ្រប់កម្រិតសិក្សាទាំងអស់ ក៏ត្រូវបន្ថយបរិមាណដែរ។ សិស្សនៅតែមានចរិតអសកម្ម ក្នុងការយល់ជ្រួតជ្រាប ចំណេះដឹង ថ្វីបើការសិក្សាត្រូវបានយកភាសាយានក៏ដោយ។ បម្រើបម្រាស់ ភាសាជាតិ ជំនួសភាសា បរទេសនៅពេលនោះមិនទាន់មានភាពសម្បូរបែបសម្រាប់គ្រប់មុខវិជ្ជាឯកទេសនៅឡើយ។ មុខវិជ្ជាឯកទេសខ្លះប្រទះការពិបាកស្មុគស្មាញយ៉ាងធ្ងន់ធ្ងរហើយចំណុចខ្វះខាត និងការមិនទាន់ឯកភាព នៅតែមានបន្សល់ទុកមក។ គុណភាពនៃកម្រិតយល់ដឹងរបស់សិស្ស នៅតែមានចំណុចខ្វះខាតដដែល។

**ឃ.** ក្រោយថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ មកថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ នៅលើផ្ទៃនៃប្រទេសកម្ពុជាទាំងមូលមិនមានសាលារៀនឡើយ។ សាលារៀនមួយចំនួនត្រូវបានរើរុះដុតបំផ្លាញ ឬរងគ្រោះ

ដោយសារសង្គ្រាមរបស់ចក្រពត្តិអាមេរិកកាំង។ ឯសាលារៀនមួយចំនួនទៀត ដែលនៅសេសសល់ត្រូវបានបនប្រល័យពូជសាសន៍ ប៉ុលពត អៀងសារី ខៀវសំផន រើរុះបំបាត់ ចោល ឬយកធ្វើជាគុក ឬជាកន្លែងចិញ្ចឹមសត្វ។សង្គមកម្ពុជាក្នុងសម័យនោះ ស្ថិតនៅក្នុងគ្រោះភ័យខ្លាចអន្តរាយជានិច្ច ដែលពុំមាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ គឺជាសង្គមមួយកាចសាហាវហួសសង្គមបុព្វកាលទៅទៀត គឺគ្មានសាលារៀន គ្មានវិទ្យាសាស្ត្រ គ្មានពាណិជ្ជកម្ម គ្មានប្រាក់កាស គ្មានទីផ្សារ គ្មានឧស្សាហកម្ម គ្មានសាសនា គ្មានសញ្ចេតនា គ្មានសម្បត្តិឯកជន...។

**ង.** ក្រោយថ្ងៃរំដោះ ៧មករា១៩៧៩ យើងបានចាប់ផ្ដើមកសាងសាលារៀនយើងឡើងវិញ ពីលេខសូន្យ។បច្ចុប្បន្ននេះ នៅក្នុងសាលារៀនចំណេះទូទៅរបស់យើង កំពុងប្រើប្រាស់ប្រព័ន្ធវិធីបង្រៀន ដោយឈរលើមូលដ្ឋាននៃវិទ្យាសាស្ត្រ និងបច្ចេកទេស។ ក្នុងប្រព័ន្ធវិធីសាស្ត្រ ដែលយើងប្រើប្រាស់នៅក្នុងសាលារៀន របស់យើងលេចឡើងយ៉ាងច្បាស់លាស់នូវចរិតវិទ្យាសាស្ត្រ និងចរិតអប់រំសំដៅពង្រឹងពង្រីកកម្រិតយល់ ដឹងរបស់សិស្សឱ្យមានកម្រិតខ្ពស់តាមសន្ទុះរបស់វិទ្យាសាស្ត្រ និងបច្ចេសទេស និងដើម្បីឆ្លើយតបបានទៅ នឹងវត្ថុបំណងនៃការបណ្តុះបណ្តាលធនធានមនុស្ស ដែលធ្វើម្ចាស់លើធម្មជាតិ លើសង្គម និងលើខ្លួនឯង។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ វិធីបង្រៀនដែលយើងកំពុងប្រើប្រាស់នៅក្នុងសាលារៀនចំណេះទូទៅ សព្វថ្ងៃនេះ នៅតែមានចំណុចខ្វះខាតជាច្រើន។ ចំណុចខ្សោយ និងកង្វះខាតទាំងនោះ បណ្តាលមកពី យើងខ្វះឯកសារវិទ្យាសាស្ត្រជាមូលដ្ឋាន ដើម្បីសិក្សាស៊ីជម្រៅទៅលើប្រព័ន្ធវិធីបង្រៀន តាមលក្ខណៈវិទ្យាសាស្ត្រដូចជា ឯកសារចិត្តវិទ្យា គរុកោសល្យវិទ្យា ទស្សនាវដ្ដីអប់រំ ទស្សនាវដ្ដីវិទ្យាសាស្ត្រ ទស្សនាវដ្ដី អក្សរសាស្ត្រ...។ សម្រាប់ឱ្យគ្រូបង្រៀន និងសាស្ត្រាចារ្យយើ ងម្នាក់ៗ បានអាន បានសិក្សាស្រាវជ្រាវស្វែងយល់ទៅលើវិធីបង្រៀនតាមមុខវិជ្ជាឯកទេសរបស់ខ្លួន។ ព្រោះហេតុនេះហើយបានជាយើងខិតខំសិក្សាស្រាវជ្រាវ និងប្រមែប្រមូលឯកសារគរុកោសល្យវិទ្យា ដើម្បីកសាងបានជាសំណុំមេរៀនគរុកោសល្យវិទ្យានេះឡើង សំដៅកែច្នៃ ឬធ្វើឱ្យវិធីបង្រៀនតាមមុខវិជ្ជាសិក្សានីមួយៗកាន់តែមានប្រសិទ្ធភាព និងដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន និងការអប់រំព្រមជាមួយនឹងកម្រិតយល់ដឹងរបស់សិស្សទៀតផង។

## ៣.៣.ប្រព័ន្ធវិធីបង្រៀន ឬគោលវិធីបង្រៀន

សព្វថ្ងៃនេះគរុកោសល្យវិទូទាំងឡាយនៅលើសកលលោកមិនទាន់មានមតិឯកភាពគ្នានៅឡើយចំពោះប្រព័ន្ធវិធីបង្រៀន។ រីឯបំណែងចែកវិធីបង្រៀនទៅតាមប្រភេទក៏មិនទាន់មាននៅឡើយដែរ។

យើងសិក្សាស្រាវជ្រាវ និងស្វែងយល់ពីប្រព័ន្ធវិធីបង្រៀនមួយចំនួនដែលមានមូលដ្ឋាន និងប្រភេទផ្សេងៗគ្នា។

## ៣.៣.១.ប្រព័ន្ធវិធីបង្រៀនត្រូវបានបែងចែកជាប្រភេទទៅតាមធម្មជាតិរបស់វា

ដោយឈរលើមូលដ្ឋាននៃចរិតសកម្ម និងចរិតអសកម្មនៅក្នុងលំនាំនៃការសិក្សារបស់សិស្ស។

**ប្រព័ន្ធវិធីបង្រៀនសកម្ម ឬ គោលវិធីបង្រៀនសិស្សមជ្ឈមណ្ឌលរួមមាន៖**

ភាពម្ចាស់ការក្នុងការសិក្សាស្រាវជ្រាវ (ស្វ័យសិក្សា)

- ភាពម្ចាស់ការក្នុងការដកពិសោធន៍
- ភាពច្នៃប្រឌិតក្នុងការអនុវត្ត
- ភាពច្នៃប្រឌិតក្នុងការហ្វឹកហ្វឺន

**ប្រព័ន្ធវិធីបង្រៀនអសកម្ម(ប្រពៃណី) ឬ គោលវិធីបង្រៀនគ្រូមជ្ឈមណ្ឌលរួមមាន៖**

- ការពិពណ៌នា
- បំណកស្រាយពន្យល់
- ការធ្វើអត្ថាធិប្បាយ

បំណកស្រាយ ពន្យល់ទាមទារ ឱ្យសាស្ត្រាចារ្យប្រើប្រាស់សម្ភារៈអព្ភន្ត ញាណ។ បំណែងចែកនេះគ្មានមូលដ្ឋានវិទ្យាសាស្ត្រត្រឹមត្រូវឡើយ។ ប៉ុន្តែទោះជាវិធីបង្រៀនណាក៏ដោយ ត្រូវតែធ្វើឱ្យបានសម្រេច តាមសំណូមពរ គោលដៅ និងការកិច្ចដែលទាមទារឱ្យសិស្សមានកម្រិតយល់ដឹងខ្ពស់គឺ ចរិតស្វ័យភ្ញាក់រលឹក សកម្ម ម្ចាស់ការនិងច្នៃប្រឌិត។

## ៣.៣.២.ប្រព័ន្ធវិធីបង្រៀនត្រូវបានកសាងឡើងដោយឈរលើមូលដ្ឋាននៃសារជាតិរបស់វិធីសិក្សា

សិស្សត្រូវអនុវត្ត៖

**-វិធីបង្រៀនតាមគម្ពីរនិយម៖** គ្រូផ្តល់ឱ្យសិស្សនូវចំណេះដឹងដែលបានរៀបចំ និងកំណត់ ទុកជាមុនស្រេច។

**-វិធីបង្រៀនតាមការធ្វើវិភាគ៖**គ្រូរាប់ពីចំណេះដឹងតាមលំដាប់លំដោយនិងតាមរូបភាពនៃ រូបមន្តដោយបង្កើតបានជាគំនូរ រូបចម្លាក់ វត្ថុបាតុភូតជាក់ស្តែងនិងអត្ថន័យសំខាន់ៗរបស់កត្តានីមួយៗ រួចកសាងបានជារូបមន្តមានលក្ខណៈគ្រប់គ្រាន់។

**- វិធីបង្រៀនតាមការត្រួសត្រាយ៖** គ្រូត្រួសត្រាយផ្លូវ និងធ្វើឱ្យលេចចេញនូវចំណេះដឹង និងលំនាំអភិវឌ្ឍរបស់ចំណេះដឹងនោះ រួចមក ទើបនិយាយសរុបទៅលើចំណុចសំខាន់ៗ ។

អ្នកនិពន្ធ បានវាយតម្លៃខ្ពស់ទៅលើវិធីបង្រៀនទី២ ហើយធ្វើការទិទៀនយ៉ាងខ្លាំង ទៅលើវិធីបង្រៀនទី១ក៏ប៉ុន្តែបំណែងចែកជាប្រភេទទៅលើប្រព័ន្ធវិធីបង្រៀន ឱ្យបានត្រឹមត្រូវសមហេតុផលនោះនៅតែមានចំណុចខ្វះខាតជានិច្ច។

## ៣.៤.វិធីបង្រៀននានា

### ៣.៤.១.វិធីឧទ្ទេស

### ក. សញ្ញាណទូទៅ

វិធីឧទ្ទេសគឺជាវិធីដែលគ្រូប្រើប្រាស់ពាក្យសំដីក្នុងការបកស្រាយ ពន្យល់ និងអត្ថាធិប្បាយខ្លឹមសារដើម្បីឱ្យសិស្សធាប់ចាប់បាននូវចំណេះដឹងថ្មី។ វិធីឧត្ទេសចែកចេញជា៖

- **វិធីពន្យល់៖** ជាការបកស្រាយពន្យល់ខ្លឹមសារជាមូលដ្ឋាននៅក្នុងការអនុវត្តតាមលំនាំនៃការបង្រៀនពោល វិធីនេះទាមទារឱ្យសាស្ត្រាចារ្យប្រើប្រាស់វាចាររដ៏រស់រវើកនិងសម្បូរដោយរូបារម្មណ៍ ដើម្បីទាក់ទាញ ទឹកចិត្ត និងចំណង់ចំណូលចិត្តរបស់សិស្ស។ វិធីនេះ ត្រូវបានសាស្ត្រាចារ្យយ កមកប្រើប្រាស់យ៉ាង ទូលំទូលាយគឺសំដៅ៖

-បកស្រាយពន្យល់ឯកសារថ្មី ដែលមានចំណេះដឹងផ្សារភ្ជាប់គ្នាតាមប្រព័ន្ធកម្មក្នុងរយៈពេលមួយ

ជាកំណត់

-ធ្វើអត្ថាធិប្បាយបន្ថែម ពីបញ្ហាដ៏ស្មុគស្មាញ ពីព្រោះសិស្សជួបប្រទះការលំបាក ដែលខ្លួនមិនអាចស្វែងយល់ស៊ីជម្រៅទៅតាមកម្រិតយល់ដឹងរបស់ខ្លួនបាន។

-ធ្វើអត្ថាធិប្បាយឬឧទ្ទេសពីបញ្ហាជាក់ស្តែងដែលជាប់ទាក់ទងទៅនឹងគោលដៅនៃមេរៀនដែលសិស្ស បានរៀនរួចមកហើយ ឬកំពុងរៀន។

- ធ្វើប្រព័ន្ធកម្ម ទៅលើចំណេះដឹងដែលសិស្សបានយល់ជ្រួតជ្រាបរួចមកហើយ។

- **វិធីពិពណ៌នា(រ៉ាយរ៉ាប់)** គឺជាយុទ្ធវិធីមួយ នៅក្នុងចំណោមវិធីឧទ្ទេសដែលមានកត្តាសំខាន់របស់វាគឺដើម្បីរាបរាប់និងការពិពណ៌នានេះឯង។ វិធីពិពណ៌នា បានត្រូវយកទៅប្រើប្រាស់យ៉ាងទូលំទូលាយ នៅ ក្នុងការបង្រៀនមុខវិជ្ជាឯកទេសវិទ្យាសាស្ត្រសង្គមដូចជា អក្សរសិល្ប៍ ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌...។ ក៏ប៉ុន្តែ វិធីពិពណ៌នានេះក៏ត្រូវសាស្ត្រាចារ្យ អាចយកមកប្រើប្រាស់បានផងដែរ នៅក្នុងការ បង្រៀន មុខវិជ្ជាវិទ្យាសាស្ត្រធម្មជាតិ គឺនៅពេលដែលសាស្ត្រាចារ្យ ត្រូវផ្សព្វផ្សាយចំណេះដឹងបន្ថែម ឱ្យដល់ សិស្សដូចជា៖

  -ចំណេះដឹងវិទ្យាសាស្ត្រក្នុងជីវភាពរស់នៅ

  -ស្នាដៃរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រដ៏ល្បីល្បាញ

  -ការធ្វើដំណើរកំសាន្ត និងទេសចរណ៍

  -ស្នាដៃ និងជោគជ័យនៅក្នុងមូលហេតុនៃការដណ្តើមយកជ័យជម្នះលើធម្មជាតិ

  -ជ័យជម្នះថ្មីៗ និងដ៏ល្បីល្បាញនៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេស

វិធីពិពណ៌នានេះ ត្រូវបានគ្រូបង្រៀន និងសាស្ត្រាចារ្យយកមកប្រើប្រាស់យ៉ាងទូលាយនៅថ្នាក់បឋមសិក្សា អនុវិទ្យាល័យ និងថ្នាក់ដំបូងនៃវិទ្យាល័យគឺ ក្នុងរយៈពេលពី១០ទៅ១៥នាទីសម្រាប់ថ្នាក់បឋមសិក្សា និង ពី៣០ទៅ៤០នាទី សម្រាប់ថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ។ ក្នុងពេលធ្វើពិពណ៌នា សាស្ត្រាចារ្យអាចដកស្រង់យកមកអាននូវកថាខ័ណ្ឌខ្លីៗ ឬឃ្លាសំខាន់ដែលដកស្រង់ចេញពីស្នាដៃអក្សរសិល្ប៍ សិល្បៈ ឬឯកសារ ជាប្រវត្តិសាស្ត្រជាដើម។ សាស្ត្រាចារ្យ ត្រូវបកស្រាយពន្យល់ឱ្យមានសភាពរស់រវើក ហើយពាក្យសំដី សម្បូរទៅដោយរូបារម្មណ៍ ហើយទន្ទឹមនឹងនោះ អាចប្រើប្រាស់សម្ភារៈបង្រៀនថែមទៀត ដើម្បីឱ្យសិស្ស ងាយយល់។ នៅក្នុងលំនាំនៃការពិពណ៌នា សាស្ត្រាចារ្យ អាចចោទជាសំណួរខ្លះចំពោះសិស្ស ដើម្បីទាញ ស្មារតីប្រុងប្រយ័ត្នរបស់សិល្បៈ ត្រួតពិនិត្យការយល់ជ្រួតជ្រាបចំណេះដឹង និងពង្រឹងចរិតសកម្មក្នុងការគិតរបស់សិស្ស។

**គ/ ការនិទានរឿង** ជាយុទ្ធវិធីមួយនៃវិធីឧទ្ទេសដែរ ដែលគ្រូប្រើក្នុងការនិយាយរឿងនិទានខ្លីៗឱ្យសិស្សស្តាប់។ក្នុងការនិយាយរឿងគ្រូគាប្បីចេះបញ្ចេញសម្លេងជាកុមារា កុមារី យាយ តា ...។

ជារួមបំណកស្រាយពន្យល់ គឺជាបម្រើបម្រាស់ទិន្នន័យ ដើម្បីស្រាយបំភ្លឺពីគោលការណ៍ វិធានទ្រឹស្តីបទ ក្រឹត្យក្រម និងរូបមន្តនៅក្នុងមុខវិជ្ជាសិក្សាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងវេយ្យាករណ៍ជាដើម។ ក្នុងបំណកស្រាយពន្យល់សាស្ត្រាចារ្យ គប្បីប្រើប្រាស់គ្រប់កត្តាទាំងអស់ក្នុងវិចារណញ្ញាណ និងក្នុងការវិនិច្ឆ័យដើម្បីឱ្យមានសមត្ថភាពយ៉ាងគ្រប់គ្រាន់ និងយ៉ាងប៉ិនប្រសប់នៅក្នុងការពង្រឹងចំណេះដឹង ភាពឈ្លាសវៃ និងចរិតច្នៃប្រឌិតរបស់សិស្ស។ ក្នុងករណីនេះតួនាទីដឹកនាំរបស់សាស្ត្រាចារ្យចំពោះសិស្សសំខាន់ណាស់។ សាស្ត្រាចារ្យត្រូវមានបំណិនប្រសប់ ក្នុងការចោទជាបញ្ហា រួចដឹកនាំសិស្សឱ្យសកម្មម្ចាស់ការក្នុង

ដំណោះស្រាយបញ្ហានេះ។ លើសពីនេះទៅទៀត សាស្ត្រាចារ្យត្រូវយកចិត្តទុកដាក់ ជំរុញសិស្សឱ្យមាន សមត្ថភាពដោះស្រាយបញ្ហាអស់ទាំងនោះបានជាអតិបរមា។

នៅថ្នាក់វិទ្យាល័យ ក្រៅពីវិធីបកស្រាយពីបញ្ហាមួយ និងវិធីពិពណ៌នា នៅមានបម្រើ បម្រាស់វិធីអធិប្បាយទៀត។ វិធីអធិប្បាយ គឺជាការរៀបរាប់ពីបញ្ហាមួយ ដើម្បីបំពេញ ឬបង្គ្រប់ទៅលើ ចំណេះដឹងដែលមានភាពស្មុគស្មាញ អរូបី ដែលត្រូវធ្វើទូទៅកម្ម នៅក្នុងរយៈពេលមួយដ៏ខ្លីបង្គួរ។

*ឧទាហរណ៍:* ទ្រឹស្តីនៅក្នុងជីវវិទ្យា និងទស្សនៈអក្សរសិល្ប៍ជាដើម។ បើប្រៀបធៀបទៅនឹង វិធី បកស្រាយពន្យល់ និងវិធីពិពណ៌នា យើងឃើញថាវិធីអធិប្បាយមានចំណុចល្អៗគួរឱ្យកត់ សម្គាល់បាន ដូចតទៅ៖

- សន្សំសំចៃពេលវេលា ព្រោះនៅក្នុងរយៈពេលមួយជាកំណត់សិស្សអាចទទួលយល់ជ្រួតជ្រាបចំណេះដឹងបានច្រើន។
- មានលក្ខណៈវិទ្យាសាស្ត្រយ៉ាងជិតស្និទ្ធ និងពិតប្រាកដ ពីព្រោះសាស្ត្រាចារ្យបានផ្សព្វផ្សាយនូវសច្ចភាពផង ធ្វើការវិភាគផង ធ្វើការប្រៀបធៀបទៅលើវិធីផ្សេងៗផង ហើយទីបំផុតបង្កើតបានជាចំណងទាក់ទងរវាងវិធីមួយៗទៀតផង។
- មានឥទ្ធិពលជំរុញសិស្ស ឱ្យមានភាពសកម្មក្នុងការគិត ពីព្រោះសាស្ត្រាចារ្យធ្វើអធិប្បាយពីបញ្ហាអរូបី។
- និយាយសរុប ឬរៀបរាប់បានពីចំណុចផ្សេងៗទៀតទៅលើបញ្ហាដែលបានលើកយកមកសិក្សាស្រាវជ្រាវក្នុងមេរៀនកន្លងមកបានរឹតតែត្រឹមត្រូវច្បាស់លាស់។ ក្នុងបញ្ហានេះមានប្រការមួយដែលត្រូវយកចិត្តទុ ក ដាក់ គឺ វិធីអធិប្បាយនៅសាលារៀ នចំណេះទូទៅមិនដូចគ្នានឹ ងវិធីអធិប្បាយ នៅថ្នាក់ឧត្តមសិក្សាឡើយ ថ្វីបើវាបាន ចរិតរួមដូចដែលបានលើឡើងមកហើយក៏ដោយ។
- នៅសាលារៀនចំណេះទូទៅ សាស្ត្រាចារ្យធ្វើអធិប្បាយ ពីឯកសារសិក្សាសំខាន់ៗ ទៅតាម ខ្លឹមសារ និង ចំណងជើងមេរៀននៅក្នុងសៀវភៅសិក្សា ។ រីឯនៅថ្នាក់ឧត្តមសិក្សាវិញ អ្នកធ្វើបាឋកថាសាស្ត្រាចារ្យធ្វើការបំភ្លឺ ពីបញ្ហាជាមូលដ្ឋាន នៃវិទ្យាសាស្ត្រទៅតាម ផែនការបង្រៀន និងតាមសម្ភារបង្រៀន ហើយអាចមាន លក្ខណៈចង្អៀតចង្អល់ ឬទូលំទូលាយ ឬក៏ស៊ីជម្រៅទៅលើ បញ្ហាសំខាន់ៗ ដោយឈរលើមូលដ្ឋាននៃការជានាបាននូវលក្ខណៈដ៏សមហេតុផលតាមវិទ្យាសាស្ត្រ។
- នៅសាលារៀនចំណេះទូទៅ សាស្ត្រាចារ្យ អាចឈប់ធ្វើអធិប្បាយមួយរយៈដើម្បីដាក់ ឬចោទជាសំណួរចំពោះសិស្ស សំដៅប្រមូលផ្តុំនូវស្មារតីប្រុងប្រយ័ត្នរបស់សិស្ស និងបណ្តុះឱ្យបាននូវលក្ខខណ្ឌ ពង្រឹងចរិតសកម្មក្នុងការគិតរបស់សិស្ស។ រីឯនៅក្នុងថ្នាក់ឧត្តមសិក្សាវិញ អ្នកធ្វើបាឋកថា ឬសាស្ត្រាចារ្យមិន អាច ចោទ ឬដាក់ ជាសំណួរឱ្យនិស្សិតបានឡើយ ប៉ុន្តែគ្រាន់តែ អាច ចោទ ជាសំណួររួចដោះ ស្រាយដោយខ្លួនឯង ដើម្បីជម្រុញនិស្សិតឱ្យមានសកម្មភាពក្នុងការគិតប៉ុណ្ណោះ។
- នៅសាលារៀនចំណេះទូទៅ សាស្ត្រាចារ្យអាចធ្វើអត្ថាធិប្បាយជូនសិស្សបានក្នុងរយៈពេលត្រឹមតែពីមួយម៉ោង ទៅពីរម៉ោងប៉ុណ្ណោះ។ រីឯនៅកម្រិតឧត្តមសិក្សាវិញ អ្នកធ្វើបាឋកកថាអាចធ្វើអត្ថាធិប្បាយបានពី ពីរ ទៅបីម៉ោងពីព្រោះនិស្សិតមានសមត្ថភាពក្នុងការទទួលយល់ជ្រួបជ្រាបចំណេះដឹងបានក្នុងរយៈពេលមួយម៉ោង ទៅពីរម៉ោងបានយ៉ាងយូរ។

**ខ. ចំណុចខ្លាំង និងចំណុចខ្សោយរបស់វិធីឧទ្ទេស**

**ក. វិធីឧទ្ទេសមានចំណុចខ្លាំងគួរឱ្យកត់សម្គាល់បានដូចតទៅ៖**

១. ជួយសិស្សឱ្យក្តាប់ ចំ ណេះដឹងបានជាពិ សេសគឺ ក្តាប់ បាននូវបញ្ហាពិ បាកហើយស្មុគស្មាញ។

២. បង្កបាន នូវលក្ខខណ្ឌងាយ ស្រួលឱ្យដល់សាស្រ្តាចារ្យ ក្នុងការជះឥទ្ធិពលទៅលើសតិអារម្មណ៍ និង សញ្ចេតនារបស់សិស្ស ដោយឆ្លងកាត់តាមរយៈការធ្វើអធិប្បាយតាមឯកសារ និងបម្រើបម្រាស់វាចា រនិង កាយវិការដ៏សមរម្យ ទៅតាមលំនាំនៃការធ្វើអធិប្បាយនោះ។

៣. ជំរុញសិស្សឱ្យមានចរិតសកម្មក្នុងការគិត និងកំណត់ត្រាបាននូវចំណុចសំខាន់ៗ។

**ខ.ទន្ទឹមនឹងចំណុចខ្លាំង វិធីឧទ្ទេសក៏មានចំណុចខ្សោយខ្លះដែរ៖**

១.ងាយធ្វើឱ្យសិស្សអសកម្មក្នុងការយចិត្តទុកដាក់ស្តាប់សាស្រ្តាចារ្យ។ កាលបើសាស្រ្តចារ្យ និយាយ វែងពេក ឬដដែលនោះជាហេតុធ្វើឱ្យសិស្សធុញទ្រាន់។

២. មិនបានធ្វើឱ្យសាស្រ្តាចារ្យ យកចិត្តទុកដាក់ឱ្យបានដិតដល់ ទៅលើកម្រិតដឹងរបស់សិស្ស ហើយ សាស្រ្តាចារ្យ ក៏មិនអាចត្រួតពិនិត្យបានទៅលើការយល់ជ្រួតជ្រាបរបស់សិស្សម្នាក់ៗដែរ។

ដើម្បីពង្រឹងចំណុចខ្លាំង និងចៀសវាងចំណុចខ្សោយ យើងជាសាស្រ្តាចារ្យគប្បីយកចិត្តទុកដាក់ ដល់សំណូមពរក្នុងបម្រើបម្រាស់វិធីនេះ។

**គ.សំណូមពរមួយចំនួនជាមូលដ្ឋានចំពោះវិធីឧទ្ទេស៖**

១. ធានាបាននូវចរិតអប់រំចរិតវិទ្យាសាស្រ្ត និងចរិតអនុវត្តរបស់ខ្លឹមសារនៃវិធីឧទ្ទេសដែលក្នុង នោះគប្បីយកចិត្តទុកដាក់ដល់លក្ខណៈត្រឹមត្រូវពិតប្រាកដរបស់ព្រឹត្តិការណ៍ អត្ថន័យសតិអារម្មណ៍ នយោបាយរបស់ឯកសារ និងសារជាតិរបស់បញ្ហាដែលត្រូវបានបលើកមកសិក្សាស្រាវជ្រាវ។

២. ធានាបាននូវលំដាប់ថ្នាក់ដ៏ត្រឹមត្រូវ ទៅលើសេចក្តីអធិប្បាយតាមឯកសារសិក្សា ដើម្បីចំណេះដឹង ទាំងឡាយផ្សារជាប់គ្នាជាប្រព័ន្ធកម្ម។

៣. ធានាបាន នូវភាពក្លីស្វាងច្បាស់លាស់ងាយយល់ក្នុងការធ្វើអធិប្បាយតាមឯកសារ។

៤. ធានាបាននូវស្មារតីប្រុងប្រយ័ត្នរបស់សិស្សក្នុងការស្តាប់និងការគិត។

៥. ធានាឱ្យសិស្សយល់ច្បាស់ និងអាចកត់ត្រាបាន។

**៣.៤.២.វិធីចោទ-ឆ្លើយ**(**សន្ទនា**)

**ក.សញ្ញាណទូទៅ**

វិធីចោទ/ឆ្លើយ ត្រូវបានសាស្រ្តាចារ្យភាគច្រើនយកមកប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងលំនាំនៃ ការបង្រៀន។ វិធីនេះសំដៅ៖

-ជួយណែនាំ និងបំផុសគំនិតសិស្ស ឱ្យយល់ក្លីស្វាងទៅលើបញ្ហាថ្មី រកឃើញចំណេះដឹង ថ្មី ទាញសន្និដ្ឋានសរុប ជាចាំបាច់បានពីក្នុងមេរៀន និងបទពិសោធន៍ដែលបានឆ្លងកាត់ក្នុងជីវភាព រស់នៅ។

-គួបផ្សំចំណេះដឹងថ្មីទៅនឹងចំណេះដឹងដែលសិស្សបានយល់ជ្រួតជ្រាបរួចមកហើយ។

-ពង្រឹ ងការសិក្សាសារ ឡើងវិញបើកទូលាយ និងស៊ី ជម្រៅទៅលើ ចំណេះដឹងដែលបានរៀនរួចមក ហើយ។

-ត្រួតពិនិត្យចំណេះដឹងក្នុងកម្រិតយល់ដឹងរបស់សិស្ស។

លំហាត់ចោទ / ឆ្លើយជាមូលដ្ឋានមាន៖

**ក/ ចោទ ឆ្លើយតាម បែបណែនាំ**

ការចោទ / ឆ្លើយតាមបែបណែនាំ បានត្រូវអនុវត្តនៅពេលចាប់ផ្ដើមពន្យល់មេរៀនថ្មី។ ក្នុងពេលនោះ សាស្ត្រាចារ្យ គ្រូ ប៉ិនប្រសប់ចោទជាសំណួរ និងណែនាំសិស្សឱ្យរកឃើញចំណេះដឹងថ្មី និងទាញសេចក្ដីសន្និដ្ឋាន សរុបថ្មីដើម្បីទទួលយល់ជ្រួតជ្រាបនិងក្ដាប់បានចំណេះដឹងថ្មី។ វិធីនេះ ត្រូវបានទស្សនវិទូ សូក្រាត (៤៦៩-៣៩៩មុនគ.ស)អនុវត្តមុនគេបង្អស់ ក្នុងបំណកស្រាយទស្សនវិជ្ជា។ វិធីនេះត្រូវគេយកទៅប្រើប្រាស់នៅគ្រប់សាលារៀនក្នុងពិភពលោក។ សាស្ត្រាចារ្យ គប្បីរៀបចំសំណួរជាមុន ឱ្យសិស្សត្រៀម លក្ខណៈឆ្លើយជាស្រេចរួចក្រោយមក ទើបសាស្ត្រាចារ្យ ពង្រឹងចរិតសកម្ម និងម្ចាស់ការរបស់សិស្ស។ ក្នុងសាលារៀនមធ្យមសិក្សាចំណេះទូទៅ នៅប្រទេសកម្ពុជាយើងសព្វថ្ងៃ វិធីនេះមានឥទ្ធិពលណាស់គឺជួយសិស្សឱ្យ៖

- ពង្រឹងបាននូវចរិតសកម្មម្ចាស់ការនិងច្នៃប្រឌិតក្នុងការគិត។
- អភិវឌ្ឍបាននូវអត្ថប្រយោជន៍ ក្នុងទំនួលចំណេះដឹង និងចំណង់ចំណូលចិត្តក្នុងការសិក្សា។

**ខ/ ចោទ ឆ្លើយតាមបែបពង្រឹង**

វិធីនេះត្រូវបានយកមកប្រើប្រាស់៖

-ក្រោយពេលបកស្រាយពន្យល់ចំណេះដឹងថ្មី

-នៅពេលសិក្សាសារឡើងវិញ

-ក្រោយពេលធ្វើកិច្ចការត្រួតពិនិត្យទៅលើចំណេះដឹងថ្មី។

វិធីនេះជួយសិស្សឱ្យ៖

-ពង្រឹងបាននូវចំណេះដឹងជាមូលដ្ឋានសំខាន់។ ហើយសិស្សអាចធ្វើប្រព័ន្ធកម្មទៅ លើចំណេះដឹងនោះបានទៀតផង។

-បើកទូលាយ និងស៊ីជម្រៅទៅលើចំណេះដឹងដែលបានរៀនរួចមកហើយ។

-ជម្នះបានលើលក្ខណៈជារូបភាព លក្ខណៈជាភាពងងឹងងល់ ខ្វះជាតុពិតត្រឹមត្រូវ ក្នុងការយល់ជ្រួតជ្រាប និងក្ដាប់បានចំណេះដឹង។

**គ/ ចោទ ឆ្លើយតាមបែបគួបផ្សំ**

ការចោទឆ្លើយតាមបែបគួបផ្សំ ត្រូវបានយកមកប្រើប្រាស់ នៅពេលដែលសាស្ត្រាចារ្យ ណែនាំសិស្សឱ្យធ្វើទូទៅកម្ម និងធ្វើប្រព័ន្ធកម្ម ក្នុងផ្នែកណាមួយនៃមេរៀន ឬនៅក្នុងជំពូកនីមួយៗនៃមេរៀន។ វិធីនេះជួយសិស្សឱ្យ៖

-អភិវឌ្ឍបាននូវសមត្ថភាពខាងទូទៅកម្ម និងប្រព័ន្ធកម្ម និងទទួលយល់ជ្រួតជ្រាបចំណេះដឹង បានយ៉ាង ត្រឹមត្រូវ។

-ជម្នះបាននូវលក្ខណៈ ជារូបភាពដែលកាត់ផ្ដាច់ស្រលះពីចំណេះដឹងដែលសិស្សត្រូវរៀន។

**ឃ/ ចោទ ឆ្លើយតាមបែបត្រួតពិនិត្យ**

វិធីនេះត្រូវបានយកមកប្រើប្រាស់៖

-មុន ឬក្នុងពេល ឬក្រោយពេលម៉ោងបង្រៀនមេរៀនណាមួយ។

-ក្រោយពេលបង្រៀនចប់មេរៀនមួយ ឬមេរៀនជាច្រើន ឬនៅពេលបង្រៀនចប់ជំពូកណាមួយនៃមេរៀន ឬនៅពេលបង្រៀនចប់ជំពូកទាំងអស់នៃមេរៀនក៏បាន។ វិធីនេះជួយសិស្ស ឱ្យមានស្វ័យត្រួតពិនិត្យ

យ៉ាងឆាប់រហ័សទាន់ពេលវេលា និងជួយសាស្ត្រាចារ្យ ឱ្យត្រួតពិនិត្យបានទៅលើចំណេះដឹងរបស់សិស្ស។

## ខ. ចំណុចខ្លាំងនិងចំណុចខ្សោយ របស់វិធីចោទ ឆ្លើយ

### ក/ ចំណុចខ្លាំង

ប្រសិនបើសាស្ត្រាចារ្យ ចេះអនុវត្តវិធីនេះបានយ៉ាងប៉ិនប្រសប់ នោះវិធីចោទឆ្លើយនេះ នឹងត្រូវទទួលលទ្ធផលល្អ ហើយមានឥទ្ធិពលសំខាន់ណាស់គឺ៖

-ជំរុញសិស្សឱ្យសកម្ម និងម្ចាស់ការក្នុងការគិត រកឃើញចម្លើយដ៏ត្រឹមត្រូវគ្រប់គ្រាន់ហើយមានរបៀបរៀបរយពោលគឺសិស្សរកឃើញនូវចម្លើយល្អយ៉ាងរហ័ស។

-បំប៉នសិស្សឱ្យមានសមត្ថភាព ក្នុងការនិយាយរៀបរាប់ និងមានអត្ថប្រយោជន៍ ចំពោះការសិក្សាតាមរយៈរង្វាយតម្លៃទៅលើចម្លើយសិស្ស។

-ជួយសាស្ត្រាចារ្យ ឱ្យទទួលបាននូវទំនាក់ទំនងបញ្ច្រាសពីសិស្សវិញបានយ៉ាងឆាប់រហ័ស ហើយបង្កើតបានលក្ខខណ្ឌមួយ គឺទាក់ទាញស្មារតីប្រុងប្រយ័ត្នរបស់សិស្សម្នាក់ៗទាំងសិស្សខ្សោយក៏ ដូចសិស្សពូកែ។

-បណ្តុះបណ្តាលបាននូវបរិយាកាសដ៏សប្បាយរីករាយហើយមានភាពរស់រវើកនៅក្នុងម៉ោងសិក្សា។

### ខ/ ចំណុចខ្សោយ

បើសាស្ត្រាចារ្យមិនឈ្លាសវៃប៉ិនប្រសប់ ហើយអនុវត្តធ្លងទៅលើវិធីនេះ នោះចំណុចខ្សោយក៏លេចមានឡើងដែរ៖

-នាំឱ្យខាត ពេលវេលា មានឥទ្ធិពលមិនល្អ បណ្តាលមកពីការបង្រៀនរបស់សាស្ត្រាចារ្យ ដូចជាឃ្លាពិបាកយល់ ឃ្លាមិនច្បាស់លាស់ ខ្វះធាតុពិតត្រឹមត្រូវ ឃ្លាពិបាកយល់នាំឱ្យសិស្សឆ្លើយគ្មានលក្ខណៈវិទ្យាសាស្ត្រ។

-ផ្លាស់ប្តូរសំណួរឱ្យទៅជាសន្ទនារវាងសាស្ត្រាចារ្យ និងសិស្សម្នាក់ៗ ឬមិនបានទាញស្មារតីប្រុងប្រយ័ត្នដល់សិស្សក្នុងថ្នាក់ទាំងមូលឱ្យចូលរួមក្នុងការឆ្លើយ។

## គ. សំណូមពរមួយចំនួនចំពោះការអនុវត្តវិធីចោទ ឆ្លើយ

ពេលអនុវត្តវិធីនេះ សាស្ត្រាចារ្យគប្បីយកចិត្តទុកដាក់ដល់សំណូមពរចំពោះសំណួរ និងការណែនាំឱ្យសិស្សឆ្លើយ។ ដូចនេះ សាស្ត្រាចារ្យត្រូវមានសំណូមពរចំពោះសិស្សក្នុងការឆ្លើយផងដែរ។

### ក/ សំណូមពរចំពោះសំណួរ

សំណួរ ត្រូវឱ្យមានឥទ្ធិពលខ្ពស់ ហើយកំណត់បាននូវចម្លើយមួយច្បាស់លាស់ ពេលរៀបចំសំណួរសាស្ត្រាចារ្យ គប្បីយកចិត្តទុកដាក់នឹងសំណួរមួយចំនួនដូចតទៅ៖

កំណត់ច្បាស់ នូវគោលដៅ សំណូមពរនិងខ្លឹ មសារក្នុងការចោទ /ឆ្លើយ ចំពោះប្រព័ន្ធនៃ សំណួរទាំងមូល។ សំណួរទាំងអស់ត្រូវមានលក្ខណៈណែនាំមួយ។

-ដាក់សំណួរឱ្យមាន ខ្លឹមសារច្បាស់ លាស់ ត្រឹមត្រូវ ងាយយល់ មានលក្ខណៈ ឯកភាពហើយសមរម្យទៅ នឹងកម្រិតយល់ដឹងរបស់សិស្ស មានរៀបរៀបរយ ក្លីស្វាងហើយដែលសិស្សអាចឆ្លើយបាន។

-ដាក់សំណួរ ឱ្យមានឥទ្ធិពលជំរុញដល់ចរិតសកម្ម ម្ចាស់ការក្នុងការគិត ធ្វើឱ្យអត្ថប្រយោជន៍ក្នុង

ការយល់ជ្រួតជ្រាបចំណេះដឹងរបស់សិស្សអភិវឌ្ឍហើយគប្បីចៀសវាងដាច់ខាតចំពោះសំណួរដែលគ្រាន់តែឆ្លើយថា " មាន " " គ្មាន " និងសំណួរ ឬចម្លើយ " កុហក " ខ្វះធាតុពិត។

ក្នុងការអនុវត្តវិធីចោទឆ្លើយ សាស្ត្រាចារ្យភាគច្រើនចូលចិត្តដាក់សំណួរ ដែលមានលក្ខណៈគួរឱ្យកត់សម្គាល់បានដូចតទៅៈ

-សំណួរទាមទារឱ្យសិស្សបកស្រាយពន្យល់ពីបាតុភូតថ្មី ដែលទើបនឹងរៀនហើយ។

-សំណួរទាមទារឱ្យសិស្សប្រៀបធៀបវត្ថុ បាតុភូត ហេតុការណ៍ក្នុងមេរៀន។

-សំណួរទាមទារឱ្យសិស្សធ្វើប្រព័ន្ធកម្ម ទូទៅកម្ម ប្រៀបធៀបទៅលើចំណេះដឹងដែលបានរៀនរួចមកហើយ។

-សំណួរតម្រូវឱ្យសិស្សស្រាយបំភ្លឺពីព្រឹត្តិការណ៍ ឬបាតុភូតក្នុងសង្គម ឬក្នុងជីវភាពរស់នៅសព្វថ្ងៃ។

-សំណួរតម្រូវឱ្យសិស្សយកចំណេះដឹងដែលបានរៀនរួចហើយទៅអនុវត្តនៅក្នុងដំណោះស្រាយបញ្ហាជាក់ស្តែង។

-សំណួរមានខ្លឹមសារដូចគ្នាប៉ុន្តែរូបភាពផ្សេងគ្នា។

**ខ/ សំណូមពរចំពោះការលើកជាសំណួរនិងការណែនាំសិស្សឱ្យឆ្លើយ**

ក្នុងការចោទជាសំណួរ និងការណែនាំ ឬបំផុសគំនិតសិស្សឱ្យឆ្លើយ សាស្ត្រាចារ្យត្រូវយកចិត្តទុកដាក់និងសំណូមពរជាមូលដ្ឋានដូចតទៅៈ

-លើកជាសំណួរ ឱ្យសិស្សក្នុងថ្នាក់ទាំងមូលឆ្លើយ ហើយទាញស្មារតីប្រុងប្រយ័ត្ន និងជំរុញសកម្មភាពរួមរបស់សមូហភាពសិស្សឆ្លើយ ក្រោយមកសាស្ត្រាចារ្យ ត្រូវសម្រេចឱ្យសិស្សម្នាក់ឆ្លើយ។ ពេលសិស្សណាម្នាក់ឆ្លើយ សាស្ត្រាចារ្យ ត្រូវសំណូមពរឱ្យសិស្សឯទៀត យកចិត្តទុកដាក់ស្តាប់តាមដានរួចទើបឱ្យសិស្សឯទៀតបញ្ចេញមតិយោបល់។ពេលដែលសិស្សម្នាក់ៗឆ្លើយត្រូវ សំណូមពរឱ្យសិស្សឯទៀត ពិនិត្យ សង្កេត វិភាគត្រិះរិះ និងតាមដានចម្លើយមិត្តភក្តិរបស់ខ្លួន។ ក្រោយមកសាស្ត្រាចារ្យ ត្រូវធ្វើការបូក សរុបទៅលើចម្លើយសិស្សម្នាក់ៗ។ សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់សិស្សខ្សោយ និងសិស្សខ្វះ សេចក្តីក្លាហាន។

-តែត្រូវជៀងវាងការខ្ជះខ្ជាយពេលវេលាដូចជាទុកចោលឱ្យសិស្សគិតតែសិស្សមិនអាចឆ្លើយបាន។

-សាស្ត្រាចារ្យ ត្រូវមានអាកប្បកិរិយានឹងនរ ពេលតាមដានចម្លើយសិស្ស ជៀសវាងការកាត់ផ្តាច់ចម្លើយសិស្សការតក់ក្រហល់ទៅមតិរបស់សិស្សក្នុងពេលដែលមិនចាំបាច់។ សាស្ត្រាចារ្យ ត្រូវញ៉ាំងសិស្សឱ្យក្លាហាននិងជៀសវាងពាក្យសំដីខ្វះការគោរពបុគ្គលិកលក្ខណៈរបស់សិស្ស។

-យកចិត្តទុកដាក់កែតម្រូវ បូកសរុបឃ្លាចម្លើយរបស់សិស្ស គួបផ្សំចម្លើយសិស្សប្រសិនបើចាំបាច់សាស្ត្រាចារ្យ ត្រូវធ្វើប្រព័ន្ធកម្មទៅលើចំណេះដឹងដែលសិស្សទើបនឹងក្តាប់ បានទៅក្នុងលំនាំនៃ ការចោទ/ ឆ្លើយនេះ។

**គ/ សំណូមពរចំពោះសិស្ស**

-ត្រូវផ្តោតស្មារតីប្រុងប្រយ័ត្នចំពោះសំណួរ ដើម្បីឱ្យមានការយល់ដឹងត្រឹមត្រូវ ហើយគ្រប់គ្រាន់ច្បាស់លាស់សកម្មក្នុងការគិត ប្រើអស់សមត្ថភាពយល់ដឹងដែលខ្លួនមាន រកឃើញចម្លើយគ្រប់គ្រាន់ក្នុងរយៈពេលមួយយ៉ាងខ្លី ចៀសវាងការឆ្លើយតាមសៀវភៅ ឬតាមសាស្ត្រាចារ្យព ន្យល់ ឬចៀសវាងចម្លើយមិនគ្រប់គ្រាន់។

-ត្រូវយកចិត្តដាក់ស្តាប់មិត្តភក្តិឆ្លើយចេះសង្កេតពិចារណា ហើយចៀសវាងការខ្សឹបប្រាប់មិត្តភក្តិ

-ត្រូវក្លាហានក្នុងការឆ្លើយសំណួរ ហើយចូលរួមពិភាក្សាពេលសាស្ត្រាចារ្យសំណូមពរ ។

## ៣.៤.៣ វិធីប្រើប្រាស់សៀវភៅសិក្សា និងឯកសារសិក្សាផ្សេងទៀត

### ក. អត្ថន័យនៃបម្រើបម្រាស់សៀវភៅ

សៀវភៅសិក្សា ឆ្លុះបញ្ចាំងឱ្យឃើញនូវបទពិសោធន៍ ដែលត្រូវបានធ្វើទូទៅកម្ម និងប្រព័ន្ធកម្ម ដែលមនុស្សជាតិបានចងក្រងទុក ដោយឆ្លងកាត់ជំនាន់មនុស្សក្នុងសង្គម ហើយពិសេស សៀវភៅសិក្សាក៏ឆ្លុះបញ្ចាំងឱ្យឃើញផងដែរ ពីរបកគំហើញថ្មីបំផុតរបស់វិទ្យាសាស្ត្រ បច្ចេកទេស អក្សរសាស្ត្រ ដែលជាប្រភព នៃចំណេះដឹងដ៏សម្បូរបែប ប្រកបទៅដោយភាពរស់រវើក ហើយដែលអាចទាក់ទាញបាននូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ជីវភាពពលកម្ម និងជីវភាពរស់នៅរបស់មនុស្ស។ នៅក្នុងសាលារៀនកម្ពុជាយើងសព្វថ្ងៃ សិស្សានុសិស្សត្រូវការ ប្រើប្រាស់សៀវភៅសិក្សា តាំងពីថ្នាក់បឋមសិក្សាឡើងទៅ។ កាលណាសិស្សរៀនដល់កម្រិតសិក្សាខ្ពស់ តម្រូវ ការរបស់សិស្សខាងសៀវភៅសិក្សានេះ ក៏កាន់តែចាំបាច់ណាស់។ សៀវភៅសិក្សាមានឥទ្ធិពល ណាស់គឺៈ

-ជួយឱ្យសិស្សបើកទូលាយ និងស៊ីជម្រៅទៅលើការយល់ដឹងរបស់ខ្លួនយ៉ាងល្អត្រឹមត្រូវ។

-ជួយសិស្សឱ្យហ្វឹកហ្វឺនបាននូវចំណេះធ្វើ និងបំណិនប្រសប់ ជួយសិស្សឱ្យមានទម្លាប់ក្នុងបម្រើបម្រាស់សៀវភៅបំប៉នទុនវេយ្យាករណ៍ បទពិសោធន៍ក្នុងការតែងសេចក្តី ស្មារតីពិនិត្យសង្កេត និងការទិទៀន។

-បំប៉នឱ្យសិស្សនូវអត្ថប្រយោជន៍ក្នុងការសិក្សាដូចជា សញ្ចេតនា និងសតិអារម្មណ៍ភ្លឺស្វាងជាដើម លោកហ៊ិចសិន(១៨១២-១៨៧០)ជាទស្សនវិទូ ជនជាតិរុស្ស៊ីដ៏ល្បីល្បាញបាន សរសេរថា "សៀវភៅ ជាមធ្យោបាយអប់រំ ប្រើសំដីរបស់ស្មារតីមនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត ជាមធ្យោបាយ ទូន្មានរបស់មនុស្សចាស់ ដែលហៀបនឹងដាច់ខ្យល់ស្លាប់ ចំពោះយុវវ័យដែលកំពុងឈានចូលក្នុងជីវភាព រស់នៅ ជាបទបញ្ជារបស់អ្នកមានស្នាដៃក្នុងប្រវត្តិសាស្ត្របន្សល់ទុកឱ្យអ្នកបន្តវេន" ។

យើងជាសាស្ត្រាចារ្យ យើងគប្បីយកចិត្តទុកដាក់ណែនាំសិស្ស ឱ្យចេះប្រើប្រាស់សៀវភៅសិក្សា ហើយទន្ទឹមនឹងនេះ យើងត្រូវប្រឆាំងនឹងនិន្នាការដែលវាយតម្លៃខ្ពស់ ទៅលើតួនាទីស្វ័យសិក្សា របស់សិស្សតាមរយៈសៀវភៅសិក្សា និងវាយតម្លៃទាប ទៅលើតួនាទីដឹកនាំរបស់សាស្ត្រាចារ្យ។ ផ្ទុយទៅវិញ យើងក៏ត្រូវប្រឆាំងផងដែរចំពោះនិន្នាការ ដែលលើកកម្ពស់តួនាទីដឹកនាំរបស់សាស្ត្រាចារ្យ ហើយមើលស្រាលតួនាទីស្វ័យ សិក្សារបស់សិស្សតាម សៀវភៅសិ ក្សា។ និន្នាការ ទាំ ងនេះ សុទ្ធតែ នាំ មកនូវផលវិបាក ឬកាត់ផ្តាច់តួនាទីដឹកនាំរបស់ សាស្ត្រាចារ្យ ពីតួនាទីស្វ័យសិក្សារបស់សិស្ស។ ដូចនេះការសិក្សាគ្មានសាស្ត្រាចារ្យណែនាំ មិនបានចេះជ្រៅជ្រះទេ។

### ខ. បម្រើបម្រាស់សៀវភៅសិក្សានៅក្នុងថ្នាក់រៀន

នៅក្នុងលំនាំនៃការបង្រៀន សាស្ត្រាចារ្យត្រូវបកស្រាយ ពន្យល់ សិស្សឱ្យបាន គ្រប់គ្រាន់ពីផ្នែក ឬអត្ថន័យសំខាន់ៗនៅក្នុងសៀវភៅសិក្សាដូចជាៈ

-បកស្រាយពន្យល់ពីន័យរបស់ពាក្យថ្មីឬបច្ចេកស័ព្ទថ្មី។

-ណែនាំសិស្សឱ្យអូសបន្ទាត់ពីក្រោមពាក្យណាឬឃ្លាប្រយោគណាដែលសំខាន់ៗ។

-ណែនាំសិស្សឱ្យចេះប្រើប្រាស់ផែនទីគំនូរគំនូសតាងឬធ្វើលំហាត់ក្នុងសៀវភៅសិក្សា។

## គ. បម្រើបម្រាស់សៀវភៅសិក្សានៅផ្ទះ

បម្រើបម្រាស់សៀវភៅនៅផ្ទះ សំខាន់ណាស់ចំពោះសិស្សអនុវិទ្យាល័យ និងវិទ្យាល័យ ព្រោះសៀវភៅសិក្សាទាំ ងនេះ ជួយសិស្សឱ្យបូ កសរុប និងសិក្សាស៊ី ជម្រៅទៅចំ ណេះដឹងដែលបានសិក្សា រួចមកហើយនៅក្នុងថ្នាក់រៀន។ ដើម្បីប្រើប្រាស់សៀវភៅសិក្សាឱ្យមានប្រសិទ្ធិភាព សិស្ស គប្បីក្តាប់បាននូវចំណេះធ្វើ និង បំណិនប្រសប់ឱ្យបានសមស្របទៅនឹងមុខវិជ្ជា ដែលខ្លួនកំពុងសិក្សា។ សិស្សដែលសិក្សា មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា អាចប្រើប្រាស់សៀវភៅជំនួយស្មារតីតារាងលោការីត និងចេះអានសៀវភៅវិទ្យាសាស្ត្រ និងបច្ចេក ទេស។ចំពោះសិស្ស ដែលសិក្សាភូ មិវិទ្យា ត្រូវចេះប្រើប្រាស់ ផែនទី និងសៀវភៅជំនួយស្មារតី។ សិស្សដែលសិក្សា ភាសាប រទេស អាចប្រើប្រាស់ វចនានុក្រម សៀវភៅសន្ទនា និងសៀវភៅជំនួយស្មារតីខាងវេយ្យាករណ៍ ក្រៅពីនេះ សិស្សត្រូវអានសៀវភៅ ឯកសារ ទស្សនាវ ដ្ដី អត្ថបទកាសែត ដើម្បីយល់បន្ថែម និងស៊ីជម្រៅឱ្យបាន គ្រប់គ្រាន់ទៅលើខ្លឹមសារនៃមេរៀនដែលបានរៀនរួចមកហើយ។ សាស្ត្រាចារ្យ ត្រូវណែនាំ ឬកំណត់ឱ្យសិស្សអាន នូវផ្នែកណាដែលសំខាន់ៗ និងចាំបាច់ ហើយជាប់ទាក់ ទងទៅនិងមុខវិជ្ជាសិក្សាទាំងឡាយដូចជា អត្ថបទ ឬផ្នែកណាសំខាន់ៗ ដែលមាននៅក្នុងឯកសារសិក្សា ទស្សនាវដ្ដី ឬកាសែត។ ក្នុងលំនាំនៃអំនានឯកសារសិក្សា សិស្សម្នាក់ៗគប្បីៈ

- សរសេរជាអត្ថបទកាសែតជញ្ជាំង
- កត់ត្រាអត្ថបទដកស្រង់
- តាក់តែងគម្រោងមេរៀនឱ្យងាយយល់តាមអត្ថបទដកស្រង់
- កត់ត្រាសង្ខេប
- និយាយរៀបរាប់ឡើងវិញ

### ១.សំណេរជាអត្ថបទកាសែតជញ្ជាំង

រូបភាពនេះសំដៅជួយសិស្សឱ្យប្រមូលផ្ដុំបាននូវការយល់ដឹងសរុបពីក្នុងសៀវភៅសិក្សា ឬឯកសារសិក្សាដែលបានរៀនរួចមកហើយ ហើយថែមទាំងធ្វើឱ្យសិស្សកត់ត្រាបានឡើងវិញ ពីចំណាប់អារម្មណ៍ និងកំណត់ចំណាំទៅលើអត្ថបទក្នុងឯកសារសិក្សាផង។ តាមបទពិសោធន៍ទូទៅ សំណេរអត្ថបទកាសែតជញ្ជាំងត្រូវមានលក្ខណៈគួរឱ្យកត់សម្គាល់បានដូចតទៅៈ

-កត់ត្រាឱ្យបានច្បាស់នូវឈ្មោះអ្នកនិពន្ធ ឈ្មោះសៀវភៅ ឬឯកសារសិក្សា ឈ្មោះរោងពុម្ព និងឆ្នាំបោះពុម្ព។

-កត់ត្រាបញ្ជីអត្ថបទនិងគម្រោងសង្ខេបរបស់សៀវភៅនិងឯកសារសិក្សា។

-កត់ត្រា ឬដកស្រង់ ឃ្លាប្រយោគ ឬកថាខ័ណ្ឌ និងឯកសារសិក្សា។

-កត់ត្រា ឬដកស្រង់ ឃ្លាប្រយោគ ឬកថាខ័ណ្ឌដែលចាំបាច់។

-សរសេរពីចំណាប់អារម្មណ៍ និងកំណត់សម្គាល់របស់អ្នកអានចំពោះសៀវភៅ និងឯកសារសិក្សា ឬធ្វើការរិទៀនក៏បាន។

### ២.កំណត់ត្រាអត្ថបទដកស្រង់

រូបភាពនេះ ជួយសិស្សឱ្យកត់ត្រាបានឡើងវិញ ពីឃ្លាប្រយោគ ឬកថាខ័ណ្ឌដែលឆ្លើយតបបានទៅនឹងសំណូមពរសិក្សាចំពោះខ្លឹមសារ និងរូបភាពនៃការរៀបរាប់ដូចជា កថាខ័ណ្ឌសំខាន់ៗ ឃ្លាប្រយោគ ដ៏ពិ

ពោះៗនិងរូបភាពល្អៗ។ ឃ្លាប្រយោគ ឬកថាខ័ណ្ឌទាំងនេះ ត្រូវបានសិស្សយកទៅប្រើប្រាស់ក្នុង សំណេរ អត្ថបទកាសែតជញ្ជាំង ឬតាក់តែងគម្រោងកម្មវិធី ដើម្បីស្វែងយល់ស៊ីជម្រៅទៅលើជំពូកមេរៀន។ ពេលកត់ត្រាអត្ថបទដកស្រង់ គប្បីសរសេរឱ្យបានច្បាស់លាស់ពីអាស័យដ្ឋាន ឈ្មោះអ្នកនិពន្ធ ឈ្មោះសៀវ ភៅ ឬឯកសារពោងពុម្ពនិងចំនួនទំព័រ។

**៣.ការតាក់តែងគម្រោងមេរៀនឱ្យងាយយល់តាមអត្ថបទដកស្រង់**

រូបភាពនេះ ជួយសិស្សឱ្យអភិវឌ្ឍន៍បានខាងសមត្ថភាពក្នុងទូទៅនិងប្រព័ន្ធកម្មហើយសិស្ស មានទីបង្អែកក្នុងការចង់ចាំបានច្បាស់ នៅពេលដែលត្រូវសង្ខេបឡើងវិញ ឬធ្វើអត្ថាធិប្បាយសារជាថ្មីម្តងទៀត។

**៤.កំណត់ត្រាសង្ខេប**

រូបភាពនេះ ជួយសិស្សឱ្យពឹងផ្អែកលើគម្រោងដែលបានរៀបចំរួចមកហើយគឺកត់ត្រាឡើងវិញនូវមតិជាមូលដ្ឋានដ៏សំខាន់ៗដែលឆ្លុះបញ្ចាំងឱ្យឃើញនូវខ្លឹមសាររបស់មេរៀនមួយឬជំពូកមេរៀនណាមួយ។

**៥.ការនិយាយរៀបរាប់ឡើងវិញ**

ការនិយាយរៀបរាប់ឡើងវិញជួយសិស្សឱ្យហ្វឹកហ្វឺន បាននូវសមត្ថភាពខាងការនិយាយរៀបរាប់ ពីចំណេះដឹងដែលត្រូវបានប្រមូលផ្តុំ ដើម្បីឱ្យកាន់តែងាយដល់ជ្រួតជ្រាប និងចងចាំបាន។ ចង់ឱ្យបានសម្រេចតាមបំណងនេះ គ្រូបង្រៀនអាចឱ្យសិស្សនិយាយឡើងវិញពីផ្នែកសង្ខេប ទៅលើចំណុចសំខាន់ៗក្នុងសៀវភៅសិក្សាទាំងមូលក៏បាន។ ដើម្បីនិយាយរៀបរាប់ឡើងវិញបាន សិស្សត្រូវតែកសាងឱ្យបាននូវគម្រោងកម្មវិធីវិញដើម្បីងាយយល់និងងាយចងចាំរួចរៀបរាប់ទៅតាមលំដាប់លំដោយមានភាពរស់រវើក។

## ឃ. សំណូមពរមួយចំនួនជាមូលដ្ឋាន

**ក/ ចំពោះសិស្ស**

- មុនពេលសិក្សា គប្បីអានមេរៀន ឬអត្ថបទដែលសាស្ត្រាចារ្យត្រូវបង្រៀនជាមុន ដើម្បីក្តាប់បានគម្រោង និងខ្លឹមសារមេរៀនថ្មី រៀបចំការត្រិះរិះពិចារណាក្នុងផ្លូវចិត្តពេលស្តាប់សាស្ត្រាចារ្យពន្យល់ មានភាពម្ចាស់ការ និងចេះទាញអត្ថប្រយោជន៍ពីសំដីសាស្ត្រាចារ្យ។

-ក្នុងពេលអានអត្ថបទក្នុងសៀវភៅសិក្សា ត្រូវសកម្មក្នុងការគិត បណ្តុះគំនិតចងចាំឱ្យបានល្អផ្សារភ្ជាប់ចំណេះដឹងក្នុងសៀវភៅសិក្សាទៅនឹងចំណេះដឹង ដែលបានរៀនរួចមកហើយ ផ្សារភ្ជាប់សច្ចភាពក្នុងការពង្រឹងចំណេះដឹង។

-ប្រើប្រាស់ទ្រឹស្តីដែលបានរៀនរួចមកហើយ ទៅក្នុងការប្រតិបត្តិក្នុងដំណោះស្រាយលំហាត់។ សំណួរក្នុងសៀវភៅសិក្សា ដើម្បីស្វ័យត្រួតពិនិត្យ និងព្រងឹងចំណេះដឹងរបស់ខ្លួន។

**ខ/ ចំពោះសាស្ត្រាចារ្យ**

-ធ្វើឱ្យសិស្សមានទម្លាប់ក្នុងអំណានសៀវភៅសិក្សា និងក្នុងបម្រើបម្រាស់វចនានុក្រម។

-មុនពេលបង្រៀន ត្រូវស្រាវជ្រាវឯកសារឱ្យបានស្របគ្នាទៅនឹងឯកសារដែលសិស្សកំពុងអាន ឬកំពុងឈ្វេងយល់ហើយត្រូវរកឱ្យឃើញនូវផ្នែកណាមួយនៃមេរៀន ដែលសិស្សពិបាកយល់ដើម្បីលើកយកមកបកស្រាយពន្យល់បំភ្លឺឱ្យឃើញជាតុពិតជាក់ស្តែង ។ ត្រូវលើកកម្ពស់ និងបើកទូលាយចំពោះសំណួរចម្ងល់របស់សិស្ស។

-ដាក់លំហាត់ ឬសំណួរឱ្យសិស្សធ្វើនៅផ្ទះ។

## ៣.៤.៤ វិធីអព្ភន្តរញ្ញាណ( អព្ភន្តរញ្ញាណវិធី )

## គ. សញ្ញាណទូទៅ

ការបង្រៀនតាមអព្ភន្តរញាណវិធីចែកចេញជា យុទ្ធវិធីសង្កេត និង យុទ្ធវិធីអធិប្បាយ ដោយប្រើប្រាស់អព្ភន្តរញាណ។ យុទ្ធវិធីទាំងពីរនេះផ្សារភ្ជាប់គ្នាជិតស្និទ្ធ។ វិធីនេះត្រូវបានសាស្ត្រាចារ្យយកមកប្រើប្រាស់នៅក្នុងពេលសាស្ត្រាចារ្យត្រូវធ្វើអត្ថាធិប្បាយពីវត្ថុឬបាតុភូតណាមួយដោយប្រើអព្ភន្តរញាណ ដើម្បីឱ្យសិស្សអាចដំណើរការទាញសេចក្ដីសន្និដ្ឋានបានតាមរយៈវិទ្យាសាស្ត្រ ។

### ក/ យុទ្ធវិធីសង្កេត

ការសង្កេត គឺជាវិ ធីមួយ ឬជារូ បភាពមួយ នៃការ ទទួលយល់ជ្រួ តជ្រាប ចំណេះ ដឹងយ៉ាង សកម្ម។ វិធីនេះត្រូវបានសាស្ត្រាចារ្យយកមកប្រើប្រាស់ យ៉ាងទូលំទូលាយ នៅក្នុងលំនាំនៃការបង្រៀន ជាពិសេសនៅក្នុងលំនាំនៃការបង្រៀន មុខវិជ្ជាវិទ្យាសាស្ត្រធម្មជាតិ សំដៅជួយសិស្សឱ្យរកឃើញសញ្ញាណ និងទាញបានសេចក្ដីសន្និដ្ឋានក្នុង មេរៀន។ ក្នុងការ អនុវត្តវិធីនេះ បង្ហាញឱ្យឃើញថាការ ធ្វើសេចក្ដីសន្និដ្ឋាននេះ ត្រូវបានសិស្សអនុវត្តនៅក្រោមការដឹកនាំផ្ទាល់របស់សាស្ត្រាចារ្យ ឬក៏សិស្សត្រូវអនុវត្តដោយភាពម្ចាស់ការ ។ ឈរលើមូលដ្ឋាននៃមធ្យោបាយក្របខ័ណ្ឌ លក្ខណៈពិសេស និងកម្រិតសង្កេតរបស់វិធីនេះគេអាចបែងចែកវិធីសង្កេតផ្សេងគ្នាដូចតទៅ ៖

-ការសង្កេតផ្ទាល់ និងការសង្កេតជាប្រយោង ទៅលើវត្ថុ បាតុភូត ឬហេតុការណ៍ ។

-ការសង្កេតតាមផ្នែកនៃ វត្ថុ បាតុភូត ឬការសង្កេតលើផ្នែកទាំងមូលរបស់វា ។

-ការសង្កេតតាមដំណាក់កាល និងការក្នុងរយៈពេលយូរអង្វែង ។

-ការសង្កេតដោយការរៀបចំ និងការតាមលក្ខណៈធម្មជាតិ ។

-ការសង្កេតពីជំហានដំបូង និងការតាមបែបត្រួតពិនិត្យ ។

-ការសង្កេតទៅលើគុណភាព និងការសង្កេតទៅលើបរិមាណ ។

ការសង្កេតត្រូវបានធ្វើនៅពេលៈ

-សាស្ត្រាចារ្យ បកស្រាយពន្យល់មេរៀនថ្មី។

-ក្នុងលំនាំនៃការពិសោធ ពលកម្ម លំនាំនៃការសិក្សាឡើងវិញ និងនៅក្នុងការពង្រឹងចំណេះដឹង។

ការសង្កេតទៅវត្ថុ ឬបាតុភូត ត្រូវធ្វើឡើងនៅពេលដែលវត្ថុ ឬបាតភូតនេះធ្វើចលនា ហើយឆ្លងកាត់តាមរយៈនេះ សិស្សអាចទទួលយល់ដឹងបានពីក្រឹត្យក្រមនៃចលនារបស់វា ។

ក្នុងពេលសង្កេតសាស្ត្រាចារ្យត្រូវយកចិត្តទុកដាក់ដូចតទៅៈ

-ត្រូវកំណត់គោលដៅ សំណូមពរ ភារកិច្ច និងដឹកនាំការសង្កេតនេះ ឱ្យបានច្បាស់លាស់ត្រឹមត្រូវ។

-ឱ្យសិស្សសង្កេតដោយខ្លួនឯង កត់ត្រានូវប្រការដែលបានសង្កេត រួចឈរលើមូលដ្ឋាននេះណែនាំសិស្ស ឱ្យទាញបាននូវសេចក្ដីសន្និដ្ឋានដែលមានលក្ខណៈរួម។

-ទីបំផុត ណែនាំសិស្សឱ្យសរសេរ និងបូកសរុបពីលទ្ធផលនៃការសង្កេត។

ជាការពិតណាស់ អាស្រ័យដោយសំណូមពរក្នុងការបង្រៀនរបស់សាស្ត្រាចារ្យ និងការសិក្សារបស់សិស្ស លំនាំនៃការសង្កេតនឹងត្រូវបានកំណត់ជាមួយក្របខ័ណ្ឌ និងកម្រិតដែលជាប់ទាក់ទងគ្នាតាមករណីដែលត្រូវលើកមកសិក្សា។

### ខ/ វិធីអធិប្បាយដោយប្រើប្រាស់អព្ភន្តរញ្ញាណ

វិធីអធិប្បាយដោយប្រើប្រាស់អព្ភន្តរញ្ញាណ ទាមទារឱ្យសិស្សប្រើប្រាស់គ្រប់មធ្យោបាយអព្ភន្តរ-

ញ្ញាណទាំងអស់គឺ នៅមុនពេល ក្នុងពេល និងក្រោយពេលសិស្សត្រូវសិក្សាមេរៀនថ្មី។

វិធីនេះ ក៏ត្រូវបានយកមកប្រើប្រាស់ផងដែរនៅក្នុងលំនាំនៃការសិក្សាឡើងវិញ និងក្នុងការពង្រឹង ឬការ ត្រួតពិនិត្យទៅលើចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស។នៅក្នុងការអនុវត្តវិធីនេះ ក្នុងការបង្រៀនរបស់សាស្ត្រាចារ្យ និងការសិក្សារបស់សិស្ស តម្រូវឱ្យសាស្ត្រាចារ្យ និងសិស្ស ប្រើប្រាស់មធ្យោបាយអព្ភន្តរញ្ញាណ ជាច្រើនផ្សេងៗគ្នា។ តាមក្រឹត្យក្រមគរុកោសល្យរបស់វិធីនេះ សាស្ត្រាចារ្យត្រូវធ្វើអធិប្បាយទៅលើសម្ភារៈពិតប្រាកដដូចជា រូបតំណាង រូបភាពរបស់វត្ថុ ឬបាតុភូតណាមួយនៅចំពោះមុខសិស្ស។

**-វត្ថុពិត**ដូចជា សត្វ-រុក្ខជាតិ ដែលរស់នៅក្នុងមជ្ឈមដ្ឋានរបស់វា ជាតិរ៉ែ និងបម្រើបម្រាស់ឧបករណ៍ ឬបាតុភូតគីមីជាដើមអាចជួយសិស្សឱ្យមានភាពជិតស្និទ្ធទៅនឹងជីវភាពរស់នៅទៅនឹងធម្មជាតិងាយស្រួលក្នុងការបង្កើតឱ្យសិស្ស មានចំណាប់អារម្មណ៍ដ៏ជ្រាលជ្រៅហើយជក់ចិត្តក្នុងការសិក្សាស្រាវជ្រាវផង។

**-វត្ថុជាតំណាង**ដូចជា ផែនទី គំនូរបំព្រួញ ក្រាភិច តារាងសុទ្ធតែអាចជួយសិស្សឱ្យមើលឃើញ និងយល់ដឹងបានដោយប្រើអព្ភន្តរញ្ញាណ ទៅលើវត្ថុ ឬបាតុភូត ដែលត្រូវបានក្លាយទៅជា រូបតំណាងនៅក្រោមរូបភាពនៃទូទៅកម្មដ៏ងាយស្រួល។ ចំពោះវត្ថុជាតំណាងមួយចំនួនទៀត ក៏ចាំបាច់ណាស់ដែរនៅក្នុងការបណ្តុះសញ្ញាណនៅក្នុងលំនាំនៃការបង្រៀន ដើម្បីឱ្យកម្រិតយល់ដឹងរបស់សិស្សមានភាពរឹងមាំច្បាស់លាស់ដូចជាផែនទីសេដ្ឋកិច្ច ផែនទីគមនាគមន៍ ផែនទីរូប គំនូរបំព្រួញ ឬមាត្រដ្ឋានផលិតកម្មនៅ ក្នុង រោងចក្រ គំនូរបំព្រួញនៃរចនាសម្ព័ន្ធរបស់បេះដូងមនុស្ស តារាងប្រៀបធៀប លក្ខណៈនៃអាស៊ីត និងអំបិលជាដើម។

**-ចំពោះវត្ថុ** ជារូបភាពដូចជាផ្ទាំងគំនូរ រូបសូន រូបចម្លាក់ គំនូរ ហ្វីល ទូរទស្សន៍ ខ្សែភាពយន្តដែលជាជំនួយឱ្យដល់វត្ថុ ឬបាតុភូតដែលពិបាកនឹងរកឃើញដោយផ្ទាល់ និងពិបាកមើលឱ្យឃើញ សុទ្ធតែមានអត្ថប្រយោជន៍ ដល់ការសិក្សារបស់សិស្ស។ វត្ថុ និងបាតុភូតទាំងនោះ មានរចនាសម្ព័ន្ធដី ថ្ម សមុទ្រ ចរន្តនៃសរសៃប្រសាទ ឬសរសៃឈាមក្នុងខ្លួនមនុស្ស សត្វក្នុងសម័យបុរាណ និងសត្វដែលពិបាក រកបានជាដើម។

## ខ. របៀបអនុវត្តទូទៅ

ក.សាស្ត្រាចារ្យ គប្បីជ្រើសរើសមធ្យោបាយប្រើប្រាស់អព្ភន្តរញ្ញាណ ដែលបម្រើឱ្យគោលដៅ និងភារកិច្ច របស់មេរៀន។ ត្រូវមើលឃើញក្នុងករណីណាដែលត្រូវប្រើវត្ថុពិត វត្ថុជារូបសំណាក ឬវត្ថុជារូបភាព ក្នុងករណីណា ដែលត្រូវប្រើចម្រុះ ក្នុងករណីណាដែលត្រូវប្រើប្រាស់ វត្ថុអស់ទាំងនេះ នៅក្នុងសភាពស្ងប់ស្ងាត់មិនប៉ះ ពាល់វាបាន ឬក៏ក្នុងករណីណាមួយទៀតនោះ ត្រូវប្រើប្រាស់ វត្ថុអស់ទាំងនោះ នៅក្នុងសភាពប៉ះពាល់វា។ សាស្ត្រា ចារ្យគប្បីរៀបចំសម្ភារៈអស់ទាំងនោះឱ្យបានគ្រប់គ្រាន់ តាមបរិមាណរបស់វាហើយត្រួតពិនិត្យឡើងវិញពីស្ថាន ភាពរបស់វាតាមលំដាប់លំដោយ ហើយជាពិសេស គឺនៅក្នុងការធ្វើពិសោធឱ្យឃើញជាក់ស្តែង។

ខ. បកស្រាយពន្យល់តាមគោលដៅរបស់មេរៀន ដោយណែនាំសិស្សឱ្យប្រើប្រាស់អព្ភន្តរញ្ញាណ តាមការកំណត់ក្នុងសំណួមពរ និងខ្លឹមសារនៃមេរៀន ពោលគឺសាស្ត្រាចារ្យ ត្រូវប្រើប្រាស់ឱ្យអស់ សមត្ថភាព និងបំណិនប្រសប់ដែលខ្លួនមាន។ ក្នុងការពិនិត្យសង្កេតសាស្ត្រាចារ្យ ត្រូវទាញស្មារតីប្រុង ប្រយ័ត្នរបស់សិស្សឱ្យយកចិត្តទុកដាក់តាមដានបំណកស្រាយពន្យល់ និងពិនិត្យសង្កេតទៅលើវត្ថុ ឬបាតុភូត ឱ្យ

បានហ្មត់ចត់។

**គ.** ធានាឱ្យសិស្សទាំងអស់ពិនិត្យសង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ ទៅលើវត្ថុ ឬបាតុភូតដែលត្រូវលើកមកសិក្សានៅចំពោះមុខសិស្ស។ ការពិនិត្យសង្កេត ត្រូវធ្វើតាមក្រុម ឬដោយសិស្សម្នាក់ៗហើយ ឱ្យសិស្សយកចិត្តទុកដាក់ដល់ក្រឹត្យក្រមរបស់ឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ដូចជា ច្បាប់ផ្ទុយនិង ច្បាប់ស្រប រវាងវត្ថុនិងមូលដ្ឋានក្រឹត្យក្រមបរិមាណ របស់ប្រត្យក្សារម្មណ៍ដែលចំណុះឱ្យការស្វែងយល់ទៅលើវត្ថុ ឬបាតុភូត និងការគួបផ្សំរវាងវត្ថុ និងបាតុភូតទាំងនោះទៅតាមអត្ថន័យមួយដ៏ច្បាស់លាស់។

**ឃ.** ធានាបាននូវការអភិវឌ្ឍ ក្នុងការពិនិត្យសង្កេតយ៉ាងរហ័យច្បាស់លាស់ត្រឹមត្រូវ និងមានភាពម្ចាស់ការផង។ ការពិនិត្យសង្កេត អាចធ្វើឡើងទៅលើផ្នែកនីមួយៗ នៃវត្ថុ ឬបាតុភូត ឬទៅលើផ្នែកទាំងមូលតែម្តងក៏បាន។ សាស្ត្រាចារ្យ គប្បីណែនាំសិស្សឱ្យរកឃើញនូវភាពរួម និងភាពដោយឡែករបស់វត្ថុនិងបាតុភូត។ការពិនិត្យសង្កេត ត្រូវធ្វើឡើងទៅលើផ្នែកប្រមូលផ្តុំ ឬធ្វើឡើងដោយលម្អិត ឬក៏ធ្វើឡើងតែផ្នែកណា សំខាន់ៗរបស់វត្ថុ និងបាតុភូតក៏បាន។ ចៀសវាងការពិនិត្យ សង្កេតវែងឆ្ងាយគ្មានគោលដៅ។ សិស្សម្នាក់ៗត្រូវសកម្មក្នុងការវិភាគ ការប្រៀបធៀប ការគួបផ្សំ ទូទៅកម្មហើយចាំបាច់ត្រូវទាញជាសេចក្តី សន្និដ្ឋានបានដោយខ្លួនឯង។

**ង.** ធានាបាននូវការចេះគួបផ្សំវាចារ ក្នុងការនិយាយរៀបរាប់ និងការធ្វើអត្ថាធិប្បាយ ដោយប្រើប្រាស់គ្រប់មធ្យោបាយអព្ភន្តរញ្ញាណៈ

+ **រូបភាពនៃការគួបផ្សំទី១៖** សាស្ត្រាចារ្យប្រើប្រាស់វាចារ ក្នុងការដឹកនាំសិស្ស ឱ្យពិនិត្យសង្កេតវត្ថុ ឬបាតុភូតដោយខ្លួនឯង គឺតាំងពីកម្មវ ត្ថុនៃការពិនិត្យស ង្កេត ក្នុងលំនាំនៃការពិនិត្យ សង្កេត ដឹកនាំសិស្ស ឱ្យទាញបាន នូវលក្ខណៈ និងចំណងទាក់ទងគ្នាដោយផ្ទាល់រវាងវត្ថុ និងបាតុភូតទាំងនោះ។

+ **រូបភាពនៃការគួបផ្សំទី២៖** ឈរលើមូលដ្ឋាននៃការពិនិត្យ សង្កេតតាមកម្មវត្ថុ និងមូលដ្ឋាននៃចំណេះដឹងដែលសិស្សទទួលបាន សាស្ត្រាចារ្យ ត្រូវជំរុញសិស្សឱ្យចេះគិតត្រិះរិះពិចារណា ដើម្បីយល់ជ្រួតជ្រាប ច្បាស់លាស់ និងលើកឡើងនូវចំណងទាក់ទងគ្នារវាងវត្ថុ និងបាតុភូតដែលត្រូវលើកមកសិក្សា។

+ **រូបភាពនៃការគួបផ្សំទី៣៖** តាមរយៈវាចាររបស់សាស្ត្រាចារ្យ សិស្សទទួលយល់ជ្រួតជ្រាបចំណេះដឹងក្នុងកម្មវត្ថុសិក្សាខាងលក្ខណៈនិងចំណងទាក់ទងដោយផ្ទាល់របស់វត្ថុនិងបាតុភូត។ មិនតែប៉ុណ្ណោះសោត សិស្សអាចប្រើប្រាស់គ្រប់មធ្យោបាយអព្ភន្តរញ្ញាណ ដើម្បីធានាបានដល់ការធ្វើរូបីយកម្មទៅលើវាចាររបស់សាស្ត្រាចារ្យក្នុងបំណកស្រាយពន្យល់។

• **រូបភាពនៃការគួបផ្សំទី៤៖** រូបភាពនេះ ផ្តើមចេញពីការពិនិត្យសង្កេតរបស់សិស្សទៅលើវត្ថុ និងបាតុភូត ដែលលើកមកសិក្សា។ សាស្ត្រាចារ្យ ត្រូវផ្សព្វផ្សាយពីចំណងទាក់ទងគ្នារវាងវត្ថុ និងបាតុភូតដែល សិស្សមិនអាចប៉ះពាល់ដោយផ្ទាល់បាន ឬក៏មិនអាចទាញបានជាសេចក្តីសន្និដ្ឋាន និងទូទៅកម្មទៅលើកម្មវត្ថុ សិក្សានោះបាន។ ការពិសោធន៍បានស្រាយបំភ្លឺថារូបភាពនៃការគួបផ្សំទី១ និងទី២ទទួលបាននូវលទ្ធ ផលល្អបំផុត។

**ច.**ប្រើប្រាស់ភាពយន្តនិងវីដេអូ

ភាពយន្តជួយសិស្សឱ្យ៖

+ មើលឃើញលំនាំ នៃកំណើត និងការ អភិវឌ្ឍរ បស់វត្ថុ និងបាតុ ភូតដោយសភាពរបស់រីកដូចជាបាតុ ភូត នៃការដុះពន្លករបស់គ្រាប់រុក្ខជាតិ និងអណ្តូយ៉ាងល្អិត ដែលរួមផ្សំគ្នាបានជាខ្លួនប្រាណរបស់សត្វ។

+ មើលឃើញច្បាស់ចំពោះលំនាំជាក់ស្តែង ដែលកើតឡើងឆាប់រហ័ស ឬយឺត និងភាពស្រស់បំព្រងរបស់ប្រតិកម្មគីមី។

+មើលឃើញវត្ថុ និងបាតុ ភូតខ្លះ ដែលមិនអាចពិនិត្យ សង្កេត បានដោយផ្ទាល់ នៅក្នុ ងលក្ខខណ្ឌ ធម្មតា ដូចជាលំនាំអភិវឌ្ឍរបស់កូននៅក្នុងសុក និងកំណើតនៃផ្សូងថ្មជាដើម។

+ មើលឃើញបាតុភូតសង្គម សកម្មភាពផលិតកម្ម សមិទ្ធិផលវិទ្យាសាស្ត្រ បច្ចេកទេសដែលប្រកបដោយភាពរស់រវើក។ ភាពងាយធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុងការស៊ើជម្រៅ ជំរុញសិស្សឱ្យ មើលឃើញអត្ថ ប្រយោជន៍នៃការសិក្សា ជួយសិស្សឱ្យក្តាប់បាននូវចំណេះដឹងថ្មី ពង្រឹងពង្រីក និងបើកទូលាយបានទៅលើ ចំណេះដឹង ដែលសិស្សមានរួចមកហើយ។ នៅក្នុងការប្រតិបត្តិ នៃការសិក្សាភាពយន្តអាចត្រូវបានយកមក ប្រើប្រាស់មុនពេលចាប់បង្រៀនមេរៀនថ្មី ដើម្បីរៀបចំ និងទាក់ទាញទឹកចិត្តសិស្សឱ្យមានចំណាប់ចំណូលចិត្ត ក្នុងការសិក្សា។ ភាពយន្តអាចត្រូវបានយកមកប្រើប្រាស់ផងដែរ ក្នុងពេលបង្រៀន ដើម្បីបកស្រាយ និងធ្វើអត្ថា ធិប្បាយ តាម រូបភាព ឬក៏ប្រើប្រាស់នៅក្រោយ ពេលបកស្រាយ មេរៀនថ្មីក៏បាន គឺក្នុងន័យពង្រឹងចំណេះដឹង ដែលទើប នឹងរៀនរួចមកហើយ។ បម្រើបម្រាស់ភាពយន្តនេះ គប្បីធ្វើឡើងទៅតាមសំណូមពរ និងខ្លឹមសារ ជាក់ស្តែង របស់មេរៀន។ ដើម្បីទទួលបានលទ្ធផលល្អពីការបង្រៀន នៅពេលប្រើប្រាស់ខ្សែភាពយន្ត សាស្ត្រា ចារ្យ គប្បីយកចិត្តទុកដាក់ដល់សំណូមពរខ្លះដូចតទៅៈ

+ ជ្រើសរើសយកខ្សែភាពយន្ត ដែលបម្រើឱ្យសំណូមពររបស់មេរៀន និយាយដោយឡែក និងម្យ៉ាងទៀត បម្រើឱ្យខ្លឹមសារនៃមេរៀនទាំងមូល។ និយាយរួម ភាពយន្តបម្រើឱ្យថែមទៀត ដល់កម្រិតយល់ដឹង និងវ័យសិក្សារបស់សិស្ស។

+ត្រិះរិះពិចារណា ឱ្យបានហ្មត់ចត់ពីរបៀបប្រើប្រាស់ខ្សែភាពយន្ត ដឹកនាំ សិស្សឱ្យតាមដាន មេរៀន ឬសំណួរ ដើម្បីត្រួតពិនិត្យការយល់ដឹងរបស់សិស្ស ឆ្លងកាត់តាមរយៈខ្សែភាពយន្តនោះ។

**វីដេអូ** ត្រូវបានប្រើប្រាស់នៅក្នុងលំនាំនៃការបង្រៀន ហើយដែលត្រូវអនុវត្តឱ្យបាននូវតួនាទីមួយ គឺជួយសិស្សឱ្យបណ្តុះបាននូវរូបតំណាង និងសញ្ញាណ។ ឈរលើមូលដ្ឋាន នៃការពិនិត្យសង្កេត ការ ពង្រឹងពង្រីកបំណកស្រាយពន្យល់ដោយរូបភាព និងទ្រឹស្តី តាមទូរទស្សន៍ធ្វើឱ្យសិស្សក្តាប់បានចំណេះដឹងថ្មី ដែលផ្សារភ្ជាប់ទៅនឹងបញ្ហាដែលកំពុងរៀន ឬមានអត្ថប្រយោជន៍ដល់ដំណើរការ ក្នុងការសិក្សាសារឡើងវិញ ទៅលើមេរៀនដែលសិស្សរៀនរួចមកហើយ។ ខ្សែភាពយន្តតារាង និងថាសម៉ាស៊ីន សុទ្ធតែត្រូវបានយកមកប្រើប្រាស់តាមមធ្យោបាយអព្ភន្តរញ្ញាណទាំងអស់។

**ឆ.**ភាសាសម្បូរទៅដោយរូបារម្មណ៍ៈ ភាសាសម្បូរទៅដោយរូបារម្មណ៍របស់សាស្ត្រាចារ្យ ត្រូវបាន យកមកប្រើប្រាស់ក្នុងពេលពន្យល់មេរៀនថ្មីហើយជះឥទ្ធិពលយ៉ាងខ្លាំងក្លាដល់សតិអារម្មណ៍ និងសញ្ចេតនា របស់សិស្ស ហើយម្យ៉ាងទៀត ងាយឱ្យសិស្សបណ្តុះបាននូវរូបតំណាងមួយជាក់ស្តែងច្បាស់លាស់។

## គ. ចំណុចខ្លាំង និងចំណុចខ្សោយ

ទូទៅនៅក្នុងបម្រើបម្រាស់មធ្យោបាយអព្ភន្តរញ្ញាណ

**ក/ ចំណុចខ្លាំង** គ្រប់មធ្យោបាយអព្ភន្តរញ្ញាណទាំងអស់ បើសាស្ត្រចារ្យអនុវត្តបានយ៉ាងប៉ិនប្រសប់ នោះចំណុចខ្លាំងក៏កើតមានឡើងដែរគឺៈ

+ ប្រមូលផ្តុំបាននូវការចូលរួមពីគ្រប់វិញ្ញាណទាំងអស់ មានការផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ រវាង

ប្រព័ន្ធសញ្ញាការទាំងពីរ បណ្តុះបណ្តាលបាននូវលក្ខខណ្ឌងាយស្រួល ឱ្យសិស្សយល់ចងចាំបានយូរមិនមានការនឿយហត់ហើយបង្កបាននូវចំណងទាក់ទងគ្នារវាងប្រព័ន្ធប្រសាទ ទាំងឡាយបានយ៉ាងបង្គួរ។

+ ធ្វើឱ្យសិស្សអភិវឌ្ឍបាននូវសមត្ថភាពខាងស្មារតី ប្រុងប្រយ័ត្ន ក្នុងការពិនិត្យ សង្កេតមានចំណង់ចំណូលចិត្តក្នុងការចង់យល់ ចង់ដឹង និងចង់ឃើញច្បាស់តាមលក្ខណៈវិទ្យាសាស្ត្រ។

+ បណ្តុះបណ្តាលសិស្ស ឱ្យមានលក្ខខណ្ឌងាយស្រួល ក្នុងការផ្សារភ្ជាប់ការសិក្សាទៅនឹង ជីវភាពរស់នៅឬផលិតកម្ម។

**ខ/ ចំណុចខ្សោយ** បើអនុវត្តវិធីបង្រៀនដោយប្រើប្រាស់មធ្យោបាយអព្ពន្តរញ្ញាណនេះមិនបានត្រឹមត្រូវ តាមគោលដៅ ឬតឹងរឹងចំពោះសិស្សខ្លាំ ងពេក នាំឱ្យសិ ស្សបាត់ ស្មារ តីប្រុ ងប្រយ័ត្ន ក្នុ ងការក្តាប់បាននូវបញ្ហាសំខាន់ៗ ជាមូលដ្ឋាន។

## ឃ. សំណូមពរ

សំណូមពរមួយចំនួនជាមូលដ្ឋាន ចំពោះ វិធីបង្រៀនដោយប្រើប្រាស់ មធ្យោបាយ អព្ពន្តរ ញ្ញាណ ក្នុងបម្រើ បម្រាស់វិធីបង្រៀន ដោយប្រើប្រាស់មធ្យោបាយអព្ពន្តរញ្ញាណ សាស្ត្រាចារ្យម្នាក់ៗ គប្បីក្តាប់បាននូវសំណូមពរមួយចំនួនដូចតទៅៈ

+ ជួយសិស្សឱ្យក្តាប់បាន និងប្រើប្រាស់បានយ៉ាងប៉ិនប្រសប់ចំពោះចំណេះដឹងជាមូលដ្ឋាន ហើយប្រែក្លាយចំណេះដឹងនោះឱ្យទៅជាមធ្យោបាយ ក្នុងទំនួលយល់ជ្រួតជ្រាបចំណេះដឹងថ្មី។

+ ត្រូវបែងចែកជំពូកមេរៀនឱ្យបានច្បាស់លាស់ ក្នុងការបង្រៀនហើយទុកសិស្សឱ្យមានសេរីភាពក្នុងការឆ្លើយយ៉ាងសកម្ម។

+ ត្រូវបញ្ចេញឥទ្ធិពលយ៉ាងសកម្ម ក្នុងការណែនាំ និងជំរុញសិស្សឱ្យយល់ជ្រួតជ្រាប ចំណេះដឹង ថ្មីហើយធ្វើឱ្យសិស្សមានការអភិវឌ្ឍក្នុងសកម្មភាពម្ចាស់ការ ច្នៃប្រឌិតក្នុងការឆ្លើយសំណួរប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។

+ គប្បីធានាបាននូវសំណូមពរ ខាងសិល្បវិជ្ជាកម្រិតខ្ពស់ សន្តិសុខក្នុងពលកម្ម អនាម័យ បច្ចេកទេសនិងសេដ្ឋកិច្ច។

## ៣.៤.៥. វិធីធ្វើពិសោធន៍

## ក. អត្ថន័យ

ក. វិធីធ្វើពិសោធន៍ ត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងលំនាំនៃការបង្រៀនខាងមុខវិជ្ជាឯកទេសរូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា... ។

វិធីនេះមានគោលដៅដូចតទៅៈ

+ជួយសិស្សឱ្យក្តាប់បាននូវចំណេះដឹងរឹងមាំ និងមានជំនឿស៊ប់ទៅលើលក្ខណៈដ៏ត្រឹមត្រូវនៃចំណេះដឹងវិទ្យាសាស្ត្រ។

+បង្កបាននូវចំណង់ចំណូលចិត្តរបស់សិស្សក្នុងការសិក្សា និងធ្វើឱ្យសិស្សមានស្មារតីចង់ឃើញចង់ដឹង និងចង់យល់តាមលក្ខណៈវិទ្យាសាស្ត្រ។

+ជួយសិស្សឱ្យក្តាប់បាននូវបំណិនប្រសប់ខ្លះ ក្នុងការពិនិត្យសង្កេត និងជួយសិស្សឱ្យមានសមត្ថភាពក្នុងការបម្រើបម្រាស់សម្ភារៈបរិក្ខារ ឬឧបករណ៍សម្រាប់ធ្វើពិសោធន៍។

+បំប៉នឱ្យដល់សិស្សនូវសមត្ថភាពក្នុងពលកម្ម និងផលិតកម្មខាងវិស័យវិទ្យាសាស្ត្រ និងបច្ចេក

ទោសរបស់ពលករដូចជា ទម្លាប់ក្នុងការថែរក្សាឧបករណ៍ ទម្លាប់ធ្វើការមានសណ្ដាប់ធ្នាប់ល្អ លក្ខណៈ ចាត់តាំងក្នុងបច្ចេកទេស និងអាកប្បកិរិយាត្រឹមត្រូវក្នុងសកម្មភាពពិសោធន៍។ ទោះណាជាវិធីនេះ មាន កំណត់ព្រំដែនក៏ដោយ បើសាស្ត្រាចារ្យមិនបានណែនាំសិស្សឱ្យប្រុងប្រយ័ត្ន យកចិត្តទុកដាក់ឱ្យបានហ្មត់ ចត់ទេនោះ វិធីនេះនឹងងាយបង្កឱ្យមានគ្រោះថ្នាក់នៅក្នុងដំណើរការពិសោធ ហើយម្យ៉ាងទៀត វាក៏មិន អាចផ្ដល់ចំណេះដឹងឱ្យដល់សិស្សតាមលក្ខណៈប្រព័ន្ធកម្មផងដែរ។

ខ. នៅក្នុងបន្ទប់ពិសោធ ន៍សិស្សអាចប្រើប្រាស់គ្រឿងម៉ាស៊ីនមួយចំនួនបានដោយខ្លួនឯង ដែលអាចបង្កចេញបានជាបាតុភូត និងលំនាំដែលត្រូវសិក្សាស្រាវជ្រាវ ធ្វើឱ្យវត្ថុ និងបាតុភូតដែលត្រូវធ្វើ ការពិសោធន៍បង្កើតចេញបានជាបន្លាស់ប្ដូរផ្សេងៗបម្រើបម្រាស់គ្រឿងម៉ាស៊ីនពិសេស ដើម្បីងាយពិនិត្យសង្កេតនិងធ្វើវិភាគហើយទីបំផុតឈរលើមូលដ្ឋាននេះសិស្សអាចទាញបានសេចក្ដីសន្និដ្ឋានជាចាំបាច់។

គ. វិធីធ្វើពិសោធន៍ មានចំណងទាក់ទងគ្នាដោយផ្ទាល់ ទៅនឹងវិធីផ្សេងទៀត ដូចជាការពិនិត្យសង្កេត ការសម្ដែងចេញនូវបាតុភូត ការហ្វឹកហ្វឺន និងដំណោះស្រាយបញ្ហាជាដើម។ វិធីធ្វើពិសោធន៍នេះអមដោយសេចក្ដីអធិប្បាយទៅតាមលំនាំ ឬសកម្មភាពពិសោធន៍ ដើម្បីស្រាយបំភ្លឺឱ្យឃើញច្បាស់។ យកល្អសាស្ត្រាចារ្យត្រូវបង្គាប់សិស្សឱ្យសិ ក្សាស្រាវ ជ្រាវឯកសារឬទ្រឹស្ដីដែលទាក់ទងនឹងការធ្វើពិសោធន៍ នេះ ជាមុន។ ប៉ុន្តែ ទោះជានៅក្នុងករណីណាក៏ដោយ ពេលអនុវត្តវិធីនេះ គឺសំដៅរកចម្លើយច្បាស់លាស់ត្រឹមត្រូវ ក្នុងបំណកស្រាយពន្យល់ទៅលើបញ្ហាណានីមួយនោះតាមលក្ខណៈវិទ្យាសាស្ត្រ។

## ខ. ការរៀបចំធ្វើពិសោធន៍

ក/ គេបែងចែកជាការពិសោធន៍

- ការពិសោធន៍ជាសាលក
- ការពិសោធន៍ដោយបុគ្គល

•ការពិសោធន៍ជាសកល ត្រូវបានប្រព្រឹត្តឡើងនៅក្រោយពេលដែលសាស្ត្រាចារ្យ បានធ្វើអត្ថាធិប្បាយយ៉ាង ខ្លីពីទ្រឹស្ដីណាមួយដែលទាក់ទងនឹងការពិសោធន៍។ ការធ្វើអត្ថាធិប្បាយនេះ ត្រូវដំណើរការឡើងតាមរយៈ រូបភាពនៃការសន្ទនា ឬបំណកស្រាយពន្យល់ ឬក៏ដំណោះស្រាយតាមទ្រឹស្ដីទៅលើបញ្ហាណាមួយ។ សមូហ ភាពសិស្សក្នុងថ្នាក់ ត្រូវអនុវត្តសកម្មភាពពិសោធន៍ដោយប្រើសម្ភារៈនិងបរិក្ខាដូចគ្នា ក្រោមការដឹកនាំ របស់សាស្ត្រាចារ្យ។

• ពេលខ្លះគ្រឿងម៉ាស៊ីន ឬសម្ភារៈពិសោធន៍សាស្ត្រាចារ្យអាចឱ្យសិស្សធ្វើការពិសោធនោះតាមក្រុមវិញ។ ក្រុមនីមួយៗ ត្រូវមានសិស្សពី២ទៅ៣នាក់ ហើយមានភារកិច្ចធ្វើឱ្យបានសម្រេច ឬបង្ហើយ សកម្មភាពពិសោធន៍ណាមួយ។បើសិស្សណាម្នាក់មានការពិបាកដើម្បីធ្វើឱ្យបានសម្រេចតាមគោល ដៅនៃសកម្មភាពពិសោធន៍នោះ(ដោយសារមានលក្ខណៈ ស្មុគស្មាញ នៃគ្រឿងម៉ាស៊ី នដែលធ្វើពិសោធ ឬពិបាកក្នុង ការពិនិត្យសង្កេតដើម្បីធ្វើកំណត់ត្រាទៅលើដំណើរការ និងលទ្ធផលនៃការពិសោធន៍នោះ) នោះសាស្ត្រា ចារ្យអាចបង្គាប់ឱ្យសិស្សពូកែជួយសិស្សខ្សោយនោះបាន។សិស្សម្នាក់ៗក្នុងក្រុម ត្រូវ ផ្លាស់វេនគ្នាចែកការងារគ្នា ក្នុងលំនាំនៃការពិសោធន៍នេះ។

•រីឯការពិសោធន៍ដោយបុគ្គលវិញ ត្រូវបានអនុវត្តឡើងនៅពេលដែលសិស្សម្នាក់ៗ ត្រូវធ្វើឱ្យបានសម្រេចសកម្មភាពនៃការពិសោធន៍ផ្សេងៗគ្នា តែក្នុងពេលជាមួយគ្នា ហើយសូម្បីតែសម្ភារៈ និងបរិក្ខារសម្រាប់ធ្វើពិសោធន៍ក៏ផ្សេងៗគ្នាដែរ។តាមធម្មតាសាស្ត្រាចារ្យត្រូវជ្រើសរើសរៀបធ្វើការពិសោធន៍ផ្សេងៗ

ទៅតាមសម្ភារៈបរិក្ខារ និងគ្រឿងម៉ាស៊ីន ដើម្បីឱ្យសកម្មភាពពិសោធន៍សម្រេចបានលទ្ធផលល្អ និយាយរួម និងធ្វើឱ្យមុ ខសញ្ញាពិ សោធន៍របស់សិស្សម្នាក់ ៗ ត្រូវអនុវត្តបាន សម្រេច និយាយដោយឡែក។

**ខ. ពេលអនុវត្តការពិសោធន៍**

• សាស្ត្រាចារ្យត្រូវកំណត់ឱ្យបានច្បាស់លាស់ ពីឯកសារដែលទាក់ទងនឹងការពិសោធន៍ ក្រៅពី នេះ ត្រូ វយកចិត្តទុ កដាក់ ដល់ គោល ដៅ សំណួ មពក្នុ ងការ ពិសោធ សេចក្តី ណែនាំ ខ្លឹ មសារ និងដំណាក់ កាល ក្នុងការ ធ្វើពិសោធន៍ជាមួយនឹងសម្ភារៈបរិក្ខារនិងគ្រឿងម៉ាស៊ីនដែលចាំបាច់ក្នុងការពិសោធ។ត្រូវរំលឹក សិស្សឱ្យ យកចិត្តទុកដាក់ក្នុងលំនាំនៃការពិសោធន៍ដើម្បីធានាបាននូវសន្តិសុខគ្រប់គ្រាន់និងដើម្បីថែរក្សា ការពារឧបករណ៍ និងសន្សំសំចៃជាតិគីមីផង។

• ត្រូវបែងចែកសិស្សជាក្រុម (ប្រសិនបើចាំបាច់)

• សិស្សត្រូវម្ចាស់ការ ក្នុងការអនុវត្តការពិសោធន៍ដូចជាកត់ត្រា គូររូប។ ឯសាស្ត្រាចារ្យវិញត្រូវពិនិត្យ សង្កេត ឬត្រួតពិនិត្យ និងជួយណែនាំសិស្សដែលអនុវត្តខុសឆ្គង ឱ្យបានទាន់ពេលវេលាដោយនិយាយ តិចៗ។សាស្ត្រាចារ្យ គ្រាន់តែកំណត់ឱ្យសិស្សធ្វើរបាយការណ៍ឡើងវិញពីសកម្មភាព និងសេចក្តីសន្និដ្ឋាន ទៅលើការពិសោធ បង្គាប់សិស្សឱ្យប្តូរយោបល់គ្នាហើយទីបំផុតសាស្ត្រាចារ្យ ត្រូវបូកសរុបនិងវាយតម្លៃរួម ទៅលើលទ្ធផលជាក់ស្តែង។ប្រសិនបើការពិសោធមានលក្ខណៈជាការអនុវត្តទៅលើសញ្ញាណ ឬទ្រឹស្តី នីមួយ នោះជាសក្ខីភាពសាស្ត្រាចារ្យត្រូវពិនិត្យសង្កេត កត់ត្រាចុះក្នុងទិនានុលេខន៍ ធ្វើវិភាគទៅលើឯកសារ និង ចំនួនតួលេខចំនួនវិញ្ញាសារបស់សិស្សដែលសម្រេចបានពីការពិសោធរួចវាយតម្លៃឱ្យបានត្រឹមត្រូវផង។

**៣.៤.៦.វិធីហ្វឹកហ្វឺន**

**ក. សញ្ញាណទូទៅ**

ក. ហ្វឹកហ្វឺន គឺការហាត់ទៅហាត់មកឱ្យបានច្រើនដងទៅលើសកម្មភាពដែលបានកំណត់ សំដៅ ធ្វើឱ្យកើតបានជារូបរាងក្នុងការពង្រឹងពង្រីកចំណេះដឹងចំណេះធ្វើ និងបំណិនប្រសប់ដែលចាំបាច់។ តាម ធម្មតាវិធីហ្វឹកហ្វឺននេះ ត្រូវបានអនុវត្តឡើងទៅតាមផែនការរៀបចំត្រឹមត្រូវច្បាស់លាស់។តាមទស្សនៈ ជាមូលដ្ឋាននៃវិធីហ្វឹកហ្វឺននេះ គឺជាការហាត់ឱ្យស្ទាត់ដើម្បីពង្រឹង និងក្តាប់ឱ្យបានច្បាស់ពីចំណាង់ទាក់ទង តាមស្មារតីដែលកើតបានជារូបរាង ហើយបង្កើតបានជាចំណាងទាក់ទងថ្មី ក្នុងស្មារតីរួមចំណាងទាក់ទងថ្មីនេះ ត្រូវបានយល់ជ្រួតជ្រាបគួបផ្សំទៅនឹងចំណេះដឹងដែលមានរួចមកហើយ។ វិធីហ្វឹកហ្វឺនដែលត្រូវបាន សាស្ត្រាចារ្យរៀបចំល្អនឹងជួយសិស្សឱ្យៈ

+ពង្រឹងបាននូវចំណេះដឹង ហាត់ពត់ចំណេះធ្វើ និងបំណិនប្រសប

+ ធ្វើឱ្យសតិបញ្ញាសិស្សអភិវឌ្ឍបានយ៉ាងរឹងមាំ

+ ហាត់ពត់លត់ដំបាននូវចរិតម្ចាស់ការក្នុងការសិក្សា

+ ទម្លាប់ល្អ ក្នុងពលកម្មច្នៃប្រឌិតមានចរិតអំណត់ព្យាយាមអត់ធ្មត់ ហើយឈរលើមូលដ្ឋាន ទាំងនេះសិស្សមានលក្ខខណ្ឌងាយស្រួល ក្នុងចូលរួមការងារពលកម្មជាក់ស្តែង។

ខ.ការហ្វឹកហ្វឺនមានរូបភាពច្រើនយ៉ាង។ រូបភាពទាំងនេះ បម្រើឱ្យលក្ខណៈដោយឡែកតាមមុខវិជ្ជាសិក្សា នីមួយៗ។ *ឧទាហរណ៍ៈ*

- នៅក្នុងមុខវិជ្ជាគណិតវិទ្យាសិស្សត្រូវហ្វឹកហ្វឺនធ្វើលំហាត់ឱ្យ ចេះស្ទាត់

-នៅក្នុងមុខវិជ្ជាគីមីវិទ្យា សិស្សត្រូវហ្វឹកហ្វឺន ថ្លឹងសមីការ ធ្វើលំហាត់ និងហ្វឹកហ្វឺន បច្ចេកទេស

ពិសោធន៍។

- នៅក្នុងវេយ្យាករណ៍ សិស្សត្រូវហ្វឹកហ្វឺន ប្រើប្រាស់គ្រប់វិធានទាំងអស់

- នៅក្នុងអប់រំកាយ សិស្សត្រូវហ្វឹកហ្វឺនធ្វើចលនា

- នៅក្នុងការងារពលកម្ម ឬក្នុងផលិតកម្ម សិស្សត្រូវហ្វឹកហ្វឺនបំណិនប្រសប់ ក្នុងបម្រើបម្រាស់ឧបករណ៍ និងគ្រឿងម៉ាស៊ីន។ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គ្រប់មុខវិជ្ជាសិក្សាទាំងនោះសុទ្ធតែមានចំណេះធ្វើ និងបំណិនប្រសប់ក្នុងការគិតដ៏សមហេតុផល។ ក្នុងរយៈពេលសិក្សា នៅសាលារៀនមធ្យមសិក្សាចំណេះ ទូទៅសិស្សានុសិស្សគប្បីហ្វឹកហ្វឺនក្នុងការពិនិត្យសង្កេតក្នុងជម្រើស និងក្នុងការប្រមូលឯកសារទុក តាមក្រុមជាកំណត់ដូចជា កំណត់ត្រាមេរៀន គំនូរ ការចេះធ្វើវិភាគ និងរកគំនិតឯកភាព ការធ្វើសំយោគ ការប្រៀបធៀប ការធ្វើប្រព័ន្ធកម្មសំរាយបំភ្លឺ និងការទាញសេចក្ដីសន្និដ្ឋាន។ នៅក្នុងករណីអស់ទាំងនេះ សិស្សត្រូវ ប្រើប្រាស់ឱ្យអស់នូវសមត្ថភាពបញ្ញាដែលខ្លួនមាន។ នៅក្នុងលំនាំនៃវិធីហ្វឹកហ្វឺន ប្រការមួយដែលមាន អត្ថន័យដ៏ធំធេងនោះគឺបំប៉នឱ្យសិស្សនូវសមត្ថភាពដែលរីកដុះដាលឥតឈប់ឈរ លើគ្រប់ចំណេះដឹង និងបំណិន ប្រសប់ក្នុងការបម្រើបំរាស់អាល់កូរីត។

## ខ. រូបភាពនៃវិធីហ្វឹកហ្វឺន

សព្វថ្ងៃនេះគេបែងចែករូបភាពនៃវិធីហ្វឹកហ្វឺន ទៅតាមមូលដ្ឋានផ្សេងៗគ្នាជាច្រើនគឺៈ

### ក/ តាមរូបភាពនៃវិធីហ្វឹកហ្វឺនឱ្យស្ទាត់

-នៅក្នុងលំនាំនៃការបង្រៀន សិស្សត្រូវហ្វឹកហ្វឺននិយាយ អាន រាប់ សរសេរ គិតគូរគូរប្លង់ គូរគំនូរបំព្រួញគូរ ក្រាភិច និងគូរផែនទីឱ្យបានស្ទាត់។ ប៉ុន្តែ សរុបសេចក្ដីមក យើងអាចនិយាយដល់វិធីហ្វឹកហ្វឺនឱ្យស្ទាត់ដោយប្រើវិធី ហ្វឹកហ្វឺនតាមរយៈសរសេរ។ វិធីហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការនិយាយ សន្សំសំចៃពេលវេលាជាងវិធីហ្វឹកហ្វឺនឱ្យ ស្ទាត់ ដោយសរសេរតាមធម្មតា វិធីទាំងពីរនេះ ត្រូវបានយកមកប្រើប្រាស់ភ្ជាប់ជាមួយនឹងវិធីផ្សេងៗទៀត។

វិធីហ្វឹកហ្វឺនឱ្យស្ទាត់ ត្រូវបានស្តែងឡើង នៅពេលដែលសិស្សស្វ័យត្រិះរិះ រកឧបករណ៍តាមមេរៀន ប្រុងប្រៀបរៀបចំឧទាហរណ៍មុនដោយខ្លួនឯង បញ្ចេញមតិដោយខ្លួនឯង អានឯកសារដោយខ្លួនឯង។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏មិនអាចទាត់ចោលកំណត់ត្រាសង្កេតដូចជា កំណត់ត្រាទិន្នន័យពីក្នុងមេរៀន គម្រោងមេរៀននិងគំនូរបំព្រួញបានឡើយ។វិធីហ្វឹ កហ្វឺ នស្ទាត់ ដោយ សរសេរខុសផ្សេង គ្នា ពីវិធីហ្វឹ កហ្វឺនឱ្យស្ទាត់ក្នុង ការនិយាយត្រង់ដែលវិធីហ្វឹកហ្វឺនឱ្យស្ទាត់ ដោយសរសេរមានលក្ខណៈស្មុគស្មាញ ហើយត្រូវផ្សារភ្ជាប់គ្នាទៅ តាមលក្ខណៈជារប្រព័ន្ធកម្ម។ វិធីហ្វឹកហ្វឺនឱ្យស្ទាត់ ដោយសរសេរឱ្យគួបផ្សំទៅនឹងបំណកស្រាយពន្យល់ ដោយវាចារបាន។

*ឧទាហរណ៍:* ក្នុងពេលធ្វើលំហាត់ តាមការកំណត់របស់សាស្ត្រាចារ្យ សិស្សម្នាក់ៗសុទ្ធតែអាចធ្វើអត្ថាធិប្បាយ និងបកស្រាយពន្យល់ ទៅតាមចលនានៃការគិតរៀងៗខ្លួនដោយឡែកពីគ្នាដែរ។

គេអាចបែងចែកជាបីកម្រិត ក្នុងការធ្វើឱ្យបានសម្រេចលើគ្រប់រូបភាពនៃវិធីហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការនិយាយ និងវិធីហ្វឹកហ្វឺនឱ្យស្ទាត់ដោយសរសេរ។

**-កម្រិតទី១៖** វិធីហ្វឹកហ្វឺនឱ្យស្ទាត់ ធ្វើឡើងដោយឈរលើមូលដ្ឋាននៃការបង្កើតឡើងវិញនូវមេរៀន ឬចំណុចសំខាន់ៗក្នុងមេរៀនសំដៅពង្រឹងចំណេះដោយមិនឱ្យខាតបង់ពេលវេលា និងកម្លាំងកាយច្រើន។

**-កម្រិតទី២៖** វិធីហ្វឹកហ្វឺនឱ្យស្ទាត់ ធ្វើឡើងសំដៅអនុវត្តចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់

នៅក្នុងលក្ខខណ្ឌថ្មី។ វិធីនេះ ទាមទារឱ្យធ្វើឡើងដោយឈរលើមូលដ្ឋាននៃបម្រើបំរាស់ចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ជាបន្តបន្ទាប់គ្នាពីក្នុងមុខវិជ្ជាសិក្សាមួយទៅក្នុងមុខវិជ្ជាសិក្សាមួយទៀត។

-**កម្រិតទី៣** ៖ វិធីហ្វឹកហ្វឺនឱ្យស្ទាត់តាមលក្ខណៈច្នៃប្រឌិត ទាមទារឱ្យសិស្សប្រើប្រាស់ចំណេះដឹងទាំង អស់ដែលសិស្សមាន ឱ្យសិស្សចេះរៀបចំ និងចេះអនុវត្តចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ ទៅតាម ចលនានៃការគិតដែលផ្សារភ្ជាប់ជាប្រព័ន្ធកម្ម ហើយមានលក្ខណៈឆ្លាស់គ្នាផង។

វិធីហ្វឹកហ្វឺនឱ្យស្ទាត់តាមលក្ខណៈច្នៃប្រឌិត មានអត្ថន័យដ៏ធំធេងដល់ការធ្វើឱ្យអភិវឌ្ឍ នូវចរិតមនុស្ស និងចរិតម្ចាស់ការរបស់សិស្ស។ វិធីនេះជួយសិស្សឱ្យបណ្តុះបណ្តាលបានថែមទៀត នូវគុណសម្បត្តិផ្សេងៗ ទៀត ជាច្រើនខាងផ្នែកបុគ្គលិកលក្ខណៈដូចជា ចរិតធ្មត់ព្យាយាមមនសិការ ដែលជម្នះបានលើភាពលំបាកជាដើម។

នៅសាលារៀនមធ្យមសិក្សាចំណេះទូទៅវិធីនេះជារូបភាពនៃមូលដ្ឋានក្នុងការហ្វឹកហ្វឺនឱ្យស្ទាត់តាម លក្ខណៈច្នៃប្រឌិត។ នៅថ្នាក់បឋមសិក្សា យើងចូលចិត្តប្រើប្រាស់វិធីហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការនិយាយ ហើយចាប់ពីថ្នាក់អនុវិទ្យាល័យឡើងទៅ យើងប្រើប្រាស់វិធីហ្វឹកហ្វឺនឱ្យស្ទាត់ដោយសរសេរ។

ក្រៅពីវិធីហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការនិយាយ និងវិធីហ្វឹកហ្វឺនឱ្យស្ទាត់ដោយសរសេរ នៅមានរូបភាពនៃវិធីហ្វឹកហ្វឺនឱ្យស្ទាត់តាមលក្ខណៈច្នៃប្រឌិតផ្សេងទៀតដូចជា សំណេរដោយសង្ខេប និងសំណេរជារបាយការណ៍ជាដើម។ ហើយក្រៅពី វិធីហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការនិយាយ និងដោយសរសេរសិស្សានុសិស្ស ត្រូវបានហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការងារពលកម្មផលិតទៀតផង។វិធីហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការងារពលកម្មផលិតស្តែងឡើង តាមបីដំណាក់កាល៖

- **ដំណាក់កាលទី១** ៖សាស្ត្រាចារ្យត្រូវលើកឡើងយ៉ាងច្បាស់លាស់ពីគោលដៅសំណូមពរក្នុងការអនុវត្ត ដាក់ស្តែង ទ្រឹស្តីវិទ្យាសាស្ត្រ បច្ចេកទេស ក្នុងការអនុវត្តការរៀបរាប់ពីវិធីអនុវត្តន៍ដោយខ្លួនឯង។ ទន្ទឹមនឹងនេះ ត្រូវទប់ស្កាត់ចំពោះកំហុស ដែលអាចកើតមានឡើងត្រូវគោរពតាមគោលការណ៍ស្វ័យត្រួតពិនិត្យ និងការធានា បានសន្តិសុខ។ ក្រោយមកទើបសាស្ត្រាចារ្យ ធ្វើអត្ថាធិប្បាយពីកង្វះខាតក្នុងការអនុវត្តដោយបំណក ស្រាយ ពន្យល់ឱ្យបានច្បាស់លាស់។
- **ដំណាក់កាលទី២** ៖ សិស្សត្រូវម្ចាស់ការ ក្នុងការអនុវត្តវិធីហ្វឹកហ្វឺនឱ្យស្ទាត់។ ឬឯសាស្ត្រាចារ្យវិញ គ្រាន់តែតាមដានត្រួតពិនិត្យ និងជួយណែនាំសិស្ស ប្រសិនបើសិស្សមិនយល់ច្បាស់ពីបញ្ហាណាមួយនោះ។ សាស្ត្រាចារ្យ ត្រូវណែនាំសិស្សឱ្យដោះស្រាយដោយខ្លួនឯង ហើយក្នុងករណីជាចាំបាច់នោះសាស្ត្រាចារ្យ ត្រូវជួយ បំពេញទៅលើកង្វះខាតឱ្យបានគ្រប់គ្រាន់ និងស៊ីជម្រៅផង។
- ដំណាក់ កាលទី៣ ៖សាស្ត្រាចារ្យត្រូវដឹកនាំសិស្ស ឱ្យវាយតម្លៃដោយខ្លួនឯងរកឱ្យឃើញចំណុចខ្លាំង និងចំណុចខ្សោយ ហើយនៅទីបំផុតសាស្ត្រាចារ្យត្រូវធ្វើការបូកសរុបរួម។

**ខ/ តាមដំណាក់ការរបស់លំនាំនៃការបង្រៀន**

ឈរលើមូលដ្ឋាននៃភារកិច្ច របស់ដំណាក់កាលនីមួយៗ របស់លំនាំនៃការបង្រៀនសាស្ត្រាចារ្យត្រូវកំណត់ឱ្យបាននូវរូបភាពនៃការហ្វឹកហ្វឺន ឱ្យស្ទាត់តាមលក្ខណៈដ៏សមស្របដូចតទៅ៖

- ការហ្វឹកហ្វឺនឱ្យស្ទាត់សំដៅក្តាប់បានចំណេះដឹងថ្មី
- ការហ្វឹកហ្វឺនឱ្យស្ទាត់សំដៅបណ្តុះបណ្តាលនូវចំណេះដឹងនិងបំណិនប្រសប់ថ្មី
- ការហ្វឹកហ្វឺនឱ្យស្ទាត់សំដៅអនុវត្តចំណេះដឹងថ្មី

• ការហ្វឹកហ្វឺនឱ្យស្ទាត់សំដៅពង្រឹងចំណេះដឹង និងសិក្សាសារឡើងវិញ

**គ/ យោងទៅតាម លក្ខណៈ ពិសេស របស់វិធីហ្វឹកហ្វឺនឱ្យស្ទាត់** លំនាំនៃការគិតតែងតែចូលរួមនៅក្នុងលំនាំរបស់វិធីហ្វឹកហ្វឺន។នៅក្នុងលំនាំនៃការបង្រៀន សាស្ត្រាចារ្យអាចបង្គាប់សិស្សឱ្យអនុវត្តន៍ឱ្យបានសម្រេច ចំពោះលំហាត់ដែលទាមទារឱ្យសិស្សប្រមូលផ្តុំ បាននូវចលនានៃការគិតទាំងឡាយគួប ផ្សំនឹងលំនាំនៃការគិតដែលតម្រូវតាមសំណូមពររបស់លំនាំនៃការបង្រៀនជាក់ស្តែង៖

• ពិនិត្យសង្កេតទៅលើវត្ថុ ឬបាតុភូតដែលលើកមកសិក្សា

• ផ្ទុះផ្តងវត្ថុ និងវត្ថុ បាតុភូត និងបាតុភូត ប្រៀបធៀបលក្ខណៈទូទៅ និងលក្ខណៈដោយឡែករបស់វា រួចហើយទើបបង្កើតបានចំណងទាក់ទងរវាងវត្ថុ និងបាតុភូតទាំងឡាយ។ វែកញែកឱ្យច្បាស់ពីលក្ខណៈ សំខាន់ និងរកឱ្យឃើញនូវភាពចាំបាច់របស់វត្ថុ និងបាតុភូតនីមួយៗ។

• កំណត់និមិត្តរូបរបស់វត្ថុ និងបាតុភូតឱ្យបានច្បាស់ ធ្វើឱ្យវត្ថុ និងបាតុភូតលេចឡើងជាបន្តបន្ទាប់គ្នា រួចហើយ ទើបធ្វើទូទៅកម្ម និងទាញសេចក្តីសន្និដ្ឋានសរុប។

**ឃ/ យោង ទៅតាម កម្រិ តនៃ ភាព ម្ចាស់ ការ សកម្ម និ ងច្នៃប្រ ឌិតរបស់សិស្ស**

វិ ធីហ្វឹ កហ្វឺ នមាន អត្ថន័ យដូចតទៅ៖

• ការហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការបង្កើតឡើងវិញ

• ការហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងការអនុវត្ត

• ការហ្វឹកហ្វឺនឱ្យស្ទាត់ក្នុងលក្ខណៈច្នៃប្រឌិត

ក្នុងបញ្ហានេះ សាស្ត្រាចារ្យម្នាក់ ៗ គប្បី យកចិត្តទុ កដាក់ ដល់ វិធីហ្វឹ កហ្វឺ នឱ្យស្ទាត់ ទាំងអស់ ដែលមានអត្ថន័យ ដ៏បង្គួរចំពោះលំនាំនៃការសិក្សារបស់សិស្ស ដូចដែលបានលើកឡើងរួចមកហើយនេះ។ ទន្ទឹមនឹងនេះ វិធីហ្វឹក ហ្វឺនទាំងអស់មានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។

*ឧទាហរណ៍៖* នៅក្នុងលំនាំនៃវិធីហ្វឹកហ្វឺនឱ្យស្ទាត់ដើម្បីទទួលក្តាប់ចំណេះដឹងថ្មីឱ្យបានច្បាស់ សិស្សម្នាក់ៗអាចហ្វឹក
ហ្វឺនឱ្យស្ទាត់ក្នុងការនិយាយផង និងដោយសរសេរផង ក្នុងកម្រិតនៃការបង្កើតឡើងវិញផង និងការចូលរួមរបស់ចលនានៃការគិតផង។

## គ.សំណូមពរមួយចំនួនជាមូលដ្ឋាន

ក/ វិធីហ្វឹកហ្វឺន ត្រូវបានអនុវត្តទៅតាមគោលដៅ និងសំណូមពរដែលបានកំណត់។

**ខ**/ត្រូវក្តាប់ទ្រឹស្តី និងសញ្ញាណឱ្យបានច្បាស់លាស់មុននឹងធ្វើការហ្វឹកហ្វឺនឱ្យស្ទាត់។

• ទ្រឹស្តីសម្រាប់យកធ្វើជាមូលដ្ឋាន ឱ្យដល់ការហាត់ឱ្យស្ទាត់ចំពោះចំណេះដឹង និងបំណិនប្រសប់។បើគ្មានទ្រឹស្តីច្បាស់លាស់ទេនោះ ចំណេះដឹង និងបំណិនប្រសប់ និងត្រូវបានបណ្តុះបណ្តាលឡើងទាំងងងឹតងងល់ តាមបែបពិសោធន៍និយម ឬក៏មិនអាចបណ្តុះបណ្តាលបានផងដ៏សឹងមាន។

• វិធីហ្វឹកហ្វឺនឱ្យស្ទាត់ សម្រាប់បំភ្លឺទ្រឹស្តីបើកទូលាយ និងស៊ីជម្រៅទៅលើទ្រឹស្តី។

គ/ វិធីហ្វឹកហ្វឺន ចំណេះធ្វើ និងបំណិនប្រសប់ ត្រូវបានប្រព្រឹត្តឡើងទៅតាមលក្ខណៈផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្មហើយត្រូវបានធ្វើឡើងទៅតាមលំដាប់ជាច្រើនដង។

• ការហ្វឹកហ្វឺនឱ្យស្ទាត់ ត្រូវធ្វើឡើងពីភាពងាយស្រួលទៅភាពលំបាកស្មុគស្មាញ ពោលគឺ យកចំណេះដឹង និងបំណិនប្រសប់ដែលមានរួចមកហើយធ្វើជាមូលដ្ឋាន ដើម្បីជ្រួតជ្រាប និងក្តាប់ឱ្យបានច្បាស់

នៅលើចំណេះធ្វើ និងបំណិនប្រសប់ថ្មី។ ដូចនេះ ការហ្វឹកហ្វឺនឱ្យស្ទាត់ទៅលើចំណេះធ្វើ និងបំណិនប្រសប់ថ្មី ត្រូវយកចំណេះធ្វើ និងបំណិនប្រសប់ចាស់ ធ្វើជាបង្អែកហើយពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែមានប្រសិទ្ធភាពខ្ពស់ទៅលើចំណេះធ្វើ និងបំណិនប្រសប់ថ្មីជាបន្តបន្ទាប់គ្នា។នៅក្នុងលំនាំនៃការហ្វឹកហ្វឺននេះចលនានៃការគិតកាន់តែមានភាពច្នៃកដ៏រឹងមាំពិតប្រាកដ។

- ការហ្វឹកហ្វឺនឱ្យស្ទាត់ជាអចិន្ត្រៃយ៍ សំដៅពង្រឹងពង្រីកចំណេះដឹង និងបំណិនប្រសប់
- ការហ្វឹកហ្វឺនឱ្យស្ទាត់ជាច្រើនដងសំដៅបណ្តុះបណ្តាលចំណេះដឹង និងបំណិនប្រសប់ឱ្យមានភាពរឹងមាំង

**ឃ/**វិធីហ្វឹកហ្វឺនឱ្យស្ទាត់ត្រូវបានធ្វើឡើងទៅតាមរូបភាពផ្សេងៗគ្នា គឺសំដៅហ្វឹកហ្វឺនសមត្ថភាពក្នុងការអនុវត្តចំណេះដឹងទៅតាមស្ថានភាពផ្សេងៗគ្នាទាំងក្នុងការ
សិក្សាទាំងក្នុងការងារពលកម្ម និងក្នុងជីវភាពរស់នៅ។

**ង/** វិធីហ្វឹកហ្វឺន ទាមទារឱ្យសិស្សមានសេចក្តីព្យាយាម ការអត់ធ្មត់ តស៊ូ និងប្រមូលផ្តុំឱ្យបាននូវស្មារតីប្រុងប្រយ័ត្ន។ សាស្ត្រាចារ្យម្នាក់ៗ គប្បីយកចិត្តទុកដាក់តាមដាន ត្រួតពិនិត្យ ហើយណែនាំសិស្សឱ្យជម្នះបាននូវភាពលំបាកក្នុងជំហានដំបូង។

## ៣.៤.៧. វិធីសិក្សាសារឡើងវិញ

## ក. តម្រូវសំខាន់របស់វិធីសិក្សាសារឡើងវិញ

ក្នុងប្រវត្តិសាស្ត្រ នៃការអភិវឌ្ឍន៍របស់សាលារៀន និងការអប់រំ បញ្ហាសិក្សាសារឡើងវិញ ត្រូវ បានគេយកចិត្តទុកដាក់យ៉ាងខ្លាំង៖

+ គរុកោសល្យវិទូ ដ៏ល្បីល្បាញជាតិឆេកូ **ឈ្មោះ កូមិុនស្គី** បានបកស្រាយបំភ្លឺឱ្យដឹងថា " វិធីសិក្សាសារឡើងវិញ រួមចំណែកជួយឱ្យសិស្សក្តាប់បាន ចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ បង្កើត បានលទ្ធភាពដ៏ងាយស្រួលឱ្យដល់សាស្ត្រាចារ្យ ក្នុងកំណែប្រែបានទាន់ពេលវេលា ឬកង្វះខាតបន្តិច បន្តួចក្នុងចំណេះដឹងរបស់សិស្សធានាបាន ឯកភាពក្នុងការអភិវឌ្ឍ របស់សមូហភាពសិស្សក្នុងថ្នាក់រៀន ជួយសិស្សឱ្យហ្វឹកហ្វឺនបានចំពោះចំណេះធ្វើ ក្នុងការអនុវត្តបានត្រឹមត្រូវ ហើយពង្រីកបានចរិតសកម្ម ម្ចាស់ការ ក្នុងចលនានៃការគិតក៏ដូចជាសមត្ថភាពអភិវឌ្ឍក្នុងស្មារតីប្រុងប្រយ័ត្ន " ។

+ គរុកោសល្យវិទូដ៏ល្បីល្បាញជាតិរុស្ស៊ី **ឈ្មោះ អ៊ូជិនស្គី** ក៏បានពោលអះអាងដែរថា៖" ការសិក្សាសារឡើងវិញ ជួយសិស្សានុសិស្សឱ្យពង្រឹង និងស៊ីជម្រៅ បានទៅលើចំណេះដឹង ហាត់ពត់ និងកែតម្រូវទៅលើបញ្ហាដែលមិនត្រឹមត្រូវ ហើយសំខាន់បំផុតនោះ គឺការអភិវឌ្ឍនៃការគិត "។ លោកមានប្រសាសន៍បញ្ជាក់ទៀតថា " សិស្សានុសិស្សងាយយល់ច្បាស់លាស់ ហើយរហ័សបំផុត ប៉ុន្តែសិស្សានុសិស្សក៏ ងាយភ្លេចយ៉ាងឆាប់រហ័សដែរ ប្រសិនបើបញ្ហាទាំងអស់ ត្រូវបានសិស្សានុសិស្សយល់ច្បាស់ហើយ តែ មិនបានធ្វើការសិក្សាសារឡើងវិញ " ។ ដូចនេះ លោកអ៊ូជិនស្គី យល់ឃើញថាការសិក្សាសារឡើងវិញ សម្រាប់ប្រយុទ្ធទល់នឹងការភ្លេចភ្លាំង។

**លោកអ៊ូជិនស្គី** បានបែងចែកការសិក្សាសារឡើងវិញជាពីរយ៉ាង៖

- ការសិក្សាសារឡើងវិញយ៉ាងសកម្មៈ ត្រូវបានធ្វើឡើង នៅពេលដែលសិស្សមិនទាន់យល់ច្បាស់ពីរូបារម្មណ៍ ឬពីមជ្ឈដ្ឋានជុំវិញខ្លួនដែលបង្កើតបានជាចំណេះដឹង ហើយតម្រូវឱ្យសិស្សយល់ជ្រួតជ្រាប និងក្តាប់បានច្បាស់ ។

- ការសិក្សាសារឡើងវិញដោយអសកម្មៈ ត្រូវបានធ្វើឡើង នៅពេលដែលសិស្សយល់ច្បាស់ពីអ្វីៗ ដែល បានយល់ជ្រួតជ្រាបរួចមកហើយ ហើយសិស្សគ្រាន់តែមើលសារឡើងវិញពីអ្វីៗដែលសិស្សបានឃើញ បានដឹង បានស្តាប់រួចមកហើយប៉ុណ្ណោះ ។

+ គរុកោសល្យវិទូផ្សេងទៀតជាច្រើន ក៏បានទទួលស្គាល់ដែរថា ការសិក្សាសារឡើងវិញនេះ នឹងជួយសិស្សានុសិស្សឱ្យបើកទូលាយ និងស៊ីជម្រៅបានចំពោះ ទូទៅកម្ម និងប្រព័ន្ធកម្មទៅលើចំណេះដឹងដែលបានរៀនរួចមកហើយ។ ម្យ៉ាងវិញទៀត ការសិក្សាសារឡើងវិញនេះ នឹងពង្រឹងពង្រីកឱ្យបានរឹតតែច្បាស់លាស់ទៅលើចំណេះដឹង និងបំណិនប្រសប់ ដែលត្រូវបានបណ្តុះបណ្តាលរួចមកហើយដូចជា ធ្វើឱ្យលំនឹកអភិវឌ្ឍន៍ឡើងចលនានៃការគិត មានភាពម្ចាស់ការហើយផលប្រយោជន៍នៃការសិក្សា ត្រូវបានលើកកម្ពស់ទៀតផង។

## ខ. រូបភាពនៃការសិក្សាសារឡើងវិញ

ក/ គរុកោសល្យវិទូ និងអ្នកនិពន្ធជាច្រើនបានកំណត់រូបភាព នៃការសិក្សាសារឡើងវិញដូចតទៅៈ

- ការសិក្សាសារឡើងវិញនៅដើមឆ្នាំសិក្សា
- ការសិក្សាសារឡើងវិញជាប្រក្រតី
- ការសិក្សាសារឡើងវិញតាមបែបបូកសរុប
- ការសិក្សាសារឡើងវិញនៅដំណាច់ឆ្នាំសិក្សា

ប៉ុន្តែប្រភេទនីមួយៗ នៃការសិក្សាសារឡើងវិញនេះ គ្រាន់តែមានលក្ខណៈជាទ្រង់ទ្រាយទេពោលគឺសាស្ត្រាចារ្យភាគច្រើន មិនបានយកចិត្តទុកដាក់ឱ្យបានជិតដល់។ គឺយ៉ាងនេះហើយបានជាអ្នកនិពន្ធខ្លះបានវាយតម្លៃខ្ពស់ចំពោះផ្នែក និងតួនាទីនៃការការសិស្សាសារឡើងវិញ ដោយលើកឡើងពីរបៀបអនុវត្តទៅតាមប្រភេទផ្សេងៗរបស់ការសិក្សាសារឡើងវិញនេះ។

**ខ/ ជាកស្តែងគឺថាៈ**

- ការសិក្សាសារឡើងវិញនៅដើមឆ្នាំសិក្សាៈ វិធីនេះ ត្រូវបានអនុវត្តឡើងនៅដើមឆ្នាំសិក្សា មុននឹងចាប់ផ្តើម សិក្សាជំពូកថ្មីមួយទៀតនៃមេរៀន ឬជំពូកទាំងមូលនៃមេរៀន។
- ការសិក្សាសារឡើងវិញដើម្បីពង្រឹងជំហានដំបូងៈ ត្រូវបានអនុវត្តសំដៅសិក្សាសារឡើងវិញទៅលើមេរៀនដែលបានរៀនរួចហើយភ្លាមៗ ក្រោយពេលដែលសិស្សយល់មេរៀននោះហើយ។
- ការសិក្សាសារឡើងវិញតាមការហ្វឹកហ្វឺនឱ្យស្ទាត់ៈ ត្រូវបានអនុវត្តឡើងវិញសំដៅកែលំអ និងពង្រឹងចំណេះធ្វើ បំណិនប្រសប់ ដែលចាំបាច់។
- ការសិក្សាសារឡើងវិញតាមបែបបំពេញបង្គ្រប់ៈ ត្រូវបានអនុវត្តនៅពេលដែលរកឃើញកង្វះខាត និងភាពខុសឆ្គងបន្តិចបន្តួច ក្នុងការយល់ដឹងរបស់សាស្ត្រាចារ្យចំពោះសិស្ស។
- ការសិក្សាសារឡើងវិញតាមបែបស៊ីជម្រៅៈ ត្រូវបានអនុវត្តឡើងសំដៅសិក្សាឱ្យលម្អិត និងបើកទូលាយទៅលើចំណេះដឹង ដែលបានរៀនរួចមកហើយ។
- ការសិក្សាសារឡើងវិញតាមបែបទូទៅកម្ម និងប្រព័ន្ធកម្មៈ ត្រូវបានដំណើរការឡើងដោយធ្វើទូទៅកម្ម និងប្រព័ន្ធកម្ម ទៅលើចំណេះដឹងដែលសិស្សបានយល់ជ្រួតជ្រាបរួចមកហើយ។

## គ. សំណូមពរមួយចំនួនជាមូលដ្ឋាន

១.ការសិក្សាសារឡើងវិញ ត្រូវបានធ្វើឡើងទៅតាមផែនការ ទៅតាមប្រព័ន្ធកម្ម និងឱ្យបានទាន់

ពេលវេលា។ ការសិក្សាសារឡើងវិញ ត្រូវធ្វើឡើងទៅតាមរូបភាពជាច្រើនផ្សេងៗគ្នា។ ការសិក្សាសារឡើងវិញលើគ្រប់ជំពូកនៃមេរៀន ល្អជាងការសិក្សាសារឡើងវិញ តាមបែបបូកសរុបក្នុងរយៈពេលមួយយ៉ាងខ្លី។

ការសិក្សាសារឡើងវិញ ដោយឆ្លាស់គ្នាតាមមុខវិជ្ជាជាច្រើន ល្អជាងការសិក្សាសារឡើងវិញក្នុងមុខវិជ្ជាសិក្សាតែមួយ។

២. ការសិក្សាសារឡើងវិញដោយសកម្ម

សាស្ត្រាចារ្យម្នាក់ៗ ដែលបង្ហាត់បង្រៀនមុខវិជ្ជាឯកទេសរបស់ខ្លួនគប្បី៖

- នាំកម្មវត្ថុសិក្សាថ្មី ចូលទៅក្នុងអត្ថន័យនៃមេរៀន ដែលត្រូវសិក្សាសារឡើងវិញ
- នាំសិស្ស ឱ្យត្រិះរិះរកឧបករណ៍ និងចងក្រងមេរៀនដោយខ្លួនឯង
- ណែនាំសិស្សឱ្យសម្រេចបានមេរៀនជាក់ស្តែងឡើងវិញ
- ធ្វើកិច្ចការដែលដាក់ឱ្យសិស្សធ្វើ និងចំនួនសំណួរខុសប្លែកគ្នា កិច្ចការត្រូវឱ្យស្របតាមទិសដៅនៃមេរៀន
- ដឹកនាំសិស្សឱ្យពិនិត្យមើលឯកសារដែលបានរៀនរួចមកហើយ ដោយឆ្លុះបញ្ចាំងទៅក្នុងស្ថានភាពថ្មីឱ្យ បានគ្រប់ជ្រុងជ្រោយ ដើម្បីឈានទៅដល់ការប្រៀបធៀបការធ្វើប្រព័ន្ធកម្ម ទូទៅកម្ម ទៅលើមេរៀនដែល បានសិក្សារួចមកហើយ។ ក្នុងបញ្ហានេះ យើងអាចនិយាយដល់ទស្សនៈ និងតួនាទីដ៏សកម្មទៅក្នុងសកម្ម ភាពនៃទំនួលយល់ជ្រួតជ្រាបចំណេះដឹងរបស់សិស្ស តាមលំនាំនៃការសិក្សារសារឡើងវិញ។ តួនាទី ដ៏សកម្ម នៅក្នុងសកម្មភាពនៃទំនួលយល់ជ្រួតជ្រាបចំណេះដឹងរបស់សិស្ស តាមលំនាំនៃការ សិក្សាសារ ឡើងវិញគឺជា លក្ខខណ្ឌនិងមធ្យោបាយដ៏សំខាន់ ដើម្បីបើកទូលាយបន្តិចម្តងៗ ទៅលើបរិមាណនៃចំណេះដឹង ដែល សិស្សក្តាប់បានហើយឈានទៅរកគុណសម្បត្តិនៃចំណេះដឹង គឺចំណេះធ្វើ និងបំណិនប្រសប់ ដែល ទន្ទឹមនឹងនោះចលនានៃការគិតរបស់សិស្សតាមបែបច្នៃប្រឌិត ក៏អភិវឌ្ឍឡើងដែរ។

ដូចនេះ មានន័យថានៅក្នុងលក្ខខណ្ឌនៃសកម្មភាពក្តាប់យកចំណេះដឹងរបស់សិស្សក៏ត្រូវមានលក្ខណៈសកម្មដែរនោះ ទើបការសិក្សាសារឡើងវិញមានឥទ្ធិពលរឹងមាំស៊ីជម្រៅបើកទូលាយងាយធ្វើ ទូទៅកម្មបានទៅលើចំនេះដឹង ហើយបណ្តុះបណ្តាលបាន នូវលក្ខខណ្ឌកាន់តែងាយស្រួល ដើម្បីឱ្យសិស្សក្តាប់ យកចំណេះដឹងទាំងអស់ឱ្យបានកាន់តែច្បាស់លាស់ ។ ឈរលើមូលដ្ឋាននេះ សិស្សានុសិស្សចេះអនុវត្ត តាមបែបច្នៃប្រឌិត ទៅលើមេរៀន ដែលបានរៀនរួចមកហើយ នៅក្នុងការប្រតិបត្តិ ហើយទន្ទឹមនឹងនេះសាស្ត្រាចារ្យ និងសិស្សអាចចៀសវាងបានផងដែរ ចំពោះការសិក្សាតាមបែបគម្ពីរនិយម និងការសិក្សាតាមបែប រូបភាពនិយម។

ម្យ៉ាងទៀត នៅក្នុងលក្ខខណ្ឌនៃការសិក្សាសារឡើងវិញ សាស្ត្រាចារ្យត្រូវចាត់តាំងឱ្យបានត្រឹមត្រូវនោះទើបសកម្មភាព ទទួលយល់ដឹងរបស់សិស្សមានលក្ខណៈសកម្មដើម្បីឱ្យសតិបញ្ញារបស់សិស្សកាន់តែអភិវឌ្ឍន៍ឡើង។

+ លោកដានីឡូសបានមានប្រសាសន៍ថាលក្ខណៈ " ពិសេសជាមូលដ្ឋាននៃការអភិវឌ្ឍន៍ខាងសតិបញ្ញារបស់សិស្សគឺស្ថិតនៅត្រឹងដែលសតិបញ្ញានោះអភិវឌ្ឍន៍ឡើងជានិច្ច។ ផ្ទុយទៅវិញតាមភាពសមហេតុផលនៃចលនាពីមុនរបស់ខ្លួនឋិតនៅក្រោមឥទ្ធិពលនៃមជ្ឈដ្ឋានជុំ វិញខ្លួនដូចជា ស្វ័យភ្ញាក់រលឹក និងស្វ័យត្រិះរិះជាដើម។ ការអភិវឌ្ឍន៍នេះ និងឈានដល់គោលដៅថ្មី ហើយបណ្តុះបណ្តាលបានជាសមត្ថ

ភាពតាមលំនាំនៃការអភិវឌ្ឍន៍ជាបន្តទៅទៀត " ។

ដើម្បីឱ្យសកម្មភាពនៃទំនួលចំណេះដឹងរបស់សិស្សនៅក្នុងការសិក្សាសារឡើងវិញមានចរិតសកម្ម យើង បង្ហាញឱ្យឃើញនូវមធ្យោបាយផ្សេងៗគ្នាជាច្រើនទៀត។

*ឧទាហរណ៍៖* ការអនុវត្តវិធីប្រៀបធៀប៖

នៅក្នុងលំនាំនៃការសិក្សាសារឡើងវិញសិស្សអាចសម្រេចបានសំណួរនិងមេរៀនបីប្រភេទដូចតទៅ៖

- សំណួរ និងមេរៀនដែលធ្វើឱ្យសិស្សយល់ដឹង ពីរបៀបធៀបកម្មវត្ថុ ប្រៀបធៀបសញ្ញាសម្គាល់ក្នុងការប្រៀបធៀប។
- សំណួរ និងមេរៀនទាំងឡាយ ដែលធ្វើឱ្យសិស្សយល់ពីវិធីប្រៀបធៀប និងកម្មវត្ថុដែលត្រូវប្រៀបធៀប។
- សំណួរនិងមេរៀនដែលគ្រាន់តែធ្វើឱ្យសិស្សយល់ពីរបៀបប្រៀបធៀបប្រភេទនៃសំណួរនិងមេរៀន ទាំងនេះ ត្រូវបានរៀបចំឡើង ដោយផ្តើមចេញពីការវិភាគ ទៅលើកត្តាសំខាន់ៗជាមូលដ្ឋានក្នុង ការប្រៀ បធៀប៖

ប្រៀបធៀបទៅលើកម្មវត្ថុណា? តាមវិធីណា?(ដូចគ្នា ឬខុសគ្នា ឬក៏ប្រៀបធៀបទៅលើលក្ខណៈដូចគ្នាទាំងអស់ និងខុសទាំងអស់ ហើយតាមសញ្ញាសម្គាល់យ៉ាងណាខ្លះ?)។ ការប្រតិបត្តិ បាន បង្ហាញឱ្យឃើញច្បាប់ថា៖បម្រើបម្រាស់ប្រភេទនៃសំណួរ និងមេរៀន ប្រៀបធៀបនៅក្នុងលំនាំនៃការសិក្សាសារឡើងវិញបម្រើឱ្យគោលដៅភារកិច្ច និងខ្លឹមសាររបស់ការសិក្សាសារឡើងវិញ តាំងពីប្រភពដើមនៃចំណេះដឹងរហូតដល់កម្រិតអភិវឌ្ឍន៍នៃសកម្មភាពបញ្ញារបស់សិស្ស។ តាមធម្មតាជាការល្អនោះ មិនត្រូវប្រើប្រាស់វិធីប្រៀបធៀបតែមួយនោះទេ គឺត្រូវប្រើប្រាស់វិធីប្រៀបធៀបទាំងអស់គួបផ្សំគ្នា។ ប៉ុន្តែ ជាដំបូងត្រូវប្រើប្រាស់ប្រភេទទី១ រួចប្រភេទទី២ និងចុងក្រោយគឺប្រភេទទី៣។ ដើម្បីធ្វើឱ្យបានសម្រេចនូវសំណួរនិងមេរៀនទាំងឡាយក្នុងការប្រៀបធៀបនៅក្នុងលំនាំនៃការសិក្សាសារឡើងវិញនោះសិស្សគប្បីធ្វើឱ្យបានសម្រេចក្នុងការអនុវត្តទៅលើចំណេះដឹងដែលសាស្ត្រាចារ្យបានកំណត់៖

- កំណត់នូវគោលដៅប្រៀបធៀប នៅក្នុងការសិក្សាសារឡើងវិញតាមឯកសារ ឬជំពូកមេរៀននីមួយៗដែលបានរៀនរួចមកហើយ។
- កំណត់កម្មវត្ថុប្រៀបធៀប (បើសំណួរនិងមេរៀនមិនទាន់បានលើកឡើងច្បាស់) ។
- កំណត់សញ្ញាសម្គាល់ ក្នុងការប្រៀបធៀប ដោយឈរលើមូលដ្ឋាន នៃការផ្តាច់សញ្ញាសម្គាល់ទាំង អស់ក្នុងការប្រៀបធៀប ជាពិសេស សញ្ញាសម្គាល់សំខាន់ៗរបស់សំណួរ និងមេរៀនសមស្របទៅនឹង គោលដៅនៃការប្រៀបធៀបដែលត្រូវលើកឡើង។
- កំណត់ប្រៀបធៀប( ខុសគ្នា ឬដូចគ្នា ឬក៏ខុសគ្នាទាំងអស់ ដូចគ្នាទាំងអស់) ដែលសមស្របទៅនឹងគោលដៅកំណត់។
- ផ្ទៀងផ្ទាត់គ្នាពីកម្មវត្ថុប្រៀបធៀបទាំងអស់ ទៅតាមសញ្ញាសម្គាល់សំខាន់ៗ ដែលបានកំណត់ច្បាស់ តាមរបៀប្រៀបធៀបនីមួយៗ។
- លើកឡើងនូវសេចក្តីសន្និដ្ឋានដកស្រង់ចេញពីមេរៀននៅក្នុងឯកសារដែលបានយកមកសិក្សាក្រោមរូបភាពនៃទូទៅកម្មឱ្យបានសមស្របទៅនឹងគោលដៅប្រៀបធៀបដែលបានកំណត់។

ការធ្វើទូទៅកម្ម និង ប្រព័ន្ធកម្ម លើចំណេះដឹង ដែលបានរៀនរួចមកហើយនៅក្នុងលំនាំនៃការសិក្សាសារឡើងវិញ ទូទៅកម្មនិងប្រព័ន្ធកម្ម ទទួលបន្ទុកតួនាទីដ៏សំខាន់បំផុត។ការពិត គឺវិធីនេះជួយសិស្សឱ្យក្តាប់បានតាមលក្ខណៈប្រព័ន្ធកម្ម ទៅលើមេរៀនតាមឯកសារ ដែលបានរៀនរួចមកហើយ ក្រោមរូបភាពរបស់ទូទៅកម្ម។ វិធីនេះ បណ្តុះបណ្តាលបាននូវលក្ខខ័ណ្ឌងាយស្រួល ដើម្បីឱ្យសិស្សអាចក្តាប់ បានមេរៀនថ្មី និងអនុវត្តតាមលក្ខណៈច្នៃប្រឌិតទៅលើចំណេះដឹង ដែលខ្លួនបានយល់ជ្រួតជ្រាបច្បាស់ លាស់រួចមកហើយ នៅក្នុងការប្រតិបត្តិ។ ទូទៅកម្ម និងប្រព័ន្ធកម្ម ជំរុញឱ្យមានអភិវឌ្ឍន៍ខាង សមត្ថភាពក្នុងការវិភាគ ការបូកសរុប ការប្រៀបធៀប អរូបិយ៍កម្ម និងអនុវត្តតាមលក្ខណៈច្នៃប្រឌិត ទៅ លើចំណេះដឹងដែលខ្លួនបានយល់ជ្រួតជ្រាបច្បាប់លាស់រួចមកហើយ នៅក្នុងការប្រតិបត្តិ។នៅក្នុងលំនាំ នៃការសិក្សាសារឡើងវិញសិស្សត្រូវធ្វើទូទៅកម្មនិងប្រព័ន្ធកម្មទៅលើចំណេះដឹងក្នុងមេរៀនដែលបានរៀន រួចមកហើយក្រោមរូបភាពច្រើនយ៉ាងផ្សេងៗគ្នាដូចជា ចងក្រងគម្រោងមេរៀននិយាយរៀបរាប់ឡើងវិញ ធ្វើអត្ថធិប្បាយសង្ខេបខ្លីៗតែមានន័យគ្រប់គ្រាន់ ធ្វើតារាងមេរៀន និងគូសគំនូរបំព្រួញ។ ដើម្បីអនុវត្ត តាមរូបភាពទាំងនេះ សិស្សម្នាក់ៗ ត្រូវសម្រេចបាននូវសតិបញ្ញាជាចាំបាច់ (ចំពោះរូបភាពចងក្រង គម្រោងមេរៀន ធ្វើអត្ថាធិប្បាយសង្ខេបខ្លីៗ និយាយរៀបរាប់ឡើងវិញ ពិនិត្យសង្កេតទៅលើសកម្មភាព ទទួលចំណេះដឹងដែលប្រហាក់ប្រហែលគ្នា) ដូចដែលយើងបានអធិប្បាយរួចមកហើយ នៅក្នុងផ្នែក និយាយពីវិធីប្រើប្រាស់សៀវភៅនិងឯកសារសិក្សា។ នៅក្នុងបញ្ហានេះយើងយកចិត្តទុកដាក់ទៅលើរូបភាព របស់ការសិក្សាសារឡើងវិញ តាមគំនូរបំព្រួញ និងតារាងបណ្តុះបណ្តាលបាននូវលក្ខខណ្ឌងាយស្រួល ក្នុងការធ្វើទៅកម្ម និងប្រព័ន្ធកម្ម ទៅលើឯកសារសិក្សាដែលបានរៀនរួចមកហើយ ប្រយោជន៍ដើម្បីចងចាំ ឱ្យបានរឹងមាំច្បាស់លាស់ទៅលើមេរៀនក្នុងឯកសារសិក្សាទាំងនោះ។ហើយការចាំបាច់បំផុតនោះគឺ សាស្ត្រាចារ្យត្រូវធ្វើសេចក្តីពង្រាងឡើងវិញឱ្យបានសម្រេចតាមរូបភាពនៃគំនូរបំព្រួញនិងតារាងសម្រាប់ផ្ទុះ បញ្ចាំងតាមលក្ខណៈអត្តន្តរញ្ញាណ និងចំណងទាក់ទងដ៏សំខាន់ៗ រវាងវត្ថុ និងវត្ថុ ឬបាតុភូត និង បាតុភូត ដោយគ្រាន់តែចង្អុលបង្ហាញពីរចនាសម្ព័ន្ធនិងប្រព័ន្ធប៉ុណ្ណោះ។ ការបង្កើតគំនូរបំព្រួញ និង តារាងត្រូវធ្វើឡើងឱ្យបានសមស្របទៅនឹងសំណូមពររបស់វិធីសិក្សាសារឡើងវិញដូច ជាផ្ទុះបញ្ចាំងបាន នូវកម្រិតដ៏គ្រប់គ្រាន់សញ្ញាសម្គាល់ទូទៅរបស់កម្មវត្ថុសិក្សា និងចំណងទាក់ទងរួម ដែលត្រូវធ្វើ ទូទៅកម្ម និង ប្រព័ន្ធកម្ម។

• គំនូរបំព្រួញ និងតារាង ត្រូវមានរចនាសម្ព័ន្ធច្បាស់លាស់ មានភាពរស់រវើក និងមានលក្ខណៈងាយស្រួលក្នុងការមើល។ ការពិសោធន៍បានឱ្យដឹងថា ដើមឡើយនៅក្រោមការដឹកនាំរបស់សាស្ត្រាចារ្យសិស្សមានទម្លាប់ក្នុងបម្រើបម្រាស់តារាងគម្រោងគំនូរបំព្រួញនៅក្នុងការសិក្សាសារឡើងវិញហើយ ក្រោយៗ មកសិស្សអាចកសាងបានដោយខ្លួនឯងនូវតារាង និងគំនូរបំព្រួញទាំងនោះក្នុងមេរៀនថ្មីដោយ ឈរលើមូលដ្ឋាននៃចំណេះដឹងចាស់ដែលសិស្សបានយល់ច្បាស់។ ការបង្កើតជា គម្រោង តារាង គំនូរបំព្រួញសំដៅបម្រើបម្រាស់ឱ្យគោលដៅផ្សេងៗគ្នាជាច្រើនដូចជា៖

- គំនូរដោយមានសេចក្តីអធិប្បាយអម សេចក្តីពិពណ៌នាពីវត្ថុឬបាតុភូតណាមួយ។គម្រោងមេរៀន ជាកំពែងដ៏រឹងមាំ របស់ឫសគល់នៃ ចំណេះដឹង ជាសមាសភាព ឬជាធាតុនៃគ្រាប់ដែលដាំដុះ ឬឯតារាង វិញ គឺជាផ្នែករបស់ឫសគល់ ឬក៏ជាលក្ខណៈពិសេសរបស់លំនឹក។
- ការប្រៀបធៀប ការយកវត្ថុឬបាតុភូតមកផ្ទួរនឹងគ្នា (គំរោង:ប្រៀបធៀបការបណ្តុះគ្រាប់សណ្តែក និងគ្រាប់ស្រូវ)(តារាង:ការខុសគ្នារវាងលំនាំនៃការកកើតបានជាម្សៅនិងលំនាំនៃការដក

ដង្កើមចេញចូល)

- បែងចែកប្រភេទនៃកម្មវត្ថុសិក្សា(គំរោង:បែងចែកប្រភេទផ្កា។តារាង:បែងចែកប្រភេទផ្លែ)

ការពិសោធន៍បានបង្ហើញឱ្យឃើញច្បាស់ថាពេលបង្កើតគម្រោងនិងតារាងសំដៅតាក់តែងរៀបចំគំនូរ ដោយ មានអមសេចក្តីអធិប្បាយឬសេចក្តីពិពណ៌នាទៅលើវត្ថុឬបាតុភូតដែលបានសិក្សារួចមកហើយ។ សិស្សត្រូវអនុវត្តសកម្មភាពបញ្ញាដូចតទៅៈ

- កំណត់ច្បាស់នូវគោលដៅនៃការបង្កើតគម្រោងនិងតារាង
  - បង្កើតឡើងវិញនូវឯកសារដែលបានរៀនរួចមកហើយនិងឯកសារដែលត្រូវពិនិត្យពិចារណាបន្ថែម ក្នុងករណីដែលចាំបាច់គឺត្រូវធ្វើការវិភាគនិងការប្រៀប។សិស្សត្រូវធ្វើការវិភាគឱ្យដាច់ស្រលះទៅលើសញ្ញា សម្គាល់សំខាន់។
  - ធ្វើអរូបិយ៍កម្ម, ប្រព័ន្ធកម្មនិងទូទៅកម្មទៅលើសញ្ញាសម្គាល់ទាំងនោះ
  - សង្កត់ធ្ងន់ទៅលើឯកសារដែលត្រូវធ្វើទូទៅកម្មនិងប្រព័ន្ធកម្មតាមកំណត់
  - កំណត់ច្បាស់ និងកសាង ឱ្យមាននូវរូបភាពរបស់គម្រោង ឬតារាងដោយលើមូលដ្ឋាននៃបម្រើបម្រាស់ ឯកសារដែលនឹងត្រូវធ្វើទូទៅកម្ម និងប្រព័ន្ធកម្ម។ នៅពេលដែលបង្កើតបានជាគម្រោងឬតារាងប្រៀបធៀប ទៅលើវត្ថុ ឬបាតុភូត ដែលបានរៀនរួចមកហើយ សិស្សត្រូវអនុវត្តសកម្មភាពបញ្ញាមួយដដែលមានលំនាំ ប្រហាក់ប្រហែលគ្នានឹងសកម្មភាពបញ្ញា ដែលសិស្សធ្លាប់បានឆ្លងកាត់រួចមកហើយ។ ប៉ុន្តែនៅទីបំផុត សិស្សត្រូវតែទាញឱ្យបាននូវសេចក្តីសន្និដ្ឋាន ក្រោមរូបភាពនៃគម្រោង គំនូរបំព្រួញ ឬតារាងដែលសម ស្រប។យោងទៅតាមបំណែងចែកកម្មវត្ថុសិក្សាដែលបានសិក្សារួចមកហើយនៅក្នុងជំពូកនៃមេរៀន ណាមួយនោះសិស្សត្រូវៈ
- សិក្សាស្រាវជ្រាវកម្មវត្ថុសិក្សា និងចំណងទាក់ទងគ្នាឱ្យដាច់ដោយឡែកពីគ្នា
  - បង្កើតឡើងវិញ នូវបញ្ញត្តិ វិធានច្បាប់ដែលដូចគ្នា ឬខុសគ្នារបស់កម្មសិក្សា ឱ្យដាច់ដោយឡែកពីគ្នា ដោយឈរលើមូលដ្ឋាននៃចំណងទាក់ទងគ្នាតាមលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នាប្លែកគ្នា។
  - ធ្វើការប្រៀបធៀប ដើម្បីឱ្យឃើញនូវសញ្ញាសម្គាល់ទូទៅ និងលក្ខណៈពិសេសដោយឡែកពីគ្នា របស់កម្មវត្ថុសិក្សាជាមួយនឹងសញ្ញាណវិធាន និងច្បាប់ដែលដូចគ្នា
  - តម្រៀបកម្មវត្ថុសិក្សាឱ្យដាច់ដោយឡែកពីគ្នានៅក្នុងករណីដែលវាមានចំណងទាក់ទងគ្នាទៅតាម ប្រភេទរបស់វា។

## ៣.៤.៨ វិធីធ្វើកិច្ចការត្រួតពិនិត្យវាយតម្លៃចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់

### ក. អត្ថន័យ

វិធីធ្វើកិច្ចការត្រួតពិនិត្យវាយតម្លៃ ចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ របស់សិស្ស គឺជាវិធីមួយមានកម្រិតសំខាន់ និងចាំបាច់ណាស់។ វិធីនេះ ធានាឱ្យសាស្ត្រាចារ្យ មានជំនឿ និងទុកចិត្តទៅលើ ការសិក្សារបស់សិស្សនៅក្នុងលំនាំនៃការបង្រៀន។ ម្យ៉ាងវិញទៀត សាស្ត្រាចារ្យ អាចទទួលបាននូវទំនាក់ ទំនងបញ្ច្រាសពីសិស្សមកវិញ។ឆ្លងកាត់តាមប្រការនេះសាស្ត្រាចារ្យមានលក្ខខណ្ឌដោយងាយស្រួលក្នុង ការស៊ីជម្រៅទៅលើកម្មវត្ថុបង្រៀនរបស់ខ្លួន ហើយទន្ទឹមនឹងនេះ សាស្ត្រាចារ្យ អាចជួយសិស្សឱ្យបើក ទូលាយ និងស៊ីជម្រៅទៅលើការពង្រឹងចំណេះ ដឹងចំណេះធ្វើ និងបំណិនប្រសប់ ដែលខ្លួនបានរៀន រួចមកហើ

យ។ មិនតែប៉ុណ្ណោះសោតសាស្ត្រាចារ្យ កាន់តែមានជំនឿក្នុងវង្វាយតម្លៃ និងកែតម្រូវល្អ ឥតខ្ចោះហើយ ទាន់ពេលវេលា ពីសកម្មភាពបង្រៀន និងអប់រំរបស់ខ្លួន។ការគួបផ្សំគ្នារវាងទំនាក់ ទំនងបញ្ច្រាសខាងក្រៅ និងខាងក្នុងខ្លួនរបស់សិស្ស បណ្ដុះបណ្ដាលបាននូវលក្ខខណ្ឌងាយស្រួល និងការ ធានាបានលទ្ធផលល្អ ប្រសើរ នៅក្នុងលំនាំនៃការបង្រៀន។ សំខាន់ គឺថានៅក្នុងបញ្ហានេះ យើងធ្វើការ ពាក់ព័ន្ធ ឱ្យឃើញពីចំណុចខ្សោយ ជាមូលដ្ឋានរបស់ប្រព័ន្ធនៃវិធីបង្រៀនតាមប្រពៃណីពោលគឺ ទំនាក់ ទំនងបញ្ច្រាសត្រូវមានកម្រិតជាច្រើន។ វិធីធ្វើកិច្ចការត្រួតពិនិត្យវាយតម្លៃ ចំណេះដឹង ចំណេះធ្វើ និង បំណិនរបស់សិស្ស មិនមែនមានន័យថាផ្ដល់ចំណេះនោះទេ ប៉ុន្តែមានន័យថាអប់រំទៅវិញ។ ជាការពិត ណាស់ ព្រោះ វិធីនេះ ជំរុញសិស្សឱ្យលើ កកម្ពស់ ស្មារ តីទទួលខុសត្រូវ នៅក្នុ ងការសិក្សាសកម្ម ម្ចាស់ការច្នៃប្រឌិត ក្នុងសកម្មភាពសិក្សា បំពាក់បំប៉នបាននូវឆន្ទះទម្លាប់ល្អ ក្នុងកិច្ចការទៅតាមលក្ខណៈប្រព័ន្ធកម្ម ហើយ ទន្ទឹមនឹងនេះ បណ្ដុះបណ្ដាល និងធ្វើឱ្យអភិវឌ្ឍបាននូវមនសិការស្វ័យត្រួតពិនិត្យ ស្វ័យវាយតម្លៃ ស្វ័យកែ តម្រូវទាន់ពេលវេលា មានសកម្មភាពល្អក្នុងការសិក្សាសំដៅរួមចំណែកដល់ការអនុវត្តឱ្យបានល្អតាម សំណូមពរភារកិច្ច និងគោលដៅនៃការបង្រៀន ការអប់រំ និងការសិក្សា។

## ខ. ប្រភេទនៃការត្រួតពិនិត្យជាមូលដ្ឋាន

នៅសាលារៀនមធ្យមសិក្សាចំណេះទូទៅ សាស្ត្រាចារ្យ ចូលចិត្តប្រើប្រាស់ប្រភេទនៃកិច្ចការត្រួតពិនិត្យ ជាមូលដ្ឋានដូចតទៅ៖

### ការត្រួតពិនិត្យប្រចាំថ្ងៃ៖

ការត្រួតពិនិត្យប្រចាំថ្ងៃ ត្រូវបានសាស្ត្រាចារ្យ ចាប់ផ្ដើមអនុវត្តជារឿយៗសំដៅអនុវត្តឱ្យបានទាន់ពេលវេលានូវសកម្មភាពរបស់សាស្ត្រាចារ្យ និងសិស្សដើម្បីជំរុញសិស្សឱ្យសកម្មព្យាយាមជានិច្ចជាកាលសិក្សាតាមលក្ខណៈនៃប្រព័ន្ធកម្ម ហើយទន្ទឹមនឹងនោះ បណ្ដុះបាននូវលក្ខខណ្ឌដ៏រឹងមាំ ដើម្បីឱ្យលំនាំនៃការបង្រៀនរបស់សាស្ត្រាចារ្យ និងការសិក្សារបស់សិស្សអភិវឌ្ឍទៅរកជំហានថ្មី។

ការត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវបានអនុវត្តដោយឆ្លងកាត់តាមការពិនិត្យសង្កេត ទៅតាមលក្ខណៈនៃប្រព័ន្ធកម្ម និងសកម្មភាពរបស់សមូហភាពសិស្ស និយាយរួមហើយ និងសកម្មភាពរបស់សិស្សម្នាក់ៗនិយាយដោយឡែក។ ឆ្លងកាត់តាមការត្រួតពិនិត្យលើចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស សាស្ត្រាចារ្យ ត្រូវចេះគួប ផ្សំទៅនឹងការសិក្សាស្រាវជ្រាវមេរៀនថ្មី ការសិក្សាសារឡើងវិញ និងការពង្រឹងមេរៀនចាស់ដោយណែនាំសិស្ស
ឱ្យ យកចំណេះដឹង ចំណេះធ្វើ និង បំណិនប្រសប់ ទៅអនុវត្តនៅក្នុងការប្រតិបត្តិ។

### ការត្រួតពិនិត្យតាមកាលកំណត់៖

ប្រភេទនៃការត្រួតពិនិត្យនេះ ត្រូវបានអនុវត្តជានិច្ចនៅក្រោយពេលសិក្សាចប់ផ្នែកមួយ នៃកម្មវិធីសិក្សា ឬក្រោយពេលចប់ត្រីមាសនីមួយៗ។ អាស្រ័យដោយការត្រួតពិនិត្យបែបនេះ បរិមាណនៃ ចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស ដែលត្រូវធ្វើការត្រួតពិនិត្យ ក៏មានកំណត់ព្រំដែន ដែរ។ ប្រភេទនៃការត្រួតពិនិត្យតាមកាលកំណត់នេះមានឥទ្ធិពលពណាស់ ក្នុងការជួយសាស្ត្រាចារ្យ និង សិស្សឱ្យមើលឃើញលទ្ធផលនៃការងាររបស់ខ្លួនក្នុងរយៈមួយជាកំណត់ ដើម្បីពង្រឹង និងបើកទូលាយទៅ លើមេរៀនដែលសិស្សបានរៀនរួចមកហើយ ហើយម្យ៉ាងទៀតបណ្ដុះបណ្ដាលបាននូវមូលដ្ឋាន ក្នុងការ បង្ហាត់បង្រៀនក្នុងជំពូកថ្មីនៃមេរៀនជាបន្តទៅទៀត។

## ការត្រួតពិនិត្យតាមបែបបូកសរុប៖

ប្រភេទនៃការត្រួតពិនិត្យតាមបែបបូកសរុប ត្រូវបានអនុវត្តនៅដំណាច់ឆ្នាំសិក្សា ឬនៅពេលរៀនចប់សៀវភៅសិក្សានីមួយៗ។ វិធីនេះសំដៅវាយតម្លៃ ទៅលើលទ្ធផលទូទៅ ពង្រឹងនិងបើកទូលាយ ទៅលើមេរៀនទាំងមូល ដែលបានសិក្សាតាំងពីដើមឆ្នាំ ឬតាំងពីមេរៀនដំបូងបង្អស់ដើម្បីឈានទៅកាន់ ឆ្នាំសិក្សាថ្មី កម្មវិធីសិក្សាឆ្នាំថ្មី និងមុខវិជ្ជាសិក្សាថ្មី។

ប្រភេទនៃការត្រួតពិនិត្យទាំងអស់ ដូចដែលបានរៀនរាប់មកនេះមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធរហូតដល់ការចាប់ផ្តើមអនុវត្តការពិនិត្យ សង្កេតតាមលក្ខណៈប្រព័ន្ធកម្មរបស់សាស្ត្រាចារ្យ ចំពោះសកម្មភាពរបស់សិស្សនៅក្នុងថ្នាក់ ក៏ដូចជានៅក្រៅថ្នាក់។ ឯកសារដែលត្រូវពិនិត្យសង្កេត ត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់ពីសិស្សម្នាក់ៗក្នុងទំនួលខុសត្រូវ ចំពោះការសិក្សា។ មានសាស្ត្រាចារ្យជាច្រើនបានកត់ត្រាឡើងវិញ នូវឯកសារដែលត្រូវពិនិត្យសង្កេតនោះ ទៅក្នុងទិនានុលេខដ៏របស់ខ្លួន។ ដើម្បីឈរលើមូលដ្ឋាននេះកំណត់ឱ្យបានច្បាស់ពីកម្រិតអភិវឌ្ឍរបស់សិស្សម្នាក់ៗ។តាមធម្មតាកំណត់ត្រានេះចំពោះខ្លួនសាស្ត្រាចារ្យម្នាក់ៗផ្ទាល់គឺគ្រាន់តែយកធ្វើជាមូលដ្ឋានក្នុងវាយតម្លៃឱ្យបានត្រឹមត្រូវតាមលក្ខណៈវិទ្យាសាស្ត្រ និងតាមសត្យានុម័តតែប៉ុណ្ណោះ។

ប្រភេទនៃការត្រួតពិនិត្យប្រចាំថ្ងៃតាមកាលកំណត់ និងតាមបែបបូកសរុប បានត្រូវធ្វើឡើងក្រោមរូបភាពបីយ៉ាង៖ ការសួរផ្ទាល់មាត់ ការសួរដោយសរសេរ និងការសួរតាមបែបអនុវត្ត។

## ការត្រួតពិនិត្យតាមការសួរផ្ទាល់មាត់៖

ការត្រួតពិនិត្យបែបនេះត្រូវបានសាស្ត្រាចារ្យយកមកប្រើប្រាស់មុនពេល ក្នុងពេល និងក្រោយពេលសិក្សាមេរៀនថ្មីណាមួយ ក៏ដូចជាក្នុងពេលប្រឡងត្រីមាស និងប្រឡងដំណាច់ឆ្នាំសិក្សាដែរ។

វិធីនេះជួយសាស្ត្រាចារ្យ ឱ្យទទួលបានយ៉ាងរហ័សនូវទំនាក់ទំនងបញ្ច្រាសពីសិស្សមកវិញចំពោះប្រភេទសិស្សផ្សេងៗគ្នា (សិស្សពូកែសិស្សខ្សោយសិស្សមធ្យម)។ វិធីនេះ ជំរុញឱ្យសិស្សសិក្សាជាអចិន្ត្រៃយ៍តាមប្រព័ន្ធមេរៀន និងហ្វឹកហ្វឺនសមត្ថភាព ខាងការរៀបរាប់ដោយវាចារ។

នៅពេលធ្វើកិច្ចការត្រួតពិនិត្យដោយសួរផ្ទាល់មាត់ សាស្ត្រាចារ្យគប្បីប្រតិបត្តិតាមសំណូមពររបស់វិធីចោទឆ្លើយហើយត្រូវយកចិត្តទុកដាក់ជាបន្ថែមគឺ៖

- ទាក់ទាញទឹកចិត្តសមូហភាពសិស្ស ឱ្យផ្តោតស្មារតីក្នុងកិច្ចការត្រួតពិនិត្យ
  - ត្រូវកំណត់ព្យាយាម ក្នុងការយកចិត្តទុកដាក់តាមដានចម្លើយសិស្ស ជួយផ្តួចផ្តើមមតិឱ្យសិស្សតែ មិនត្រូវធ្វើឱ្យសិស្សភ័យខ្លាចផ្តេសផ្តាសឡើយ
  - ត្រូវរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស ដោយពឹងផ្អែកលើខ្លឹមសារនៃ មេរៀនរូបភាពស្មារតី និងអាកប្បកិរិយារបស់សិស្ស។

## កិច្ចការត្រួតពិនិត្យដោយសរសេរ

កិច្ចការត្រួតពិនិត្យដោយសរសេរ ត្រូវបានអនុវត្តឡើងក្រោយពេល ដែលបង្រៀនចប់ជំពូកមួយ ឬជំពូកជាច្រើននៃមេរៀន ក្នុងកម្មវិធីសិក្សា ឬពំនោះសោត ក្រោយពេលរៀនចប់មេរៀនណាមួយក៏បាន។ រយៈពេលធ្វើកិច្ចការត្រួតពិនិត្យនេះ ត្រូវប្រព្រឹត្តឡើងក្នុងរយៈពេលពី ១៥ទៅ២០នាទី ឬពីមួយម៉ោង ទៅពីរម៉ោង តាមថ្នាក់នៃកិច្ចសិក្សា។

កិច្ចការត្រួតពិនិត្យដោយសរសេរមានឥទ្ធិពលដូចតទៅ៖

• ត្រួតពិនិត្យបានពីបញ្ហាតូចតាច ទៅបញ្ហាធំដុំ ហើយមានលក្ខណៈលាយចម្រុះគ្នាផង

- ត្រួតពិនិត្យ បានទៅលើកម្រិតយល់ដឹងរបស់សិស្សក្នុងថ្នាក់ទាំងមូល ក្នុងរយៈពេលមួយជាកំណត់
- ជួយសិស្ស ឱ្យហ្វឹកហ្វឺនបាននូវសមត្ថភាពខាងភាសាសរសេរ កាលណាធ្វើកិច្ចការ ត្រួតពិនិត្យដោយ សរសេរ សាស្ត្រាចារ្យ គប្បីយកចិត្តទុកដាក់នឹងសំណូមពរទាំងឡាយដូចតទៅៈ

•សំណួរ ឬប្រធានបទ ត្រូវបានច្បាស់លាស់ដើម្បីឱ្យសិស្សម្នាក់មានលក្ខណៈឯកភាពគ្នា ក្នុងការយល់ និងឆ្លើយបាន។ ម្យ៉ាងទៀត សំណួរ ឬប្រធានបទ ត្រូវឱ្យសមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស និងរយៈពេលវេលា ដែលធ្វើកិច្ចការនោះ ហើយអាចពង្រឹងបាននូវបញ្ញាយល់ដឹងរបស់សិស្សផង។

•អប់រំសិស្ស ឱ្យមានចរិតភ្ញាក់រលឹកនៅពេលធ្វើកិច្ចការត្រួតពិនិត្យ ចៀសវាងការចម្លងតាម សំណេរសរសេរ ចម្លងមេរៀន ឬចម្លងមិត្តភក្តិ

•បណ្តុះបណ្តាលបាននូវលក្ខខណ្ឌ ឱ្យដល់សិស្សក្នុងធ្វើការត្រួតពិនិត្យ ចៀសវាងការធ្វើឱ្យសិស្សភ័យបាត់ស្មារតី ឬបាត់បង់ស្មារតីប្រុងប្រយ័ត្ន

•ប្រមូលកិច្ចការឱ្យបានទាន់ពេលវេលា ដាក់ពិន្ទុដោយប្រយ័ត្នប្រយែង ដាក់និទ្ទេសឱ្យបានត្រឹមត្រូវ ដាក់ស្លែង ចម្លើយ គប្បីសរសេរឱ្យបានត្រឹមត្រូវប្រហាក់ប្រហែលគ្នា ពិនិត្យពិន័យមើលភាពទូទៅភាពដោយឡែក ខ្លឹមសាររូបភាពនៃសំណេរ ស្មារតីអាកប្បកិរិយាក្នុងការធ្វើកិច្ចការ។

## កិច្ចការត្រួតពិនិត្យតាមបែបអនុវត្ត

វិធីធ្វើកិច្ចការត្រួតពិនិត្យតាមបែបអនុវត្តប្រព្រឹត្តឡើង សំដៅត្រួតពិនិត្យទៅលើចំណេះធ្វើ និងបំណិនប្រសប់ ក្នុងការអនុវត្តដូចជា ការវាស់វែង ការពិសោធន៍ពលកម្មនៅក្នុងថ្នាក់រៀន នៅក្នុងបន្ទប់ពិសោធន៍ ក្នុងសួនច្បារសាលារៀន ក្នុងរោងជាងសិក្សា ឬក្រៅសាលារៀន។ពេលធ្វើកិច្ចការត្រួតពិនិត្យប្រភេទនេះ សាស្ត្រាចារ្យគប្បីយកចិត្តទុកដាក់នឹងសំណូមពរខ្លះដូចតទៅៈ

• តាមដានកិច្ចការសិស្សទៅតាមលំដាប់លំដោយ ទៅលើកម្រិតយល់ដឹងច្បាស់លាស់ និងក្នុងការធ្វើប្រមាណវិធី

• ត្រួតពិនិត្យមើលការយកទ្រឹស្តីធ្វើជាមូលដ្ឋានក្នុងការប្រតិបត្តិប្រភេទ និងរូបភាពនៃកិច្ចការត្រួត ពិនិត្យដូចដែលបានរៀបរាប់រួចមកហើយនេះត្រូវបានយកមកអនុវត្តនៅក្នុងសមូហភាពសិស្សឬចំពោះសិស្សម្នាក់ៗក៏បាន តែត្រូវគោរពតាមសំណូមពរ និងខ្លឹមសាររបស់កិច្ចការត្រួតពិនិត្យ។

## កិច្ចការត្រួតពិនិត្យពិសេសៈ តេស្ត ឬប្រឡងៈ

**តេស្តៈ** តេស្តគឺជាការត្រួតពិនិត្យសរុប និងតាមកាលកំណត់ទៅលើស្នាដៃសិក្សារបស់ សិស្ស។តេស្ត ត្រូវបានអនុវត្តគ្រប់ថ្នាក់នៃមធ្យមសិក្សាចំណេះទូទៅ ក្រោមរូបភាពនៃការ សួរ- ឆ្លើយ។ ការប្រតិបត្តិនិង ការពិសោធន៍ ក្នុងវិធីនេះបង្ហាញឱ្យឃើញថា តេស្តត្រូវបានគេយកមកអនុវត្តយ៉ាងទូលំទូលាយ នៅថ្នាក់សិក្សារបស់ក្រុមមនុស្សចាស់។ នៅថ្នាក់កម្រិតនេះ តេស្តត្រូវបានគេអនុវត្តទៅតាមចំណេះដឹង ដ៏សមស្របតាមលំដាប់ដោយ ជាងតេស្តដែលគេធ្វើសម្រាប់ថ្នាក់តូចតាច។ គឺយ៉ាងនេះហើយ បានជានៅថ្នាក់សម្រាប់មនុស្សចាស់ឬថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការដោយសារមូលហេតុជាសត្យានុម័ត គេគ្មានលទ្ធភាពនឹងបណ្តុះបណ្តាលបានតាមមេរៀន ដែលមានលក្ខណៈផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម ដូចសិស្សនៅសាលាចំណេះទូទៅធម្មតាឡើយ។ នៅថ្នាក់នៃកម្រិតមធ្យមសិក្សា តេស្តត្រូវបានបណ្តុះបណ្តាល ឱ្យមាន

លក្ខខណ្ឌកំណត់ជាមុន ក្នុងការបំពេញត្រង់កន្លែងចន្លោះ ដោយចំណេះដឹងដែលដកស្រង់ចេញពី ផ្នែកដាច់ដោយឡែកពីគ្នា ក្នុងកម្មវិធីសិក្សាទាំងមូល។ តេស្ត ត្រូវបានគេធ្វើឡើងសម្រាប់វាស់កម្រិត យល់ដឹង។ ដើម្បីសន្សំសំចៃពេលវេលា គេចូលចិត្តប្រើប្រាស់មធ្យោបាយបង្រៀនតាមកម្មវិធី។

ការត្រួតពិនិត្យសរុបទៅលើការសិក្សារបស់សិស្ស ត្រូវបានអនុវត្តឱ្យបានពេញលក្ខណៈ។

**ប្រឡង៖** វិធីនេះ ជាមធ្យោបាយត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល ចំពោះការងាររបស់ សាស្ត្រាចារ្យ និងសមូហភាពបុគ្គលិកសិក្សាក្នុងសាលារៀន។ ការរៀបចំប្រឡង ជួយសិស្សឱ្យសិក្សាសារ ឡើងវិញ និងធ្វើប្រព័ន្ធកម្មទៅលើចំណេះដឹង ដែលបានរៀនរួចមកហើយ ។ ការប្រឡង តម្រូវឱ្យសិស្ស ស្វ័យភ្ញាក់រលឹកហើយសកម្មក្នុងការសិក្សា។ ទន្ទឹមនឹងនេះ ការប្រឡងទាមទារឱ្យសិស្ស ព្យាយាមប្រឹង ប្រែងអស់ពីសមត្ថភាព។ ការប្រឡង ត្រូវធ្វើឡើងនៅដំណាច់ឆ្នាំសិក្សានីមួយៗ។ ដើម្បីសម្រាលនូវបន្ទុក ដ៏ធ្ងន់ឱ្យដល់សិស្ស សព្វថ្ងៃនេះ យើងគ្រាន់តែរៀបចំការប្រឡងបញ្ចប់អនុវិទ្យាល័យ និងវិទ្យាល័យ ប៉ុណ្ណោះ។ សព្វថ្ងៃនេះ បញ្ហាធ្វើកិច្ចការត្រួតពិនិត្យ និងការប្រឡង មិនទាន់បានដោះស្រាយបានតាម លក្ខណៈវិទ្យាលសាស្ត្រត្រឹមត្រូវពិតប្រាកដនៅឡើយ។ វិធីនេះស្តែងឱ្យឃើញត្រង់ដែលសិស្សមានពេលជា ច្រើន ហើយងាយស្រួលក្នុងការបង្កើតមេរៀនឡើងវិញ ដើម្បីអនុវត្តឱ្យបានសម្រេចតាមគោលដៅរបស់កិច្ច ការត្រួតពិនិត្យ និងការប្រឡង។ គឺយ៉ាងនេះឯង ទើបការគិតរបស់សិស្សបានអនុវត្តដល់កម្រិតខ្ពស់។

ហេតុនេះ យើងគប្បីសិក្សាស្រាវជ្រាវកែច្នៃ ឬកែប្រែឱ្យបានល្អលើសមុន ចំពោះកិច្ចការត្រួតពិនិត្យ និងការប្រឡងដើម្បីទទួលបាននូវលទ្ធផលមួយ ដែលមានកម្រិតខ្ពស់ក្នុងការបង្រៀន និងការអប់រំ។

## គ. វង្វាយតម្លៃចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់៖

**លទ្ធផលនៃការត្រួតពិនិត្យទៅលើស្នាដៃរបស់សិស្ស** ត្រូវបានស្តែងឡើងតាមរយៈនៃវង្វាយតម្លៃទៅលើចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ របស់សិស្ស។

ពេលវាយតម្លៃ សាស្ត្រាចារ្យ គប្បីឈរលើមូលដ្ឋានដូចតទៅ៖

- បរិមាណ និងគុណភាពនៃចំណេះដឹង
- ចំណេះធ្វើក្នុងការអនុវត្តចំណេះដឹង ចំណេះធ្វើក្នុងការបង្កើតសម្ភារៈ តាមកម្មវត្ថុដែលកំណត់
- គុណភាពនៃសេចក្តីអធិប្បាយ (ដោយវាចារ ឬដោយសរសេរ )
- បរិមាណ និងគុណភាពដែលខ្វះខាត
- ការប្រាសចាកប្រធានបទ ឬសំណួរក្នុងកិច្ចការត្រួតពិនិត្យ ឬការប្រឡង

នេះគឺគ្រាន់តែជាមូលដ្ឋានទូទៅក្នុងវង្វាយតម្លៃប៉ុណ្ណោះ។យោងទៅតាមចំណុចពិសេសរបស់មុខវិជ្ជាសិក្សានីមួយៗសាស្ត្រាចារ្យត្រូវធ្វើរូបិកម្មដោយឈរលើមូលដ្ឋាននេះ ក្នុងវង្វាយតម្លៃលើកិច្ចការសិស្ស។

*ឧទាហរណ៍:*

- ចំពោះមុខវិជ្ជាឯកទេសភូមិវិទ្យា សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់វង្វាយតម្លៃឱ្យបាន ត្រឹមត្រូវទៅលើគំនូរ និងបម្រើបម្រាស់ផែនទី ។

-ចំពោះមុខវិជ្ជាឯកទេសគណិតវិទ្យា សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់វង្វាយតម្លៃទៅលើចំណេះធ្វើតាមលក្ខណៈគណិតវិទ្យា

-ចំពោះមុខវិជ្ជាឯកទេសគីមីវិទ្យា សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់វង្វាយតម្លៃក្នុងការថ្លឹងសមីការការពិសោធន៍។

**លទ្ធផលនៃវង្វាយតម្លៃត្រូវបានកំណត់ដោយការដាក់ពិន្ទុ:**

- នៅសហភាពសូវៀត គេប្រើប្រាស់ប្រព័ន្ធពិន្ទុត្រឹម៥ គឺពី៥ទៅ១
- នៅសាធារណៈរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ គេប្រើប្រាស់ប្រព័ន្ធពិន្ទុត្រឹម៥ដែរ គឺពី១ទៅ៥
- នៅសាធារណៈរដ្ឋប្រជាមានិតចិន គេប្រើប្រាស់ប្រព័ន្ធពិន្ទុ ពី០ទៅ១០០
- នៅសាធារណៈរដ្ឋបារាំង គេប្រើប្រាស់ប្រព័ន្ធពិន្ទុ ពី១ទៅ២០
- នៅសហរដ្ឋអាមេរិក គេប្រើប្រាស់ប្រព័ន្ធពិន្ទុមាន ពី១ទៅ២០០
- នៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម គេប្រើប្រាស់ប្រព័ន្ធពិន្ទុមានពី១ទៅ១០

**ឃ. ពេលត្រួតពិនិត្យ និងវាយតម្លៃទៅលើចំណេះដឹង ចំណេះធ្វើ និងបំណិនរបស់របស់ សិស្ស**

សាស្ត្រាចារ្យ ត្រូវគោរតាមសំណូមដាកំណត់ដូចទៅះ

- ត្រូវដាក់កិច្ចការត្រួតពិនិត្យ ឱ្យមានប្រចាំទៅតាមប្រព័ន្ធមេរៀន តាមផែនការកំណត់ រួមផ្សំគ្នាច្រើនប្រភេទ ឬប្រើរូបភាព
- ត្រូវអប់រំសិស្ស ឱ្យមានមនសិការត្រឹមត្រូវ ចំពោះកិច្ចការត្រួតពិនិត្យ ឱ្យសិស្សមានមនសិការស្វ័យត្រួតពិនិត្យ ការពារសតិអារម្មណ៍ក្នុងការស្វែងរកពិន្ទុល្អ អាកប្បកិរិយាទប់ទល់ ឬជម្នះបានលើភាព លំបាកក្នុងកិច្ចការត្រួតពិនិត្យ
- ត្រូវវាយតម្លៃ ឱ្យបានត្រឹមត្រូវតាមសត្យានុម័ត និងគតិយុត្តិធម៌ចៀសវាងការត្រួតពិនិត្យ និងការវាយតម្លៃ តាម បែបរូបភាព ចៀសវាងការលំអៀង សញ្ចេតនាការស្អប់ គុំទុកក្នុងចិត្ត វង្វាយតម្លៃស្រាលៗ ការដាក់ពិន្ទុ បន្ថែមឬបន្ថយទៅលើពិន្ទុដែលដាក់រួចមកហើយ (ដូចជា: +៣, -២) ហើយមិនត្រូវយកពិន្ទុ ទៅគំរាមកំហែងសិស្សឡើយ។ពេលវាយតម្លៃដាក់ពិន្ទុ ត្រូវលើកឡើងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សទៅតាមចម្លើយនិងសំណេរ (ស្អាតបាត កខ្វក់ ច្បាស់លាស់ ) ហើយត្រូវបង្ហាញទិសរីកចម្រើនរបស់សិស្ស។ ប្រសិនបើអាចធ្វើបាន និងយោងទៅតាមកាលៈទេសៈដ៏សមស្រប ត្រូវមានការសរសេរលើកទឹកចិត្ត ការប្រគល់ប័ណ្ណសរសើរ ឬលិខិតសរសើរនៅដំណាច់ត្រីមាសឆមាស ចុងឆ្នាំ ឬនៅពេលរៀនចប់មុខវិជ្ជាសិក្សានីមួយៗ។

**សេចក្តីសន្និដ្ឋានសរុបៈ**

១. វិធីបង្រៀនទាំងអស់ ផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទទៅតាមគោលដៅអប់រំ ភារកិច្ច និងខ្លឹមសារនៃការបង្រៀន។

២. វិធីបង្រៀននីមួយៗ មានចំណុចខ្លាំង និងចំណុចខ្សោយដោយឡែករបស់វា។ នៅក្នុងការអនុវត្តសាស្ត្រាចារ្យត្រូវចេះប្រើប្រាស់គួបផ្សំឱ្យបានយ៉ាងប៉ិនប្រសប់ ហើយមិនត្រូវចាត់ទុកថា វិធីបង្រៀននីមួយៗមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការសម្រេចបានគ្រប់ការងារ និងភារកិច្ចនៃការបង្រៀនទាំងអស់នោះទេ។

៣. បម្រើបម្រាស់វិធីបង្រៀន ត្រូវតែនាំមកនូវលទ្ធផលជាផ្លែផ្កាដូចជា ការផ្តល់ចំណេះដឹង ការអប់រំ និងការអភិវឌ្ឍខាងសតិបញ្ញាជាដើម។

៤. ជម្រើស និងបម្រើបម្រាស់វិធីបង្រៀនទាំងអស់ ត្រូវតែពឹងផ្អែកលើកត្តាសំខាន់ៗដូចតទៅះ

- ភារកិច្ចនៃមេរៀនដែលត្រូវបកស្រាយ ពន្យល់ (ផ្សព្វផ្សាយ ចំណេះដឹងថ្មី ត្រួតពិនិត្យ សិក្សាសារឡើងវិញ)

- លក្ខណៈពិសេសរបស់មុខវិជ្ជាសិក្សានីមួយៗ
- ខ្លឹមសារជាក់ស្តែងរបស់មេរៀននីមួយៗ
- លក្ខណៈពិសេសរបស់កម្មវត្ថុសិក្សា (សិស្ស អាយុ កម្រិតយលដឹងនិងជីវភាព)
- ស្ថានភាព និងលក្ខខណ្ឌចាំបាច់របស់សាលារៀន

**៥**. គោលការណ៍នៃការបង្រៀនទាំងអស់ត្រូវបានសាស្ត្រាចារ្យយល់ឱ្យច្បាស់លាស់ក្នុងជម្រើស និង បម្រើបម្រាស់វិធីបង្រៀន ។

**៦**. ចំពោះវិធីបង្រៀនតាមប្រពៃណី ទោះណាជាមានចំណុចខ្លាំង និងចំណុចខ្សោយ ជាកំណត់ ដ៏ដោយក៏មិនទាន់បានជំរុញសិស្សឱ្យមានលក្ខណៈសកម្មម្ចាស់ការក្នុងការគិតនិងការក្តាប់យកចំណេះដឹងឈានដល់កម្រិតខ្ពស់នៅឡើយ។ ដូចនេះហើយបានជាសព្វថ្ងៃនេះគេកំពុងតែកែលំអវិធីបង្រៀនទាំងនេះឱ្យកាន់តែសុក្រឹតឡើងថែមទៀតហើយ ជាពិសេសគេកំពុងរកឃើញវិធីបង្រៀនថ្មីៗទៀតដែលរួមចំណែកដល់ការលើកកម្ពស់លទ្ធផលជាផ្លែផ្ការបស់សកម្មភាពនៃការបង្រៀន ការអប់រំ និងការសិក្សា។

## សំណួរ

១.ចូររំលឹកឡើងវិញពីសិក្សានៅសាលាចំណេះទូទៅកម្ពុជាក្រោយឆ្នាំ១៨៦៣ និងក្រោយឆ្នាំ១៩៧០។

២.ដើម្បីបង្រៀននិងរៀនល្អ ចំពោះមុខវិជ្ជាសិក្សានីមួយៗ សាស្ត្រាចារ្យ ត្រូវប្រើវិធីបង្រៀនបែបណា?

៣.វិធីបង្រៀនណាខ្លះ ដែលសមស្របនឹងយកមកប្រើប្រាស់ ក្នុងការបង្រៀនមុខវិជ្ជាវិ ទ្យាសាស្ត្រសង្គម និងមុខវិជ្ជា វិទ្យាសាស្ត្រធម្មជាតិ?

៤. ចូរលើកឡើងពីចំណុចសំខាន់ៗ ក្នុងអត្ថន័យរបស់វិធីបង្រៀននីមួយៗ។

៥. ប្រៀបធៀបចំណុចខ្លាំង និងចំណុចខ្សោយរបស់វិធីបង្រៀននីមួយៗ។

៦. ដើម្បីពង្រឹងចំណេះដឹង ដែលសិស្សបានរៀនរួចមកហើយ សាស្ត្រាចារ្យ ត្រូវប្រើរូបភាពត្រួតពិនិត្យបែបណាខ្លះដើម្បីឱ្យមានប្រសិទ្ធភាព?

## មេរៀនទី ៤ ខ្លឹមសារ និង លំនាំនៃការបង្រៀន

### ៤.១ វត្ថុបំណងមេរៀន

- ក្តាប់បានសញ្ញាណទូទៅ សារជាតិដ៏សមហេតុផល និងមូលហេតុដើមរបស់លំនាំនៃការបង្រៀន
- ផ្សារភ្ជាប់ជំហានដំបូងនៃការបង្រៀនទៅនឹងភាពជាក់ស្តែងនៅសាលារៀនចំណេះទូទៅ ទៅនឹងភាពជាក់ស្តែងក្នុងមុខវិជ្ជាសិក្សារបស់សាស្ត្រាចារ្យម្នាក់ៗ ដែលកំពុងបង្រៀន ឬបម្រុងនឹងបង្រៀន រួចដកស្រង់យកនូវចំណុចខ្លាំងពូកែ និងចំណុចខ្សោយនៅក្នុងលំនាំនៃការបង្រៀន។
- ការបង្រៀនសិស្សជាលំនាំនៃការផ្តល់ចំណេះដឹងវិទ្យាសាស្ត្រមួយ ជាសិល្បៈមួយ ជាបច្ចេកទេសមួយ និងជាសីលធម៌មួយ។
- ក្តាប់បានច្បាស់ពីសញ្ញាណស្តីពីការបង្រៀន និងការស្តែងចេញនូវខ្លឹមសារនៃការបង្រៀន
- ក្តាប់បានគោលការណ៍ជាមូលដ្ឋានដើម្បីរៀបចំខ្លឹមសារនៃការបង្រៀន

### ៤.២.សញ្ញាណស្តីពីការបង្រៀន

ដូចម្តេចដែលហៅថា ខ្លឹមសារនៃការបង្រៀន ?

ខ្លឹមសារនៃការបង្រៀនគឺជា៖

ក. ប្រព័ន្ធនៃចំណេះដឹងស្តីពីធម្មជាតិ សង្គម ការគិត បច្ចេក ទេស និងសកម្មភា ពបញ្ញា ហើយឈរលើមូល ដ្ឋាននៃប្រព័ន្ធចំណេះដឹងទាំងនោះ សាស្ត្រាចារ្យ អាចបណ្តុះបណ្តាលបាននូវទស្សនៈវិទ្យាសាស្ត្រ ដល់ សិស្ស។

ខ. ប្រព័ន្ធនៃចំណេះធ្វើ និងបំណិនប្រសប់ ស្តីពីសកម្មភាពបញ្ញា និងការប្រតិបត្តិ

គ. បទពិសោធន៍ស្តីពីសកម្មភាពច្នៃប្រឌិត និងចរិតលក្ខណៈជាមូលដ្ឋាននៃសកម្មភាព នោះដែលមនុស្សជាតិបានចងក្រងទុក នៅក្នុងលំនាំនៃការអភិវឌ្ឍរបស់ប្រវត្តិសាស្ត្រក្នុងសង្គមមនុស្ស។

ឃ. ប្រព័ន្ធនៃនិយាម ស្តីពីអាកប្បកិរិយារបស់មនុស្សចំពោះធម្មជាតិ សង្គម និងចំពោះខ្លួនឯង។ តាមពិតជម្រើសខ្លឹមសារនៃមេរៀន ត្រូវធ្វើឡើងដោយយោងទៅតាមសមត្ថភាពយល់ដឹងរបស់សិស្ស និង ត្រូវឱ្យបានសមស្របទៅនឹងភារកិច្ចនៃការបង្រៀន និងការអប់រំដែលសង្គមបានកំណត់។ យើងនឹងសិក្សាឱ្យបានលម្អិតអំពីធាតុសំខាន់ៗ របស់ខ្លឹមសារនៃការបង្រៀន។

### ៤.៣ ធាតុទី១ ជាមូលដ្ឋាននៃចំណេះដឹង ៖

ខ្វះចំណេះដឹង គឺខ្វះមូលដ្ឋានដើម្បីបណ្តុះបណ្តាលទស្សនៈវិទ្យាសាស្ត្រ និងសីលធម៌។ នោះជាហេតុនាំឱ្យខ្វះវិធីសាស្ត្រដ៏ត្រឹមត្រូវ នៅក្នុងសកម្មភាពយល់ជ្រួតជ្រាបចំណេះដឹង និងការប្រតិបត្តិ។ ក្នុងន័យនេះ គឺថា ខ្វះចំណេះដឹងជាហេតុនាំឱ្យសកម្មភាពដឹកនាំចុះខ្សោយ ហើយគ្មានប្រសិទ្ធភាពអ្វីទាំងអស់។ ដូចដែលយើងបាន យល់ដឹងរួចមកហើយ ចំណេះដឹងដែលមនុស្សជាតិបានចងក្រងទុកមកនោះ គឺមានច្រើនអនេក។ មនុស្ស ម្នាក់ៗមិនអាចក្តាប់ចំណេះដឹងទាំងអស់នោះបានឡើយ។មនុស្សម្នាក់ៗមានលទ្ធភាពក្តាប់ចំណេះដឹង ទាំងនោះ បានតែមួយផ្នែកៗប៉ុណ្ណោះ។ ប្រការដ៏សំខាន់ គឺចំណេះដឹងទាំងនោះត្រូវបានបែងចែកជាវិស័យ ចំណេះដឹង ផ្សេងៗគ្នា សម្រាប់យកធ្វើជាមូលដ្ឋាននៃវិទ្យាសាស្ត្រ និងសម្រាប់យកធ្វើជាគម្រូឱ្យដល់សកម្មភាពសង្គម និងជីវភាព រស់នៅ។ ចំណេះដឹង ដែលមនុស្សម្នាក់ក្តាប់បាននោះ ត្រូវបែងចែកទៅតាមរូប

ភាពនៃ វិទ្យាសាស្ត្រ ជា មូល ដ្ឋានគ្រឹះ។ ក្នុងករណីនេះ ចំណេះដឹងថ្មីដែលមនុស្សម្នាក់ៗយល់ជ្រួតជ្រាប និងក្តាប់បាននោះ មានមុខងារ ជាមូលដ្ឋានរបស់ខ្លួន គឺបង្កើតបានជារូបភាពទាំងមូលស្តីពីវិទ្យាសាស្ត្រ និងសីលធម៌ក្នុងសង្គម ជាឧបករណ៍ក្នុង ការយល់ជ្រួតជ្រាបចំណេះដឹង និងសកម្មភាពប្រតិបត្តិ។

ដូចនេះខ្លឹមសារមេរៀនក្នុងគ្រប់មុខវិជ្ជាសិក្សាទាំងអស់នៅសាលារៀនចំណេះទូទៅត្រូវបែងចែកជាផ្នែកចំណេះដឹងដូចតទៅ៖

## ៤.៣.១ ចំណេះដឹងមានលក្ខណៈជាបទពិសោធន៍

ផ្នែកចំណេះដឹង ដែលមានលក្ខណៈជាបទពិសោធន៍គឺ៖

- បណ្តារូបតំណាងជាក់ស្តែង និងចំណាប់អារម្មណ៍លើវត្ថុ និងបាតុភូតនៅក្នុងលោកៈសត្យានុម័ត
- សញ្ញាណ និងលក្ខណៈរបស់វត្ថុ និងបាតុភូតទាំងនោះ
- ព្រឹត្តិការណ៍ដែលឆ្លុះបញ្ចាំងពីបាតុភូតសង្គម និងសកម្មភាពរបស់តួអង្គនៅក្នុងអត្ថបទអក្សរសិល្ប៍
- ចំណេះដឹងស្តីពីប្រវត្តិសាស្ត្រនៃវិទ្យាសាស្ត្រនិងអ្នកបង្កើតវប្បធម៌វិទ្យាសាស្ត្រដ៏ល្បីល្បាញក្នុងពិភពលោក

ខ្វះចំណេះដឹង ស្តីពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនោះគឺ មិនអាចបណ្តុះបណ្តាលបាននូវសញ្ញាណ និងក្រឹត្យក្រមវិទ្យាសាស្ត្រ ហើយក៏មិនអាចមានជំនឿដ៏ជ្រាលជ្រៅលើវិទ្យាសាស្ត្រ ឬក៏មិនអាចស្រាយ បំភ្លឺ និងការពារបាននូវឧត្តមគតិរបស់ខ្លួនបានឡើយ។

## ៤.៣.២ ចំណេះដឹងជាទ្រឹស្តី

នោះគឺជាលទ្ធផលបូកសរុបរបស់ចំណេះដឹងលើលោក ដែលមានលក្ខណៈសង្គមប្រវត្តិ និងវិទ្យាសាស្ត្រ ដូចជាសញ្ញាណក្រឹត្យក្រម គោលការណ៍ ទ្រឹស្តីជាមូលដ្ឋាន សតិអារម្មណ៍វិទ្យាសាស្ត្រក្នុងការដឹកនាំ ឬគ្រប់គ្រង ឧត្តមគតិ សតិអារម្មណ៍ស្តីពីលោកទស្សនៈ ក្បួនច្បាប់ សីលធម៌ សិល្បវិទ្យា និងសិទ្ធិសេរីភាព។

**ចំណេះដឹងទ្រឹស្តីនោះបែងចែកជា៖**

ក. បណ្តាសញ្ញាណវិទ្យាសាស្ត្រ និងបច្ចេកស័ព្ទវិទ្យាជាមូលដ្ឋាន

ខ. បណ្តាក្រឹត្យក្រមវិទ្យាសាស្ត្រជាមូលដ្ឋាន ដែលបង្កើតបានជាចំណងទាក់ទងរវាងកម្មវត្ថុ និងបាតុភូតផ្សេងៗគ្នាក្នុងតថភាពសត្យានុម័ត។

គ. បណ្តាក្រឹត្យក្រមវិទ្យាសាស្ត្រដែលអ្នកប្រាជ្ញបានចងក្រងជាប្រព័ន្ធនៃចំណេះដឹងវិទ្យាសាស្ត្រស្តីពីវិធីសាស្ត្រក្នុងបំណកស្រាយពន្យល់ និងបេកគំហើញលើវត្ថុ ឬបាតុភូតនៅក្នុងវិស័យណាមួយនោះ។

ឃ. បណ្តាឧត្តមគតិស្តីពីវិទ្យាសាស្ត្រ និងសង្គមដែលបានកំណត់នូវអាកប្បកិរិយារបស់មនុស្សម្នាក់ៗចំពោះលោក។

ង. បណ្តាក្បួនច្បាប់ សីលធម៌ សិល្បវិជ្ជា សិទ្ធិអំណាច ការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជា ធិប្បតេយ្យ។

## ៤.៣.៣ ចំណេះដឹងក្នុងការអនុវត្ត

ចំណេះដឹងក្នុងការអនុវត្ត គឺជាចំណេះដឹងដែលសំដៅធ្វើឱ្យសិស្សក្តាប់បាននូវចំណេះធ្វើ និងបំណិន ប្រសប់ក្នុងការអនុវត្ត។ ចំណេះដឹងទាំងនោះរួមមាន ចំណេះធ្វើដែលឈានចូលក្នុងការសិក្សាស្រាវជ្រាវ ចំណេះដឹងថ្មី និងចំណេះធ្វើក្នុងបម្រើបម្រាស់ចំណេះដឹងថ្មីនោះ នៅក្នុងការប្រតិបត្តិ។ លំនាំនៃការក្តាប់ យកចំណេះដឹងនៅក្នុងការអនុវត្តនេះ ចេះតែអភិវឌ្ឍឡើងជាលំដាប់។

## ៤.៣.៤ ចំណេះដឹងក្នុងសកម្មភាពច្នៃប្រឌិត

ចំណេះដឹងទាំងនេះមិនគ្រាន់តែបណ្តុះបណ្តាលបាននូវសញ្ចេតនាសីលធម៌និងសិល្បវិជ្ជា ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជួយដល់ការអភិវឌ្ឍខាងផ្នែករូបារម្មណ៍ច្នៃប្រឌិតទៀតផង។ ឆ្លងកាត់តាមរយៈ ការសិក្សាអត្ថបទអក្សរសិល្ប៍វិចិត្រសិល្បៈ តូរ្យតន្ត្រី សាស្ត្រាចារ្យ ត្រូវបណ្តុះបណ្តាល ឱ្យដល់សិស្សនូវ រូបភាពសិល្បៈ ស្តីពីបទភ្លេង គំនូរ រូបភាពទៅតាមឧត្តមគតិដែលបានកំណត់។ ទន្ទឹមនឹងនេះ សាស្ត្រាចារ្យ ត្រូវបណ្តុះបណ្តាលឱ្យសិស្សថែមទៀតនូវរូបភាពកសាងគម្រោងបច្ចេកទេសច្នៃប្រឌិត។ **ច/ចំណេះដឹងក្នុងវិធីសិក្សាស្រាវជ្រាវ**

ចំណេះដឹងវិទ្យាសាស្ត្រ ត្រូវបានបញ្ចូលទៅក្នុងមុខវិជ្ជាសិក្សានីមួយៗ ដែលសិស្សត្រូវរៀន។ បើខ្វះចំណេះដឹងវិទ្យាសាស្ត្រជាមូលដ្ឋាន នៅក្នុងមុខវិជ្ជាសិក្សានីមួយៗ សិស្សមិនអាចយល់ជ្រួតជ្រាប និងក្តាប់បានច្បាស់លាស់នូវចំណេះដឹងដែលបានសិក្សានៅក្នុងមុខវិជ្ជាសិក្សានីមួយៗនោះបានឡើយ។រីឯសតិបញ្ញាក្នុងការសិក្សារបស់សិស្ស ក៏មិនអាចអភិវឌ្ឍឡើងបានដែរ។

រូបភាពនៃចំណេះដឹងក្នុងមុខវិជ្ជានីមួយៗខុសប្លែកគ្នា មានតួនាទីផ្សេងៗគ្នានៅក្នុង ការបង្រៀន និងការអប់រំ។ ហេតុនេះសាស្ត្រាចារ្យ ត្រូវប៉ិនប្រសប់រៀបចំបង្រៀនសិស្ស ឱ្យចេះប្រើប្រាស់ចំណេះដឹង ទាំងនោះទៅតាមរបៀបផ្សេងៗគ្នាដើម្បីឱ្យសិស្សយល់ជ្រួតជ្រាបនិងក្តាប់បាននូវចំណេះដឹងទាំងនោះ ឱ្យបានរឹងមាំច្បាស់លាស់។ទន្ទឹមនឹងនេះរូបភាពនៃចំណេះដឹងទាំងនោះ ក៏ផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធដែរ។ ដូចនេះ សាស្ត្រាចារ្យ ត្រូវបង្រៀនសិស្សតាមវិធីគួបផ្សំគ្នារវាងចំណេះដឹងទាំងនោះ។

## ៤.៤ ធាតុទី២ គឺជាបទពិសោធន៍ក្នុងសកម្មភាព ៖

ជាតុទី១របស់ខ្លឹមសារនៃការបង្រៀនបានបែងចែកចំណេះដឹងទៅតាមសកម្មភាព។បើខ្វះចំណេះដឹងនោះបម្រើបម្រាស់វិធីអនុវត្តទៅលើចំណេះដឹងណាមួយនោះ តែងតែធ្វើឡើងទៅតាមគំនិតយល់ឃើញរបស់ខ្លួនឯង។ប៉ុន្តែបើគ្រាន់តែក្តាប់បាននូវចំណេះដឹងនោះប៉ុណ្ណោះគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេគឺត្រូវតែក្តាប់បាននូវបទពិសោធន៍ ក្នុងការអនុវត្តចំណេះដឹងនោះផងទើបគ្រប់គ្រាន់។ បទពិសោធន៍ទាំងនោះ គឺជាបទពិសោធន៍ដែលមនុស្សជាតិបានចងក្រងទុកនៅតាមលំនាំនៃពលកម្មរបស់សង្គមមនុស្ស។ បទពិសោធន៍ទាំងនោះស្ថិតនៅក្រៅចំណេះដឹងរបស់បុគ្គលម្នាក់ៗ កាលណាបុគ្គល មិនទាន់បានយល់ជ្រួតជ្រាបបទពិសោធន៍ទាំងនោះ ហើយមិនទាន់ប្រែក្លាយបទពិសោធន៍ទាំងនោះ ឱ្យទៅជាបទពិសោធន៍ផ្ទាល់ ខ្លួននៅក្នុងលំនាំនៃសកម្មភាពអនុវត្ត។ ចំណេះធ្វើ និងបំណិនប្រសប់ គឺជាបទពិសោធន៍ស្តីពីវិធីអនុវត្ត ផ្សេងៗគ្នាដែលមនុស្សបានឆ្លងកាត់រួចមកហើយ។ កាលណាមនុស្សមានចំណេះធ្វើ និងបំណិនប្រសប់ក្នុង ការអនុវត្ត បានន័យថា មនុស្សនោះមានចំណេះធ្វើ និងបំណិនប្រសប់ក្នុងវិស័យបញ្ញា។ ដូចនេះ មនុស្ស ម្នាក់ៗត្រូវមានចំណេះធ្វើ និងបំណិនប្រសប់ទូទៅចំពោះមុខវិជ្ជាសិក្សាទាំងអស់ដូចជា ចំណេះធ្វើ និង បំណិនប្រសប់ ក្នុងការរៀបចំគម្រោងការងារ ចំណេះធ្វើនិងបំណិនប្រសប់ក្នុងការប្រៀបធៀបក្នុង ទំនាញសន្និដ្ឋានសរុប ក្នុងការរែកញែករកចំណុចខ្លាំង និងចំណុចខ្សោយក៏ដូចជាចំណេះធ្វើ និងបំណិនប្រសប់ក្នុងមុខវិជ្ជាសិក្សានីមួយៗ ដោយឡែកដែរ។

*ឧទាហរណ៍៖*

ចំណេះធ្វើ និងបំណិនប្រសប់ ដែលក្តាប់បានក្នុងការពិសោធន៍ទៅលើមុខវិជ្ជាសិក្សា រូបវិទ្យា គឺមី

វិទ្យា ជីវវិទ្យា និងចំណេះធ្វើ ក្នុងដំណោះស្រាយគណិតវិទ្យា។

ក្នុងចំណោមចំណេះធ្វើ និងបំណិនប្រសប់ទាំងនេះ មានចំណេះធ្វើ និងបំណិនប្រសប់ខ្លះផ្សារភ្ជាប់គ្នាដោយផ្ទាល់ទៅនឹងការត្រិះរិះផ្នែកបញ្ញា ហើយក៏មានចំណេះធ្វើ និងបំណិនប្រសប់ខ្លះទៀត គ្រាន់តែបង្ហាញនូវលក្ខខ័ណ្ឌលើភាពម្ចាស់ការ ក្នុងការយល់ជ្រួតជ្រាបចំណេះដឹងប៉ុណ្ណោះ។ នោះ គឺជាចំណេះធ្វើ និងបំណិនប្រសប់ដែលសរុបបានពីក្នុងការពិនិត្យសង្កេត ការទិទៀន ការរៀបចំគម្រោងការងារ ការរៀបចំបញ្ជី ឬបម្រើបម្រាស់សៀវភៅ និងឯកសារសិក្សាជាដើម។

## ៤.៥ ធាតុទី៣ គឺជាបទពិសោធន៍នៃសកម្មភាពច្នៃប្រឌិត៖

ធាតុទី៣ របស់ខ្លឹមសារនៃការបង្រៀន សំដៅរៀបចំឱ្យសិស្សមានសមត្ថភាពយល់ដឹង និងដោះស្រាយបាននូវបញ្ហាអ្វីៗដែលថ្មីថ្មោង។ បើសាលារៀន គ្រាន់តែផ្តល់ឱ្យសិស្សនូវចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ក្រោមរូបភាពនៃទិន្នន័យ និងទម្រង់ទេនោះ គឺមិនអាចបណ្តុះបណ្តាលបាននូវ សមត្ថភាពច្នៃប្រឌិតឱ្យសិស្សបានឡើយ។ ដូចនេះ សាស្ត្រាចារ្យត្រូវបង្រៀន និងអប់រំសិស្សឱ្យមានភាពម្ចាស់ការ ក្នុងការត្រិះរិះវិនិច្ឆ័យដើម្បីទទួលយល់ជ្រួតជ្រាបនិងក្តាប់បាននូវចំណេះដឹងដែលផ្សារភ្ជាប់ជាប្រព័ន្ធ សំដៅពង្រឹងគំនិតច្នៃប្រឌិតរបស់សិស្ស។

តើសកម្មភាពច្នៃប្រឌិត មានចរិតលក្ខណៈយ៉ាងណាខ្លះ?

បណ្តាចរិតលក្ខណៈ នៅក្នុងសកម្មភាពច្នៃប្រឌិតមាន៖

១. មើលឃើញមុខងារថ្មី របស់កម្មវត្ថុសិក្សា
២. ធ្វើសំយោគដោយឡែកពីបែបបទសកម្មភាពដែលបានយល់ដឹងរួចហើយ ឱ្យទៅជាបែបបទសកម្មភាពថ្មី។
៣. មើលឃើញរចនាសម្ព័ន្ធ របស់កម្មវត្ថុសិក្សា
៤. មើលឃើញវិធីដោះស្រាយផ្សេងៗគ្នា ទៅលើបញ្ហាណាមួយនោះ
៥. កសាងបាននូវវិធីដោះស្រាយថ្មីមួយទៀតផ្សេងគ្នាពីវិធីដោះស្រាយដែលបានយល់ដឹង រួចមកហើយ។

ទោះជានៅពេលណាក៏ដោយ ចរិតលក្ខណៈទាំងអស់របស់សកម្មភាពច្នៃប្រឌិត សុទ្ធតែស្តែងឡើងក្នុងពេលដោះស្រាយបញ្ហា។ មិនថាបញ្ហាណាឡើយ ជានិច្ចកាល សិស្សត្រូវចេះគួបផ្សំវិធី ដោះស្រាយផ្សេងគ្នាឱ្យមកជាចរិតលក្ខណៈច្នៃប្រឌិតតែមួយរបស់ខ្លួន។

## ៤.៦ ធាតុទី៤ គឺជាឥរិយាបថរបស់មនុស្សចំពោះធម្មជាតិ សង្គម និងមនុស្សផ្សេងគ្នា៖

ធាតុទី៤ នេះគឺជាចរិតអប់រំរបស់ខ្លឹមសារនៃការបង្រៀន។ រូបភាពនៃខ្លឹមសារនេះ មានចរិតលក្ខណៈរបស់ វា ពីព្រោះវាមិនអាចបែងចែកជាចំណេះដឹង ឬចំណេះធ្វើបានឡើយ ថ្វីបើធាតុនេះសំខាន់ និងចាំបាច់យ៉ាងណា ក៏ដោយ។ ធាតុនេះ ស្តែងឡើងដោយអាកប្បកិរិយា វង្វាយតម្លៃ និងសញ្ចេតនារបស់មនុស្សចំពោះលោកៈ ចំពោះ សង្គម ចំពោះមនុស្សផងគ្នា និងចំពោះសកម្មភាព។ នៅក្នុងតថភាព យើងតែងសង្កេតឃើញអាកប្បកិរិយា របស់ មនុស្ស ចំពោះតថភាពជុំវិញខ្លួនឯង និងសញ្ចេតនាសមស្រប ឬមិនសមស្រប ឬមិនដូចគ្នាជាមួយនឹងខ្លឹមសារនៃ ចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់ខ្លួន។ តាមពិត ចំណេះដឹងរបស់មនុស្សទោះជាក្នុង កាលៈទេសៈណាក៏ដោយ ត្រូវតែឱ្យបានសមស្របទៅនឹងសកម្មភាពរបស់ខ្លួន។

ដោយឆ្លងកាត់តាមរយៈខ្លឹមសារនៃការបង្រៀន សាស្ត្រាចារ្យ ត្រូវតែបណ្តុះបណ្តាលលោក ទស្ស

នៈវិទ្យាសាស្ត្រ និងអប់រំសញ្ចេតនាដ៏ត្រឹមត្រូវបរិសុទ្ធ អាកប្បកិរិយាក្នុងរង្វាយតម្លៃ និងចិត្តរំភើបចំពោះ វិទ្យាសាស្ត្រ ចំពោះនិយាមសីលធម៌ និងសិល្បៈវិទ្យាឱ្យដល់សិស្ស។

ជាតុទាំង៤ របស់ខ្លឹមសារនៃការបង្រៀននេះ ផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ។ កាលបើខ្វះចំណេះដឹងរបស់ខ្លួនសាស្ត្រាចារ្យមិនអាចបណ្តុះបណ្តាលចំណេះធ្វើ ឱ្យដល់សិស្សបានឡើយ។ សកម្មភាពច្នៃប្រឌិតត្រូវតែបានស្តែងឡើង ដោយឈរលើមូលដ្ឋាននៃចំណេះដឹង និងចំណេះធ្វើ ដែលសិស្សបានយល់ជ្រួតជ្រាបរួចមកហើយ។ ប៉ុន្តែ សាស្ត្រាចារ្យ ត្រូវតែមើលឃើញនូវបទពិសោធន៍ក្នុងសកម្មភាពច្នៃ ប្រឌិត របស់សិស្ស ដែលសមស្រប ឬមិនសមស្របទៅនឹងគុណភាពនៃចំណេះដឹងរបស់សិស្ស។ បទពិសោធន៍ ក្នុងសកម្មភាពច្នៃប្រឌិតទាំងនោះ នឹងជួយសិស្សឱ្យក្តាប់បាន ឬយល់ជ្រួតជ្រាបបានដោយងាយទៅ លើចំណេះដឹង ចំណេះធ្វើ។ ចរិតអប់រំរបស់ខ្លឹមសារនៃការបង្រៀននេះ ទាមទារឱ្យមានចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ក្នុងតថភាព និងក្នុងសកម្មភាពប្រតិបត្តិ។ គឺចំណេះដឹងទាំងនេះឯង ដែលផ្តល់វិភាគទានឱ្យ ដល់សិស្ស ឱ្យមានអាកប្បកិរិយាដ៏ត្រឹមត្រូវក្នុងរង្វាយតម្លៃ និងសញ្ចេតនាដ៏បរិសុទ្ធចំពោះធម្មជាតិ ចំពោះសង្គម និងចំពោះមនុស្សផងគ្នា រួចហើយ អាចកំណត់បានជាចំណេះធ្វើ និងបំណិនប្រសប់ផ្ទាល់ខ្លួន។

## ៤.៧ ចរិតប្រវត្តិសាស្ត្ររបស់ខ្លឹមសារនៃការបង្រៀន

ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ក៏ខ្លឹមសារនៃការបង្រៀនមានចរិតប្រវត្តិសាស្ត្រដែរ។ របបគ្រប់គ្រងយ៉ាង ណាខ្លឹ មសារនៃការបង្រៀន ក៏មានលក្ខណៈយ៉ាងនោះដែរ។

គោលដៅ និងភារកិច្ចនៃការអប់រំរបស់សង្គមមួយ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ នូវខ្លឹមសារនៃការ បង្រៀន។ ខ្លឹមសារនេះ ឆ្លុះបញ្ចាំងឱ្យឃើញជានិច្ចនូវសំណូមពរ ស្តីពីនយោបាយ និងសេដ្ឋកិច្ចរបស់សង្គម មួយជាក់លាក់ ហើយទន្ទឹមនឹងនេះ ឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវកម្រិតអភិវឌ្ឍរបស់ខឿនវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសរបស់សង្គមនោះ។ករណីនេះ មានន័យថា រួមជាមួយនឹងការអភិវឌ្ឍរបស់សង្គមប្រវត្តិ និងវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ខ្លឹមសារនៃការបង្រៀនតែងតែអភិវឌ្ឍ ហើយផ្លាស់ប្តូរជានិច្ច។

ខ្លឹមសារនៃការបង្រៀនសំដៅបណ្តុះបណ្តាលមនុស្ស និងកសាងធនធានមនុស្សដែលមាន អត្តចរិតសំខាន់ៗគឺៈ

- ចិត្តស្មោះត្រង់ចំពោះសង្គមជាតិ ប្រជាជន និងដើរតាមគោលមាគាននយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលគ្រប់ពេលវេលា។
- ប្រកាន់នូវសីលធម៌ជាជនស្អាតស្អំមិនពាលាអាវ៉ាសែនិងមិនលោភលន់ ហើយជាអ្នកមានសេចក្តីអំណត់ ព្យាយាម ស្មារតីជឿនលឿន និងសុខភាពល្អគ្រប់គ្រាន់។
- មានសាមគ្គីផ្ទៃក្នុង និងសាមគ្គីអន្តរជាតិល្អ និងគំនិតសុទិដ្ឋិនិយមគ្រប់ជ្រុងជ្រោយ
- មានស្មារតីសមូហភាព ស្រលាញ់ពលកម្ម និងមានភាពម្ចាស់ការច្នៃប្រឌិតក្នុងការងារ
- មានគុណសម្បត្តិល្អ និងមានសមត្ថភាព កម្រិតវប្បធម៌ នយោបាយ មុខជំនាញ បច្ចេកទេសគ្រប់គ្រាន់ក្នុងការងារ

## ៤.៨ គោលការណ៍ជាមូលដ្ឋាន ក្នុងការគោក់តែងខ្លឹមសារនៃការបង្រៀន

ការកំណត់ខ្លឹមសារនៃការបង្រៀន មានអត្ថន័យសំខាន់ណាស់ ចំពោះការ ធ្វើឱ្យបាន សម្រេចនូវគោលដៅ និងភារកិច្ចរបស់ការអប់រំ។ ដើម្បីកំណត់ច្បាស់ នូវខ្លឹមសារនៃការបង្រៀន ឱ្យបាន សមស្រប

ទៅនឹងការអភិវឌ្ឍខាងវិស័យសេដ្ឋកិច្ច និងវប្បធម៌ តាមគោលការណ៍នយោបាយដឹកនាំ របស់រាជរដ្ឋាភិបាលយើងនាបច្ចុប្បន្ននេះ យើងជាសាស្ត្រាចារ្យ គប្បីយកចិត្តទុកដាក់ដល់កត្តាសំខាន់ៗ ក្នុងការតាក់តែងខ្លឹមសារនៃការបង្រៀនដូចតទៅៈ

- លើកកម្ពស់គុណភាពរបស់ខ្លឹមសារនៃមេរៀននីមួយៗ
- រៀបចំកម្មវិធីបង្រៀនឱ្យទំនើបហើយជឿនលឿនតាមការវិវត្តរបស់វិទ្យាសាស្ត្រ និងបច្ចេកទេស
- បើកទូលាយចំណេះដឹង ខាងវិស័យគ្រប់គ្រងសេដ្ឋកិច្ចជាតិ
- លើកកម្ពស់ការបណ្តុះបណ្តាលធនធានមនុស្ស
- បំពាក់បំប៉នដល់សិស្ស នូវសមត្ថភាពខាងពលកម្មផលិត និងសមត្ថភាព សិក្សាស្រាវ ជ្រាវ វិទ្យាសាស្ត្របច្ចេកទេស
- យកចិត្តទុកដាក់ដល់គោលដៅអប់រំសិល្បវិទ្យា ការអប់រំកាយ និងយុទ្ធសាស្ត្រ

ដើម្បីក្តាប់ឱ្យបានច្បាស់លាស់ និងសិក្សាស៊ីជម្រៅក្នុងការដឹកនាំខ្លឹមសារនៃការបង្រៀន សាស្ត្រាចារ្យគប្បីយកចិត្តទុកដាក់ជាបន្ថែមទៀតទៅលើគោលការណ៍ជាមូលដ្ឋានក្នុងខ្លឹមសារនៃការបង្រៀនដូចតទៅៈ

### ៤.៨.១ ខ្លឹមសារនៃការបង្រៀនត្រូវធានាបាននូវចរិតសាកល និងភាពមានលំនឹងៈ

ខ្លឹមសារនៃការបង្រៀនត្រូវធានាបាននូវចរិតសាកល និងភាពមានលំនឹង របស់ការអប់រំដែលក្នុងនោះគ្រូបង្រៀន ត្រូវយកចិត្តទុកដាក់ដល់ការអប់រំសតិអារម្មណ៍ នយោបាយ និងសីលធម៌ក្នុងសង្គមៈ

ក/ចរិតសាកល និងភាពមានលំនឹងនៅក្នុងមុខវិជ្ជាសិក្សានីមួយៗក្នុងសាលារៀនសុទ្ធតែមានភារកិច្ចរួមចំណែកក្នុងការពង្រឹងផ្នែកសីលធម៌ បញ្ញា ការអប់រំកាយ ការអប់រំសិល្បវិទ្យា ការអប់រំពហុ បច្ចេកទេស។ ទន្ទឹមនឹងនេះ សាស្ត្រាចារ្យត្រូវចេះគួបផ្សំ និងផ្សារភ្ជាប់គ្នារវាងបញ្ញាពលកម្មទៅនឹង កាយពលកម្ម ការអប់រំកាយទៅនឹងស្មារតីអំណត់ព្យាយាម សីលធម៌ទៅនឹងសមត្ថភាព ការសិក្សាទៅ នឹងការប្រតិបត្តិ សាលារៀនទៅនឹងគ្រួសារសិស្ស អង្គការមហាជន និងសង្គម។ ទោះជាក្នុងមុខវិជ្ជា សិក្សាណាក៏ដោយ ក៏សុទ្ធតែមានសកម្មភាព និងលទ្ធភាពគ្រប់គ្រាន់នៅក្នុងការអប់រំមនុស្សដែរ ថ្វីបើមុខវិជ្ជាសិក្សានោះមានឥទ្ធិពលផ្សេងៗគ្នាក៏ដោយ។

ខ/ក្នុងការយកចិត្តទុកដាក់ដល់គោលដៅ និងការពង្រឹងវិស័យអប់រំក្នុងខ្លឹមសារនៃការបង្រៀន សាស្ត្រា ចារ្យម្នាក់ៗ ត្រូវយកចិត្តទុកដាក់ដល់ការអប់រំសតិអារម្មណ៍ នយោបាយ និងសីលធម៌។ ដូចនេះ សាស្ត្រាចារ្យ ត្រូវយកភារកិច្ចអប់រំទាំងនេះជាភារកិច្ចស្នូល។

គ/ចង់ធ្វើឱ្យបានសម្រេចនូវភារកិច្ចនេះ សាស្ត្រាចារ្យ គប្បីកែច្នៃខ្លឹមសារនៃការបង្រៀនតាមមុខវិជ្ជាសិក្សានីមួយៗ ឱ្យបានសមស្របទៅតាមសមត្ថភាពរបស់សិស្ស។

ឃ/នៅក្នុងផែនការនៃការបង្រៀន សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់មុខវិជ្ជាសិក្សាខាងវិទ្យាសាស្ត្រ សង្គមដោយធ្វើឱ្យមុខវិជ្ជាសិក្សានេះ មានតួនាទីដ៏ឧត្តុង្គឧត្តមក្នុងការកសាងសតិអារម្មណ៍ និងសញ្ចេតនាសិស្ស។

ង/ឈរលើមូលដ្ឋាននៃការអប់រំសតិអារម្មណ៍ នយោបាយ និងសីលធម៌ ឱ្យដល់សិស្សានុសិស្ស សាស្ត្រាចារ្យ ត្រូវលើកកម្ពស់គុណភាពអប់រំខាងវិស័យវប្បធម៌ពង្រឹងពង្រីកការអប់រំពហុបច្ចេកទេស ការគ្រប់គ្រង

សេដ្ឋកិច្ចជាតិ និង ការពិសោធន៍វិទ្យាសាស្ត្រ សំដៅធ្វើឱ្យសិស្សានុសិស្សក្ដាប់បានចំណេះដឹង ចំណេះធ្វើ និង បំណិនប្រសប់ គឺជា ឧបករណ៍សម្រាប់កែប្រែកសាង និងការពារមាតុភូមិ។

✓ សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀនភាសាបរទេស ដើម្បីឱ្យសិស្សានុសិស្សកាន់តែយល់ជ្រួតជ្រាបច្បាស់លាស់ថែមទៀតពីតម្លៃ និងស្មារតីរបស់វប្បធម៌សាកលលោក ធ្វើឱ្យសតិបញ្ញារបស់សិស្សានុសិស្សអភិវឌ្ឍទាន់ជំហានរបស់វប្បធម៌ និងវិទ្យាសាស្ត្របរទេស សំដៅធ្វើឱ្យសិស្សម្នាក់ៗ យកចំណេះដឹងទាំងនោះ មកប្រើប្រាស់ជាឧបករណ៍ក្នុងសកម្មភាពច្នៃប្រឌិតរបស់ខ្លួន។

✓ នៅក្នុងផែនការ និងកម្មវិធីបង្រៀន សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់គោលដៅរបស់ការអប់រំសិល្បវិជ្ជានិងការអប់រំកាយ។ការអប់រំសិល្បវិទ្យា ត្រូវតែធ្វើឡើងក្នុងពេលរៀបចំតាក់តែងកិច្ចការសម្រាប់បង្រៀននៅគ្រប់មុខវិជ្ជាសិក្សា និងក្នុងសកម្មភាពនីមួយៗ។ ជាពិសេស នៅក្នុងការបង្ហាត់បង្រៀន មុខវិជ្ជាអក្សរសិល្ប៍ គំនូរ ចម្រៀង តូរ្យតន្ត្រី ព្រោះមុខវិជ្ជាសិក្សាទាំងនេះ មានតួនាទីសំខាន់ណាស់នៅក្នុង ការអប់រំសិល្បវិទ្យា។

✓ ដើម្បីធានាបាននូវការអភិវឌ្ឍពេញសមត្ថភាព និងភាពមានលំនឹងក្នុងបញ្ហានេះសាស្ត្រាចារ្យម្នាក់ៗ ត្រូវរៀបចំរបបបង្រៀនមួយ ដ៏ត្រឹមត្រូវទៀងទាត់ដូចជា កាលវិភាគប្រចាំថ្ងៃ ប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំឆ្នាំ សំដៅធានាបានដល់សិស្ស «ការរៀនល្អ» ផង ការចូលរួមក្នុងពលកម្មផលិត ការងារសង្គមផង និងពេលវេលាសម្រាកបានស្រួលផង។

## ៤.៨.២ ខ្លឹមសារនៃការបង្រៀនត្រូវធានាបាននូវការផ្ដល់ដល់សិស្សនូវចំណេះដឹងវិទ្យាសាស្ត្រទូទៅជាមូលដ្ឋាន ហើយទំនើប៖

ខ្លឹមសារនៃការបង្រៀនត្រូវធានាបាននូវការផ្ដល់ដល់សិស្សនូវចំណេះដឹងវិទ្យាសាស្ត្រទូទៅជាមូលដ្ឋាន ហើយទំនើប ផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម សមស្របទៅនឹងជាតុពិតនៅកម្ពុជាខាងវិស័យវិទ្យាសាស្ត្រធម្មជាតិ វិទ្យាសាស្ត្រសង្គម ហើយឆ្លងកាត់តាមរយៈមុខវិជ្ជាសិក្សាទាំងនោះសិស្សានុសិស្សអភិវឌ្ឍបានខាងសតិបញ្ញាច្នៃប្រឌិត។

ក/បណ្ដាចំណេះដឹងទូទៅជាមូលដ្ឋាន គឺជាចំណេះដឹងដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់ឱ្យ យុវសិស្សនៅសាលារៀនចំណេះទូទៅ ត្រៀមខ្លួនចូលក្នុងជីវភាពរស់នៅក្នុងសង្គម។ ម្យ៉ាងទៀត ចំណេះ ដឹងទូទៅជាមូលដ្ឋាន គឺជាចំណេះដឹងដែលមានឥទ្ធិពលក្នុងការជួយសិស្សឱ្យក្ដាប់បាន ឬយល់ជ្រួតជ្រាបច្បាស់លាស់ទៅលើខ្លឹមសារផ្សេងៗ ក្នុងបញ្ហាដោះស្រាយពីវត្ថុ ឬបាតុភូត ក្នុងប្រភេទដូចគ្នា ឬផ្សេងគ្នា និងសម្រាប់យកធ្វើជាមូលដ្ឋាន ក្នុងការបណ្ដុះបាននូវលោកទស្សនៈ និងទស្សនៈវិទ្យាសាស្ត្រ។

ខ/ចំណេះដឹងទំនើប គឺជាចំណេះដឹងថ្មីបំផុត សមស្របទៅនឹងតថភាពសត្យានុម័ត សមស្របទៅ នឹងកម្រិតអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកទេស និងវប្បធម៌នាបច្ចុប្បន្នកាល។ ទន្ទឹមនឹងនេះ សាស្ត្រាចារ្យម្នាក់ៗ ត្រូវ យល់ច្បាស់ ផងដែរ ចំណេះដឹងទូទៅទាំងអស់ មិនមែនសុទ្ធតែទំនើបទាំងអស់នោះទេ ហើយក៏មិនមែនសុទ្ធតែជា លទ្ធផល នៃការសិក្សាស្រាវជ្រាវរបស់វប្បធម៌វិទ្យាសាស្ត្រ បច្ចេកទេសទាំងអស់នោះដែរ។ សាស្ត្រាចារ្យ អាចបញ្ចូលចំណេះដឹង ទាំងនេះទៅក្នុងខ្លឹមសារនៃការបង្រៀន នៅសាលារៀនចំណេះទូទៅ។ ក៏ប៉ុន្តែ សាស្ត្រាចារ្យគប្បីជ្រើសរើសក្នុង ចំណោមចំណេះដឹងទំនើប យកមកធ្វើជាចំណេះដឹងទូទៅ ជាមូលដ្ឋាន ឱ្យបានសមស្របទៅនឹងទិដ្ឋភាពជាក់ស្ដែង ក្នុងការបង្ហាត់បង្រៀនសិស្ស។ ក្នុងករណីនេះ សាស្ត្រាចារ្យម្នាក់ៗ គប្បីក្ដាប់ឱ្យបានច្បាស់

នូវកត្តាសំខាន់ៗដូចជា៖

✓ ធ្វើអត្ថាធិប្បាយ ពីចំណេះដឹងជាមូលដ្ឋានក្នុងការសិក្សា តាមរូបភាពនៃទស្សនៈដ៏ជឿនលឿន។

✓ បកស្រាយពន្យល់ជាឧទាហរណ៍ ដោយជ្រើសរើសចំណេះដឹងតាមឯកសារព្រឹត្តិការណ៍ សេចក្តីសន្និដ្ឋាន និងការអនុវត្តជាក់ស្តែងទាំងឡាយ ដែលមានលក្ខណៈទំនើបជឿនលឿន តាមវិទ្យាសាស្ត្របច្ចេកទេស វប្បធម៌ ហើយសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រទេសជាតិ។

✓ ធ្វើអត្ថាធិប្បាយពីចំណេះដឹងជាមូលដ្ឋានទំនើប ដោយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹង ចំណេះដឹងទូទៅ ជាមូលដ្ឋានក្នុងការសិក្សារបស់សិស្ស។

✓ ឈរលើមូលដ្ឋាន នៃឯកសារសម្រាប់បង្ហាត់បង្រៀនពីព្រឹត្តិការណ៍សំខាន់ៗ សាស្ត្រាចារ្យ ត្រូវពឹងផ្អែកលើ ទ្រឹស្តីដឹកនាំតាមទស្សនៈដែលទំនើប ហើយជឿនលឿន។ ផ្អែកលើវិធីនេះ សាស្ត្រាចារ្យ អាចសម្រួលបាននូវ ខ្លឹមសារនៃការបង្រៀន ហើយអាចជៀសវាងបានផងដែរ ចំពោះការបញ្ជ្រកចំណេះដឹងក្នុងខួរក្បាលសិស្ស។

គ/ខ្លឹមសារនៃការបង្រៀន ត្រូវតែឆ្លុះបញ្ចាំងឱ្យបានគ្រប់ជ្រុងជ្រោយនូវធាតុពិតជាក់ស្តែងក្នុងប្រទេសជាតិ។ បណ្តាចំណេះដឹងទូទៅជាមូលដ្ឋាន សមស្របទៅនឹងធាតុពិតជាក់ស្តែងក្នុងប្រទេសនីមួយៗ មានលក្ខណៈ ពិសេសដូចតទៅ៖

✓ ចំណេះដឹង ដែលញុាំងឱ្យសិស្សានុសិស្សងាយយល់ពីទឹកដី ប្រវត្តិសាស្ត្រ ធម្មជាតិ សង្គម ប្រជាជននិយាយដោយឡែក និងធម្មជាតិ ប្រវត្តិសាស្ត្រ នយោបាយសង្គម និងប្រជាជននៅតាមតំបន់នានា។ និយាយរួម ចំណេះដឹងទាំងនេះ ជួយសិស្សឱ្យចេះវិភាគ និងដោះស្រាយបាននូវបញ្ហាជាក់ស្តែង ដោយចេះគួបផ្សំទៅនឹងលក្ខខ័ណ្ឌពិសេសរបស់មាតុភូមិ។

✓ ចំណេះដឹង ដែលបណ្តុះបណ្តាលសិស្ស ឱ្យមានសមត្ថភាពប្រតិបត្តិម្ចាស់ការ ក្នុងការបម្រើបម្រាស់ចំណេះ ដឹងដែលបានសិក្សារួចមកហើយដើម្បីបម្រើសង្គមកែប្រែសង្គមធម្មជាតិនិងខ្លួនឯង។ ឃ/ចំណេះដឹងទាំងនោះ សំដៅធានាបាននូវលក្ខណៈរបស់ប្រព័ន្ធកម្ម និងអាចឆ្លុះបញ្ចាំងបាន ដ៏សមហេតុផលរបស់វិទ្យាសាស្ត្រដែលទាក់ទងទៅនឹងមុខវិជ្ជាសិក្សានីមួយៗ។ សាស្ត្រាចារ្យ គប្បីយល់ ច្បាស់ថា មុខវិជ្ជាសិក្សានីមួយៗផ្សារភ្ជាប់គ្នា និងមានទំនាក់ទំនងនឹងគ្នាជានិច្ច សំដៅផ្តត់ផ្តង់ឱ្យ សិស្ស ក្តាប់បាននូវប្រព័ន្ធចំណេះដឹងមួយដ៏សមស្រប ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។

ង/ខ្លឹមសារនៃការបង្រៀន ត្រូវឈរលើមូលដ្ឋាននៃការផ្តល់ឱ្យសិស្សានុសិស្ស នូវចំណេះដឹងវិទ្យាសាស្ត្រទូទៅដ៏ទំនើប ហើយផ្សារភ្ជាប់គ្នាជាប្រព័ន្ធដ៏សមស្របទៅនឹងភាពជាក់ស្តែងនៅក្នុងប្រទេស គឺសំដៅធ្វើឱ្យសតិបញ្ញាច្នៃប្រឌិតរបស់សិស្សអភិវឌ្ឍឡើងជាលំដាប់។

ច/បញ្ហាដែលធ្វើឱ្យសតិបញ្ញារបស់សិស្សអភិវឌ្ឍឡើង មិនគ្រាន់តែជាបញ្ហាមួយ ដែលបម្រើឱ្យវិធីសាស្ត្របង្រៀន និងអប់រំប៉ុណ្ណោះទេ ក៏ប៉ុន្តែ គឺជាបញ្ហាមួយដែលបម្រើឱ្យខ្លឹមសារនៃការបង្រៀនទៀតផង។ ខ្លឹមសារនៃការបង្រៀន ត្រូវធ្វើឱ្យការអភិវឌ្ឍខាងសតិបញ្ញាបានសម្រេច ដែលក្នុងនោះ គឺត្រូវធ្វើឱ្យមាន ការអភិវឌ្ឍខាងសមត្ថភាពត្រិះរិះពិចារណា និងសមត្ថភាពច្នៃប្រឌិតម្ចាស់ការ។

ទ្រឹស្តី «អប់រំតាមរូបភាព» និងទ្រឹស្តី «អប់រំតាមតថភាព» បានបដិសេធចោលទាំងស្រុង ចំពោះ បញ្ហានេះ។ ចំពោះយើងជាសាស្ត្រាចារ្យ ត្រូវប៉ិនប្រសប់ក្នុងការគួបផ្សំបញ្ចូលគ្នានូវទ្រឹស្តីអប់រំទាំងពីរនេះ នៅក្នុងការកំណត់ខ្លឹមសារនៃការបង្រៀន។ ដូចនេះ បើយើងចង់ឱ្យសតិបញ្ញា និងសមត្ថភាពប្រតិបត្តិរបស់សិស្សានុសិស្សអភិវឌ្ឍឡើងបាន ជាបឋមយើងត្រូវផ្តត់ផ្តង់ដល់សិស្សានុសិស្សនូវចំណេះដឹងទូទៅ ជា

មូល ដ្ឋានដ៏ទំនើប ផ្សារភ្ជាប់គ្នាជាប្រព័ន្ធ ហើយសមស្របទៅនឹងជាតុពិតជាក់ស្តែងនៅក្នុងប្រទេសជាតិ។

**៤.៨.៣ ខ្លឹមសារនៃការបង្រៀនត្រូវធានាឱ្យបានដល់ការសិក្សាទ្រឹស្តីផ្សារភ្ជាប់និងការប្រតិបត្តិ៖**

ខ្លឹមសារនៃការបង្រៀនត្រូវធានាឱ្យបានដល់ការសិក្សាទ្រឹស្តីផ្សារភ្ជាប់និងការប្រតិបត្តិ ការអប់រំផ្សារភ្ជាប់ទៅនិងពលកម្មផលិត ការពិសោធន៍វិទ្យាសាស្ត្រផ្សារភ្ជាប់ទៅនិងសកម្មភាពប្រតិបត្តិ សកម្មភាពសិក្សាក្នុងថ្នាក់រៀនផ្សារភ្ជាប់ទៅនឹងសកម្មភាពក្រៅថ្នាក់រៀន។

គោលការណ៍នេះ ស្តែងចេញនៅក្នុងផែនការរបស់ខ្លឹមសារនៃការបង្រៀន គឺសាស្ត្រាចារ្យត្រូវ ធានាឱ្យសិស្សបានរៀនមួយថ្ងៃពេញពេល និងទុកពេលវេលាទំនេរខ្លះ ដើម្បីឱ្យសិស្សមានពេលបាន ចូលរួមក្នុងពលកម្មបច្ចេកទេសពិសោធន៍វិទ្យាសាស្ត្រ នៅក្នុងសាលារៀន នៅតាមសហគមន៍ នៅតាម សហគ្រាសផលិតនៅតាម កសិដ្ឋាន ឬនៅតាមគ្រួសារដោយទៀតទាត់ ស្វ័យសិក្សា ឬចូលរួមក្នុង ពលកម្មសមូហភាព និងសកម្មភាពសមូហភាពផ្សេងទៀត ល្បែងកំសាន្ត ដំណើរកំសាន្ត និងសកម្មភាព សិក្សានយោបាយ។

ខ្លឹមសារនៃការបង្រៀន ត្រូវបញ្ចូលនូវស្មារតីអប់រំ ពហុបច្ចេកទេសសំដៅបម្រើនូវសំណូមពរជាមូលដ្ឋានដូចតទៅ

- ✓ ធ្វើឱ្យសិស្សានុសិស្ស ក្តាប់បាននូវផ្នែកផលិតកម្មដ៏សំខាន់ៗបំផុតដូចជា ឧស្សាហកម្ម និងកសិកម្មទំនើបរបស់ខឿនផលិតកម្ម។
- ✓ ធ្វើឱ្យសិស្សានុសិស្សក្តាប់ ឬយល់ជ្រួតជ្រាបបាននូវគោលការណ៍ជាមូលដ្ឋានទូទៅ របស់ លំនាំផលិតកម្មសំខាន់ៗ និងអង្គការគ្រប់គ្រងសេដ្ឋកិច្ច
- ✓ កាលណាក្តាប់បានចំណេះធ្វើ ក្នុងបម្រើបម្រាស់ឧបករណ៍ងាយៗ ហើយដោយបានឆ្លងកាត់បម្រើឧបករណ៍ទាំងនោះ សិស្សអាចក្តាប់បាននូវចលនាជាមូលដ្ឋានទូទៅ របស់ឧបករណ៍ផ្សេង ទៀតដូចជា សមត្ថភាពខាងការគិត ការវាស់វែង ការពិសោធន៍។ល។
- ✓ ធ្វើឱ្យការត្រិះរិះពិចារណាខាងផ្នែកបច្ចេកទេស របស់សិស្សអភិវឌ្ឍឡើង
- ✓ អប់រំដល់សិស្ស នូវឥរិយាបថក្នុងពលកម្មសង្គម និងវប្បធម៌ជឿនលឿន

ដើម្បីក្តាប់បាន និងយល់ជ្រួតជ្រាបនូវសំណូមពរខាងលើនេះ ជាបឋមគ្រប់មុខវិជ្ជាសិក្សាទាំងអស់ដូចជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា គំនូរ ឧស្សាហកម្ម ត្រូវធ្វើឱ្យសិស្សក្តាប់បាននូវមូលដ្ឋាន វិទ្យាសាស្ត្រ លើគ្រប់គោលការណ៍ផលិតកម្ម និងការគ្រប់គ្រងផលិតកម្ម សំដៅជួយសិស្សឱ្យមានសមត្ថភាពជាប្រចាំ ក្នុងវិស័យផលិតកម្មដូចជា សមត្ថភាពក្នុងការត្រិះរិះពិចារណា ការវាស់វែង ការគិត អំណាន គំនូរ និង ធ្វើគម្រោងពិសោធន៍ជាដើម។

កាយវប្បកម្មមានភារកិច្ចរៀបចំឱ្យបានល្អខាងផ្នែកសុខភាពដល់សិស្សានុសិស្សដូចជា មុខវិជ្ជាវិទ្យាសាស្ត្រដទៃដែរ កាយវប្បកម្មនេះ សំដៅធ្វើឱ្យសតិបញ្ញា និងសញ្ចេតនាក្នុងការបំពេញការងារ ឬភារកិច្ចឱ្យបានខ្លាំងក្លាខាងផ្នែកពលកម្មផលិត និងសកម្មភាពនយោបាយ។

ម្យ៉ាងទៀត ដើម្បីធានាឱ្យសិស្សក្តាប់បាននូវចំណេះដឹងជាមូលដ្ឋាន ខាងផ្នែកបច្ចេកទេសបានច្បាស់លាស់ ការអប់រំពហុបច្ចេកទេស ត្រូវតែបញ្ចូលទៅក្នុងផែនការបង្រៀន តាំងពីអនុវិទ្យាល័យរហូតដល់វិទ្យាល័យ។ ខ្លឹមសាររបស់មុខវិជ្ជាពលកម្មបច្ចេកទេស ជួយសិស្សឱ្យពង្រឹងពង្រីក បើកទូលាយ និងស៊ីជម្រៅបាន

ទៅលើចំណេះដឹងវិទ្យាសាស្ត្រជា មូលដ្ឋាន ហើយឆ្លងកាត់តាមការសិក្សាមុខវិជ្ជានេះ សាស្ត្រាចារ្យ ត្រូវបំប៉នឱ្យដល់សិស្ស នូវគុណសម្បត្តិសីលធម៌ល្អ ដែល ជាម្ចាស់សមូហភាព និងម្ចាស់ផលិតកម្ម។

ក្រៅពីនេះ ដើម្បីឱ្យបម្រើបម្រាស់បច្ចេកទេស ក្នុងផលិតកម្មកាន់តែមានប្រសិទ្ធភាព ឡើង នោះសាស្ត្រាចារ្យ ត្រូវផ្តល់ឱ្យសិស្សនូវចំណេះដឹង និងសមត្ថភាព ដែលអាចឆ្លើយតបបានទៅនឹង សំណូមពរ ឬតម្រូវការជាក់ស្តែងតាមតំបន់ ឬភូមិភាគដូចជា បច្ចេកទេសជ្រើសរើស ឬប្រមូលផ្តុំ គ្រាប់ដំណាំបច្ចេកទេសប្រើប្រាស់ឧបករណ៍កសិកម្ម បច្ចេកទេសធ្វើជីធម្មជាតិ និងបច្ចេកទេសក្នុងការ ចិញ្ចឹមត្រី ឬសត្វជាដើម។

- នៅក្នុងលំនាំ នៃការសិក្សាតាមមុខវិជ្ជាឯកទេសនីមួយៗ សិស្សអាចក្តាប់បានចំណេះដឹង ដែលក្លាយទៅជាចំណេះធ្វើ និងបំណិនប្រសប់ ហើយដែលសិស្ស ត្រូវយកទៅប្រើប្រាស់ក្នុងការប្រតិបត្តិជាក់ស្តែង។ ការសិក្សាមុខវិជ្ជាឯកទេសនីមួយៗ តែងតែមានផ្នែកទ្រឹស្តីផង ផ្នែកប្រតិបត្តិផង។ នៅក្នុង ផ្នែកប្រតិបត្តិ សាស្ត្រាចារ្យ ត្រូវកំណត់ឱ្យបានច្បាស់ពីការផ្សារភ្ជាប់រវាងចំណេះធ្វើ និងបំណិនប្រសប់ ទៅតាមមុខវិជ្ជាឯកទេសនីមួយៗ ដែលសិស្សត្រូវក្តាប់បាន។ ទន្ទឹមនឹងនេះ ក្នុងការប្រតិបត្តិ សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់ការរៀបចំឱ្យសិស្ស បានធ្វើការពិសោធន៍ វិទ្យាសាស្ត្រគួបផ្សំទៅនឹងពលកម្មផលិត។

សិស្សានុសិស្ស មិនគ្រាន់តែបានសិក្សាតែតាមរយៈសកម្មភាពសិក្សាមុខវិជ្ជាឯកទេសនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែ សិស្សានុសិស្សត្រូវបានសិក្សាដោយឆ្លងកាត់តាមសកម្មភាពក្រៅពីការសិក្សាតាមមុខវិជ្ជាឯកទេសទៀតផង ។ ការសិក្សាក្រៅមុខវិជ្ជាឯកទេស សំដៅធ្វើឱ្យសិស្សម្នាក់ៗមានការអភិវឌ្ឍពេញសមត្ថភាព។ សកម្មភាព សិក្សាតាមមុខវិជ្ជាឯកទេស និងសកម្មភាពសិក្សាក្រៅមុខវិជ្ជាឯកទេស ត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ។

## ៤.៨.៤ ខ្លឹមសារនៃការបង្រៀនត្រូវធានាឱ្យបានឯកភាពគ្នាទូទាំងប្រទេស៖

ខ្លឹមសារនៃការបង្រៀនត្រូវធានាឱ្យបានឯកភាពគ្នាទូទាំងប្រទេស ទន្ទឹមនឹងនេះត្រូវគិតដល់លក្ខណៈភូមិសាស្ត្រតាមតំបន់ត្រូវឱ្យបានសមស្របទៅនឹងលក្ខណៈពិសេសនៃវ័យ និងភេទសិក្សារបស់សិស្ស ហើយត្រូវឱ្យបានសមស្របទៅនឹងលក្ខខ័ណ្ឌបង្រៀន និងរៀននៅក្នុងសាលារៀន។

- សាលារៀនចំណេះទូទៅ មានចរិតប្រជាធិបតេយ្យ និងសមភាព។ មិនថាសិស្សានុសិស្ស សញ្ជាតិណា ឬពីតំបន់ណាឡើយ គឺមានសិទ្ធិចូលរៀនបានដូចគ្នា។ ដូចនេះ ខ្លឹមសារនៃការបង្រៀន ត្រូវតែបានកំណត់ និងឯកភាពគ្នានៅក្នុងមជ្ឈដ្ឋានសាលារៀន និងសំណូមពរទូទៅ។
- ថ្វីបើមនុស្សក្នុងសាលារៀន បានបណ្តុះបណ្តាលរួចមកហើយ មិនទាន់បានស៊ីជម្រៅទៅលើធម្មជាតិសង្គម និងមនុស្សនៅក្នុងប្រទេសក៏ដោយ ក៏មនុស្សនោះឯង បានយល់ស៊ីជម្រៅពីចរិតតំបន់ ដែលខ្លួនបានរស់នៅដែរ។ កម្រិតយល់ដឹងរបស់គេនឹងរួមវិភាគទានយ៉ាងសកម្មដល់ការការពារ និងកសាងមាតុភូមិ។ គឺយ៉ាងនេះហើយបានជាខ្លឹមសារនៃការបង្រៀនត្រូវតែសម្របសម្រួលទៅតាមលក្ខណៈពិសេសនៃតំបន់ ឬភូមិភាគទៅតាមតម្រូវការជាមូលដ្ឋានដូចតទៅ៖
  - ✓ មុខវិជ្ជាសិក្សានីមួយៗ និងកម្មវិធីបង្រៀន ត្រូវការពេលវេលាយ៉ាងច្រើន ដើម្បីសិក្សាស៊ីជម្រៅ ពី ឃ្លាប្រយោគ ដែលមានចំណងទាក់ទងទៅនឹងលក្ខណៈពិសេសនៃតំបន់។
  - ✓ នៅក្នុងកម្មវិធីបង្រៀនតាមមុខវិជ្ជាសិក្សាមួយចំនួន ទាមទារនូវម៉ោងសិក្សាបង្រៀនបន្ថែម ដើម្បីសិក្សាស្រាវជ្រាវស៊ីជម្រៅ លើលក្ខណៈពិសេសនៅក្នុងតំបន់។ បញ្ហាទាំងឡាយនៅក្នុងខ្លឹមសារនៃ

កម្មវិធីបង្រៀនត្រូវតែលើកយកមកបង្រៀនសិស្ស ដោយឈរលើមូលដ្ឋាននៃព្រឹត្តិការណ៍ជាក់ស្តែង នៅក្នុងតំបន់ ឬភូមិភាគនីមួយៗ

- ខ្លឹមសារនៃការបង្រៀន ត្រូវតែបានរៀបចំតាក់តែងឡើង ឱ្យបានសមស្របទៅនឹងលក្ខណៈពិសេសនៃវ័យសិក្សារបស់សិស្ស។ បើសាស្ត្រាចារ្យម្នាក់ៗ មិនបានយកចិត្តទុកដាក់ដល់លក្ខណៈពិសេសនៃវ័យសិក្សារបស់ សិស្សានុសិស្សទេនោះ បានន័យថា សាស្ត្រាចារ្យ មិនបានរៀបចំកែប្រែខ្លឹមសារនៃការបង្រៀនឡើយ។ ហេតុនេះ ហើយ នៅពេលរៀបចំតាក់តែងខ្លឹមសារនៃការបង្រៀន សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង ដល់លក្ខណៈ ពិសេសនៃវ័យសិក្សារបស់សិស្ស ហើយមិនត្រូវវាយតម្លៃទាប ឬមើលស្រាលដល់សមត្ថភាព ទទួលចំណេះដឹង របស់សិស្សឡើយ។ ដើម្បី រៀបចំតាក់តែងខ្លឹមសារនៃការបង្រៀនឱ្យបានសមស្របទៅនឹងលក្ខណៈពិសេសនៃវ័យ សិក្សារបស់សិស្ស សាស្ត្រាចារ្យ ត្រូវកសាងឱ្យបាននូវខ្លឹមសារនៃការបង្រៀនដែលមានលក្ខណៈជាសាកល គឺការអនុវត្តបំណែងចែកសិស្សជាក្រុមនៅក្នុងថ្នាក់វិទ្យាល័យ ដោយទុកពេលឱ្យសិស្សពិភាក្សាស៊ីជម្រៅទៅលើ ចំណេះដឹង ដែលទើបនឹងបានរៀនរួចហើយ។ សាស្ត្រាចារ្យ មានសិទ្ធិបន្ថយ ឬបន្ថែមម៉ោងសិក្សាបាន ប្រសិនណា ជាមើលទៅឃើញថា ចាំបាច់ ប៉ុន្តែ ត្រូវធានាឱ្យបាននូវការអភិវឌ្ឍខាងកម្រិតវប្បធម៌ទូទៅផង។
- ខ្លឹមសារនៃការបង្រៀន មិនគ្រាន់តែត្រូវរៀបចំតាក់តែងឡើង ឱ្យបានសមស្របទៅនឹងលក្ខណៈ ពិសេសនៃវ័យសិក្សារបស់សិស្សប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវតែរៀបចំឱ្យបានសមស្របទៅនឹងភេទរបស់សិស្សទៀតផង។ យុវសិស្សម្នាក់ៗសុទ្ធតែមានលក្ខណៈពិសេសខាងផ្លូវកាយ និងផ្លូវចិត្តផ្សេងគ្នា។ ការខុសប្លែកគ្នានេះត្រូវតែបានគ្រូយកចិត្តទុកដាក់តាំងពីពេលប្រឡងចូលរៀនអនុវិទ្យាល័យម្លេះ។ ដូចនេះគ្រប់សកម្មភាពទាំងអស់នៅក្នុងសាលារៀនដូចជាសកម្មភាពសិក្សា ពលកម្ម ល្បែង កំសាន្ត ត្រូវតែយកចិត្តទុកដាក់គិតដល់អាយុ និងភេទរបស់សិស្ស។

*ឧទាហរណ៍៖* សាស្ត្រាចារ្យ ត្រូវអប់រំ និងបង្រៀនសិស្សនារីពីមុខវិជ្ជាមេផ្ទះ ការគ្រប់គ្រងគ្រួសារ ការដេរប៉ាក់ ត្រូវអប់រំ និងបង្ហាត់បង្រៀនសិស្ស ជាយុវជនពីពលកម្ម និងកីឡាដែលចាំបាច់ទាមទារនូវកម្លាំងដ៏ខ្លាំងក្លា។

- ខ្លឹមសារនៃការបង្រៀន ត្រូវតែបានរៀបចំតាក់តែងឡើងឱ្យបានសមស្របទៅនឹងលក្ខខ័ណ្ឌបង្រៀន និងរៀននៅក្នុងសាលារៀនចំណេះទូទៅ។

គោលការណ៍ជាមូលដ្ឋាន ក្នុងការដឹកនាំខ្លឹមសារនៃការបង្រៀន ត្រូវតែពឹងផ្អែកលើចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ពោលគឺ ស៊ីសង្វាក់គ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។ ដូចនេះនៅពេលសិក្សាស្រាវជ្រាវដើម្បីរៀបចំតាក់តែងខ្លឹមសារនៃការបង្រៀនសាស្ត្រាចារ្យម្នាក់ៗគប្បីយកចិត្តទុកដាក់ដល់ចំណងទាក់ទងទាំងនេះ។

## ៤.៩ ផែនការបង្រៀន កម្មវិធីសិក្សា សៀវភៅសិក្សា និងឯកសារសិក្សាដទៃទៀត

ខ្លឹមសារនៃការបង្រៀនស្តែងឡើង ឱ្យឃើញជាក់ស្តែងនៅក្នុង ផែនការបង្រៀន កម្មវិធីសិក្សា សៀវភៅសិក្សា និងឯកសារសិក្សាផ្សេងទៀត។

### ៤.៩.១. ផែនការបង្រៀន

ផែនការបង្រៀន គឺជាឯកសារដ៏សំខាន់របស់រដ្ឋាភិបាលដែលក្នុងនោះមានចែង និងកំណត់ច្បាស់លាស់ពីមុខវិជ្ជានីមួយៗ ការបង្រៀនមុខវិជ្ជាឯកទេសនីមួយៗ ឆ្លងកាត់តាមកម្រិតសិក្សានីមួយៗ ការសិក្សាប្រចាំឆ្នាំនីមួយៗ ចំនួនម៉ោងសិក្សាប្រចាំឆ្នាំរបស់មុខវិជ្ជាឯកទេសនីមួយៗ ចំនួនសប្តាហ៍សិក្សា និងចំណាត់

តាំង ឆ្នាំសិក្សា (ចំនួនសប្ដាហ៍សិក្សា ចំនួនសប្ដាហ៍ពលកម្ម និងរបបសម្រាកប្រចាំឆ្នាំ និងប្រចាំថ្ងៃ)។

នៅក្នុងមុខវិជ្ជាសិក្សានីមួយៗ សុទ្ធតែមានធាតុអប់រំ។ មុខវិជ្ជាសិក្សានីមួយៗ ត្រូវមានកម្មវិធីអប់រំដោយឡែក។ នៅពេលបង្រៀនមុខវិជ្ជាឯកទេសនីមួយៗ សាស្ត្រាចារ្យត្រូវឈរលើមូលដ្ឋាននៃវិទ្យាសាស្ត្រ។ សាស្ត្រាចារ្យ ត្រូវបកស្រាយពន្យល់សិស្សឱ្យបានច្បាស់លាស់ ហើយសមហេតុផលតាមលក្ខណៈវិទ្យាសាស្ត្រ តាមប្រព័ន្ធវិទ្យាសាស្ត្រ ព្រឹត្តិការណ៍ សញ្ញាណ ក្រឹត្យក្រម និងទ្រឹស្ដី។

នៅសាលារៀនចំណេះទូទៅ (អនុវិទ្យាល័យ និងវិទ្យាល័យ) ក្នុងផែនការបង្រៀនដែលបានកំណត់ សាស្ត្រាចារ្យត្រូវតែផ្ដល់ឱ្យសិស្សក្ដាប់បាន ឬយល់ជ្រួតជ្រាប ច្បាស់លាស់ ពីវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រធម្មជាតិ មូលដ្ឋានផលិតកម្ម ការអប់រំកាយ និងសិល្បៈ ដែលក្នុងនោះចែកចេញជា នយោបាយ សីលធម៌ និរុត្តិវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា ភាសាបរទេស គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ពលកម្ម និងបច្ចេកទេស ការអប់រំកាយ គំនូរ ចំរៀង តូរ្យតន្ត្រី។

របបសិក្សា ដើម្បីធានាបានដល់សិស្សក្នុងការៈ

- រៀនល្អ
- មានពេលវេលាចូលរួមក្នុងពលកម្មផលិត និងពលកម្មសង្គម
- រៀនល្អ រៀនពូកែ នៅក្នុងថ្នាក់ក៏ដូចជានៅក្រៅថ្នាក់
- បានសម្រាក និងមានដំណើរកំសាន្តក្នុងរយៈសិក្សា

រយៈពេលសិក្សាក្នុងម៉ោងនីមួយៗ ត្រូវធ្វើឡើងតែក្នុង ៤៥នាទី។ សាស្ត្រាចារ្យ ត្រូវទុកពេលឱ្យសិស្សសួរ ឬសិស្សសម្រាក។ សិស្ស ត្រូវបានសម្រាកជាសមូហភាពដោយមានលេងល្បែងកំសាន្ត ក្នុងរយៈពេលពី ១០នាទី ទៅ ១៥នាទី។

ក្នុងមួយថ្ងៃ សិស្សត្រូវរៀនមួយពេល ឬពីរពេល។ ពេលក្រៅពីនេះ ត្រូវទុកឱ្យសិស្សបានចូលរួមក្នុងការងារសង្គម សកម្មភាពក្រៅការសិក្សា ការសម្រាក និងការកំសាន្ត។

ចំនួនសប្ដាហ៍សិក្សា សម្រាប់គ្រប់ថ្នាក់ក្នុងមួយឆ្នាំគឺ ៣៤សប្ដាហ៍ លើកលែងតែថ្នាក់ទី១១ ដែលត្រូវសិក្សាក្នុងរយៈពេល៣២សប្ដាហ៍។ រយៈពេលសម្រាប់មហាវិស្សមកាលគឺ ១៤សប្ដាហ៍។ ចំនួនសប្ដាហ៍សល់ពីនេះទុកបម្រុងរដូវប្រមូលផលស្រូវ ចូលរួមក្នុងពលកម្មសាធារណៈ ឬការងារផលិតកម្ម។ ក្នុងមួយឆ្នាំសិក្សារយៈពេលសម្រាប់ធ្វើពលកម្មគឺ ៣០ថ្ងៃ។ រយៈពេលធ្វើពលកម្មនេះ ត្រូវបានរៀបចំឡើងក្នុងមួយសប្ដាហ៍មួយពេល រហូតដល់គ្រប់ ៣០សប្ដាហ៍។ រយៈពេលក្រៅពីនេះ ទុកសម្រាប់ពលកម្មវិសាមញ្ញ។

## ៤.៩.២.កម្មវិធីសិក្សា

កម្មវិធីសិក្សា គឺជាឯកសារដែលរាជរដ្ឋាភិបាលបានប្រកាស ដែលក្នុងនោះគោលដៅ និងភារកិច្ចជាក់ស្ដែង ត្រូវបានកំណត់ទៅតាមមុខវិជ្ជាសិក្សានីមួយៗ។ ប្រព័ន្ធឯកសារ និងចំនួនម៉ោងបង្រៀនតាមមុខវិជ្ជាឯកទេសនីមួយៗ ត្រូវបានកំណត់ជាស្រេចទៅតាមជំពូកនៃមេរៀន។

ដូចនេះកម្មវិធីសិក្សាបានបង្ហាញឱ្យឃើញជាក់ស្ដែងនូវផែនការបង្រៀន។ នៅក្នុងផែនការបង្រៀនរាជរដ្ឋាភិបាល បានកំណត់លើគ្រប់មុខវិជ្ជាសិក្សាទាំងអស់ដូចជា វិធី បង្រៀន និងចំនួនម៉ោងបង្រៀន តាមមុខវិជ្ជាឯកទេសនីមួយៗ ក៏ត្រូវបានកំណត់ហើយជាស្រេចដែរ។ ក៏ប៉ុន្តែ ចំនួនមេរៀន និងប្រព័ន្ធឯកសារលើមុខវិជ្ជាឯកទេសនីមួយៗ មិនបានកំណត់ឡើយ។

រចនាសម្ព័ន្ធនៃកម្មវិធីសិក្សា ចែកចេញជាពីរផ្នែក៖ ផ្នែកបកស្រាយពន្យល់ និងផ្នែកខ្លឹមសារ។

នៅក្នុងផ្នែកបកស្រាយពន្យល់ មានអត្ថាធិប្បាយយ៉ាងសង្ខេប ស្តីពីគោលដៅភារកិច្ច និងវិធីសាស្ត្របង្រៀនលើមុខវិជ្ជាឯកទេសនីមួយៗ សំដៅឱ្យសាស្ត្រាចារ្យ អនុវត្តឱ្យបានសម្រេចតាមគោលដៅ និងភារកិច្ចនោះ។ ផ្នែកខ្លឹមសារ កំណត់នូវទំហំ និងប្រព័ន្ធនៃចំណេះដឹង ក្នុងមុខវិជ្ជាឯកទេសនីមួយៗ ដែលត្រូវបង្រៀននៅក្នុងសាលារៀន។ នៅក្នុងផ្នែកនេះ មានកំណត់ច្បាស់លាស់ពីចំនួនម៉ោងបង្រៀនក្នុងជំពូក មេរៀននីមួយៗ ដូចជាម៉ោងបង្រៀនមេរៀនថ្មី និងម៉ោងសិក្សាសារឡើងវិញជាដើម។ នៅក្នុងកម្មវិធីសិក្សារបស់មុខវិជ្ជាឯកទេសនីមួយៗក៏មានកំណត់ចំនួនម៉ោងធ្វើកិច្ចការត្រួតពិនិត្យដែរ។

កម្មវិធីសិក្សា ជាឧបករណ៍ដ៏សំខាន់របស់រាជរដ្ឋាភិបាល ដើម្បីដឹកនាំ និងត្រួតពិនិត្យលើកិច្ចការបង្រៀន និងអប់រំក្នុងសាលារៀនចំណេះទូទៅ។កម្មវិធីសិក្សា គឺជាឧបករណ៍ដែលតម្រូវឱ្យសាស្ត្រាចារ្យម្នាក់ៗ អនុវត្តឱ្យបានសម្រេចផងដែរ។ ចំពោះកម្មវិធីសិក្សា ក៏ដូចជាផែនការបង្រៀនដែរ មិនត្រូវបានអ្នកណាអាចកែផ្លាស់ប្តូរបន្ថែម ឬបន្ថយបានឡើយ។ ផ្អែកលើផែនការបង្រៀន និងកម្មវិធីសិក្សា សាស្ត្រាចារ្យ ត្រូវក្តាប់ឱ្យបាន ឬយល់ជ្រួតជ្រាប ឱ្យបានច្បាស់លាស់ពីភារកិច្ចបង្ហាត់បង្រៀន និងអប់រំសិស្ស។ ចង់សម្រេចបានតាមប្រការនេះ សាស្ត្រាចារ្យម្នាក់ៗគប្បី៖

- សិក្សាស្រាវជ្រាវ លើកម្មវិធីសិក្សានៃមុខវិជ្ជាឯកទេសរបស់ខ្លួនឱ្យបានហ្មត់ចត់
- ✓ យកចិត្តទុកដាក់ ក្តាប់ឱ្យបានច្បាស់ពីមូលដ្ឋានរបស់ខ្លឹមសារនៃការបង្រៀន និងរចនាសម្ព័ន្ធ របស់កម្មវិធីសិក្សា។
- ✓ សិក្សាស្រាវជ្រាវ ពីចំណងទាក់ទងក្នុងកម្មវិធីរបស់មុខវិជ្ជាឯកទេស ដែលសិស្សបានរៀនរួចមកហើយ ហើយដែលមានចំណងទាក់ទងទៅនឹងមុខវិជ្ជាឯកទេសរបស់ខ្លួន។
- ✓ ធានាបាននូវចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ រវាងមុខវិជ្ជាសិក្សាទាំងអស់ រវាងចំណេះដឹងដែល បានបង្រៀនរួចមកហើយ និងរវាងចំណេះដឹងដែលបម្រុងនឹងបង្រៀនសិស្ស។

យើងធ្វើការសិក្សាស្រាវជ្រាវពីអត្ថន័យ និងភារកិច្ចរបស់មុខវិជ្ជាឯកទេសទាំងអស់ដែលត្រូវបង្រៀននៅសាលារៀនចំណេះទូទៅអនុវិទ្យាល័យ និងវិទ្យាល័យដូចតទៅ៖ មុខវិជ្ជា សីលធម៌-ពលរដ្ឋ និរុត្តិវិទ្យា (ភាសាខ្មែរ) ប្រវត្តិវិទ្យា ភូមិវិទ្យា ភាសាបរទេស គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ពលកម្ម(បំណិនជីវិត) គេហវិជ្ជា អប់រំកាយ
គំនូរ ចំរៀង តូរ្យតន្ត្រី។

## ៤.៩.៣ សៀវភៅសិក្សា និងឯកសារសិក្សាផ្សេងទៀត

## ក. សៀវភៅសិក្សា

កម្មវិធីសិក្សា គ្រាន់តែកំណត់បាននូវទិដ្ឋភាពនៃឯកសារ សម្រាប់បង្រៀនក្នុងគ្រប់មុខវិជ្ជា ឯកទេសប៉ុណ្ណោះទេ។ ការធ្វើអត្ថាធិប្បាយ ឬបំណកស្រាយពន្យល់តាមឯកសារទាំងនោះ ត្រូវឱ្យបានច្បាស់លាស់ជាក់ស្តែង លម្អិត ហើយផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម ទៅតាមភារកិច្ចនៃសៀវភៅសិក្សា។ សៀវភៅសិក្សា គឺជាសៀវភៅ ដែលមានចំណុះបន្សាយចំណេះដឹងវិទ្យាសាស្ត្រដ៏សំខាន់ និងចាំបាច់ សំដៅធ្វើឱ្យសិស្សម្នាក់ៗ យល់ជ្រួតជ្រាប និងក្តាប់បានច្បាស់លាស់។ សៀវភៅសិក្សា ត្រូវបានតាក់តែង រៀបចំ ឱ្យបានសមស្រប ទៅនឹងកម្មវិធីសិក្សា និងសំណូមពររបស់ទ្រឹស្តីបង្រៀន។ សៀវភៅសិក្សាដ៏ល្អនោះ មិនគ្រាន់តែធ្វើឱ្យសតិ បញ្ញារបស់សិស្សអភិវឌ្ឍបានប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងផ្តល់នូវការអប់រំល្អដល់សិស្សទៀតផង។

ដើម្បី សម្រេចបានតាមប្រការនេះ សៀវភៅសិក្សាត្រូវធានាបាននូវសំណូមពរដូចតទៅ៖

- ចំណេះដឹងដែលលើកមកអធិប្បាយនៅក្នុងសៀវភៅសិក្សាទាំងនោះត្រូវធានាបាននូវឧត្តមគតិលក្ខណៈវិទ្យាសាស្ត្រសមស្របនឹងធាតុពិតជាក់ស្តែង និងកម្មវិធីសិក្សា ដែលបានកំណត់ ទៅតាមកម្រិតយល់ដឹងរបស់សិស្ស។

✓ នៅគ្រប់ពេលវេលា សៀវភៅសិក្សាត្រូវជួយសិស្សឱ្យក្តាប់ ឬយល់ជ្រួតជ្រាបបាន ពីវិធីស្វ័យ សិក្សា មានកំណត់ច្បាស់ ពីបរិមាណនៃចំណេះដឹងដែលត្រូវសិក្សាដូចជា លំហាត់ សំណួរពិភាក្សា សំណួរត្រួតពិនិត្យ និងដំណោះស្រាយជាគម្រូជាដើម។

✓ សៀវភៅសិក្សា ជួយសិស្សឱ្យអនុវត្តបាននូវគោលការណ៍ និងទ្រឹស្តីដែលផ្សារភ្ជាប់ទៅនឹងការប្រតិបត្តិជាក់ស្តែង។ ហេតុនេះក្នុងសៀវភៅសិក្សា គប្បីលើកឡើងពីបញ្ហាវត្ថុ ឬបាតុភូត ដែលច្រើនតែជួបប្រទះក្នុង ជីវភាពរស់នៅ សំដៅតម្រូវឱ្យសិស្សអនុវត្តបាននូវចំណេះដឹងវិទ្យាសាស្ត្រ ដើម្បីដោះស្រាយបញ្ហាជាក់ ស្តែងចំពោះមុខ ឬលំហាត់ក្នុងកិច្ចការប្រតិបត្តិ។

✓ ភាសា ឬឃ្លាប្រយោគក្នុងសៀវភៅសិក្សា ត្រូវឱ្យបានច្បាស់លាស់ហើយងាយយល់។ សៀវភៅសិក្សាត្រូវមានទ្រង់ទ្រាយល្អ សមស្របទៅនឹងក្រិត្យក្រម ឬសំណូមពរគរុកោសល្យ អនាម័យ និងសិល្បៈវិទ្យា។ ក្រដាសសម្រាប់បោះពុម្ព ចន្លោះតួអក្សរ ទឹកខ្មៅ និងក្របសៀវភៅ ឬរូប ភាពក្នុងសៀវភៅត្រូវឱ្យបានច្បាស់ ស្អាតល្អ ហើយមាំមួន។ រូបភាពតាមអត្ថបទ ត្រូវតែស្អាត ហើយសមស្របច្បាស់លាស់ទៀតផង។ នៅប្រទេសខ្លះ មានបោះពុម្ពសៀវភៅសិក្សា ដោយប្រើទឹក ខ្មៅពណ៌ចម្រុះសម្រាប់សិក្សាតាមម៉ាស៊ីនអសន្យាណូ។

## ខ. ឯកសារសិក្សាផ្សេងទៀត

ក្រៅពីសៀវភៅសិក្សា ដែលសម្រាប់ប្រើប្រាស់តាមផ្លូវការនៅគ្រប់សាលារៀនចំណេះទូទៅ នៅមានបម្រើបម្រាស់សម្ភារៈ និងឯកសារសិក្សាផ្សេងទៀត ដើម្បីបើកទូលាយ និងស៊ីជម្រៅទៅលើ ចំណេះដឹងតាមសៀវភៅសិក្សាដូចជា សៀវភៅដោះស្រាយលំហាត់ វចនានុក្រម សៀវភៅណែនាំពី ការ សិក្សាតាមមុខវិជ្ជាសិក្សាផ្សេងៗ។ ខ្លឹមសាររបស់ឯកសារសិក្សាទាំងនេះ មានពេលខ្លះមិនអាចសមស្របទៅ នឹងកម្មវិធីសិក្សាតាមមុខវិជ្ជាសិក្សានីមួយៗ ឯពេលខ្លះក៏មានលក្ខណៈសមស្របតាមកម្មវិធីសិក្សា សម្រាប់ថ្នាក់កម្រិតសិក្សានីមួយៗទាំងស្រុងដែរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ឯកសារសិក្សាទាំងនេះអាច ត្រូវបានសាស្ត្រាចារ្យ និងសិស្សយកមកប្រើប្រាស់បាន ដើម្បីយកមកបង្គ្រប់ ឬបន្ថែមទៅលើសំណូមពរគរុកោសល្យ ក៏ដូចជាសៀវភៅសិក្សារបស់ក្រសួងអប់រំដែរ។

## ៤.១០.លំនាំនៃការបង្រៀន

- ការបង្រៀន និងការសិក្សា គឺជាលំនាំនៃការបង្រៀនទ្រឹស្តី ជាលំនាំផ្តល់ចំណេះដឹង និងទទួលចំណេះដឹង។
- ការបង្ហាត់បង្រៀន គឺជាលំនាំនៃចលនា ដែលផ្តើមចេញពីការមិនទាន់យល់ ទៅការ យល់ច្បាស់ ការយល់មិនទាន់ច្បាស់គ្រប់គ្រាន់ត្រឹមត្រូវទៅការយល់គ្រប់គ្រាន់ត្រឹមត្រូវច្បាស់លាស់។
- ការបង្ហាត់បង្រៀន គឺជាលំនាំនៃសកម្មភាពដែលមានគោលដៅ មានផែនការច្បាស់លាស់ មានចំណាត់តាំងរវាងសាស្ត្រាចារ្យ និងសិស្សសំដៅស្តែងចេញនូវការផ្តល់ចំណេះដឹង និងការអប់រំ។

- លំនាំនៃការបង្រៀន និងការសិក្សា គឺជាសំណុំនៃសកម្មភាពរបស់សាស្ត្រាចារ្យ និងសិស្សដែលមានសាស្ត្រាចារ្យ ជាអ្នកដឹកនាំសកម្មភាពនេះ សំដៅធ្វើឱ្យសិស្សានុសិស្សក្តាប់បាន និងយល់ ជ្រួតជ្រាបច្បាស់លាស់ ពីប្រព័ន្ធចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់។ សាស្ត្រាចារ្យត្រូវធ្វើឱ្យ សិស្សមានការអភិវឌ្ឍន៍ខាងសមត្ថភាពយល់ដឹងក្តាប់បានច្បាស់នូវធាតុពិតទាំងឡាយរបស់វប្បធម៌ ពលកម្មបញ្ញា និងកាយពលកម្មបណ្តុះបណ្តាលបាននូវមូលដ្ឋាននៃទស្សនៈវិទ្យាសាស្ត្រ និងលទ្ធិប្រជាធិប្បតេយ្យ។
- ការបង្ហាត់បង្រៀន គឺជាលំនាំនៃការផ្សព្វផ្សាយចំណេះដឹងរបស់សាស្ត្រាចារ្យ និងទំនួលយល់ ជ្រួតជ្រាបចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ និងវិធីអនុវត្តចំណេះដឹងរបស់សិស្ស។ ការបង្ហាត់បង្រៀ នគឺជាលំនាំនៃសកម្មភាពពីរ គឺសកម្មភាពរបស់សាស្ត្រាចារ្យ «បង្រៀន» និង សកម្មភាព របស់សិស្ស «រៀន» ឬ «អនុវត្ត»។ នៅក្នុងលំនាំនៃការសិក្សា គ្រប់គោលដៅទាំងអស់នៃ ការ ផ្តល់ចំណេះដឹង ត្រូវតែបានអនុវត្តឡើង។ ភារកិច្ចនៃការបង្រៀន នៅក្នុងសាលារៀនចំណេះទូទៅ មិនគ្រាន់តែធានាបាននូវកម្រិតយល់ដឹងរបស់សិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែក ដល់ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់សិស្សតាមលទ្ធិប្រជាធិប្បតេយ្យទៀតផង។
- ការបង្ហាត់បង្រៀន គឺជាលំនាំមួយនៃការផ្សព្វផ្សាយចំណេះដឹង ជាលំនាំនៃការគ្រប់គ្រង និងស្វ័យគ្រប់គ្រងការសិក្សារបស់សិស្ស។

យើងអាចទាញបាននិយមន័យជាថ្មីទៀត ចំពោះលំនាំនៃការបង្រៀននេះ។

ទស្សនៈខាងលើ ជាទស្សនៈស្តីពីលំនាំនៃការបង្រៀននេះ មានចំណុចខ្លាំងពូកែ ចំណុចទន់ខ្សោយ និងចំណុចខ្លះដូចគ្នា។ដើម្បីអាចឆ្លើយបានយ៉ាងត្រឹមត្រូវ ហើយគ្រប់គ្រាន់ទៅលើបញ្ហានេះ ក៏ដូចជាការយល់បានយ៉ាងច្បាស់លាស់ថា តើលំនាំការបង្រៀនគឺជាអ្វី? យើងបន្តការសិក្សាស្រាវជ្រាវស្វែងយល់ឱ្យ បានច្បាស់លាស់ស៊ីជម្រៅ ទៅលើបញ្ហាមួយចំនួនខាងក្រោមនេះ។

## ៤.១០.១.កត្តាជាមូលដ្ឋានរបស់លំនាំនៃការបង្រៀន

កាលណាកំណត់ច្បាស់លាស់នូវកត្តាទាំងឡាយដែលមានលក្ខណៈផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម ហើយយើងគប្បីយកចិត្តទុកដាក់ដល់សំណួមពរទាំងឡាយដូចតទៅ៖

- រៀបរាប់ឱ្យបានគ្រប់គ្រាន់ ពីកត្តាទាំងឡាយជាមូលដ្ឋាន
- រៀបរាប់ឱ្យបានច្បាស់លាស់ ពីមុខងាររបស់កត្តានីមួយៗ
- បង្ហាញឱ្យឃើញច្បាស់ ពីចំណងទាក់ទងគ្នារវាងកត្តានីមួយៗ

នៅក្នុងលំនាំនៃការបង្ហាត់បង្រៀន មានកត្តាជាមូលដ្ឋានដូចតទៅ៖

គោលដៅ និងភារកិច្ចរបស់ការបង្រៀន

1. ខ្លឹមសារនៃការបង្រៀន
2. សាស្ត្រាចារ្យ «សកម្មភាពបង្រៀន»
3. សិស្សានុសិស្ស «សកម្មភាពរៀន»
4. សមូហភាព ពីព្រោះការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្សស្តែងឡើងក្នុងសមូហភាព
5. មធ្យោបាយបង្រៀន វាចាររបស់សាស្ត្រាចារ្យ ឧបករណ៍ សម្ភារៈឧបទេសសិក្សា
6. វិធីសាស្ត្របង្រៀន «របៀបធ្វើការរបស់សាស្ត្រាចារ្យ និងសិស្សានុសិស្ស ឆ្លងកាត់តាមរយៈបម្រើបម្រាស់ មធ្យោបាយសិក្សា ដើម្បីធ្វើឱ្យភារកិច្ចនៃការបង្រៀនបានសម្រេច»។

7. មជ្ឈមណ្ឌលសេដ្ឋកិច្ច សង្គម វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ដែលមានចែងនៅក្នុង កម្មវិធី សិក្សា។

## ៤.១០.២ លំនាំនៃការបង្រៀន គឺជាលំនាំនៃសកម្មភាពរបស់គ្រូបង្រៀន និង សិស្ស

នៅក្នុងលំនាំនេះ សាស្ត្រាចារ្យបំពេញតួនាទីជាអ្នកដឹកនាំ ចាត់តាំង និងគ្រប់គ្រង រីឯសិស្សវិញ បំពេញតួនាទីជាអ្នកភ្ញាក់រលឹក សកម្ម ម្ចាស់ការ ទទួលឥទ្ធិពលពីសាស្ត្រាចារ្យ។ បង្រៀន និងរៀន គឺជាសកម្មភាពពីរដែលបំពេញឱ្យគ្នាទៅវិញទៅមក ហើយដែលមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន នៅក្នុងលំនាំនៃការបង្រៀន ។

**ការបង្រៀន**គឺជាសកម្មភាពរបស់សាស្ត្រាចារ្យសំដៅដឹកនាំចាត់តាំងនិងគ្រប់គ្រងការសិក្សារបស់សិស្ស។

### ការងារដឹកនាំរបស់សាស្ត្រាចារ្យមាន៖

- ការលើកឡើងនូវគោលដៅ និងសំណូមពរក្នុងការបង្រៀន និងការអប់រំ
  - ការដាក់ចុះនូវផែនការសិក្សា និងការតាមដានការអនុវត្តផែនការសិក្សារបស់សិស្ស
  - ការធ្វើឱ្យបានសម្រេចតាមផែនការ
  - កំណែតម្រូវ និងការបំពេញចំណុចខ្វះខាតដែលមាន

### ចំណាត់តាំងរបស់សាស្ត្រាចារ្យចែកចេញជា៖

- ជម្រើស និងការរៀបចំខ្លឹមសារមេរៀន រូបភាពអនុវត្ត មធ្យោបាយសិក្សា
  - បង្កើតលក្ខខ័ណ្ឌងាយស្រួលឱ្យដល់ការសិក្សារបស់សិស្ស
  - ធ្វើឱ្យបានសម្រេចនូវលទ្ធផល និងជោគជ័យក្នុងការបង្រៀន និងការសិក្សារបស់សិស្ស

### ការងារគ្រប់គ្រងរបស់សាស្ត្រាចារ្យរួមមាន៖

- ការអនុវត្តគោលការណ៍ និងវិធីសាស្ត្របង្រៀនឱ្យបានសមស្របសំដៅផ្តល់ចំណេះដឹងតាមខ្លឹមសារនៃមេរៀន
- ដឹកនាំការយល់ជ្រួតជ្រាបនិងការក្តាប់បានចំណេះដឹងរបស់សិស្សតាមវិធីទាំងឡាយដ៏ប្រសើរបំផុត។

### ការរៀន ឬការសិក្សា៖

គឺជាសកម្មភាពរបស់សិស្សានុសិស្សបានដល់ការភ្ញាក់រលឹក និងសកម្មភាព ម្ចាស់ការតាមតួនាទីខាងផ្លូវចិត្ត ចាប់តាំងពីឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ លំនឹក រូបារម្មណ៍ ការគិត ភាសា រហូតដល់សញ្ចេតនា ឆន្ទៈ និងសកម្មភាពប្រតិបត្តិ សំដៅយល់ជ្រួតជ្រាប និងក្តាប់បានច្បាស់នូវចំណេះដឹង ហ្វឹកហ្វឺនចំណេះធ្វើនិងបំណិនប្រសប់ នៅក្នុងការងារពលកម្ម និងក្នុងជីវភាពរស់នៅក្នុងសង្គម។

គប្បីផ្សារភ្ជាប់យ៉ាងជិតស្និទ្ធ រវាងសកម្មភាពបង្រៀនរបស់សាស្ត្រាចារ្យ និងសកម្មភាពរៀន របស់សិស្ស ហើយនិងលទ្ធផលរបស់សកម្មភាពនេះទៅនឹងសកម្មភាពផ្សេងទៀត។ ចង់សម្រេចបាននូវ ប្រការនេះ នៅពេលបង្រៀន សាស្ត្រាចារ្យ គប្បីក្តាប់ឱ្យបានច្បាស់លាស់ពីកម្មវត្ថុបង្រៀនរបស់ខ្លួនពោលគឺសាស្ត្រាចារ្យគប្បីយល់ដឹងស៊ីជម្រៅឱ្យបានច្បាស់លាស់ពី៖

- ភាពដោយឡែកខាងផ្លូវចិត្ត និងលក្ខណៈពិសេសខាងវ័យសិក្សារបស់សិស្ស
- កម្រិតវប្បធម៌ និងសមត្ថភាពយល់ដឹងរបស់សិស្សម្នាក់ៗ ក្នុងលំនាំនៃការក្តាប់យកចំណេះដឹង
- ស្ថានភាពសេដ្ឋកិច្ច នយោបាយ សង្គម លក្ខខ័ណ្ឌ មធ្យោបាយ និងវិធីសាស្ត្រក្នុងការបង្រៀន ការអប់រំ និងការសិក្សារបស់សិស្ស។

- លទ្ធផលនៃការសិក្សារបស់សមូហភាពសិស្ស និងសិស្សម្នាក់ៗពីពេលមុនមកដល់សព្វថ្ងៃនេះ។
- ម្យ៉ាងទៀតពេលរៀនក្នុងថ្នាក់ និងរៀននៅផ្ទះ សិស្សម្នាក់ៗគប្បីយល់ជ្រួតជ្រាប និងក្តាប់ឱ្យបានច្បាស់លាស់ពីសេចក្តីទូន្មាន ឬការណែនាំរបស់សាស្ត្រាចារ្យ។ សិស្សម្នាក់ៗគប្បីអនុវត្តឱ្យបានគ្រប់គ្រាន់លើរាល់សំណូមពរ ដែលសាស្ត្រាចារ្យដាក់ចុះ។

ទោះជានៅពេលណាក៏ដោយ ការគួបផ្សំគ្នារវាងសកម្មភាពបង្រៀនរបស់សាស្ត្រាចារ្យ ទៅនឹងសកម្មភាព សិក្សារបស់សិស្សត្រូវតែរក្សាបាននូវតួនាទីមួយដ៏សំខាន់ នៅក្នុងលំនាំនៃការបង្ហាត់បង្រៀន ការអប់រំ និងការសិក្សា។ ជាការពិតណាស់ សាស្ត្រាចារ្យ ត្រូវតែធ្វើសកម្មភាពរបស់ខ្លួន ឯកភាពគ្នាជាមួយសកម្មភាពរបស់សិស្ស។ សាស្ត្រាចារ្យត្រូវដឹកនាំខ្លឹមសារ និងវិធីសាស្ត្រក្នុងការសិក្សារបស់សិស្ស។ ដូចនេះ សាស្ត្រាចារ្យ គប្បីធានាឱ្យបានតួនាទីជាអ្នកដឹកនាំ ក្នុងលំនាំនៃការបង្រៀន និងការសិក្សា។ ថ្វីបើកម្រិតរបស់ទំនើបកម្ម ក្នុងវិទ្យាសាស្ត្របច្ចេកទេសកាន់តែខ្ពស់យ៉ាងណាក៏ដោយ ក៏សាស្ត្រាចារ្យត្រូវតែបំពេញតួនាទីជាអ្នកដឹកនាំជានិច្ច។ តួនាទីរបស់សាស្ត្រាចារ្យ មិនត្រូវមានទំនាស់ជាមួយនឹងចរិតម្ចាស់ការច្នៃប្រឌិត របស់សិស្ស ឡើយ។ ផ្ទុយទៅវិញសាស្ត្រាចារ្យមានភារកិច្ចដ៏ចាំបាច់ គឺធ្វើឱ្យសិស្សានុសិស្សខិតខំប្រឹងប្រែងព្យាយាម ក្នុងការសិក្សា និងមានកម្រិតម្ចាស់ការច្នៃប្រឌិតក្នុងការអនុវត្ត។ ដូចនេះហើយ បានជាត្រូវគួបផ្សំយ៉ាងជិតស្និទ្ធ រវាងតួនាទីដឹកនាំរបស់សាស្ត្រាចារ្យទៅនឹងចរិតម្ចាស់ការច្នៃប្រឌិត ក្នុងការសិក្សារបស់សិស្ស នៅក្នុងលំនាំនៃការបង្រៀន និងការអប់រំសិស្ស។នេះ គឺជាបញ្ហាដ៏សំខាន់ នៅក្នុងសិល្បៈគរុកោសល្យ របស់លំនាំនៃការបង្រៀន សំដៅធ្វើឱ្យការសិក្សារបស់សិស្ស សម្រេចបានលទ្ធផលល្អ។ កាលណាសិស្ស សិក្សាឈានចូលដល់កម្រិតយល់ដឹងខ្ពស់ តួនាទីម្ចាស់ការ សកម្មច្នៃប្រឌិតរបស់សិស្ស កាន់តែសំខាន់ខ្លាំង ឡើងដែរ។ដើម្បីឯកភាពគ្នាបានរវាងលំនាំនៃការបង្រៀនរបស់សាស្ត្រាចារ្យទៅនឹងលំនាំនៃការ សិក្សារបស់សិស្ស ដែលជាលក្ខខ័ណ្ឌចាំបាច់មួយនៅក្នុង ចំណោមលក្ខខ័ណ្ឌជាមូលដ្ឋាននោះ គឺត្រូវធ្វើឱ្យលំនាំនៃ ការបង្រៀន និងការសិក្សានេះបានប្រែក្លាយទៅជាជុំវិលមួយ។

សាស្ត្រាចារ្យ គប្បីយល់ដឹងថាការបង្ហាត់បង្រៀនរបស់ខ្លួន គឺជាលំនាំនៃការដឹកនាំមួយ។ រវាងអ្នកដឹកនាំ «សាស្ត្រាចារ្យ» និងអ្នកធ្វើសកម្មភាពដែលត្រូវដឹកនាំ «សិស្ស» ជានិច្ចកាល ត្រូវតែមានចំណង ទាក់ទងគ្នាទៅវិញ ទៅមក «មធ្យោបាយរបស់សាស្ត្រាចារ្យ និងទំនួលព័ត៌មានពីការសិក្សា»។ ការដឹកនាំរបស់សាស្ត្រាចារ្យត្រូវ តែបានក្លាយទៅជាការដឹកនាំដ៏ពិតប្រាកដត្រឹមត្រូវ។ សាស្ត្រាចារ្យ អាចផ្សព្វផ្សាយបានដល់សិស្សានុសិស្ស ដោយបម្រើបម្រាស់ ភាសាសម្បូរដោយរូបារម្មណ៍ក្នុងបំណកស្រាយ ពន្យល់ ឬដោយមធ្យោបាយផ្សេង ទៀតដូចជាបំណកស្រាយពន្យល់តាមឯកសារ និងបម្រើបម្រាស់សម្ភារៈសិក្សា ឬម៉ាស៊ីនជាដើម។ យើងចាត់ទុកជាបំណកស្រាយពន្យល់របស់សាស្ត្រាចារ្យឱ្យសិស្ស គឺជាមាគ៌ាមួយដែលផ្សារភ្ជាប់គ្នា ដោយ ផ្ទាល់។ ក្រោយពេលបកស្រាយពន្យល់របស់សាស្ត្រាចារ្យ សិស្សគប្បីយល់ជ្រួតជ្រាប ត្រិះរិះពិចារណា ម្ចាស់ ការច្នៃប្រឌិត និងអនុវត្តបំណកស្រាយពន្យល់។ បន្ទាប់មក សិស្សត្រូវធ្វើរបាយការណ៍របស់ខ្លួន តាមរយៈកិច្ចការត្រួតពិនិត្យ។

ប្រការនេះ បានក្លាយទៅជាទំនាក់ទំនងបញ្ច្រាសមួយ ដែលធ្វើឱ្យលំនាំនៃការបង្រៀនមាន លក្ខណៈដូចសៀគ្វីបិទ។ សាស្ត្រាចារ្យ គប្បីយកចិត្តទុកដាក់ ទៅលើចំណងទាក់ទងបញ្ច្រាសនេះ ដើម្បី កំណត់បាន និងដឹកនាំសិស្ស នៅក្នុងលំនាំនៃការបង្រៀនឱ្យរិតតែមានប្រសិទ្ធភាព។ ដោយហេតុថា ចំណងទាក់ទងបញ្ច្រាសនេះ បំពេញតួនាទីក្នុងការដឹកនាំនោះហើយ ទើបតម្រូវឱ្យសាស្ត្រាចារ្យយក ចិត្តទុកដាក់

ថែរក្សាតួនាទីនេះ។

នៅក្នុងលំនាំនៃការបង្រៀន ដែលលើកឡើងនេះ ឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវលក្ខណៈស្វ័យអភិវឌ្ឍន៍របស់សិស្សដូចជា សិស្សចេះមើលឃើញនូវកំហុសក្នុងការយល់ជ្រួតជ្រាប និងក្តាប់បាននូវចំណេះដឹងពេលស្វ័យត្រួតពិនិត្យ។ ម្យ៉ាងទៀត សិស្សអាចកែប្រែកំហុស និងភាពផ្តាំផ្តងទាំងនោះបានដោយពឹងផ្អែកលើអំណានសៀវភៅបន្ថែម ឬមេរៀនដែលបានកត់ត្រារួចមកហើយ។ ប្រព័ន្ធនេះ បណ្តុះបណ្តាលបានជាមាគ៌ាមួយផ្សារភ្ជាប់ទៅនឹងទំនាក់ទំនងបញ្ច្រាស ខាងក្នុងគំនិតរបស់សិស្ស។ សិស្ស អាចអភិវឌ្ឍបានលុះត្រាតែសិស្ស ចេះមើលឃើញកំហុសចំណុចខ្វះខាត ឬចំណុចខ្លាំងពូកែរបស់ខ្លួន ក្នុងកិច្ចការត្រួតពិនិត្យ។ ដូចនេះសិស្សអាចអភិវឌ្ឍឡើង បានដោយចេះកែកំហុស ចំណុចខ្វះខាត និងចេះភ្ញាក់រលឹកយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ទៅលើការដឹកនាំរបស់សាស្ត្រាចារ្យ។ ប្រការនេះបង្កើត បានជាទំនាក់ទំនងបញ្ច្រាសខាងក្នុងគំនិតសិស្សជាលើកទីពីរ។ សិស្សគប្បីជានាបាននូវទំនាក់ទំនងបញ្ច្រាសទាំងពីរនេះ នៅក្នុងលក្ខខ័ណ្ឌជាមូលដ្ឋាន ដើម្បី អភិវឌ្ឍបាននូវស្មារតីម្ចាស់ការ ច្នៃប្រឌិត នៅក្នុងលំនាំនៃការសិក្សារបស់ខ្លួន។ ក្រៅពីនេះ នៅពេលបញ្ចេញ មតិយោបល់ជាមួយមិត្តភក្តិ ឬក្នុងសមូហភាពសិស្ស ក៏អាចស្វ័យត្រួតពិនិត្យឡើងវិញបានដែរ នូវចំណេះ ដឹងដែលក្តាប់បានរួចមកហើយ។ គឺប្រការនេះហើយ ដែលបង្កើតបានទំនាក់ទំនងបញ្ច្រាសខាងក្នុងគំនិត សិស្សជាលើកទី៣។

## ៤.១០.៣ សារជាតិរបស់លំនាំនៃការបង្រៀន

## ក. លំនាំនៃការបង្រៀនចែកចេញជាលំនាំពីរស្របគ្នា

**ក.លំនាំនៃការសិក្សា** គឺជាមូលដ្ឋាននៃចំណេះដឹង និងជាលំនាំនៃការផ្ទេរចំណេះដឹង ដែលក្នុងនោះសិស្ស ម្នាក់ៗជាអ្នកទទួលយល់ជ្រួតជ្រាប និងក្តាប់យកចំណេះដឹងនោះ។ នៅក្នុងលំនាំនៃការសិក្សានេះ សិស្ស គប្បីប្រើប្រាស់ឱ្យអស់លទ្ធភាព នូវគ្រប់មធ្យោបាយបង្រៀនរបស់សាស្ត្រាចារ្យ និងមធ្យោបាយរៀនដោយ ខ្លួនឯង ដើម្បីយល់ជ្រួតជ្រាបចំណេះដឹង និងចំណេះដឹង និងដើម្បីហ្វឹកហ្វឺនចំណេះធ្វើ និងបំណិនប្រសប់ នៅក្នុងលក្ខខ័ណ្ឌមួយ ដែលជះឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងសមូហភាព និងទៅលើចំណាត់តាំង ឬការដឹកនាំ របស់សាស្ត្រាចារ្យ។

**ខ.លំនាំនៃការបង្រៀន** គឺជាលំនាំនៃចំណាត់តាំងសកម្មភាពយល់ជ្រួតជ្រាបចំណេះដឹង។ នៅក្នុងលំនាំនៃការបង្រៀន គ្រូបង្រៀនគប្បីពឹងផ្អែកលើកត្តាទាំងឡាយជាមូលដ្ឋានដូចតទៅៈ

- កម្មវិធីសិក្សា ឯកសារសិក្សា និងឯកសារវិទ្យាសាស្ត្រដែលទាក់ទងនឹងមុខវិជ្ជា ឯកទេសខ្លួន
- ចេះបំពេញបង្គ្រប់ដោយខ្លួនឯង បាននូវចំណុចដែលចាំបាច់ ក្នុងមុខវិជ្ជាឯកទេសរបស់ខ្លួន លក្ខខណ្ឌជាក់ស្តែងរបស់សាលារៀន និងមជ្ឈដ្ឋានរស់នៅរបស់សិស្ស។
- អនុវត្តតាមទស្សនៈដ៏ត្រឹមត្រូវ តាមសមត្ថភាពរបស់ខ្លួនដើម្បីសម្រេចតាមគោលដៅនៃមេរៀន និងកម្មវិធីសិក្សា។
- ដឹកនាំសិស្សឱ្យសិក្សាស្វ័យសិក្សា និងអនុវត្តបានតាមមាគ៌ាមួយដ៏ប្រសើរបំផុត
- ធ្វើឱ្យគោលដៅនៃការសិក្សារបស់សិស្ស បានសម្រេចដោយលទ្ធផលល្អ និងមាន ប្រសិទ្ធភាពខ្ពស់ ។

ដូចនេះ សារជាតិរបស់លំនាំនៃការបង្រៀន គឺជាលំនាំនៃការក្តាប់យកចំណេះដឹង និងលំនាំនៃចំណាត់

តាំង ក្នុងការយល់ជ្រួតជ្រាបចំណេះដឹងនេះ។ម្យ៉ាងទៀតអាចនិយាយបានថាសារជាតិរបស់លំនាំនៃការបង្រៀន គឺជាលំនាំនៃការក្ដាប់យកចំណេះដឹង ជាដំបូងបង្អស់របស់សិស្ស ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យសំដៅ ធ្វើឱ្យភារកិច្ចនៃការបង្រៀនរបស់សាស្ត្រាចារ្យបានសម្រេច។

## ខ. លំនាំនៃការបង្រៀនត្រូវប្រព្រឹត្តិឡើងឱ្យបានសម្រេចតាមទឹកចិត្តរបស់សិស្ស

ក្នុងបញ្ហានេះ លំនាំនៃការយល់ជ្រួតជ្រាបចំណេះដឹងសំខាន់ និងចាំបាច់ណាស់ ហើយត្រូវឱ្យបានសមស្របទៅនឹងលក្ខណៈចាំបាច់ របស់លំនាំនៃការបង្រៀនផង។ ក្រៅពីនេះនៅមានសភាពចិត្ត និងលំនាំផ្លូវចិត្តផ្សេងទៀតជាមូលដ្ឋានដូចជា ស្មារតីប្រុងប្រយ័ត្ន លំនាំនៃសញ្ចេតនា លំនាំនៃឆន្ទៈ និងសកម្មភាពប្រតិបត្តិផ្សេងៗ។ រវាងលំនាំនៃការយល់ជ្រួតជ្រាបចំណេះដឹង និងលំនាំផ្លូវចិត្តផ្សេងទៀតនេះ សុទ្ធតែមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសកម្មភាពបង្រៀន និងសកម្មភាពសិក្សាដែល បង្កើតបានជារចនាសម្ព័ន្ធផ្លូវចិត្តរបស់សិស្ស។

## ៤.១០.៤ ភាពសមហេតុផលនៅក្នុងលំនាំនៃការបង្រៀន

ភាពសមហេតុផលនៅក្នុងលំនាំនៃការបង្រៀន គឺជាប្រភពនៃក្រិតក្រមដែលប្រកបទៅដល់លទ្ធផលល្អជាអតិបរមារបស់សិស្ស ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យចាប់តាំងពីដើមដំបូងនៃកម្រិត និងការអភិវឌ្ឍរបស់ចំណេះដឹងលើគ្រប់មុខវិជ្ជាសិក្សារហូតដល់កម្រិត និងការអភិវឌ្ឍន៍នៃចំណេះដឹង ដ៏សមស្របដែលសិស្សបានយល់ជ្រួតជ្រាប និងក្ដាប់បានច្បាស់។

ជាបឋមការបង្ហាត់បង្រៀន ត្រូវតែបានវិវត្តទៅតាមប្រព័ន្ធចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់នៅក្នុងកម្មវិធីសិក្សារបស់មុខវិជ្ជានីមួយៗ។ ដូចនេះភាពសមស្របនិងសមហេតុផលរបស់លំនាំនៃការបង្រៀនត្រូវតែផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធទៅនឹងភាពសមហេតុផលរបស់មុខវិជ្ជាសិក្សានីមួយៗ។ ការបង្ហាត់បង្រៀនមិនមែនជាការធ្វើសកម្មភាពតាមកម្មវិធីសិក្សាទាំងស្រុងនោះទេ ឬក៏នៅពេលបង្រៀន សាស្ត្រាចារ្យគ្រាន់តែពញ្ញាក់សិស្សឱ្យរៀនឱ្យយល់ជ្រួតជ្រាបចំណេះដឹងហើយឱ្យធ្វើកិច្ចការត្រួតពិនិត្យប៉ុណ្ណោះទេ។ ម្យ៉ាងវិញទៀត ការបង្ហាត់បង្រៀន គឺជាការអនុវត្តតាមលំនាំនៃការយល់ជ្រួតជ្រាប និងក្ដាប់យកចំណេះដឹងរបស់សិស្ស។ ភាពសមហេតុផលរបស់លំនាំនៃការបង្រៀន គឺចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ រវាងភាពសមហេតុផលរបស់មុខវិជ្ជាសិក្សានីមួយៗ និងលំនាំនៃការយល់ជ្រួតជ្រាប ក្ដាប់យកចំណេះដឹងរបស់សិស្ស។ឈរលើមូលដ្ឋាននៃប្រការទាំងឡាយ ដែលបានលើកឡើងស្ដីពីសារជាតិ របស់លំនាំនៃការបង្រៀន យើងគប្បីលើកឡើងឱ្យបានច្បាស់លាស់ល្អិតល្អន់ ដាក់ស្ដែងនូវកម្មវត្ថុមួយដ៏ចាំបាច់ គឺមាគ៌ាអនុវត្ត និងការអភិវឌ្ឍនៃក្រិតក្រមរបស់លំនាំនៃការបង្រៀនពោលគឺការសិក្សាស្រាវជ្រាវស៊ីជម្រៅ ទៅលើភាពសមហេតុផលនៃក្នុងលំនាំនៃការបង្រៀននេះឯង។

ដំណាក់កាលរបស់លំនាំនៃការបង្រៀនចែកចេញជាៈ

1. ការទាក់ទាញអារម្មណ៍សិស្សឱ្យយកចិត្តទុកដាក់ក្នុងការបង្រៀន
2. បំណកស្រាយពន្យល់មេរៀនថ្មី
3. ការបណ្ដុះសញ្ញាណថ្មី តាមមេរៀនថ្មី
4. ការពង្រឹងចំណេះដឹងថ្មី
5. ការអនុវត្តចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស

6. ការត្រួតពិនិត្យលើចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស

## ក. ការជំរុញសិស្សឱ្យយកចិត្តទុកដាក់ក្នុងការបង្រៀន

លំនាំនៃការបង្រៀន និងត្រូវបានទទួលលទ្ធផលល្អ នៅពេលដែលសាស្ត្រាចារ្យប៉ិនប្រសប់ចេះលើកឡើងពីភារកិច្ច នៃការយល់ជ្រួតជ្រាបចំណេះដឹងថ្មី ហើយចេះជំរុញសិស្សឱ្យមានចំណង់ចំណូលចិត្តក្នុងការសិក្សា។ ចង់សម្រេចបានតាមបំណងនេះ សាស្ត្រាចារ្យម្នាក់ៗគប្បី៖

- កំណត់បាន និងចាត់តាំងថ្នាក់រៀន គឺសមូហភាពឱ្យមានវិន័យល្អ
- បង្កើតបាននូវបរិយាកាសមួយ ដ៏រីករាយនៅក្នុងថ្នាក់
- បង្កើតបានជាស្ថានភាពមានបញ្ហាចោទ នៅចំពោះមុខសិស្ស ឱ្យសិស្សដោះស្រាយ
- បំណកស្រាយពន្យល់មេរៀន ឱ្យបានច្បាស់លាស់ល្អ
- លើកកម្ពស់ពីមូលហេតុ រៀនល្អ និងរៀនពូកែរបស់សិស្ស
- យកចិត្តទុកដាក់បង្កើតបាននូវបរិយាកាសដ៏រីករាយ ពោលគឺការចង់ឃើញ ចង់ដឹង ចង់ យល់របស់សិស្ស
- បង្កើតបានជាបញ្ហាសំខាន់ៗនៅក្នុងលក្ខខ័ណ្ឌមួយជាកំណត់ សំដៅធ្វើឱ្យសិស្សយល់ច្បាស់លាស់ពីអត្ថន័យនយោបាយ សង្គម និងខ្លឹមសារមេរៀន តាម លំនាំនៃការបង្រៀន
- ឱ្យសិស្សមានតម្រូវការ និងមើលឃើញអត្ថប្រយោជន៍ជាក់ស្តែងក្នុងការសិក្សា
- ឱ្យសិស្សសិក្សាស៊ីជម្រៅ ទៅលើទំនាស់រវាងភារកិច្ចនៃការបង្រៀន និងកម្រិត យល់ដឹង របស់សិស្ស។

## ខ. បំណកស្រាយពន្យល់មេរៀនថ្មី

ការជំរុញសិស្ស ឱ្យមានស្មារតីប្រុងប្រយ័ត្ន ការយកចិត្តទុកដាក់ និងលក្ខណៈត្រិះរិះយ៉ាងសកម្ម នៅក្នុងលំនាំនៃការបង្រៀន គឺជាការបង្កើតបាន នូវលក្ខខ័ណ្ឌមួយដ៏សមស្របទៅតាមដំណាក់កាលនានារបស់ប្រត្យក្សារម្មណ៍ទៅលើមេរៀនថ្មី។ ដំណាក់កាលនេះ សំខាន់ណាស់។ សិស្សត្រូវប្រើប្រាស់ គ្រប់វិញ្ញាសាទាំងអស់ របស់ខ្លួនដើម្បីឈ្វេងយល់និងក្តាប់ខ្លឹមសារមេរៀនថ្មី ដែលសាស្ត្រាចារ្យ បានយកមក បកស្រាយពន្យល់ដូចជា «វត្ថុ បាតុភូត អត្ថបទអក្សរសិល្ប៍ ស្នាដៃនិពន្ធ» សំដៅក្តាប់យកចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ឱ្យបានច្បាស់លាស់។ ទោះណាជាមេរៀនថ្មីនោះ ជាឯកសារចម្លង ឬជាឯក សារដែលសិស្សធ្លាប់ឃើញ ឬសិស្សមានហើយក៏ដោយ ក៏សាស្ត្រាចារ្យ ត្រូវតែធ្វើឱ្យសិស្សមានការពិនិត្យ សង្កេតផ្ទាល់ទៅលើវត្ថុ និងបាតុភូត ឬក៏អាចប្រើវិធីសន្ទនា ដើម្បីនាំផ្លូវសិស្សឱ្យស្វែងយល់ច្បាស់ ឬក៏ប្រើវិធីរ៉ាយរ៉ាប់ដោយណែនាំសិស្សឱ្យមើលសៀវភៅសិក្សា ឬឯកសារដែលទាក់ទងនឹងមេរៀនថ្មីនេះ។

ដើម្បីធ្វើឱ្យសិស្សយល់ស៊ីជម្រៅ និងក្តាប់ចំណេះដឹងឱ្យបានច្បាស់លាស់ប្រកបដោយលទ្ធផលល្អនៅក្នុងលំនាំនៃការបង្រៀនមេរៀនថ្មី សាស្ត្រាចារ្យ គប្បីក្តាប់ឱ្យបាននូវកត្តាសំខាន់ៗខ្លះដូចជា៖

- ធ្វើឱ្យសិស្សរំលឹកឡើងវិញ ទៅលើបទពិសោធន៍ និងចំណេះដឹងដែលបានរៀន ឬបានជួបប្រទះ រួចមកហើយ។
- ជំរុញសិស្ស ឱ្យឃើញនូវចំណងទាក់ទងគ្នារវាងចំណេះដឹង ដែលសិស្សក្តាប់បានរួចមកហើយ ទៅនឹងចំណេះដឹងក្នុងការសិក្សាលើវត្ថុ ឬបាតុភូតដែលកំពុងលើកមករៀន។
- ញុាំងសិស្ស ឱ្យកសាងបាននូវរូបតំណាងមួយ ដ៏ត្រឹមត្រូវច្បាស់លាស់ សម្រាប់យកធ្វើជាមូលដ្ឋានក្នុងការបណ្តុះបញ្ញា ឬសញ្ញាណ។

## គ. ការបណ្ដុះសញ្ញាណថ្មីតាមមេរៀនថ្មី

នេះគឺជាដំណាក់កាលកណ្ដាល ហើយសំខាន់បំផុត នៅក្នុងលំនាំនៃការសិក្សារបស់សិស្ស ក្នុងការយល់ជ្រួតជ្រាប និងក្ដាប់បានចំណេះដឹងថ្មី។ ឈរលើមូលដ្ឋាន នៃការបណ្ដុះបណ្ដាលបាននូវរូបតំណាង ដ៏ត្រឹមត្រូវច្បាស់លាស់ដែលបានឆ្លងកាត់ដោយបំណកស្រាយមេរៀនថ្មីក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ សិស្សត្រូវអនុវត្តចលនានៃការគិតដូចជាៈ ការធ្វើវិភាគ សំយោគ គំហៀបធៀប អរូបីយកម្ម និងទូទៅកម្មជាដើម។ លទ្ធផលរបស់លំនាំនៃសកម្មភាពត្រិះរិះពិចារណាដ៏សកម្មនោះ គឺសិស្សបណ្ដុះ បានដោយខ្លួនឯងនូវសញ្ញាណរបស់វត្ថុ ឬបាតុភូតដែលកំពុងរៀន។កាលណាយល់ជ្រួតជ្រាប និងក្ដាប់ បានសញ្ញាណនេះច្បាស់លាស់ហើយ សិស្សអាចប្រើប្រាស់ សញ្ញាណនេះ គួបផ្សំទៅនឹងសញ្ញាណ ដែលបានសិក្សារួចមកហើយ ឱ្យទៅជាការត្រិះរិះពិចារណាមួយ ដ៏ត្រឹមត្រូវច្បាស់លាស់ ហើយសមហេតុ ផល។ សញ្ញាណ ការវិនិច្ឆ័យ និងការត្រិះរិះពិចារណា គឺជាការស្ដែងចេញក្រោមរូបភាពនៃភាសា តាមរយៈ និយមន័យ ក្រឹត្យក្រម វិភាគ ទ្រឹស្ដីបទ គោលការណ៍ ជាដើម។ ការយល់ជ្រួតជ្រាប និងក្ដាប់បាន ច្បាស់ លាស់នូវសញ្ញាណថ្មីនេះ គឺជាការផ្សារភ្ជាប់សញ្ញាណថ្មីនេះ ទៅនឹងប្រព័ន្ធសញ្ញាណ និងបទពិសោធន៍ដែល សិស្សបានឆ្លងកាត់ ឬក្ដាប់បានច្បាស់រួចមកហើយ ហើយទន្ទឹមនឹងនេះសិស្សអាចសម្ដែងចេញបាននូវសញ្ញាណនោះដោយភាសាផ្ទាល់ខ្លួនឯងផង។

ចំណាត់តាំងបានដ៏ត្រឹមត្រូវច្បាស់លាស់ ពីលំនាំនៃការកសាងបាននូវសញ្ញាណថ្មីនោះ គឺស្ថិតនៅត្រង់ ដែលសាស្ត្រាចារ្យ ពូកែ ហើយប៉ិនប្រសប់ ធ្វើឱ្យសិស្សយល់ជ្រួតជ្រាប និងក្ដាប់បានជាបណ្ដើរៗ ទៅលើវិធីផ្សេងៗ ដែលជាមូលដ្ឋាននៃការគិតដ៏សមហេតុផល រួចហើយសិស្សត្រូវសកម្មម្ចាស់ការក្នុងការ ហ្វឹកហ្វឺនចំណេះធ្វើ និងបំណិនប្រសប់ សំដៅយល់ជ្រួតជ្រាប និងក្ដាប់ចំណេះដឹងថ្មីឱ្យបានច្បាស់លាស់ល្អ។

## ឃ. ការពង្រឹងចំណេះដឹងថ្មី

ចំណុចមួយដ៏សំខាន់របស់លំនាំនៃការបង្រៀន គឺនៅក្នុងរយៈពេលមួយយ៉ាងខ្លី សិស្សអាចយល់ជ្រួតជ្រាប និងក្ដាប់បានច្បាស់នូវបរិមាណចំណេះដឹងមួយ។ ដូចនេះហើយបានជាសាស្ត្រាចារ្យគប្បី យកចិត្តទុក ដាក់ដល់ការពង្រឹងចំណេះដឹងថ្មីដែលសិស្សទើបនឹងក្ដាប់បាននេះ។ ការពង្រឹងចំណេះដឹង ថ្មីនេះ គឺមានន័យថា បញ្ជាក់ឡើងវិញ ឬរំលឹកឡើងវិញឱ្យបានច្បាស់លាស់ត្រឹមត្រូវនូវទំនាក់ទំនងគ្នា រវាងសរសៃប្រសាទក្នុងខួរក្បាល ដែលត្រូវបានបណ្ដុះចំណេះដឹងថ្មីនោះដូចជា ការប្រយុទ្ធទល់នឹងការភ្លេច ហើយចាំបាច់នោះ គឺសាស្ត្រាចារ្យ ត្រូវរំលឹកសិស្សឱ្យប្រើប្រាស់ចំណេះដឹងថ្មីនោះ នៅក្នុងការប្រតិបត្តិ ឬនៅក្នុងជីវភាពរស់នៅ។ ចំណេះដឹងថ្មីតែងតែ ផ្សារភ្ជាប់ ឬមានទំនាក់ទំនងទៅនឹងចំណេះដឹង ដែលបានរៀនរួចមកហើយជានិច្ច។

វិធានការនេះ ត្រូវបានសាស្ត្រាចារ្យប្រើប្រាស់ជារឿយៗ ដើម្បីពង្រឹងចំណេះដឹងពោលគឺ ការរំលឹកការថាឡើងវិញ ឬការបង្កើតឡើងវិញតាមវិធីផ្សេងៗ ដែលសិស្សមានទម្លាប់រួចមកហើយ ឬពុំនោះសោត ត្រូវរៀបចំឱ្យមានការសិក្សាសារឡើងវិញឱ្យបានទៀងទាត់។ ក្នុងការរំលឹក ឬការថាមេរៀនឡើងវិញនេះ ជួនកាលអាចធ្វើឱ្យអត្ថប្រយោជន៍នៃការសិក្សារបស់សិស្សថយចុះបាន នៅពេលដែលសិស្ស ត្រូវយល់ ជ្រួតជ្រាបចំណេះដឹងតាមមេរៀនថ្មី ប្រសិនជាសាស្ត្រាចារ្យខ្វះបំណិនប្រសប់ក្នុងការដឹកនាំសិស្ស។ បំណិនប្រសប់របស់សាស្ត្រាចារ្យតាមន័យគរុកោសល្យនៅពេលនេះ គឺស្ថិតនៅត្រង់សាស្ត្រាចារ្យមានការស្ទាត់ជំនាញ ធ្វើឱ្យ សិស្សរំលឹកមេរៀនបានឡើងវិញទៅលើចំណេះដឹងថ្មីតាមលំដាប់លំដោយ និងឱ្យបានទៀងទាត់នៅក្នុងលក្ខខ័ណ្ឌថ្មី បានន័យថា ណែនាំនឹងជំរុញឱ្យយកចំណេះដឹងថ្មីនោះ ទៅអនុវត្តក្នុងពេលមានដំណោះ

ស្រាយបញ្ហាថ្មី សំដៅធ្វើឱ្យមេរៀនដែលទើបនឹងបានរៀនរួចមកហើយនេះ មានលក្ខណៈច្នៃប្រឌិត។

ការពង្រឹងចំណេះដឹងនេះចាំបាច់ណាស់ ត្រូវតែធ្វើឡើងក្នុងពេលជាមួយគ្នា ដើម្បីព្យាបាលបាននូវការបាត់បង់ចំណេះដឹងដែលបានរៀនរួចមកហើយ។ ល្អបំផុត គឺរៀនដល់ត្រឹមណាសាស្ត្រាចារ្យ ត្រូវពង្រឹងចំណេះដឹងសិស្សដល់ត្រឹមនោះ ឬម្យ៉ាងទៀត ទុកពេលពង្រឹងចំណេះដឹងនេះនៅក្នុងការពង្រឹងចំណេះដឹងនៅក្នុងដំណាក់កាលមួយផ្សេងទៀត របស់លំនាំនៃការបង្រៀន។

ល្បិចមួយទៀតដ៏សំខាន់បំផុត ដើម្បីសម្រេចបានការពង្រឹង និងការអភិវឌ្ឍន៍ចំណេះដឹងនេះគឺ ការសិក្សា សរុបឡើងវិញ។ ការសិក្សាសរុបឡើងវិញនេះ ត្រូវបានប្រព្រឹត្តិឡើងនៅក្រោយពេលរៀនចប់មេរៀនមួយចំនួន ឬរៀនចប់ ជំពូកណាមួយនៃមេរៀន។ ការពង្រឹងចំណេះដឹងបែបនេះ ត្រូវបានរៀបចំឡើងដោយផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ រវាងមេរៀនទាំងឡាយ និងដើម្បីបំពេញបាននូវចំណុចខ្វះខាតក្នុង ដំណាក់កាលនីមួយៗផង។

## ង. ការអនុវត្តចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស

នៅក្នុងជំនាក់កាលនៃការបង្រៀន បើសិនណាជារាប់បញ្ចូលបន្ថែមពីលើចំណេះដឹង សិស្សត្រូវយល់ជ្រួតជ្រាប និងក្តាប់បានថែមទៀតនូវចំណេះធ្វើ និងបំណិនប្រសប់ដែលបានកំណត់។ ចំណេះធ្វើ គឺបម្រើបម្រាស់ ចំណេះដឹង សំដៅធ្វើឱ្យបានសម្រេចក្នុងសកម្មភាពអនុវត្ត ឬក៏នៅក្នុងសកម្មភាពណាមួយផ្សេងទៀត។ នៅក្នុងលំនាំនៃការសិក្សារបស់សិស្ស សាស្ត្រាចារ្យ គប្បីបំពាក់បំប៉នដល់សិស្ស នូវចំណេះធ្វើជាច្រើនប្រភេទដូចជា ចំណេះធ្វើក្នុងការសង្ខេបមេរៀនដែលបានរៀនរួចមកហើយ ចំណេះធ្វើក្នុងដំណោះស្រាយលំហាត់ ចំណេះធ្វើក្នុងកិច្ចការត្រួតពិនិត្យ ចំណេះធ្វើក្នុងការពិសោធ ជីវវិទ្យា រូបវិទ្យា គីមីវិទ្យា និងចំណេះដឹងក្នុង ការវាស់វែង។ ក្រៅពីចំណេះធ្វើក្នុងសកម្មភាពបញ្ញាចេញ សាស្ត្រាចារ្យ ត្រូវបណ្តុះឱ្យដល់សិស្សនូវចំណេះធ្វើក្នុងការងារពលកម្មប្រកបដោយបច្ចេកទេខ្ពស់។ ចំណេះធ្វើនេះ ត្រូវបានបណ្តុះឱ្យសិស្ស នៅក្នុងលំនាំនៃការ ហ្វឹកហ្វឺន និងការសិក្សាបន្ថែមទៅលើ មូលដ្ឋាននៃការយល់ជ្រួតជ្រាបច្បាស់លាស់ទៅលើប្រភេទចំណេះដឹង នីមួយៗ។ នៅក្នុងលំនាំនៃការ ហ្វឹកហ្វឺននេះ សាស្ត្រាចារ្យត្រូវនៅក្បែរសិស្ស ពិនិត្យមើលសិស្ស និងដឹកនាំសិស្សនៅក្នុងការអនុវត្តលើគ្រប់សញ្ញាណ ដែលបានរៀនរួចមកហើយ។ ក្នុងពេលជាមួយគ្នានេះ សាស្ត្រាចារ្យត្រូវកែកំហុស និងចំណុចខ្វះខាត ដែលសិស្សអាចមាននៅក្នុងចលនានៃការគិត និងនៅក្នុងសកម្មភាពអនុវត្ត និងម្យ៉ាងទៀត ដើម្បី ចៀសវាងនូវទម្លាប់អាក្រក់ដែលកើតមានឡើងផង។ ទន្ទឹមនឹងនេះ សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ ដល់គំនិត ច្នៃប្រឌិត និងភាពម្ចាស់ការរបស់សិស្ស ក្នុងការអនុវត្តចំណេះដឹង ដែលបានរៀនរួចមកហើយ នៅក្នុងជីវភាពរស់នៅ។ ដោយពឹងផ្អែកលើមធ្យោបាយ នៃការហ្វឹកហ្វឺននេះ សាស្ត្រាចារ្យ ត្រូវជួយសិស្សឱ្យអនុវត្តបាននូវចំណេះធ្វើមួយចំនួន ដែលក្លាយទៅជាបំណិនប្រសប់ និងទម្លាប់ដូចជា បំណិនប្រសប់ក្នុងអំណាន ក្នុងសំណេរ ក្នុងការគិតមាត់ទទេ ទម្លាប់ ក្នុងការរៀបចំកម្មវិធី ផែនការ និងកាលវិភាគ។

ការអនុវត្តចំណេះដឹង ការបណ្តុះបណ្តាលចំណេះធ្វើ និងបំណិនប្រសប់ គឺជាដំណាក់កាលមួយដ៏សំខាន់បំផុតនៅក្នុងលំនាំនៃការបង្រៀន។ កាលណាសាស្ត្រាចារ្យ អាចធ្វើឱ្យសម្រេចបាននូវដំណាក់កាលនេះ សិស្សនឹងយល់ជ្រួតជ្រាប ហើយក្តាប់បានចំណេះដឹងយ៉ាងច្បាស់លាស់ ចេះគួបផ្សំទ្រឹស្តីទៅនឹងការប្រតិបត្តិជាក់ស្តែង។

ការអនុវត្តចំណេះដឹង ការបណ្តុះបណ្តាលចំណេះធ្វើ និងបំណិនប្រសប់ ជាដំណាក់កាលមួយដ៏សំខាន់បំផុតនៅក្នុងលំនាំនៃការបង្រៀន។

## ច. ការត្រួតពិនិត្យលើចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស

អត្ថន័យជាមូលដ្ឋាននៃដំណាក់នេះ គឺជានាបានលើគ្រប់ទំនាក់ទំនងខាងក្នុង និងខាងក្រៅផ្លូវចិត្ត របស់ សិស្សនៅក្នុងលំនាំនៃការបង្រៀន។កាលណាចំណងទាក់ទងបញ្ហាសកាន់តែគ្រប់គ្រាន់នោះ កំណែលំអក្នុងការងារដឹកនាំរបស់សាស្ត្រាចារ្យ កាន់តែមានភាពប្រសើរឡើង។

កិច្ចការត្រួតពិនិត្យ មិនគ្រាន់តែវាយតម្លៃចំណេះដឹង និងឱ្យពិន្ទុដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងធ្វើឱ្យចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស អភិវឌ្ឍបានទៀតផង។ សំណូមពររបស់ សាស្ត្រាចារ្យ វង្វាយតម្លៃទៅលើចម្លើយ និងវង្វាយតម្លៃទៅលើចំណេះដឹងសិស្ស គឺជាការបំពាក់បំប៉ន នូវស្មារតីទទួលខុសត្រូវ ឱ្យដល់សិស្សានុសិស្ស។ ដូចនេះ នៅក្នុងលំនាំនៃការបង្រៀនសាស្ត្រាចារ្យត្រូវ ចេះ គួបផ្សំដំណាក់កាលត្រួតពិនិត្យនេះទៅនឹងដំណាក់កាលផ្សេងទៀត។ សាស្ត្រាចារ្យ ត្រូវប្រើ ប្រាស់ឱ្យអស់សមត្ថភាព ដើម្បីឱ្យចំណេះដឹងរបស់សិស្សអភិវឌ្ឍឡើងបានដូចជា ការយកចិត្តទុក ដាក់ក្នុងការ ពង្រឹងចំណេះដឹង និងក្នុងការត្រួតពិនិត្យទៅលើលំនាំនៃការបង្រៀន និងលំនាំនៃការសិក្សា ជាដើម។

ដំណាក់កាលនីមួយៗមានឥទ្ធិពល និងទំនាក់ទំនងគ្នាទៅវិញទៅមក រួចបង្កើតបានជាលំនាំ នៃការបង្រៀននេះ ដើម្បីរួមចំណែកដល់ការអនុវត្តភារកិច្ច នៃការបង្រៀនឱ្យបានសម្រេចដោយ លទ្ធផលល្អ។

សរុបសេចក្តីមក សាស្ត្រាចារ្យគប្បីចេះផ្សារភ្ជាប់ និងធានាបាននូវចំណងទាក់ទងរវាង ដំណាក់កាលទាំងអស់ដូចជា ប៉ិនប្រសប់ក្នុងការអនុវត្ត ឈ្លាសវៃ និងធានាបាននូវលទ្ធផលល្អក្នុង ការបង្ហាត់បង្រៀនរាល់ម៉ោង រាល់មេរៀន និងរាល់ជំពូកតាមមុខវិជ្ជាសិក្សានីមួយៗ។

## ៤.១០.៥ កម្លាំងចលកររបស់លំនាំនៃការបង្រៀន

កម្លាំងចលកររបស់លំនាំនៃការបង្រៀន គឺជាកត្តាទាំងឡាយដែលជំរុញសិស្សឱ្យយល់ជ្រួតជ្រាបក្តាប់បានចំណេះដឹង មានការអភិវឌ្ឍបញ្ញា ព្រមទាំងជំរុញការងារបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យ និងការសិក្សារបស់សិស្សឱ្យអភិវឌ្ឍឡើង។

ដូចនេះនៅក្នុងលំនាំនៃការបង្រៀន តើមានធាតុអ្វីខ្លះ ដែលជាកម្លាំងចលករខាងខ្លួនរបស់សិស្ស និងចំណងទាក់ ទងគ្នារវាងកម្លាំងចលករទាំងពីរប្រភេទនេះ ស្តែងចេញយ៉ាងណាខ្លះ ?

មានសាស្ត្រាចារ្យខ្លះគិតថា ចង់ឱ្យសិស្សសកម្មក្នុងការសិក្សា ត្រូវចងក្រងមេរៀនសម្រាប់ បកស្រាយពន្យល់សិស្ស ឱ្យបានយល់ច្បាស់លាស់ ធ្វើកិច្ចការត្រួតពិនិត្យជាអចិន្ត្រៃយ៍ និងដាក់ពិន្ទុ។ ប្រការនេះគឺមានន័យថា អនុវត្តបានតែមួយផ្នែកនៅក្នុងការត្រួតពិនិត្យ និងឱ្យពិន្ទុ។ នេះមិនទាន់រាប់ថា ជាកម្លាំងចលករដ៏សំខាន់ទេ។ ការងារបង្ហាត់បង្រៀន និងអប់រំកំណត់នូវអាកប្បកិរិយារបស់សិស្ស ក្នុងការសិក្សាដូចជាចលនាប្រឡងប្រណាំងរៀនពូកែ វង្វាយតម្លៃ និងការលើកទឹកចិត្តសិស្សរបស់សាលារៀន របស់គ្រួសាររបស់សមូហភាព និងរបស់សង្គម។ ទាំងនេះ ជាប្រការដែលជំរុញសិស្ស ឱ្យខិតខំយកចិត្ត ទុកដាក់ក្នុងការសិក្សា។ តាមពិតនេះក៏មិនទាន់ចាត់ទុកថា ជាកម្លាំងចលករបានដែរ។ ពីព្រោះប្រការទាំង នេះ គ្រាន់តែជាកម្លាំងចលករនៅខាងក្រៅខ្លួនរបស់សិស្សប៉ុណ្ណោះ។ប្រភពពិតប្រាកដរបស់ការអភិវឌ្ឍន៍ ក្នុងបញ្ហានេះ គឺទំនាស់នៅខាងក្នុងខ្លួនរបស់សិស្ស។ ទំនាស់ទាំងនេះកើតមានឡើងនៅក្នុងលំនាំនៃការសិក្សាមេរៀនថ្មី។ នោះទើបហៅថា កម្លាំងចលករដ៏សំខាន់ដែលជំរុញសិស្សឱ្យសកម្មក្នុងការសិក្សា។

កម្លាំងចលករដ៏សំខាន់របស់លំនាំនៃការបង្រៀននេះគឺជាទំនាស់រវាងផ្នែកនីមួយៗ។នោះគឺជាភារកិច្ចរបស់ការបង្រៀន និងការប្រតិបត្តិរបស់សិស្ស ដែលលំនាំនៃការបង្រៀនបានលើកឡើង ហើយម្យ៉ាងទៀត គឺ

កម្រិតចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ និងកម្រិតអភិវឌ្ឍខាងផ្នែកបញ្ញាដែលសិស្សមានរួចមកហើយ។ទំនាស់ទាំងនេះលេចឡើង តាំងពីពេលដែលសិស្សចាប់ផ្តើមយល់ជ្រួតជ្រាបចំណេះដឹងថ្មីគឺគិត តាំងពីពេលដែលសិស្សប្រើឥន្ទ្រីយារម្មណ៍ រហូតដល់សិស្សឈានចូលក្នុងដំណាក់កាលវិនិច្ឆ័យ ត្រិះរិះពិចារណាពោលគឺតាំងពីពេលដែលសិស្សចាប់យកចំណេះដឹងខាងផ្នែកទ្រឹស្តីរហូតដល់ប្រតិបត្តិ។

*ឧទាហរណ៍៖* សាស្ត្រាចារ្យបង្រៀនសិស្សពីបាតុភូតមួយ។ សិស្សត្រូវទាញសេចក្តីសន្និដ្ឋានដោយខ្លួនឯង ពីសញ្ញាណ និងក្រិតក្រមរបស់បាតុភូតនោះ។ ក្រោយពេលដែលទាញបានជាក្រិតក្រមមកហើយ សិស្ស ត្រូវយកចំណេះដឹងនោះ ទៅអនុវត្តនៅក្នុងការប្រតិបត្តិ។ ពេលនេះឯង ដែលសិស្សជួបប្រទះការលំបាក និងត្រូវជម្នះការលំបាកនេះ។ ដូចនេះ ដំណោះស្រាយលើទំនាស់លំបាកទាំងនោះបានយ៉ាងត្រឹមត្រូវ និងយ៉ាងប៉ិនប្រសប់នោះបានន័យថា សិស្សយល់ជ្រួតជ្រាប និងក្តាប់បានចំណេះដឹងពិតប្រាកដ។ ការអភិវឌ្ឍនៃចំណេះដឹង និងការហ្វឹកហ្វឺនចំណេះដឹងនេះ នៅក្នុងការប្រតិបត្តិប្រព្រឹត្តទៅបាន ដោយ សុចន្ទៈ និងចរិតសកម្មរបស់ខ្លួន។ នោះហៅថា សិស្សជម្នះការលំបាកបានដោយខ្លួនឯង ហើយក្តាប់បាន ចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ក្នុងការប្រតិបត្តិ។ក៏ប៉ុន្តែ មិនថាករណីណាជាករណីណាឡើយ ទំនាស់ខាងលើនេះ អាចប្រែក្លាយទៅជាកម្លាំងចលករដ៏សំខាន់បាន ពីព្រោះ វាអាចឆ្លើយតបបានទៅនឹង លក្ខខ័ណ្ឌដូចតទៅ៖

ទំនាស់ និងភារកិច្ចនោះ ត្រូវឱ្យបានសមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស។ ជាការជាក់ស្តែង ត្រូវឱ្យសិស្ស យល់ច្បាស់លាស់ ហើយសិស្សអាចដោះស្រាយ បានតាមការខិតខំប្រឹងប្រែងរបស់ខ្លួន ជាកំណត់។ ម្យ៉ាងទៀតភារកិច្ចនេះ ត្រូវបានក្លាយទៅជាភារកិច្ចជាអត្តនោម័តរបស់សិស្ស។ ទំនាស់នោះ គឺជាទំនាស់ដែលសិស្សអាចដោះស្រាយបាន រវាងចំណេះដឹងដែលសិស្សមាន និងចំណេះដឹង ដែលសិស្សកំពុងយល់ជ្រួតជ្រាប។ ផ្ទុយ ទៅវិញ បើទំនាស់ដែលកើតឡើងចំពោះមុខសិស្ស ហួសកម្រិតយល់ដឹងរបស់សិស្សនោះ ទំនាស់នោះ មិនអាច ប្រែក្លាយទៅជាកម្លាំងចលករក្នុងការសិក្សា និងក្នុងការអភិវឌ្ឍខាងបញ្ញា ឬចំណេះដឹងរបស់សិស្សបានឡើយ។ ទំនាស់របៀបនេះ នាំឱ្យរាំងស្ទះដល់សកម្មភាពទទួលចំណេះដឹងរបស់សិស្ស។

1) ដោយសារការអភិវឌ្ឍរបស់លំនាំនៃការបង្រៀន និងការសិក្សារបស់សិស្ស ទំនាស់នោះគឺជាទំនាស់ដែលសមហេតុផល ហើយដែលត្រូវបានកំណត់ និងរៀបចំជាស្រេច។ ដូចនេះ នៅក្នុង លក្ខខ័ណ្ឌនោះ តើមានកត្តាអ្វីខ្លះ ដែលជាកម្លាំងចលករខាងក្រៅខ្លួនសិស្ស? កម្លាំងចលករនោះ មិនគ្រាន់តែធ្វើឱ្យសិស្សក្តាប់បាននូវទំនាស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យសិស្ស រកវិធីដោះ ស្រាយទំនាស់នោះទៀតផង។

ភារកិច្ចរបស់សាស្ត្រាចារ្យ មិនគ្រាន់តែឆ្លុះបញ្ចាំងបាននូវទំនាស់ខាងលើនោះទេ ចំពោះការដឹកនាំសិស្ស នៅក្នុងលំនាំនៃការបង្រៀន ក៏ប៉ុន្តែសាស្ត្រាចារ្យ ត្រូវពុះពារ និងស៊ីជម្រៅទៅលើទំនាស់នោះ ជម្នះបាននូវ រាល់ការលំបាក ញ៉ាំងសិស្សឱ្យមើលឃើញសកម្មភាព និងផលប្រយោជន៍ក្នុងដំណោះស្រាយទំនាស់នោះ ទៀតផង។ បន្ទាប់មកសាស្ត្រាចារ្យត្រូវឈ្លាសវៃ និងប៉ិនប្រសប់ អត់ធ្មត់ ក្នុងការណែនាំសិស្សដោះស្រាយទំនាស់ទាំងនោះដោយខ្លួនឯង។ រួចមកទៀតសាស្ត្រាចារ្យ ត្រូវធ្វើឱ្យលេចឡើងនូវទំនាស់ថ្មី បើកទូលាយ ឱ្យដល់សិស្សក្នុងការរាវរកវិធីដោះស្រាយថ្មីតាមការសិក្សាស្រាវជ្រាវ ក្នុងមុខវិជ្ជាសិក្សានីមួយៗ។ ជាបណ្តើរៗ សិស្សមានការសប្បាយរីករាយក្នុង ការយល់ជ្រួតជ្រាបចំណេះដឹង មានស្មារតីយកចិត្តទុកដាក់ និងមានចំណង់ចំណូលចិត្តក្នុងការសិក្សាទៀតផង។

ក្រៅពីនេះ នៅក្នុងលំនាំនៃការបង្រៀន នៅមានទំនាស់មួយចំនួនទៀតខាងក្នុងខ្លួនរបស់សិស្ស

ដែលសាស្ត្រាចារ្យ ត្រូវដោះស្រាយដោយវិធីផ្សេងៗដ៏ប៉ិនប្រសប់ និងឈ្លាសវៃបំផុត ដើម្បីរួមចំណែក ដល់ការជំរុញឱ្យលំនាំនៃការបង្រៀនរបស់គាត់ កាន់តែមានប្រសិទ្ធភាពឡើងដូចជា ទំនាស់រវាងកម្រិត យល់ដឹង ល្បឿននៃការគិត សញ្ចេតនារវាងសាស្ត្រាចារ្យ និងសិល្បៈ ទំនាស់រវាងតួនាទីដឹកនាំ របស់ សាស្ត្រាចារ្យ និងចរិតសកម្មម្ចាស់ការច្នៃប្រឌិតរបស់សិស្ស ។ល។

សរុបសេចក្ដីមក លំនាំនៃការបង្រៀន គឺជាលំនាំដែលផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ រវាង ដំណាក់កាល ទាំងឡាយ ដើម្បីដោះស្រាយនូវទំនាស់ខាងក្នុង និងខាងក្រៅខ្លួនសិស្ស ហើយជានិច្ចកាល បង្កើតបានជាមាគ៌ាអភិវឌ្ឍនៃចំណេះដឹងរបស់សិស្ស។ ភារកិច្ចរបស់សាស្ត្រាចារ្យ នៅក្នុងលំនាំនៃការ បង្រៀនគឺ៖

- គប្បីយកចិត្តទុកដាក់ដល់កម្លាំងចលករខាងក្នុង និងខាងក្រៅខ្លួនរបស់សិស្ស
- ត្រូវចេះតាក់តែងរៀបចំទំនាស់ក្នុងមេរៀនថ្មី ឱ្យបានសមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស
- គប្បីបញ្ចេញឱ្យអស់នូវសមត្ថភាព និងកម្លាំងកាយចិត្តរបស់ខ្លួន ក្នុងការលើកកម្ពស់តួនាទី សកម្ម ម្ចាស់ការច្នៃប្រឌិតរបស់សិស្ស។ធ្វើឱ្យសិស្សមានអាកប្បកិរិយា និងមូលហេតុត្រឹមត្រូវក្នុងការសិក្សា។

## សន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ ពីសញ្ញាណសារជាតិភាពសមហេតុផល និងកម្លាំងចលកររបស់លំនាំនៃការបង្រៀនមក យើងជាសាស្ត្រាចារ្យអាចយល់ច្បាស់ថា៖

**ក.លំនាំនៃការបង្រៀន** មិនគ្រាន់តែជាលំនាំមួយដែលផ្សព្វផ្សាយចំណេះដឹង និងទទួលយល់ជ្រួតជ្រាបចំណេះដឹងប៉ុណ្ណោះទេ ហើយក៏មិនមែនជាលំនាំមួយដែលបង្រៀនសិស្សតែពីទ្រឹស្ដីដែរ ប៉ុន្តែ គឺជាលំនាំមួយដែលបណ្ដុះបណ្ដាលបាននូវបុគ្គលិកលក្ខណៈសិស្ស ដោយឈរលើមូលដ្ឋាននៃចំណាត់តាំងលំនាំនៃការសិក្សា និងការអនុវត្តរបស់សិស្សផង។

**ខ.លំនាំនៃការបង្រៀន** គឺជាលំនាំមួយដែលមានចរិតលក្ខណៈពីរយ៉ាងគឺការបង្រៀនរបស់សាស្ត្រាចារ្យ និងការ រៀនរបស់សិស្ស។ បានន័យថា សាស្ត្រាចារ្យ បំពេញតួនាទីជាអ្នកដឹកនាំ ឯសិស្សបំពេញតួនាទីសកម្មម្ចាស់ការ ច្នៃប្រឌិត ក្នុងការយល់ជ្រួតជ្រាបចំណេះដឹង។ សកម្មភាពទាំងពីរនេះភ្ជាប់គ្នា ហើយមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។ ឆ្លងកាត់តាមរយៈនៃការបង្រៀននេះ សាស្ត្រាចារ្យមិនគ្រាន់តែផ្លាស់ប្ដូរ និងញ៉ាំងការអភិវឌ្ឍនៃចំណេះដឹងរបស់សិស្ស ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកែលម្អ និងមើលឃើញលទ្ធផល នៃការបង្រៀនរបស់ខ្លួនទៀតផង

**គ. សារជាតិរបស់លំនាំនៃការបង្រៀន** គឺជាលំនាំនៃប្រភពចំណេះដឹងរបស់សិស្ស ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ សំដៅក្ដាប់បាននូវរាល់ភារកិច្ចនៃការបង្រៀនដូចជា ការផ្ដល់ចំណេះដឹង កា អភិវឌ្ឍនៃបញ្ញា និងបុគ្គលិកលក្ខណៈ ការអប់រំ ការអនុវត្តចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ជាដើម។

**ឃ. លំនាំនៃការបង្រៀន** គឺជាលំនាំមួយដែលអាដឹកនាំ និងគ្រប់គ្រងបានពីព្រោះការបង្រៀន គឺជារូបភាពរបស់ការដឹកនាំ ជាពិសេសលំនាំនេះ មានក្រិត្យក្រមជាកំណត់។ សព្វថ្ងៃនេះ បើចង់ដឹកនាំ លំនាំនៃការបង្រៀនឱ្យបានល្អ សាស្ត្រាចារ្យ គប្បីយកចិត្តទុកដាក់នឹងសេចក្ដីណែនាំមួយចំនួនដូចតទៅ៖

- ត្រូវតំរង់ទិសរបស់លំនាំនៃការបង្រៀន ឆ្ពោះទៅរកការកសាងបុគ្គលិកលក្ខណៈរបស់សិស្ស ឱ្យមានការអភិវឌ្ឍពេញសមត្ថភាព។

1. គប្បីដឹកនាំការបង្រៀន និងការអប់រំ តាមរូបភាពរបស់សៀគ្វីបិទ។ ចង់សម្រេច តាមប្រការនេះ សាស្ត្រាចារ្យ គប្បីជានាឱ្យបាននូវចំណងទាក់ទងគ្នាទៅវិញទៅមក រវាងដំណាក់កាលទាំង ឡាយជាមូលដ្ឋាននៅក្នុងលំនាំនៃការបង្រៀនជាពិសេសជានាបាននូវចំណងទាក់ទង បញ្ច្រាស ខាងក្រៅខ្លួន រវាងសាស្ត្រាចារ្យ និងសិស្សជាមួយគ្រប់ចំណងទាក់ទង ខាងក្នុងខ្លួន របស់សិស្ស។
2. សាស្ត្រាចារ្យ ត្រូវធ្វើឱ្យលំនាំនៃការបង្រៀន មានចរិតសកម្ម ពីពេលមួយទៅពេលមួយ រួចញ៉ាំង វិធីសិក្សារបស់សិស្ស ឱ្យក្លាយទៅជាវិធីសិក្សាស្រាវជ្រាវរបស់សិស្ស។
3. សាស្ត្រាចារ្យ ត្រូវធ្វើឱ្យលំនាំនៃការបង្រៀនមានសកម្មភាពសមស្រប តាមកម្មវិធីសិក្សា និងសមស្របជាមួយនឹងលំនាំចំណេះដឹងដើមរបស់សិស្ស។ គប្បី ចេះគួបផ្សំគ្នាយ៉ាងប៉ិនប្រសប់នូវដំណាក់កាល ទាំងអស់របស់លំនាំនៃការបង្រៀន។
4. ត្រូវធ្វើឱ្យលំនាំនៃការបង្រៀន ប្រព្រឹត្តទៅបានយ៉ាងត្រឹមត្រូវ ទៀងទាត់តាមគោលការណ៍គរុកោសល្យ។ ការសិក្សា ទ្រឹស្តី ផ្សារភ្ជាប់ទៅនឹងការប្រតិបត្តិ។ ការអប់រំផ្សារភ្ជាប់ទៅនឹងពលកម្មផលិត សាលារៀនផ្សារភ្ជាប់ទៅនឹងសង្គម។

5. ត្រូវយកចិត្តទុកដាក់ទាញយកអត្ថប្រយោជន៍ ពីកម្លាំងចលករទាំងពីរប្រភេទគឺ កម្លាំងចលករខាងក្នុង និងខាងក្រៅខ្លួនសិស្ស។ នៅក្នុងលំនាំនៃការបង្រៀន សាស្ត្រាចារ្យ គប្បីយកចិត្តទុកដាក់ ដល់ កម្លាំងចលករសំខាន់ៗ ឬទំនាស់រវាងភារកិច្ចនៃការសិក្សារបស់សិស្ស ដែលលំនាំនៃការបង្រៀន បាន កំណត់ និងដាក់ចុះជាមួយនឹងកម្រិតអភិវឌ្ឍនៃចំណេះដឹងរបស់សិស្ស។សាស្ត្រាចារ្យយក ចិត្តទុកដាក់កសាងនូវអាកប្បកិរិយា និងមូលហេតុត្រឹមត្រូវ ក្នុងការសិក្សា ឱ្យដល់សិស្ស។ត្រូវយកចិត្តទុកដាក់កសាង ឬប្រើប្រាស់ ឱ្យអស់សមត្ថភាពលើគ្រប់មធ្យោបាយក្នុងការបង្រៀន គឺតាំងពីវិធីបុរាណរហូតដល់វិធីទំនើបៗ។

## <u>**សំណួរ**</u>

*១. ធ្វើអត្ថាធិប្បាយស្តីពីសញ្ញាណលើខ្លឹមសារនៃការបង្រៀន។*

*២. ធ្វើអត្ថាធិប្បាយស្តីពីសញ្ញាណ ផែនការបង្រៀន កម្មវិធីសិក្សា និងសៀវភៅសិក្សា។*

*៣. ដើម្បីឱ្យខ្លឹមសារនៃការបង្រៀនតាមមុខវិជ្ជាឯកទេសនីមួយៗ ឯកភាពគ្នាទូទាំងប្រទេស គេត្រូវរៀបចំវិធានការប្រចាំត្រីមាស ប្រចាំឆ្នាំ យ៉ាងណាខ្លះ?*

# មេរៀនទី ៥ គោលការណ៍នៃការបង្រៀន

## ៥.១. វត្ថុបំណងមេរៀន

- យល់ច្បាស់លាស់លើគោលការណ៍នៃការបង្រៀន គឺយល់ច្បាស់លាស់ពីទស្សនៈដែលបញ្ញាឬឥទ្ធិពល ទៅលើការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យ និងការសិក្សារបស់សិស្ស។
- ក្តាប់បានច្បាស់លាស់ នូវលំនាំនៃការអភិវឌ្ឍមូលដ្ឋានផ្តួចផ្តើម សេចក្តីណែនាំក្នុងការអនុវត្តគោលការណ៍ នៃ ការបង្រៀន និងចំណងទាក់ទងគ្នារវាងគោលការណ៍ទាំងអស់។
- ចេះអនុវត្ត និងប្រើប្រាស់បានលើគ្រប់គោលការណ៍នៃការបង្រៀនទាំងអស់ ដើម្បកំណត់បានក្នុង រយៈពេលមួយម៉ោងបង្រៀនក៏ដូចជាកំណត់បាននិងកែលម្អបានទៅលើការបង្ហាត់បង្រៀននិងស្មារតីសិក្សា របស់សិស្ស។

ដូចដែលយើងបានសិក្សាវិភាគរួចមកហើយនៅក្នុងមេរៀនមុនៗលំនាំនៃការបង្រៀនគឺ ជាលំនាំនៃចំណេះដឹងដើមរបស់សិស្សក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ សំដៅយល់ជ្រួតជ្រាបនឹងក្តាប់បាន នូវភារកិច្ចនៃការបង្រៀនដែលជាលំនាំមួយមានចលនា និងក្រឹត្យក្រមច្បាស់លាស់។ ដូចនេះចង់ដឹកនាំលំនាំនេះ ឱ្យបានល្អចង់ធ្វើសកម្មទៅលើដំណាក់កាលនីមួយៗរបស់វាឱ្យមានប្រសិទ្ធភាពបំផុតនោះ សាស្ត្រាចារ្យនិងសិស្សគប្បីគោរពតាមគោលការណ៍នៃ ការបង្រៀនមួយចំនួនជាកំណត់។ ក្នុងមេរៀននេះ យើងនឹងសិក្សាស្រាវជ្រាវជាបន្តបន្ទាប់គ្នាពី៖

- សញ្ញាណទូទៅស្តីពីគោលការណ៍នៃការបង្រៀន
- លក្ខណៈប្រវត្តិសាស្ត្ររបស់គោលការណ៍នៃការបង្រៀន
- ប្រព័ន្ធគោលការណ៍បង្រៀននៅក្នុងសាលារៀនមធ្យមសិក្សា

## ៥.២. សញ្ញាណទូទៅស្តីពីគោលការណ៍នៃការបង្រៀន

**ក.គោលការណ៍នៃការបង្រៀន** គឺ ជាទស្សនៈដែលផ្តួចផ្តើមការដឹកនាំសកម្មភាពបង្រៀនរបស់ សាស្ត្រាចារ្យនៅក្នុងលំនាំនៃការបង្រៀន។គោលការណ៍បង្រៀននៅសាលារៀនមធ្យមសិក្សាចំណេះទូទៅគឺ ទស្សនៈជាមូលដ្ឋាន ដែលត្រូវពឹងផ្អែកលើមូលដ្ឋាននៃវិទ្យាសាស្ត្រ។ គោលការណ៍នៃការបង្រៀន ទាំងអស់ទាមទារ ឱ្យជ្រើសរើសខ្លឹមសារ វិធីសាស្ត្រ រូបភាពចាត់តាំងនៃការបង្រៀន និងបម្រើបម្រាស់ ដំណាក់កាលទាំងអស់ របស់លំនាំនៃការបង្រៀននៅគ្រប់មុខវិជ្ជាសិក្សាទាំងអស់។

**ខ.គោលការណ៍នៃការបង្រៀន** គឺជាទស្សនៈដែលដឹកនាំការបង្រៀនរបស់សាស្ត្រាចារ្យ ក៏ដូចជាការសិក្សារបស់សិស្សហើយជាពិសេសគឺដឹកនាំលំនាំនៃការបង្រៀនទាំងមូល។

## ៥.៣. លក្ខណៈប្រវត្តិសាស្ត្ររបស់គោលការណ៍នៃការបង្រៀន

ទោះជាក្នុងកាលៈទេសៈ ឬវិធានការណ៍ណាក៏ដោយ ប្រព័ន្ធគោលការណ៍នៃការបង្រៀនសព្វថ្ងៃ សំដៅ ធ្វើឱ្យគោលការណ៍នៃការបង្រៀនអភិវឌ្ឍឡើង នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។

ក្នុងបុរាណសម័យដ៏យូរលង់ កុង ភុយស៊ុស (Confucius 551-479 BC) បានយកចិត្តទុក ដាក់ដល់ការពង្រឹងពង្រីកចរិតភ្ញាក់រលឹក និងចរិតសកម្មរបស់សិស្ស ក្នុងការសិក្សា។ កុង ភុយស៊ុស មាន ទស្សនៈថា៖ «បើចង់ចេះ តែមិនមានឆន្ទះ នោះគឺមិនរីកបញ្ញាទេ បើចង់យល់ច្បាស់ ហើយមិនប្តេជ្ញាចិត្ត នោះក៏មិនដុះគំនិតដែរ»។ លោក បានទូន្មានសិស្ស ឱ្យយកចិត្តទុកដាក់ហ្វឹកហ្វឺនក្នុងការសិក្សា ដើម្បី ពង្រឹង

ពង្រីកចំណេះដឹង។ លោក យល់ឃើញថា «ក្នុងពេលបង្រៀន មិនត្រឹមតែធ្វើឱ្យសិស្សសប្បាយទេ តែត្រូវធ្វើ ឱ្យសិស្សចូលចិត្តទៀត»។

លោក កូមិនស្គី ( Jan Amos Kominsky 1592-1670 ) ជាគរុកោសល្យជនជាតិ ឆេកូ។ គាត់ ជាជនដំបូងបង្អស់ ដែលបានលើកឡើងពីទ្រឹស្តីបង្រៀនជាមូលដ្ឋាន ដែលក្នុងនោះ មានរូបភាពបង្រៀននៅ ក្នុងថ្នាក់។ លោកបានលើកឡើង ពីគោលការណ៍នៃការបង្រៀនតាមខ្លឹមសារដូចតទៅនេះ៖

- ធានាបាននូវចរិតអព្ភន្តរញាណ
- ធានាបាននូវភាពពង្រឹងពង្រីកចរិតភ្ញាក់រលឹក និងចរិតសកម្មរបស់សិស្ស
- ធានាបាននូវប្រព័ន្ធកម្មនៃចំណេះដឹង
- ធានាបាននូវសុខភាពមាំមួនល្អគ្រប់ពេលវេលា
- ធានាបាននូវការយល់ជ្រួតជ្រាប ឬក្តាប់ចំណេះដឹងបាន
- យកចិត្តទុកដាក់ដល់ភាពដោយឡែកនៃវ័យសិក្សារបស់សិស្ស

លោក កូមិនស្គី នេះក៏ជាគរុកោសល្យវិទូដំបូងបង្អស់ ក្នុងប្រវត្តិសាស្ត្រនៃការអប់រំ ដែលបានលើកឡើងពីការផ្សារភ្ជាប់សាលារៀនទៅនឹងជីវភាពរស់នៅក្នុងសង្គម។

លោក សង់ សាក់រូសូ (1712-1778) ជាគរុកោសល្យវិទូជាតិបារាំង។ លោកបានយកចិត្តទុកដាក់ដល់បញ្ហាអភិវឌ្ឍខាងផ្នែកបញ្ញា និងចរិតសកម្មម្ចាស់ការរបស់សិស្សក្នុងការសិក្សា។

លោក ប៉េស្តាឡូស៊ី(1746-1827)ជាគរុកោសល្យវិទូជាតិ ស៊ូល។លោក បានយកចិត្តទុកដាក់ដល់ចរិតអប់រំនៅក្នុងការបង្រៀន។ នៅក្នុងលំនាំនៃការបង្រៀន សាស្ត្រាចារ្យ ត្រូវស្រលាញ់ និងចូលចិត្ត សិស្ស។ សាស្ត្រាចារ្យ ត្រូវបណ្តុះបណ្តាលឱ្យដល់សិស្សនូវគរុកោសល្យសម្បត្តិសីលធម៌។

លោក ឌិស ស្តឺវ៉ិច (1790-1866) ជាគរុកោសល្យវិទូជាតិ អាឡឺម៉ង់។ លោក បានយកចិត្តទុកដាក់ដល់ការធ្វើឱ្យអភិវឌ្ឍខាងសតិអារម្មណ៍ ដែលពីមុនលោក ប៉េស្តាឡូស៊ី បានសង្កត់ធ្ងន់ថា៖ «... នោះគឺ ការបង្រៀន ដែលត្រូវធ្វើឱ្យបុគ្គលិកលក្ខណៈរបស់មនុស្សអភិវឌ្ឍឡើងបាន។ សាស្ត្រាចារ្យ គប្បីជំរុញសតិបញ្ញារបស់សិស្ស ឱ្យអភិវឌ្ឍឡើងសមស្របទៅនឹងភារកិច្ចទូទៅនៅក្នុងការបង្រៀន»។ លោក ឌីស ស្តឺវ៉ិច បានសង្កត់ធ្ងន់ទៅលើ គោលការណ៍ពង្រឹងពង្រីកចរិតសកម្ម និងចរិតច្នៃប្រឌិតរបស់សិស្ស។

លោក អ៊ូ ជិនស្គី (1824-1870) គរុកោសល្យវិទូជាតិ រ៉ុស្ស៊ី ដែលបានបញ្ចូលលក្ខណៈវិទ្យា សាស្ត្រទៅក្នុងលំនាំនៃការបង្រៀន ឱ្យសមស្របតាមវិទ្យាសាស្ត្របដិសំយោគ នៅក្នុងគោលការណ៍នៃ ការបង្រៀន។ លោកបានលើកឡើង ពីគោលការណ៍នៃការបង្រៀន ដោយពឹងផ្អែកលើមូលដ្ឋាននៃចិត្តវិទ្យា តក្កវិទ្យា និងជីវវិទ្យា។ លោក ក៏បានសង្កត់ធ្ងន់ផងដែរ ចំពោះគោលការណ៍ដែលធានាបាននូវចរិត អព្ភន្តរញាណ ចរិតសុខភាព ចរិតសកម្មម្ចាស់ការ ចរិតយល់ជ្រួតជ្រាបច្បាស់លាស់ និងចរិតប្រព័ន្ធកម្ម។ ជាពិសេសលោកបានយកចិត្តទុកដាក់ ដល់ចរិតស្វ័យសកម្មម្ចាស់ការរបស់សិស្ស ហើយលោក បានវាយ តម្លៃខ្ពស់ ទៅលើអត្ថន័យនៃពលកម្ម ដោយចាត់ទុកពលកម្មថា ជាកត្តាដែលធ្វើឱ្យបុគ្គលិកលក្ខណៈ របស់មនុស្សអភិវឌ្ឍឡើង។

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ ពីលំនាំជាប្រវត្តិសាស្ត្រនេះ យើងឃើញថាគោលការណ៍នៃការបង្រៀន ត្រូវបានកសាងឡើងពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែសម្បូរបែប ហើយមានមូលដ្ឋានវិទ្យាសាស្ត្រ កាន់តែច្បាស់ លាស់ឡើង។ គោលការណ៍នៃការបង្រៀនមួយចំនួន កំពុងបន្តនូវអត្ថិភាព និងការអភិវឌ្ឍរបស់ខ្លួន។

ម្យ៉ាងទៀតគោលការណ៍នៃការបង្រៀនខ្លះ ត្រូវបានផ្លាស់ប្តូរអត្ថន័យចាស់ ហើយបង្កើតបានជាអត្ថន័យថ្មី ដូចជា គោលការណ៍សមស្របទៅនឹងចរិតធម្មជាតិរបស់លោក កូម៉ិនស្គី ជាដើម។ ឯគោលការណ៍ខ្លះទៀត ទើបតែ បង្កើតថ្មី។

សព្វថ្ងៃនេះប្រព័ន្ធគោលការណ៍នៃការបង្រៀនទាំងអស់ក៏ដូចជាខ្លឹមសាររបស់គោលការណ៍នីមួយៗ ដែលបានលើកឡើងខាងលើនេះ សុទ្ធតែបានអភិវឌ្ឍឡើងយ៉ាងខ្លាំងក្លារួមជាមួយនឹងការអភិវឌ្ឍ របស់វិទ្យាសាស្ត្រ និងបច្ចេកទេស។ ដូចនេះ យើងគ្រាន់តែអនុវត្តតាមលក្ខខ័ណ្ឌងាយស្រួល ដែលអាចគួប ផ្សំបានទៅនឹងខ្លឹមសាររបស់គោលការណ៍នៃការបង្រៀនទាំងអស់ ដែលមានរួចមកហើយ ដោយគ្រាន់តែបន្ថែម នូវគោលការណ៍ថ្មីមួយចំនួនប៉ុណ្ណោះ។ តទៅនេះ យើងលើកឡើង ពីប្រព័ន្ធគោលការណ៍នៃការបង្រៀន ដែលបាន នឹងកំពុងអនុវត្ត ជាសាកលនៅក្នុងសាលារៀនមធ្យមសិក្សាចំណេះទូទៅ។

1. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតអប់រំ
2. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតវិទ្យាសាស្ត្រ
3. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតប្រតិបត្តិ
4. គោលការណ៍នៃការបង្រៀន ត្រូវពង្រឹងពង្រីក ចរិតភ្ញាក់រលឹក ចរិតសកម្មម្ចាស់ការច្នៃប្រឌិតរបស់សិស្សក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ។
5. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតអព្តន្តរញាណ
6. គោលការណ៍នៃការបង្រៀនត្រូវធានាបាននូវការពង្រឹងចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់
7. គោលការណ៍នៃការបង្រៀន ត្រូវយកចិត្តទុកដាក់ដល់ភាពដោយឡែកនៃកម្មវត្ថុបង្រៀន

ប្រព័ន្ធគោលការណ៍នៃការបង្រៀនខាងលើនេះ បានឆ្លុះបញ្ចាំង ឱ្យឃើញច្បាស់នូវសមិទ្ធិផលថ្មីរបស់ទ្រឹស្តីបង្រៀន ក៏ដូចជាបទពិសោធន៍មួយចំនួន នៅក្នុងសាលារៀនមធ្យមសិក្សាចំណេះទូទៅ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធគោលការណ៍នៃការបង្រៀនទាំងនេះ នឹងត្រូវផ្លាស់ប្តូរទៅតាមសម័យកាលអភិវឌ្ឍរបស់វិទ្យាសាស្ត្រ និងបច្ចេកទេស។ ដូចនេះ នៅក្នុងលំនាំនៃការបង្រៀន យើងគប្បីយក ចិត្តទុកដាក់សិក្សាស្រាវជ្រាវ និងចេះប្រើប្រាស់វិធីគួបផ្សំ។

## ៥.៤. ប្រព័ន្ធគោលការណ៍នៃការបង្រៀនសម្រាប់សាលារៀនមធ្យមសិក្សាចំណេះទូទៅកម្ពុជា

### ៥.៤.១. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតអប់រំ

ក/ធានាបាន ចរិតអប់រំក្នុ ងការបង្រៀន គឺបានន័យថាផ្តល់ ចំណេះ ដឹង ចំណេះ ធ្វើ និងបំណិនប្រ សប់ឱ្យដល់

សិស្សានុ សិស្សនៅក្នុ ងលំនាំនៃការបង្រៀន។ សាស្ត្រាចារ្យ គប្បី អនុវត្តគ្រប់ភារ កិច្ចអ ប់ រំ ដើ ម្បី កសាង អត្តចរិតរបស់

មនុស្ស ដែលជាម្ចាស់ សមូហភាព មាន ការ អភិវឌ្ឍ ពេញសមត្ថភាព ដល់សិស្សានុ សិស្ស ឱ្យបាន សមស្របទៅនឹងលក្ខណៈពិសេសរបស់សភាព ការណ៍ជាក់ ស្តែង នៅកម្ពុ ជា។ ម្យ៉ាង ទៀត សាស្ត្រាចារ្យ គប្បី បង្រៀនសិស្ស ពី ទ្រឹ ស្តី ផង និងការប្រតិបត្តិផង។

គោល ការណ៍នេះ ទាម ទារ ឱ្យសាស្ត្រាចារ្យ អនុវត្តនៅក្នុ ងលំនាំ នៃការបង្រៀនដូចតទៅះ

- បណ្តុះលោកទស្សនៈវិទ្យាសាស្ត្រ បំពាក់បំប៉នសតិអារម្មណ៍ល្អ និងសីលធម៌ល្អឱ្យដល់សិស្ស
- ធ្វើឱ្យសតិបញ្ញាសញ្ចេតនាក្នុងទំនួលចំណេះដឹង និងសញ្ចេតនាសិល្បវិទ្យារបស់សិស្សអភិវឌ្ឍឡើង
- អប់រំគុណសម្បត្តិសីលធម៌ល្អមួយចំនួនឱ្យដល់សិស្សដូចជាសេចក្តីព្យាយាម អត់ធ្មត់ ទៀងទាត់ ទម្លាប់ មាន វិន័យល្អ ធ្វើការងារត្រឹមត្រូវតាមផែនការ ស្មារតីសមូហភាព។ល។
- យកចិត្តទុកដាក់ដល់ការអប់រំសុខភាព និងបណ្តុះបណ្តាលលក្ខខ័ណ្ឌងាយស្រួល ឱ្យដល់សិស្ស ដូច ជាបច្ចេកទេសក្នុងការងារ ទម្លាប់រស់នៅតាមក្បួនអនាម័យ និងអនាម័យសាធារណៈ។

សាស្ត្រាចារ្យគប្បីយកចិត្តទុកដាក់អនុវត្តឱ្យបានគ្រប់គ្រាន់ នូវខ្លឹមសារទាំងបួនរបស់គោលការណ៍ នៃការបង្រៀនខាងលើនេះ។

**ខ**/នេះជាគោលការណ៍ដ៏សំខាន់បំផុត ដែលដឹកនាំលំនាំនៃការបង្រៀនទាំងមូល របស់សាលារៀនមធ្យមសិក្សាចំណេះទូទៅ។ បង្រៀន និងអប់រំ គឺបានន័យថា យកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលសតិអារម្មណ៍។ ការបណ្តុះបណ្តាលសតិអារម្មណ៍នេះទាមទារឱ្យសាស្ត្រាចារ្យ ស្គាល់សិស្សឱ្យបានច្បាស់ លាស់ ដើម្បីលើកម្ពស់ សមត្ថភាពយល់ដឹង ដុសខាត់បញ្ញា និងមើលឃើញចំណុចខ្សោយរបស់ខ្លួន។នេះជាគោលការណ៍ ផ្តួចផ្តើមចេញ ពីទស្សនៈជាមូលដ្ឋានស្តីពីការអប់រំ និងគោលការណ៍អប់រំរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការអប់រំគឺជាផ្នែក មួយដ៏សំខាន់ របស់ការបណ្តុះបណ្តាលធនធានមនុស្ស និងវប្បធម៌។ ការសិក្សា គឺជាសកម្មភាពដ៏សំខាន់ របស់សាលារៀន។

**គ**/គោលការណ៍នេះក៏ផ្តួចផ្តើមចេញផងដែរពីទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរវាងការផ្តល់ចំណេះដឹង និងការអប់រំ។ ការផ្តល់ចំណេះដឹង ត្រូវសម្រេចឱ្យបានដល់គោលដៅនៃការអប់រំ។ ឯការអប់រំ ត្រូវពឹងផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រគរុកោសល្យ ដើម្បីឱ្យសិស្សយល់ជ្រួតជ្រាប និងក្តាប់បានចំណេះដឹង។

តាំងពីសតវត្សទី១៧ មកម្លេះ លោក កូម៉ីនស្គី បានលើកឡើង នូវភារកិច្ចរបស់ការបង្រៀន។ ការ បង្រៀន មិនគ្រាន់តែផ្គត់ផ្គង់ចំណេះដឹងឱ្យដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងត្រូវហ្វឹកហ្វឺន សិស្សនូវ គុណសម្បត្តិ សីលធម៌មួយចំនួនទៀតដូចជា ចរិតយុត្តិធម៌ ជំនឿវិទ្យាសាស្ត្រ ទឹកចិត្តក្លាហាន និង ចរិតអត់ធ្មត់នៅក្នុងការសិក្សា។ ការបង្រៀន ត្រូវធ្វើឱ្យសិស្សយល់ដឹង ឬស្គាល់បានច្បាស់ពីសកម្មភាពដ៏ មានអត្ថប្រយោជន៍ និងមានទម្លាប់ចេះគោរពការសិក្សា និងការងារពលកម្មទៀតផង។

គរុកោសល្យវិទូ ដ៏ជឿនលឿនទាំងឡាយក្នុងសាកលលោក និងនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិសុទ្ធតែបានសំអាងច្បាស់លាស់ ពីហេតុផលនៃការអប់រំ តាមស្មារតីរបស់សាស្ត្រាចារ្យ ហើយបានបញ្ចេញមតិជាច្រើន ស្តីពីលទ្ធផលនៃការអប់រំនេះ។ការបង្រៀន គឺជាការអប់រំ។ មុខវិជ្ជាសិក្សានីមួយៗ ដែលសិស្សត្រូវរៀនគឺ ជាលទ្ធផលរបស់លំនាំ នៃការសិក្សាមួយដ៏យូរអង្វែង ហើយដ៏លំបាកស្មុគ្រស្មាញចំពោះ អ្នកសិក្សាស្រាវជ្រាវពីបញ្ហានេះ។ ទោះបីជាស្នាដៃសិក្សាស្រាវជ្រាវណាក៏ដោយ ក៏ត្រូវគោរពតាមប្រព័ន្ធវិធីសាស្ត្រ វិទ្យាសាស្ត្រសង្គម និងប្រព័ន្ធវិទ្យាសាស្ត្រធម្មជាតិដែរ។

**ឃ**/គោលការណ៍ធានាបាននូវចរិតអប់រំនេះ ត្រូវបានគ្រូបង្រៀនម្នាក់ៗយល់ច្បាស់ និងស៊ីជម្រៅ នៅក្នុងខ្លឹមសារក៏ដូចជានៅក្នុងវិធីសាស្ត្រ និងរូបភាពចាត់តាំងការបង្រៀន។

សាស្ត្រាចារ្យតាមមុខវិជ្ជាឯកទេសនីមួយៗ គប្បីចម្រាញ់ខ្លឹមសារមេរៀនទាំងអស់ ដើម្បីបញ្ចូលនូវ ទស្សនៈអប់រំ និងជំនឿក្នុងការសិក្សាឱ្យដល់សិស្សានុសិស្ស។ឆ្លងកាត់តាមរយៈគ្រប់មុខវិជ្ជាឯកទេស សាស្ត្រាចា

រ្យ ម្នាក់ៗ គប្បីធ្វើឱ្យសិស្សយល់ជ្រួតជ្រាប និងក្ដាប់បានចំណេះដឹងដូចជា៖

- ក្រឹត្យក្រមអភិវឌ្ឍរបស់ប្រវត្តិសាស្រ្ត
- មើលឃើញច្បាស់ពីតួនាទី របស់ការអប់រំ និងវប្បធម៌
- មានជំនឿ ទៅលើជ័យជម្នះទាំងស្រុងរបស់រដ្ឋាភិបាល

**ឆ្លងកាត់តាមរយៈការផ្សារភ្ជាប់គ្នារវាងខ្លឹមសារនៃការបង្រៀនទៅនឹង៖**

- ជីវភាពរស់នៅ
- ការអនុវត្តក្នុងការកសាងសង្គមកម្ពុជាឱ្យអភិវឌ្ឍឡើង
- ការតស៊ូដើម្បីការពារមាតុភូមិកម្ពុជាឱ្យមានសន្តិភាព និងបូរណភាពទឹកដី
- ការប្រតិបត្តិផ្នែកសតិអារម្មណ៍ និងសញ្ចេតនារបស់សិស្ស សាស្ត្រាចារ្យត្រូវធ្វើឱ្យសិស្ស យល់ច្បាស់លាស់ពីសភាពការណ៍ភារកិច្ចគោលមាគ៌ានយោបាយដឹកនាំរបស់រាជរដ្ឋាភិបាល ស្មារតីមោទនភាព ចំពោះជាតិ និងលទ្ធិប្រជាធិបតេយ្យ ស្មារតីស្នេហាជាតិ និងទឹកចិត្តជិតជាប់នឹងការសិក្សាស្រាវជ្រាវវិទ្យា សាស្ត្របច្ចេកទេស។
- ក្រិត្យក្រមគរុកោសល្យ ប្រឆាំងដាច់ខាតចំពោះការបង្ហាត់បង្រៀន សិស្សតាមរបៀបចាប់បញ្ចូក ឬ ទន្ទេញចាំស្ទាត់ តែមិនយល់ពីអត្ថន័យ និងខ្លឹមសារអ្វីទាំងអស់នោះ។ វិធីសាស្ត្រអប់រំសតិអារម្មណ៍ ឆ្លងកាត់មេរៀននីមួយៗ ទាមទារឱ្យសាស្ត្រាចារ្យ អនុវត្តតាមប្រភេទនៃមេរៀនឱ្យបាន យ៉ាងប៉ិនប្រសប់ ដោយចេះគួបផ្សំទៅនឹងភាពដោយឡែក នៃមុខវិជ្ជាសិក្សានីមួយៗ។ ទន្ទឹមនឹងនេះ សាស្ត្រាចារ្យ គប្បី ចៀសវាងនូវអាកប្បកិរិយាគំរោះគំរើយ និងក្លែងបន្លំចំពោះសិស្ស។

គោលការណ៍នេះ ទាមទារឱ្យសាស្ត្រាចារ្យម្នាក់ៗ យល់ជ្រួតជ្រាបច្បាស់លាស់ និងស៊ីជម្រៅនៅ ក្នុងការរៀន កិច្ចការសម្រាប់បង្រៀនសិស្ស។ ខ្លឹមសារនៃកិច្ចតែងការសម្រាប់បង្រៀនមានដូចតទៅ៖

- រៀបចំមេរៀនសម្រាប់បង្រៀនឱ្យបានច្បាស់លាស់ល្អ
- ធ្វើឱ្យសិស្សគោរពវិន័យ និងភាពត្រឹមត្រូវទៀងទាត់តាមពេលវេលា ក្នុងការសិក្សាក៏ដូចក្នុងពេលពលកម្ម។
- កសាងបាននូវបរិយាកាសប្រជាធិបតេយ្យប្រមូលផ្តុំ ដូចជាការជួយគ្នាទៅវិញទៅមក ការបំផុសចលនាប្រឡង ប្រណាំង ស្មារតីពលកម្ម ដើម្បីកិត្តិយសថ្នាក់រៀន និងស្មារតីសមូហភាព។
- ការប្រើប្រាស់ការអប់រំសតិអារម្មណ៍ លើរាល់រូបភាពនៃចំណាត់តាំងការសិក្សាផ្សេងទៀត ដូចជាសកម្មភាពក្រៅថ្នាក់រៀន ដំណើរកំសាន្ត និងកម្មសិក្សាក្នុងការងារផលិតកម្ម។
- នៅក្នុងលំនាំនៃការបង្រៀន បើចង់អនុវត្តគោលការណ៍ដែលធានាបាននូវចរិតអប់រំឱ្យបានល្អជាមួយនឹង ខ្លឹមសារគ្រប់វិធីសាស្ត្របង្រៀន ដែលបានអធិប្បាយមកខាងលើនេះ សាស្ត្រាចារ្យក៏ដូចជាសិស្ស ជានិច្ចកាល ត្រូវក្ដាប់ ឱ្យបាននូវគោលដៅអប់រំក្នុងរបបសង្គមយើង សព្វថ្ងៃនេះ គឺសំដៅបណ្តុះបណ្ដាលពលករ ជាម្ចាស់សមូហភាព ដែលមានការអភិវឌ្ឍពេញសមត្ថភាពនិងជាជនដែលចេះគួបផ្សំទ្រឹស្តី ទៅ នឹងការប្រតិបត្តិ។
- ចង់សម្រេចបាន និងលើកកម្ពស់ភារកិច្ចដ៏សំខាន់នេះ សាស្ត្រាចារ្យម្នាក់ៗ ត្រូវមានស្មារតីប្រជាធិបតេយ្យ និងទស្សនៈមហាជននៅក្នុងការបង្រៀន គប្បីយល់ច្បាស់ស៊ីជម្រៅ និងមានជំនឿ ទៅលើកម្មវត្ថុ ដែលខ្លួនត្រូវធ្វើ។ បើយល់មិនច្បាស់ ពីកម្មវត្ថុរបស់ការបង្រៀន និងការអប់រំទេនោះ សា

ស្ត្រាចារ្យ ច្បាស់ជាជួបប្រទះនូវការលំបាកក្នុងវិធីសាស្ត្របង្រៀនមិនខាន។ ការបណ្ដុះបណ្ដាលធនធានមនុស្ស ត្រូវធ្វើឡើងដោយឆ្លងកាត់តាមរយៈការផ្សព្វផ្សាយចំណេះដឹង គឺការបង្រៀន និងការអប់រំនេះឯង។ ដើម្បីទទួលបាននូវលទ្ធផលល្អក្នុងការបង្រៀន និងការអប់រំ សាស្ត្រាចារ្យម្នាក់ៗត្រូវពឹងលើទស្សនៈ គរុកោសល្យដូចជា

- គប្បីយល់ និងស្គាល់ច្បាស់លាស់ពីកម្មវត្ថុបង្រៀន គឺសិស្សានុសិស្ស
- លើកកម្ពស់សមត្ថភាពយល់ដឹង និងលុបបំបាត់ចោលនូវគុណវិបត្តិរបស់សិស្ស
- អប់រំសិស្សឱ្យមានសញ្ចេតនាល្អ តាមរយៈគម្រូនៃជីវភាពរស់នៅរបស់សាស្ត្រាចារ្យ តាមរយៈ ការសិក្សា គោលជំហរ សីលធម៌ និងអាកប្បកិរិយារបស់សាស្ត្រាចារ្យ។
- ស្មារតីក្លាហានអង់អាច និងសេចក្ដីព្យាយាមក្នុងមុខវិជ្ជាជីវៈ គួបផ្សំនឹងទឹកចិត្តស្មោះត្រង់ យុត្តិធម៌ទៀងទាត់ របស់សាស្ត្រាចារ្យចំពោះសិស្ស
- អ្វីៗទាំងអស់ដើម្បីសិស្សជាទីស្រលាញ់ អ្វីៗទាំងអស់ជាគម្រូសម្រាប់សិស្ស

## ៥.៤.២. គោលការណ៍នៃការបង្រៀន ត្រូវធានាបាននូវចរិតវិទ្យាសាស្ត្រ

ក/ធានាបាននូវចរិតវិទ្យាសាស្ត្រនៅក្នុងលំនាំនៃការបង្រៀនគឺផ្ដត់ផ្ដង់ឱ្យសិស្សនូវចំណេះដឹងវិទ្យាសាស្ត្រពិតប្រាកដ សមស្របទៅនឹងខឿនវិទ្យាសាស្ត្រទំនើប បំប៉នជាបណ្ដើរៗនូវវិធីសិក្សាស្រាវជ្រាវទម្លាប់សិស្ស ឱ្យមានការត្រិះរិះពិចារណាក្នុងបែបបទនៃការងារត្រឹមត្រូវ និងសមស្របតាមវិទ្យាសាស្ត្រ។ ជាក់ស្ដែងគោលការណ៍តម្រូវឱ្យៈ

- សាស្ត្រាចារ្យ គប្បីផ្ដត់ផ្ដង់ឱ្យសិស្សនូវសញ្ញាណវិទ្យាសាស្ត្រជាមូលដ្ឋានដូចជា ទស្សនៈទ្រឹស្ដីដែលមានលក្ខណៈជាក់ស្ដែង និងសត្យានុម័តត្រឹមត្រូវច្បាស់លាស់ សំដៅជួយសិស្ស ឱ្យមានលោកទស្សនៈវិទ្យាសាស្ត្រ។ ក្នុងលំនាំនៃការបង្រៀន សាស្ត្រាចារ្យត្រូវបង្កើត លក្ខណៈជាមូលដ្ឋានរបស់វា។
- ខ្លឹមសារនៃការបង្រៀន ត្រូវតែឆ្លុះបញ្ចាំងបាននូវគុណប្រយោជន៍មួយដ៏ទំនើបបំផុត ស្ដីពី វប្បធម៌វិទ្យាសាស្ត្រនិងបច្ចេកទេសក្នុងប្រទេសនិងលើពិភពលោក។ក្នុងបញ្ហានេះសំខាន់បំផុតនោះគឺសារជាតិដែលត្រូវពឹងផ្អែកជាមូលដ្ឋានសម្រាប់ការយល់ជ្រួតជ្រាបនិងក្ដាប់បានចំណេះដឹងទំនើប។ ចំណេះដឹងទំនើបនេះ ត្រូវតែបានជួយបំភ្លឺឱ្យកាន់តែច្បាស់លាស់ឡើងទៅលើវត្ថុ និងបាតុភូត ជាមូលដ្ឋានក្នុងការបង្ហាត់បង្រៀន។
- សាស្ត្រាចារ្យ ត្រូវបកស្រាយ ពន្យល់ពីចំណេះដឹងវិទ្យាសាស្ត្រតាមលក្ខណៈប្រព័ន្ធកម្មមួយ ដែលមាន ចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធបំផុត។ ដូចដែលយើង បានយល់ដឹងរួចមកហើយ ស្មារតីវិទ្យាសាស្ត្រ គឺជាការគួបផ្សំរវាងប្រព័ន្ធកម្ម និងទូទៅកម្មដែលត្រូវអនុវត្ត នៅក្នុងសង្គមមនុស្សជាតិ។ នាបច្ចុប្បន្ន នេះ វិទ្យាសាស្ត្រមានប្រព័ន្ធមួយដែលមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ស្ដីពី ព្រឹត្តិការណ៍ សញ្ញាណក្រឹត្យក្រម និងទ្រឹស្ដី។
- ខ្លឹមសារនៃការបង្រៀនតាមមុខវិជ្ជាឯកទេសនីមួយៗត្រូវមានលក្ខខ័ណ្ឌងាយស្រួល។ ភាសានិយាយត្រូវឱ្យ បានច្បាស់លាស់ត្រឹមត្រូវ។សាស្ត្រាចារ្យម្នាក់ៗសុទ្ធតែបានយល់ដឹងច្បាស់ពីល្បឿនអភិវឌ្ឍយ៉ាងខ្លាំងក្លា របស់វិទ្យាសាស្ត្រ និងបច្ចេកទេស។ រីឯ ទំហំនៃចំណេះដឹងរបស់មនុស្សជាតិ ក៏អភិវឌ្ឍឡើងយ៉ាងឆាប់ រហ័សដែរ។ បញ្ហាដ៏សំខាន់បំផុតនោះ គឺតម្រូវឱ្យសាស្ត្រាចារ្យម្នាក់ៗ ជ្រើសរើសយកចំណេះដឹងជា មូលដ្ឋានដ៏ចាំបាច់បំផុតតាមមុខវិជ្ជាឯកទេសនីមួយៗមកបង្រៀនសិស្ស។ ចង់ឱ្យ

បានសម្រេចតាមបំណងនេះ នៅក្នុងលំនាំនៃការបង្រៀន ត្រូវបន្ថយបំណកស្រាយពន្យល់តែផ្នែកទ្រឹស្តីខ្លះការអនុវត្ត ឬការប្រតិបត្តិ។ ផ្ទុយទៅវិញ ត្រូវផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការប្រតិបត្តិ។

- សាស្ត្រាចារ្យ ត្រូវបំប៉នឱ្យសិស្សជាបណ្តើរៗ នូវវិធីសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ទម្លាប់ សិស្សឱ្យមាន ការត្រិះរិះ និងរចនាបថក្នុងការងារតាមលក្ខណៈវិទ្យាសាស្ត្រ។ ទន្ទឹមនឹងនេះ គប្បីយកចិត្តទុកដាក់ ចៀសវាងដាច់ខាតនូវការរាំងស្ទះ ក្នុងការផ្តល់ចំណេះដឹងវិទ្យាសាស្ត្រ ឱ្យដល់យុវសិស្ស។

**ខ**/គោលការណ៍នេះ មានអត្ថន័យដ៏ធំធេងនៅក្នុងការអនុវត្តគោលដៅ និងភារកិច្ចរបស់ការអប់រំតាមលទ្ធិប្រជាធិបតេយ្យ ជាពិសេសនៅក្នុងការសិក្សា និងការអភិវឌ្ឍនៃចំណេះដឹងរបស់សិស្ស។ សាស្ត្រាចារ្យត្រូវផ្តល់ឱ្យសិស្សនូវចំណេះដឹងវិទ្យាសាស្ត្រត្រឹមត្រូវ ច្បាស់លាស់ពិតប្រាកដ។

**គ**/គោលការណ៍នេះ ត្រូវបានស្តែងឡើងនៅក្នុងជម្រើសឯកសារសម្រាប់បង្រៀន និងនៅក្នុងបម្រើបម្រាស់វិធីសាស្ត្របង្រៀន។

ជាបឋមសាស្ត្រាចារ្យ ត្រូវផ្សព្វផ្សាយឱ្យដល់សិស្ស នូវចំណេះដឹងជាមូលដ្ឋានច្បាស់លាស់ ត្រឹមត្រូវ ហើយចាំបាច់បំផុតនោះ ត្រូវចៀសវាងចំណេះដឹងណាដែលសិស្សមិនអាចឈោងចាប់បាន ឬមិន ទាន់បានអនុវត្តក្នុងបទពិសោធន៍ ឬក៏មិនទាន់បានពិភាក្សា។ ចំណេះដឹងទាំងនោះ ត្រូវបានសង្ខេប ឱ្យយ៉ាងងាយបំផុត នៅក្នុងវិទ្យាសាស្ត្រទំនើប។ បន្ទាប់មកចំណេះដឹងនេះ ត្រូវបានសិស្ស យល់ជ្រួតជ្រាបនិងធ្វើឱ្យអភិវឌ្ឍជាបន្ថែមទៅលើចំណេះដឹងដែលសិស្សមានរួចមកហើយ។ ដូចនេះ សាស្ត្រាចារ្យ គប្បីធ្វើឱ្យចំណង់ចំណូលចិត្តរបស់សិស្សខាងវិទ្យាសាស្ត្រអភិវឌ្ឍឡើង នៅ ក្នុងបំណក ស្រាយពន្យល់មេរៀននីមួយៗ។ ក្នុងខ្លឹមសារនៃមេរៀននីមួយៗ ទាមទារឱ្យ សាស្ត្រាចារ្យ បកស្រាយពន្យល់ដល់សិស្សនូវបញ្ហាសំខាន់ៗ ដែលសិស្សកំពុងសិក្សា និងពិភាក្សាពីវិទ្យាសាស្ត្រ សម្មតិកម្ម និងរូបភាពអភិវឌ្ឍនៃវិទ្យាសាស្ត្រ។

សាស្ត្រាចារ្យ ត្រូវបកស្រាយពន្យល់សិស្សតាមសេចក្តីណែនាំ «សម្រួលខ្លឹមសារមេរៀនដើម្បីចម្រាញ់យកសារជាតិច្បាស់លាស់រឹងមាំ» គឺបានន័យថាៈ សាស្ត្រាចារ្យត្រូវប្រើភាសា និងសម្រួលខ្លឹមសារមេរៀនឱ្យបានយ៉ាងប៉ិនប្រសប់ដើម្បីឱ្យសិស្សៈ

- ✓ ក្តាប់បានសារជាតិរបស់វត្ថុ បាតុភូត លំនាំនៃចលនា ហើយសិស្សអាចឆ្លើយបាននឹងសំណួរៈ យ៉ាងដូចម្តេច? ពីព្រោះអ្វី?
- ✓ ក្តាប់បាននូវគម្រូ ដើម្បីត្រិះរិះពិចារណានូវចំណងទាក់ទងវត្ថុ បាតុភូត និងលំនាំនៃចលនា របស់វា។ កាលណាក្តាប់បានសារជាតិ និងគម្រូដែលមាននៅក្នុងចំណងទាក់ទងនោះហើយ សិស្សក៏ មានទីបង្អែកក្នុងការយល់ជ្រួតជ្រាប និងចងចាំបានដោយងាយ។ ដូចនេះ សាស្ត្រាចារ្យត្រូវចៀសវាង នូវទំនោរមួយ គឺការងាយស្រួលពេក ការពិបាកពេក ឬការឥតប្រយោជន៍ក្នុងចំណេះដឹង នៅ ពេលអនុវត្តតាមចំណេះដឹងនេះ។
- ✓ ឯកសារបង្រៀន ត្រូវបានយកមកបកស្រាយពន្យល់ តាមលក្ខណៈផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម ហើយសមស្រប ឬមានភាពសមហេតុផលចំពោះមុខវិជ្ជាសិក្សានីមួយៗ។ សាស្ត្រាចារ្យ ត្រូវប៉ិនប្រសប់ផ្សារភ្ជាប់ ចំណេះដឹងថ្មីទៅនឹងចំណេះដឹងចាស់ ចំណេះដឹងតាមមុខវិជ្ជាឯកទេសនីមួយៗ ត្រូវផ្សារភ្ជាប់ទៅនឹងចំណេះ ដឹងក្នុងមុខវិជ្ជាឯកទេសឯទៀតៗដូចជា គីមីវិទ្យា ជីវវិទ្យា ទៅនឹងគណិតវិទ្យា អក្សរសាស្ត្រ ទៅនឹង ប្រវត្តិវិទ្យា ។ល។

✓ ចរិតវិទ្យាសាស្ត្រ ត្រូវបានស្តែងឡើង នៅក្នុងវិធីសាស្ត្របង្រៀនរបស់សាស្ត្រាចារ្យ និងវិធីសិក្សារបស់សិស្ស។ សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ ក្នុងការបង្កើតបាននូវលក្ខខ័ណ្ឌងាយស្រួល ដើម្បីធ្វើឱ្យការយល់ដឹង និងអត្ថប្រយោជន៍នៃវិទ្យាសាស្ត្រ ក្នុងចំណេះដឹងរបស់សិស្សអភិវឌ្ឍឡើង។ សាស្ត្រាចារ្យត្រូវពឹងផ្អែក លើមូលដ្ឋានវិទ្យាសាស្ត្រ ត្រូវយកការអនុវត្តដ៏រស់រវើក គួបផ្សំនឹងបំណកស្រាយពន្យល់ ពីចរិតច្បាស់លាស់ ត្រឹមត្រូវ របស់វិទ្យាសាស្ត្រតាមរយៈមេរៀនឱ្យដល់សិស្ស។ ត្រូវចៀសវាង នូវបំណកស្រាយពន្យល់តាម បែប អត្តនោម័ត។ បំណកស្រាយពន្យល់ដ៏ត្រឹមត្រូវ សមរម្យមានន័យថា ក្ដាប់ខ្លឹមសារមេរៀនបានទាំងស្រុង ហើយ អាចយកមកបកស្រាយ ពន្យល់បានយ៉ាងងាយ។ ផ្ទុយទៅវិញ បើសាស្ត្រាចារ្យ ក្ដាប់ខ្លឹមសារមេរៀនមិនបាន ច្បាស់ទេនោះ ក៏មិនអាចបកស្រាយពន្យល់បានដែរ។ សាស្ត្រាចារ្យត្រូវយកចិត្តទុកដាក់ជាពិសេស ដល់ការហ្វឹកហ្វឺនសិស្សឱ្យមានទម្លាប់ក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រដូចជា៖

* ដឹកនាំសិស្ស ឱ្យម្ចាស់ការក្នុងការពិនិត្យសង្កេត
* ធ្វើការពិសោធ និងលើកឡើងនូវសមតិកម្មដោយខ្លួនឯង...។

ទន្ទឹមនឹងនេះសាស្ត្រាចារ្យគប្បីចៀសវាង៖

- ឱ្យសិស្សទន្ទេញចាំមាត់ ដោយមិនយល់ពីអត្ថន័យ ឬខ្លឹមសារមេរៀន
- ការបង្រៀនតាមបែបបញ្ច្រកចំណេះដឹង ទៅក្នុងខួរក្បាលសិស្ស

ដូចនេះ ជានិច្ចកាល ត្រូវផ្សារភ្ជាប់ការសិក្សា ទៅនឹងការអនុវត្តជាក់ស្តែង។ សាស្ត្រាចារ្យ ត្រូវមានស្មារតីលើកកម្ពស់ឥតឈប់ឈរ នូវកម្រិតចំណេះដឹងវិទ្យាសាស្ត្រ ហើយទន្ទឹមនឹងនេះ ត្រូវតាមដានសិស្ស លើគ្រប់សកម្មភាព ផ្សព្វផ្សាយវិទ្យាសាស្ត្រ ដើម្បីអាចឆ្លុះបញ្ចាំងបានច្បាស់ លើគ្រប់ការយល់ដឹង ដ៏ត្រឹមត្រូវពីវិទ្យា សាស្ត្រក្នុងមេរៀន។

### ៥.៤.៣. គោលការណ៍នៃការបង្រៀនត្រូវធានាបាននូវចរិតប្រតិបត្តិ

ក/ធានាបាននូវចរិតប្រតិបត្តិក្នុងការបង្រៀនគឺបានន័យថាគួបផ្សំទ្រឹស្តីទៅនឹងការអនុវត្ត។សាស្ត្រាចារ្យ ត្រូវចេះធ្វើឱ្យការបង្រៀនការសិក្សារបស់សិស្សនិងទ្រឹស្តីដែលបានសិក្សាក្នុងសាលារៀនផ្សារភ្ជាប់យ៉ាងជិត ស្និទ្ធទៅនឹងភាពជាក់ស្តែងនៃជីវភាពរស់នៅ។

គោលការណ៍ធានាបាននូវចរិតប្រតិបត្តិនេះ តម្រូវឱ្យសាស្ត្រាចារ្យ៖

- ធ្វើឱ្យសិស្សឃើញច្បាស់ នូវការអនុវត្តទ្រឹស្តីទៅក្នុងជីវភាពរស់នៅ រួចបន្ទាប់មកធ្វើឱ្យសិស្សឃើញច្បាស់ពីអត្ថប្រយោជន៍នៃការសិក្សាទ្រឹស្តី គឺសំដៅបម្រើគោលដៅក្នុងការអនុវត្ត និងដើម្បីបម្រើប្រជាពលរដ្ឋ។
- ជ្រើសរើសយកភាពជាក់ស្តែងក្នុងជីវភាពរស់នៅនិងគម្រូក្នុងជីវភាពការងារយកមកអប់រំក្នុងសាលា រៀន។
- ពេលបង្រៀន ពីទ្រឹស្តីត្រូវជ្រើសយកតែទ្រឹស្តីណា ដែលមានសារជាតិ និងមូលដ្ឋានត្រឹមត្រូវច្បាស់លាស់ ដើម្បី ងាយយកមកអនុវត្តបានដោយលក្ខណៈច្នៃប្រឌិត នៅក្នុងធាតុពិតជាក់ស្តែង។
- ពេលធ្វើសកម្មភាពក្នុងសាលារៀន ក៏ដូចជាក្នុងសង្គម ត្រូវយកទ្រឹស្តីដែលបានរៀនរួចមកហើយមក បំភ្លឺក្នុងការអនុវត្តការងាររបស់ខ្លួន ហើយឆ្លងកាត់តាមរយៈសកម្មភាពជាក់ស្តែងនេះ ត្រូវពង្រឹងបូកសរុប និង បំពេញចំណុចខ្វះខាតក្នុងទ្រឹស្តីផង។

ចំពោះបញ្ហានេះ យើងត្រូវយកទ្រឹស្តីធ្វើជាបង្គោល ឬជាគោលដៅក្នុងការអនុវត្ត លើជាតុពិតជាក់ស្តែងគឺបានន័យថា ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត។

- ពេលបង្រៀនពីទ្រឹស្តី សាស្ត្រាចារ្យ ត្រូវភ្ជាប់ឱ្យបានច្បាស់ពីគោលដៅរបស់ទ្រឹស្តី។ សាស្ត្រាចារ្យត្រូវ ចៀសវាងការបង្រៀនតែទ្រឹស្តី ដោយបោះបង់ចោលការអនុវត្ត ឬប្រតិបត្តិ
- ត្រូវចៀសវាង ការទន្ទេញចាំមាត់
- ពេលអនុវត្តសាស្ត្រាចារ្យ ត្រូវធ្វើឱ្យទ្រឹស្តីមានភាពសម្បូរបែប រួចពឹងផ្អែកលើសេចក្តីសន្និដ្ឋានថ្មី ដែល ដកស្រង់ចេញពីការអនុវត្ត ក្នុងការកសាងប្រទេសជាតិយើង។

ខ/គោលការណ៍នេះស្តែងឡើងពីលទ្ធិប្រជាធិបតេយ្យក្នុងការអប់រំនិងការបណ្តុះបណ្តាលធនធានមនុស្ស។ សាលារៀន ចំណេះទូទៅរបស់យើង មានទំនួលខុសត្រូវខ្ពស់ក្នុងការបណ្តុះបណ្តាល និងបំពាក់បំប៉នយុវសិស្សក្លាយទៅជាយុទ្ធជនបដិវត្ត និងពលករថ្មី ដែលមានសមត្ថភាពជាក់ស្តែងក្នុងពលកម្មថ្លៃប្រឌិត ដើម្បីកសាងលទ្ធិប្រជាធិបតេយ្យ និងការពារមាតុភូមិ។ ចង់បណ្តុះបណ្តាល បាននូវមនុស្សបែបនេះ មិនត្រូវអនុវត្តតាមសៀវភៅសិក្សា និងជីវភាពរស់នៅរបស់សង្គម ចាស់ ទាំងស្រុងឡើយ។ ផ្ទុយទៅវិញ សាស្ត្រាចារ្យ ត្រូវអនុវត្តតាមមាគ៌ាផ្សារភ្ជាប់ទ្រឹស្តីនឹង ភាពជាក់ស្តែង ការសិក្សារបស់សិស្ស ទៅនឹងការប្រតិបត្តិ។ទ្រឹស្តីចំណេះដឹងរបស់លទ្ធិ ម៉ាក្ស លេនីន បានពោលអះអាងថា៖ ការប្រតិបត្តិជាប្រភព ជាគោលដៅរបស់ចំណេះដឹង ជាលក្ខណៈវិនិច្ឆ័យរបស់សច្ចភាព។ នៅក្នុងការបង្រៀន ក៏យ៉ាងនេះដែរ។ ចង់យល់ច្បាស់ ហើយស៊ីជម្រៅក្នុងបញ្ហានេះ គប្បីផ្សារភ្ជាប់ការសិក្សា ការបង្រៀនទៅនឹងការប្រតិបត្តិ។ក្នុងការប្រតិបត្តិ ត្រូវឆ្លងកាត់តាមរយៈការយល់ជ្រួតជ្រាបច្បាស់លាស់ បទពិសោធ និងការលើកកម្ពស់ ទ្រឹស្តីនោះផង។ សាស្ត្រាចារ្យ ត្រូវធ្វើឱ្យសិស្សមានតម្រូវការក្នុងការយល់ដឹងថ្មី ដោយឆ្លងកាត់តាមរយៈ ការ ប្រតិបត្តិនេះ។ដូចនេះគោលការណ៍មានទំនាស់ទាំងស្រុងទៅលើទ្រឹស្តីដែលបង្រៀនតាមគម្ពីរដោយកាត់ ផ្តាច់ជីវភាពរស់នៅធម្មតាពីការសិក្សាការបង្រៀននិងចរិតសាកលក្រោយរបបមូលធន។ គោលការណ៍នេះក៏មានទំនាស់ដែរជាមួយនឹងលទ្ធិប្រយោជន៍និយម និងលទ្ធិលោភលន់និយម។ នៅក្នុងការបង្រៀនសព្វថ្ងៃនេះនៅក្នុងសាលារៀនរបស់ប្រទេសខាងលិចមួយចំនួនជាពិសេសគឺនៅសហរដ្ឋអាមេរិច។

គោលការណ៍ជានាបាននូវចរិតប្រតិបត្តិនេះ ស្តែងចេញគ្រប់គ្រាន់ពីការគួបផ្សំរវាងទ្រឹស្តីទៅនឹងការប្រតិបត្តិ ការអប់រំទៅនឹងពលកម្មបង្កបង្កើនផល សាលារៀនទៅនឹងសង្គម។ ការផ្សារភ្ជាប់ចំណេះដឹងទៅនឹងការប្រតិបត្តិ ការសិក្សាទៅនឹងរូបភាពពលកម្មក្នុងសង្គម ជាពិសេសគឺ ពលកម្មនៅក្នុង លក្ខខណ្ឌវិទ្យាសាស្ត្របច្ចេកទេសដែលកំពុងអភិវឌ្ឍ នោះគឺជាការដឹកនាំដ៏ត្រឹមត្រូវរបស់មូលហេតុនៃការ បណ្តុះបណ្តាលធនធានមនុស្ស។

គ/ដើម្បីសម្រេចបានលទ្ធផលល្អតាមគោលការណ៍នេះនៅក្នុងលំនាំនៃការបង្រៀនសាស្ត្រាចារ្យត្រូវអនុវត្តតាមសំណូមពរមួយចំនួនដូចតទៅ៖

- យកចិត្តទុកដាក់ក្នុងការសិក្សាស្រាវជ្រាវពីទ្រឹស្តី ក៏ដូចជាក្នុងការប្រតិបត្តិ។ គប្បីធ្វើឱ្យសិស្សមើលឃើញថាវិទ្យាសាស្ត្រកើតនិងអភិវឌ្ឍឡើងតាមសំណូមពររបស់ការប្រតិបត្តិនិងផលិតកម្ម។ នៅក្នុងកម្មវិធីសិក្សា ត្រូវចេះលៃលកឱ្យផ្នែកប្រតិបត្តិ សមស្របទៅតាមពេលវេលាជាចាំបាច់ របស់ ពលកម្មផលិត។ការងារប្រតិបត្តិនេះត្រូវបានអនុវត្តទាំងនៅក្នុងសាលារៀនទាំងនៅក្រៅសាលារៀន។

- ពេលកសាងផែនការនិងកម្មវិធីបង្រៀនគប្បីជ្រើសរើសមុខវិជ្ជាសិក្សានិងចំណេះដឹងទាំងឡាយ

ជាមូលដ្ឋាន ដែលឆ្លើយតបបានទៅនឹងសំណូមពរដ៏ត្រឹមត្រូវរបស់ក្រសួងអប់រំ លក្ខខ័ណ្ឌ ធម្មជាតិ សង្គម និងប្រជាពលរដ្ឋកម្ពុជា។ ពេលបង្ហាត់បង្រៀនមុខវិជ្ជាឯកទេសនីមួយៗ សាស្ត្រាចារ្យត្រូវសង្កត់ធ្ងន់ បើកទូលាយ និងស៊ីជម្រៅលើចំណេះដឹងជាមូលដ្ឋាន ដែលមានចំណងទាក់ទងដល់រូបភាពផ្សព្វផ្សាយចំណេះដឹងវិទ្យាសាស្ត្រដល់ចរិតលក្ខណៈ និងសភាពការណ៍ទូទាំងប្រទេស ឬតាមតំបន់ដែលសិស្សរស់នៅ។

- នៅក្នុងលំនាំនៃការបង្រៀន ត្រូវបង្កើតបានជាមូលដ្ឋានវិទ្យាសាស្ត្រ លើគ្រប់ដំណើរការប្រព្រឹត្តទៅនៃការប្រតិបត្តិដែលសិស្សត្រូវចូលរួម។ ក្នុងលំនាំនៃសកម្មភាពប្រតិបត្តិ ត្រូវសំណូមពរដល់សិស្សឱ្យប្រើប្រាស់ ចំណេះដឹងវិទ្យាសាស្ត្រ ដែលបានរៀនរួចមកហើយ។ កាលបើបានអនុវត្តតាមប្រការនេះហើយ សិស្សនឹងមានការភ្ញាក់រលឹក ហើយចំណេះដឹងដែលរៀនរួចហើយក៏មានភាពរឹងមាំ។
- ត្រូវធានាដល់ចរិតផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម នៅក្នុងចំណងទាក់ទងគ្នារវាងទ្រឹស្តី និងការប្រតិបត្តិ។ គប្បីយកចិត្តទុកដាក់ ក្តាប់ឱ្យបានច្បាស់នូវចរិតផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្ម របស់ចំណេះដឹងវិទ្យាសាស្ត្រដែលជាលក្ខខ័ណ្ឌមួយដ៏សំខាន់ ចំពោះការអនុវត្តចំណេះដឹង ដែលមានចំណងទាក់ទងទៅនឹងជីវភាពរស់នៅ និងប្រតិបត្តិ។ នេះ ជាកត្តាមួយដ៏សំខាន់បំផុតក្នុងការក្តាប់បាន និងស៊ីជម្រៅទៅលើប្រព័ន្ធចំណេះដឹង។

ដូចនេះ ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការប្រតិបត្តិ មិនត្រូវយកទៅអនុវត្តទាំងងងឹតងងល់បានឡើយ។ ផ្ទុយទៅវិញ ត្រូវធ្វើឱ្យប្រព័ន្ធចំណេះដឹង ដែលត្រូវបានយកមកអនុវត្តមានលក្ខណៈច្បាស់លាស់ភ្លឺស្វាងត្រឹមត្រូវ។តទៅនេះ គឺជារូបភាព និងល្បិចមួយចំនួន ដកស្រង់ចេញពីបទពិសោធន៍ល្អៗក្នុងសាលារៀនមធ្យមសិក្សាចំណេះទូទៅរបស់ប្រទេសទាំងឡាយលើសកលលោកដែលបាននឹងកំពុងអនុវត្ត ទទួលបានលទ្ធផលល្អប្រសើរ តាមរយៈគោលការណ៍ធានាបាននូវចរិតប្រតិបត្តិនេះ។

- ចាត់តាំងពេលវេលា និងចលនាប្រឡងប្រណាំងការបង្រៀនល្អ និងការរៀនល្អនៅក្នុង សាលារៀនគួបផ្សំជាមួយនឹងស្ថានភាពដែលបានកើតឡើងក្រៅសាលារៀន។ *ឧទាហរណ៍៖* ការប្រឡងប្រណាំងស្តីពី ការរៀនពូកែ ក្នុងខួបអនុស្សាវរីយ៍ថ្ងៃបុណ្យប្រពៃណី ឬក៏ចលនាណាមួយ ដែលកើតឡើងក្នុងតំបន់ សិស្សរស់នៅ។ ល្បិចនេះមានឥទ្ធិពលណាស់ ក្នុងការផ្សារភ្ជាប់សាលារៀនទៅនឹងជីវភាពរស់នៅក្នុង សង្គម ពោលគឺ ធ្វើឱ្យសិស្សយល់ជ្រួតជ្រាប និងក្តាប់បានការសិក្សារបស់ខ្លួន ដែលជានិច្ចកាលផ្សារភ្ជាប់ទៅ នឹងកិច្ចការពារ និងកសាងប្រទេសរបស់ប្រជាជនទាំងមូល។ បន្ទាប់មក សិស្សបានកំណត់ច្បាស់ លាស់ពីមូលហេតុ និងអាកប្បកិរិយាក្នុងការសិក្សារបស់ខ្លួន ដើម្បីបម្រើដល់ការប្រតិបត្តិក្នុងការងារពលកម្ម ផលិត និងក្នុងជីវភាពរស់នៅ។

✓ ធ្វើឱ្យសិស្សយល់ច្បាស់ ពីអត្ថន័យជាក់ស្តែងរបស់ការសិក្សា និយាយរួមនឹងអត្ថន័យរបស់ការសិក្សាលើមុខវិជ្ជាឯកទេសទាំងអស់ និយាយដោយឡែកៗល្បិចនេះសម្រាប់អប់រំទស្សនៈ នៅក្នុងការប្រតិបត្តិទៅលើចំណេះដឹងវិទ្យាសាស្ត្រឱ្យដល់សិស្ស។ សិស្សក៏មាន ចំណង់ចំណូលចិត្ត គិតដល់ អត្ថប្រយោជន៍នៃការសិក្សា និងមានមនសិកាមាំមួនក្នុងការព្យាយាម ដើម្បីយកចំណេះដឹងទៅអនុវត្តនៅក្នុងជីវភាពរស់នៅ និងនៅក្នុងការងាររបស់ខ្លួន។

✓ គួបផ្សំភាពទូទៅជាមួយនឹងភាពដោយឡែក បានន័យថា ផ្សារភ្ជាប់ចំណេះដឹងជាមូលដ្ឋាន ដែលមានចរិតសាកលទៅនឹងគោលមាគ៌ានយោបាយ ដឹកនាំរបស់រាជរដ្ឋាភិបាលទៅនឹងធាតុពិតជាក់ស្តែង

នៃប្រទេសជាតិ ឬតំបន់ដែលសិស្សរស់នៅទៅនឹងធាតុពិតនៃសតិអារម្មណ៍ សញ្ចេតនាការងារ និងជីវភាពរស់នៅ។ ការយកចិត្តទុកដាក់អនុវត្តបានតាមប្រការនេះ មានន័យថាអនុវត្តគោលការណ៍ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការប្រតិបត្តិ។

- ✓ គប្បីប្រើប្រាស់បទពិសោធន៍ ក្នុងជីវភាពរស់នៅរបស់សិស្ស ពោលគឺ បម្រើបម្រាស់នៅក្នុង ម៉ោងបង្រៀនពីឯកសារ វត្ថុ បាតុភូត ជាក់ស្តែង ដែលសិស្សមាននឹងបានជួបប្រទះ ក្នុងជីវភាពរស់ នៅក្នុងតំបន់ ឬនៅក្នុងម៉ោងបង្រៀន ក្នុងរោងជាង និងក្នុងម៉ោងបង្រៀនកសិកម្ម។

*ឧទាហរណ៍៖* ដោះស្រាយលំហាត់តាមទិន្នន័យ ដែលសិស្សជួបប្រទះ គឺចាត់តាំងឱ្យសិស្សមានភាពម្ចាស់ការ នៅក្នុងសេចក្តីសន្និដ្ឋានសរុប ក្នុងបទពិសោធន៍នៅផ្ទះ នៅក្នុងសាលារៀន ឬនៅរោងចក្រ។ ក្រោយ មកត្រូវធ្វើនៅក្នុងម៉ោងបង្រៀនជំរុញសិស្សឱ្យចេះទាញសេចក្តីសន្និដ្ឋានសរុបបានដោយខ្លួនឯង។

សាស្ត្រាចារ្យ និងសិស្ស ធ្វើការរួមគ្នាក្នុងការវិភាគ និងការសន្និដ្ឋានសរុប ដើម្បីដកស្រង់នូវបទពិសោធន៍ និងទាញយកបាននូវសេចក្តីសន្និដ្ឋានសរុប ជាចាំបាច់នោះ។

- ✓ ចាត់តាំងឱ្យសិស្សបានធ្វើដំណើរកំសាន្ត ទៅគ្រប់រមណីដ្ឋានប្រវត្តិសាស្ត្រ រោងចក្រ និងកសិដ្ឋានផ្សេងៗ។ ឆ្លងតាម រយៈនេះ បកស្រាយពន្យល់ដល់សិស្សពីបរិក្ខាបច្ចេកទេសគ្រប់លំនាំពលកម្ម និងលក្ខខណ្ឌពលកម្ម របស់កសិករ និងកម្មករ។
- ✓ ជំរុញ និងពង្រឹងការប្រតិបត្តិរបស់សិស្សលើគ្រប់រូបភាព៖សំណូមពរសិស្ស ឱ្យផ្សារភ្ជាប់ចំណេះដឹងដែលសិស្សភ្ជាប់បានទៅនឹងធាតុពិតជាក់ស្តែងក្នុងជីវភាពរស់នៅដូចជា បទពិសោធន៍ សតិអារម្មណ៍ គោល ជំហរ បម្រើបម្រាស់ចំណេះដឹង ដើម្បីបកស្រាយពន្យល់ពីបាតុភូតជាក់ស្តែងជុំវិញខ្លួន ដឹកនាំឱ្យ សិស្សឈានចូលក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ តាមរយៈការពិនិត្យសង្កេតដូចជា ក្នុងម៉ោងបង្រៀនជីវវិទ្យា នាំសិស្សឱ្យដាំដើមឈើ ពិសោធ បណ្តុះពូជស្រូវ ពូជដំណាំបន្លែ និងចាត់តាំងសកម្មភាពផ្សេងៗទៀតក្រោមមុខវិជ្ជាសិក្សា។ ដើម្បីសម្រេចបានល្អតាមសំណូមពរ និងល្បិចខាងលើនេះសាស្ត្រាចារ្យ ត្រូវសិក្សាស៊ីជម្រៅពីជីវភាពរស់នៅរបស់សិស្ស។

## ៥.៤.៤. គោលការណ៍នៃការបង្រៀន ត្រូវពង្រឹងពង្រីកចរិតភ្ញាក់រលឹក ចរិត សកម្មម្ចាស់ការច្នៃប្រឌិតរបស់សិស្ស ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ

ក/ការបង្រៀនសិស្សតាមគោលការណ៍នេះ គឺតម្រូវឱ្យសាស្ត្រាចារ្យ គួបផ្សំយ៉ាងប៉ិនប្រសប់បំផុតនូវតួនាទីដឹកនាំរបស់ខ្លួនទៅនឹងចរិតសកម្មម្ចាស់ការរបស់សិស្សក្នុងគ្រប់លំនាំនៃការសិក្សារបស់សិស្ស។ គោលការណ៍នេះទាមទារឱ្យ៖

-ជានិច្ចកាលសាស្ត្រាចារ្យត្រូវថែរក្សាតួនាទីដឹកនាំរបស់ខ្លួននៅក្នុងដំណាក់កាលរបស់លំនាំនៃការបង្រៀននីមួយៗ

ដូចជា៖

- ✓ បកស្រាយពន្យល់មេរៀន
- ✓ ដាក់លំហាត់ឱ្យសិស្សធ្វើ
- ✓ ឱ្យសិស្សធ្វើកិច្ចការត្រួតពិនិត្យ
- ✓ ឱ្យសិស្សធ្វើកិច្ចការប្រតិបត្តិ

✓ អានឯកសារពិគ្រោះ
✓ សិក្សានៅផ្ទះដោយខ្លួនឯង។ល។

សាស្ត្រាចារ្យ បង្រៀនមានទំនួលខុសត្រូវ ចំពោះគុណសម្បត្តិរបស់សិស្សក្នុងការសិក្សាហើយនេះជាលក្ខណៈវិនិច្ឆ័យមួយក្នុងរង្វាយតម្លៃទៅលើលទ្ធផលនៃការបង្រៀនរបស់សាស្ត្រាចារ្យ។

- គប្បីឱ្យសិស្សយល់ពីគោលដៅ និងភារកិច្ចនៃការសិក្សារបស់ខ្លួន។ ធ្វើឱ្យសិស្សមានសតិអារម្មណ៍គោលជំហរភ្ញាក់រលឹក លើកកម្ពស់ក្នុងការសិក្សា ហើយបន្ទាប់មកត្រូវមានអាកប្បកិរិយា និងមូលហេតុត្រឹមត្រូវ ហើយយ៉ាងខ្លាំងក្លា មានចំណង់ចំណូលចិត្តក្នុងការសិក្សា និងពលកម្ម ដើម្បីត្រៀមខ្លួនចូលបម្រើមាតុភូមិរបស់ខ្លួន។

- គប្បីជំរុញគំនិតភ្ញាក់រលឹកសកម្ម ម្ចាស់ការរបស់សិស្ស ក្នុងការយល់ជ្រួតជ្រាប និងក្ដាប់បានចំណេះដឹង រួចធ្វើឱ្យចំណេះដឹងនោះក្លាយទៅជាទុនផ្ទាល់ខ្លួន បន្ទាប់មកសិស្សអាចយកចំណេះ ដឹងនោះទៅប្រើប្រាស់ បានយ៉ាងប៉ិនប្រសប់ដោយលក្ខណៈម្ចាស់ការច្នៃប្រឌិតក្នុងជីវភាពរស់នៅ។នេះជាកត្តាសម្រេចបានដោយ ផ្ទាល់ទៅលើលទ្ធផលនៃការបង្រៀន។

ខ/គោលការណ៍នេះ ផ្ដើមចេញពីគោលដៅរបស់ខឿនអប់រំ របស់ប្រទេសជឿនលឿនក្នុងសកលលោក។

- ចង់ធ្វើឱ្យសិស្សមានសមត្ថភាពចូលរួមក្នុងពលកម្មផ្សេងៗរបស់សង្គម គប្បីធ្វើឱ្យសិស្សសកម្ម និងភ្ញាក់ រលឹកក្នុងការក្ដាប់ចំណេះដឹងជាមូលដ្ឋានបាន ហើយយកចំណេះដឹងនោះទៅអនុវត្តក្នុងជីវភាពរស់នៅជាក់ស្ដែង បានយ៉ាងប៉ិនប្រសប់ និងច្នៃប្រឌិត។ លើសពីនេះទៅទៀត ចរិតវិទ្យាសាស្ត្ររបស់ចំណេះដឹង ដែលសិស្សក្ដាប់បាន ក្នុងសាលារៀនមធ្យមសិក្សា ក៏ទាមទារឱ្យសិស្ស សិក្សាប្រកបដោយស្មារតីភ្ញាក់រលឹកខ្ពស់ដែរ។

- គោលការណ៍នេះ ផ្ដើមចេញថែមទៀតពីចំណងទាក់ទងថ្មីរវាងមនុស្ស និងមនុស្ស រវាងសាស្ត្រាចារ្យ និង សិស្សនៅក្នុងប្រព័ន្ធអប់រំ។ នោះ គឺជាចំណងទាក់ទងជាមិត្តភាព និងភាតរភាព នៅក្នុងមូលហេតុកសាងមាតុភូមិ កម្ពុជា។ហេតុនេះហើយបានជាសាស្ត្រាចារ្យត្រូវលើកកម្ពស់ស្មារតីរបស់សិស្សក្នុងការធ្វើជាម្ចាស់សមូហភាព ក្នុង ការសិក្សាដូចជាគោរពសិស្សនិងចេះចៀសអាកប្បកិរិយាគំរោះគំរើយឬទ្រគោះបោះបោកចំពោះសិស្ស។ ផ្ទុយទៅ វិញសិស្សត្រូវចេះភ្ញាក់រលឹកទៅលើសេចក្ដីទូន្មានរបស់សាស្ត្រាចារ្យ ដូចជា៖ ចេះគោរពសាស្ត្រាចារ្យ និងចេះថ្លែង អំណរគុណចំពោះសាស្ត្រាចារ្យជាដើម។

- គោលការណ៍នេះ ក៏ផ្ដើមចេញផងទៀតដែរ ពីចរិតពីរយ៉ាងរបស់លំនាំនៃការបង្រៀន និងក្រិត្យក្រមរបស់លំនាំនៃការក្ដាប់យកចំណេះដឹង។ដូចដែលយើងបានសិក្សាវិភាគច្បាស់លាស់ក្នុងមេរៀនមុនៗរួចមកហើយ នៅក្នុងលំនាំនៃការបង្រៀនរបស់សាស្ត្រាចារ្យ និងការសិក្សារបស់សិស្សត្រូវបានគួបផ្សំគ្នាយ៉ាងជិតស្និទ្ធ។ ការបង្រៀនសម្រេចបានលទ្ធផលល្អ គឺនៅពេលដែលសិស្សភ្ញាក់រលឹក និងសកម្ម។ លំនាំរបស់បន្លាស់ប្ដូរពីចំណេះដឹងសញ្ចេតនាទៅចំណេះដឹងវិចារ ហើយពីចំណេះដឹងវិចារទៅការ ប្រតិបត្តិ គឺជាលំនាំលោតផ្លោះមួយយ៉ាងសកម្ម ដែលទាមទារឱ្យសិស្សត្រិះរិះពិចារណា ពោលគឺត្រូវភ្ញាក់រលឹក និង សកម្មក្នុងការសិក្សានេះឯង។

- សកម្មនិងភ្ញាក់រលឹកក្នុងការយល់ជ្រួតជ្រាបនិងក្ដាប់បានចំណេះដឹងគឺត្រូវមានសុឆន្ទៈស្វ័យភ្ញាក់មើលឃើញការសិក្សាជាភារកិច្ចចាំបាច់មួយ។សាស្ត្រាចារ្យត្រូវធ្វើឱ្យបានសម្រេចទាំង ស្រុងចំពោះ ប្រការ

នេះ។ ដោយសារចរិតសកម្ម និងការបង្កើតបាននូវផែនការក្នុងការសិក្សា សិស្ស ត្រូវបានលើកកម្ពស់ ស្មារតីព្យាយាមប្រឹងប្រែងមិនរាថយក្រោយទោះជាជួបការលំបាកក្នុងការសិក្សាយ៉ាងណាក៏ដោយ។ គោលការណ៍នេះប្រឆាំងដាច់ខាតនឹងការសិក្សាដោយទន្ទេញចាំមាត់តាមបែបគម្ពីរនិយមនិងតាមបែបរូបភាពនិយម បានន័យថា ក្តាប់បានតែបាតុភូត តែមិនអាចក្តាប់បាននូវសារជាតិនៃបញ្ហា។ម៉្យាងទៀតគោលការណ៍នេះក៏ប្រឆាំងផងដែរនឹងអាកប្បកិរិយារបស់សាស្ត្រាចារ្យដែលធ្វើឱ្យសិស្សខ្វះការគោរព និងការអនុវត្ត។

គ/ធ្វើឱ្យសិស្សមើលឃើញនូវអត្ថប្រយោជន៍ក្នុងការសិក្សាលើគ្រប់មុខវិជ្ជាសិក្សាទាំងអស់។

- ដើម្បីជំរុញបាននូវចរិតភ្ញាក់រលឹកនិងសកម្មរបស់សិស្សជានិច្ចកាលសាស្ត្រាចារ្យម្នាក់ៗត្រូវធ្វើឱ្យសិស្សយល់ច្បាស់ពីភារកិច្ចនៃការសិក្សាជាទូទៅនិងភារកិច្ចនៃការសិក្សាតាមមុខវិជ្ជានីមួយៗ។ធ្វើយ៉ាងនេះសិស្សមានមូលហេតុ និងអាកប្បកិរិយាដ៏ត្រឹមត្រូវក្នុងការសិក្សារបស់ខ្លួន។

- គប្បីយកចិត្តទុកដាក់ធ្វើឱ្យការគិត និងភាសារបស់សិស្សអភិវឌ្ឍឡើង ពោលគឺធ្វើឱ្យ សិស្សក្តាប់បានសកម្មភាពក្នុងលំនាំនៃការយល់ជ្រួតជ្រាបចំណេះដឹងបានយ៉ាងប៉ិនប្រសប់។ ក្នុងប្រការនេះសាស្ត្រាចារ្យត្រូវ៖

- ជំរុញសិស្សឱ្យស្ថិតនៅក្នុងស្ថានភាពបញ្ហា
- ✓ ដាក់ជាសំណួរ ឬលំហាត់ឱ្យសិស្សត្រិះរិះ
- ✓ ក្រោយមកតម្រូវឱ្យសិស្សដោះស្រាយបញ្ហានោះ
- ✓ ឈ្លាសវៃក្នុងការដាក់សំណួរ ឬកិច្ចការឱ្យសមស្របនឹងសមត្ថភាពសិស្ស។

ក្នុងករណីនេះបើសិស្សមិនទាន់អាចយល់បានសាស្ត្រាចារ្យគ ប្បីផ្លាស់ប្តូរពាក្យខ្លះ ក្នុងឃ្លាប្រយោគនៃសំណួរ តែរក្សាអត្ថន័យ ខ្លឹមសារ និងគោលដៅនៅដដែល។ តែគប្បីចៀសវាងផងដែរ ចំពោះសំណួរដែលធ្វើឱ្យសិស្ស ឆ្លើយប្រាំដែល។ ធ្វើយ៉ាងនេះសិស្សនឹងចេះគិត ចេះត្រិះរិះ ពិចារណាតាមរបៀបច្នៃប្រឌិតផ្ទាល់ខ្លួន។

- គប្បីយកចិត្តទុកដាក់បំប៉នសិស្សនូវសមត្ថភាពម្ចាស់ការក្នុងការក្តាប់យកចំណេះដឹង ប្រកប ដោយសុចន្ទៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងស្វ័យសិក្សា។ ធ្វើឱ្យសិស្សមានសេចក្តីក្លាហានក្នុង ការត្រិះរិះពិចារណា និងស្មារតីងឿង ឆ្ងល់ក្នុងការគិត តាមលក្ខណៈវិទ្យាសាស្ត្រ។ ការត្រួតពិនិត្យរបស់សាស្ត្រាចារ្យ ទៅជាគ្មានន័យកាលណា សាស្ត្រាចា រ្យ មិនយកចិត្តទុកដាក់សង្កត់ធ្ងន់ទៅលើ ស្មារតីភ្ញាក់រលឹករបស់សិស្សក្នុងការសិក្សា។ កិច្ចការត្រួតពិនិត្យ គឺជាកិច្ចការ មួយដែលមានអត្ថប្រយោជន៍បំផុត នៅក្នុងការពង្រឹងពង្រីកចរិតសកម្មម្ចាស់ការរបស់សិស្ស និងនៅក្នុងបញ្ហា ធានា បានលទ្ធផលល្អក្នុងការបង្រៀន និងក្នុងធាតុពិតជាក់ស្តែង។ ផ្ទុយទៅវិញសិស្សក៏មិនអាច អភិវឌ្ឍឡើងបានដែរ ប្រសិនបើគ្មានស្មារតីភ្ញាក់រលឹកក្នុងការសិក្សា។

- ការជំរុញចរិតភ្ញាក់រលឹក សកម្មម្ចាស់ការរបស់សិស្ស ដើម្បីសម្រេចបានលទ្ធផលល្អ គឺស្ថិតនៅត្រង់ដែលសាស្ត្រាចារ្យ ធានាបាននូវតួនាទីដឹកនាំរបស់ខ្លួន។ បើមិនបានលើកកម្ពស់ សកម្មភាពម្ចាស់ការរបស់ សិស្សនោះ សិស្សនឹងកើតមានផលវិបាក គឺចំណេះដឹងដែលសិស្សក្តាប់បានត្រូវកាត់ផ្តាច់ពីគ្នា ខ្វះប្រព័ន្ធ កម្ម និងខ្វះលំនឹង។ ផ្ទុយទៅវិញ ក្រឹត្យក្រមគរុកោសល្យសង្កត់ធ្ងន់ទៅលើ តួនាទីដឹកនាំរបស់សាស្ត្រាចារ្យ ដែលកំណត់លើតួនាទីសកម្ម ម្ចាស់ការច្នៃប្រឌិត របស់សិស្សនៅក្នុងការសិក្សា។ ដូចនេះ សាស្ត្រាចារ្យត្រូវ ចេះគួបផ្សំយ៉ាងប៉ិនប្រសប់ និងត្រឹមត្រូវនូវតួនាទីរបស់ខ្លួន ជាមួយរបស់សិស្សនៅក្នុងលំនាំនៃការបង្រៀន។ ចង់សម្រេចបានយ៉ាងនេះ ត្រូវយកចិត្តទុកដាក់ធានាបានល្អ នូវចំណងទាក់ទងខាងក្រៅ ខ្លួនសាស្ត្រាចារ្យ (ដើម្បីធានាបាននូវតួនាទី ដឹកនាំរបស់សាស្ត្រាចារ្យ) ជាមួយនឹងចំណងទាក់ទងខាងក្នុងខ្លួន

របស់សិស្ស (ដើម្បីធានាបាននូវសកម្ម ម្ចាស់ការច្នៃប្រឌិតរបស់សិស្ស)។ ធ្វើបានដូចនេះ លំនាំនៃការបង្រៀនប្រាកដជាក្លាយទៅជាសៀគ្វីបិទមួយ ឬជាលំនាំមួយនៅក្នុងការសិក្សារបស់សិស្ស។ សិល្បៈគរុកោសល្យដ៏ប៉ិនប្រសប់របស់សាស្ត្រាចារ្យក្នុងបញ្ហានេះសំខាន់គឺ សាស្ត្រាចារ្យ ត្រូវយល់ដឹងពីភាពម្ចាស់ការ និងសេរីភាព ក្នុងផ្នត់គំនិតរបស់សិស្ស ត្រូវចេះធ្វើឱ្យសិស្សមានមនសិការ ចំពោះស្វ័យដឹកនាំនៅក្នុង លំនាំនៃការបង្រៀន។ ក្រោយមកសិស្សនឹងមានឆន្ទៈ និងសមត្ថភាពសិក្សាពេញមួយជីវិត។ ចំពោះសាស្ត្រាចារ្យ វិញ ដែលមានតួនាទីដ៏សំខាន់នៅក្នុងគោលការណ៍នេះ គប្បីយល់ជ្រួតជ្រាបឱ្យបាន ច្បាស់លាស់ និងស៊ី ជម្រៅ ពីស្មារតីម្ចាស់ការ និងទស្សនៈមហាជននៅក្នុងការងារបង្រៀន និងអប់រំសិស្ស។

## ៥.៤.៥ គោលការណ៍នៃការបង្រៀន ត្រូវធានាឱ្យបាននូវចរិតអព្ភន្តរញាណ

ក/ការបង្រៀនតាមគោលការណ៍នេះ គឺសាស្ត្រាចារ្យត្រូ វធ្វើឱ្យវត្ថុ បាតុភូត ឬរូបភាពរបស់វត្ថុ និងបាតុភូត ណាមួយនោះលេចឡើងចំពោះមុខសិស្សនៅក្នុងលំនាំនៃការទទួលយល់ជ្រួតជ្រាបចំណេះដឹង (ក្តាប់យក សញ្ញាណរូបី)គឺត្រូវធានាបាននូវចំណងទាក់ទងគ្នាទៅវិ ញទៅមករវាងការគិតរូបី (ការគិតតាមរយៈរូបភាព) និងការ គិតអរូបិ (ការគិតតាមរយៈសញ្ញាណ) និងការគិតផ្សារ ភ្ជាប់គ្នារវាងចំណេះដឹង សញ្ចេតនា និងចំណេះ ដឹងវិចារ។ ព្រោះយ៉ាងនេះហើយ បានជាគោលការណ៍នេះ អាចត្រូវបានហៅម្យ៉ាងទៀតថា៖ «គោលការណ៍ គួបផ្សំរូបីយ៍ទៅនឹងអរូបិយ៍ នៅក្នុងលំនាំនៃការបង្រៀន»។

ជនដំបូងបង្អស់ ដែលបានយកមូលដ្ឋាននៃទ្រឹស្តីបញ្ចូលទៅក្នុងគោលការណ៍នេះ ដើម្បីធានាបាននូវចរិតអព្ភន្តរញ្ញាណ គឺលោក កូម៉ិនស្គី។ លោក បានទាមទារឱ្យសាស្ត្រាចារ្យ ត្រូវបង្រៀនដល់សិស្សឱ្យក្តាប់បាននូវចំណេះដឹងដ៏សំខាន់ៗ ដោយប្រើសម្ភារៈនៅក្នុងការបង្រៀន។ នៅក្នុងប្រព័ន្ធវិធីបង្រៀនគ្រប់មុខវិជ្ជាសិក្សាទាំងអស់លោក ប៉េស្តាឡូស៊ី និង អ៊ូជិនស្គី បានរៀបរាប់គ្រប់វិធីសាស្ត្រ និងមធ្យោបាយប្រើអព្ភន្តរញ្ញាណនៅក្នុងការបង្រៀន។ លោក អ៊ូជិនស្គី បានពោលអះអាងថា៖ «ការបង្រៀនដោយប្រើសម្ភារៈមិនត្រឹមតែបណ្តុះបាននូវសញ្ញាណអរូបិយ៍ប៉ុណ្ណោះទេប៉ុន្តែថែមទាំងបណ្តុះបណ្តាលបាននូវរូបភាពជាក់ស្តែង ដែលសិស្សមិនទាន់ដែលបានជួបប្រទះផ្ទាល់នៅក្នុងខួរក្បាលសិស្សទៀតផង»។ លោក អ៊ូជិនស្គី ក៏បានលើកឡើងផងដែរពីភាពចាំបាច់ ក្នុងការគួបផ្សំគ្នារវាងការបង្រៀន ដោយប្រើសម្ភារៈ ជាមួយនឹងសកម្មភាពនៃការគិតរបស់សិស្ស៖ «ឥន្ទ្រីយារម្មណ៍ គឺជាមូលដ្ឋាននៃការបង្ហាត់បង្រៀនសិស្ស។ ការបង្រៀនត្រូវពឹងផ្អែកលើមូលដ្ឋាននៃការត្រិះរិះពិចារណារបស់សិស្ស»។ក្នុងបញ្ហានេះត្រូវចៀសវាងទស្សនៈ ដែលយកចិត្តទុកដាក់តែលើផ្នែកទ្រឹស្តី។គោលការណ៍នេះចង់និយាយថាលំនាំនៃការបង្រៀនក៏ត្រូវចាប់ ផ្តើមចេញពីរូបី និងពីអព្ភន្តរញ្ញាណដែរ។ សាស្ត្រាចារ្យម្នាក់ៗ គប្បីយល់ឱ្យបានច្បាស់លាស់ក្នុងការអនុវត្ត ខ្លឹមសារជាមូលដ្ឋានរបស់គោលការណ៍នេះពោលគឺត្រូវធានាបាននូវចំណងទាក់ទងគ្នារវាងហេតុការណ៍ របស់បាតុភូតជាក់ស្តែងជាមួយនឹងសញ្ញាណអរូបិយ៍។ ដូចនេះ នៅក្នុងលំនាំនៃការបង្រៀន ក៏អាចចាប់ ផ្តើមចេញពីអរូបិ (ភាពទូទៅ) ទៅរូបី (ភាពដោយឡែក) ពីទ្រឹស្តី និងពីប្រព័ន្ធសញ្ញាណដែលបានសិក្សា រួចមកហើយ ទៅបញ្ហាជាក់ស្តែងដែរ។ រីឯសិស្សវិញ ក៏អាចយល់ជ្រួតជ្រាបចំណេះដឹងតាំងពីសំដីរបស់ សាស្ត្រាចារ្យប្រកបដោយរូបារម្មណ៍ និងខ្លឹមសារអរូបិយ៍ផងដែរ។

ខ/ទ្រឹស្តីចំណេះដឹងនេះបម្រើឱ្យគោលដៅទាំងមូលរបស់សាលារៀនមធ្យមសិក្សាចំណេះទូទៅយក៏បម្រើ ឱ្យការអភិវឌ្ឍខាងផ្នែកបញ្ញាផងដែរ។ បម្រើបម្រាស់ចរិតអព្ភន្តរញ្ញាណ នៅក្នុងសាលារៀននឹងត្រូវបានលើកកម្ពស់ នៅក្នុងទំនាញសេចក្តីសន្និដ្ឋានសរុបរបស់សិស្ស ហើយបង្កើតបានជាចំណង់ចំណូលចិត្តរបស់

សិស្សនៅក្នុងការ សិក្សាយ៉ាងសកម្ម និងភ្ញាក់រលឹកខ្ពស់។ ពឹងផ្អែកលើចរិតអព្ភន្តរញាណនេះ ការបង្រៀន ក៏ត្រូវបានបើកទូលាយឱ្យ ងាយយល់ ហើយចំណេះដឹង និងសញ្ញាណអរូបិយ៍ទាំងឡាយត្រូវសិស្សក្តាប់បានយ៉ាងច្បាស់លាស់ ហើយមាន មូលដ្ឋានត្រឹមត្រូវ មាំមួនផង។ ចរិតអព្ភន្តរញាណ នៅក្នុងការបង្រៀនជួយសម្រួលដល់ចំណងទាក់ទងគ្នារវាងទ្រឹស្តី និងការប្រតិបត្តិ ហើយនឹងជីវភាពរស់នៅយ៉ាងត្រឹមត្រូវ។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សាស្ត្រាចារ្យមិនត្រូវ ប្រើសិទ្ធិអំណាចរំលោភគោលការណ៍នេះឡើយ។ចរិតអព្ភន្តរញាណដ៏រស់រវើក សំដៅជួយឱ្យការគិតអរូបិរបស់ សិស្សអភិវឌ្ឍឡើងឥតឈប់ឈរ។ ដើម្បីអនុវត្តឱ្យបានល្អនូវគោលការណ៍នេះ សាស្ត្រាចារ្យ គប្បីយកចិត្តទុក ដាក់ដល់មូលដ្ឋាននៃគោលការណ៍ធានាបាននូវចរិតអព្ភន្តរញាណគឺប្រព័ន្ធសញ្ញាការទី១ ហើយដែលក្នុង នេះប្រព័ន្ធសញ្ញាការទី២ សង្កត់ខ្លាំង ទៅលើតួនាទីនៃការរៀបចំផែនការឱ្យបានត្រឹមត្រូវ។ សំដីរបស់ សាស្ត្រាចារ្យ សំខាន់ណាស់ គឺដឹកនាំសិស្ស ឱ្យយកចិត្តទុកដាក់ពិនិត្យសង្កេតទៅលើបញ្ហាសិក្សាដ៏សំខាន់ៗ។ នៅ ក្នុងលំនាំនៃការបង្រៀនពេលប្រើប្រាស់មធ្យោបាយអព្ភន្តរញាណ សាស្ត្រាចារ្យ គប្បីធ្វើឱ្យការពិនិត្យសង្កេតរបស់ សិស្សស្តែងឡើងដោយឈរលើមូលដ្ឋាននៃបញ្ហាដែលកើតឡើង នៅក្នុងស្មារតីរបស់សិស្ស ពោលគឺ ចលនា នៃការគិតដ៏សកម្មរបស់សិស្សនេះឯង។ ចង់សម្រេចបានយ៉ាងនេះ សាស្ត្រាចារ្យ ត្រូវចេះធ្វើអត្ថាធិប្បាយ ឱ្យបានយ៉ាងប៉ិនប្រសប់ទៅលើសម្ភារៈអព្ភន្តរញាណ។សម្ភារៈអព្ភន្តរញាណលេចឡើងឱ្យឃើញច្បាស់ ជាបណ្តើរៗនៅពេលដែលសាស្ត្រាចារ្យ ធ្វើអត្ថាធិប្បាយពន្យល់ទៅលើខ្លឹមសារនៃមេរៀន។

សាស្ត្រាចារ្យ អាចប្រើប្រាស់រូបភាពអព្ភន្តរញាណនៅក្នុងលំនាំនៃការបង្រៀនដូចតទៅនេះ៖

- ឱ្យសិស្សពិនិត្យសង្កេតដោយផ្ទាល់ទៅលើវត្ថុ ឬបាតុភូតពិតប្រាកដ នៅក្នុងមជ្ឈដ្ឋានជាតិរបស់វា នៅក្នុងថ្នាក់រៀន ឬក្រៅថ្នាក់រៀន
    - ✓ បម្រើបម្រាស់មធ្យោបាយអព្ភន្តរញាណគ្រប់ប្រភេទដូចជា តារាងរូបភាព គំនូរ រូបថត គំនូរលើក្តារខៀន គំនូរ លើក្រដាស គំនូសតាង ក្រាភិច... ដើម្បីស្តែងចេញនូវចំណងទាក់ទងគ្នាខាងទំហំ។

✓ បម្រើបម្រាស់វាចារសម្បូរទៅដោយរូបារម្មណ៍ ដើម្បីជួយសិស្សឱ្យពឹងផ្អែក ទៅលើបទពិសោធន៍ដែលខ្លួន មានរួចមកហើយ។ សិស្សអាចនឹកស្មានទៅដល់វត្ថុ និងបាតុភូត ដែលគ្រូបានធ្វើការពិពណ៌នា។

ក្រៅពីនេះសាស្ត្រាចារ្យត្រូវជ្រើសរើស និងរៀបចំឱ្យសិស្សបានសិក្សាក្រៅថ្នាក់រៀន គឺចូលរួមក្នុងមូលដ្ឋាន ផលិតកម្ម។ មជ្ឈដ្ឋានធម្មជាតិ គឺជាមូលដ្ឋាននៃអព្ភន្តរញាណដ៏រស់រវើកហើយគ្រប់គ្រាន់។ មជ្ឈដ្ឋានធម្ម ជាតិ គឺជាទុនផ្ទុកដោយវត្ថុ និងបាតុភូតដ៏សម្បូរបែប ហើយដែលមានអត្ថិភាព និងបន្លាស់ប្តូរឥតឈប់ឈរ។ កេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ ត្រូវបានយកមកប្រើប្រាស់ឱ្យបានត្រឹមត្រូវ ហើយក៏រួមចំណែក ដល់ការលើកកម្ពស់គុណសម្បត្តិនៃការសិក្សារបស់សិស្សដែរ។ការអនុវត្តបានល្អនូវគោលការណ៍ធានាបាន ចរិតអព្ភន្តរញាណនេះ ជះឥទ្ធិពលយ៉ាងខ្លាំងដល់គោលការណ៍ ឯទៀត។

### ៥.៤.៦.គោលការណ៍នៃការបង្រៀនត្រូវធានាបាននូវការពង្រឹងចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់

គោលការណ៍នេះ ធានាបាននូវភាពពង្រឹងចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់របស់សិស្ស ហើយទាមទារឱ្យសាស្ត្រាចារ្យត្រូវរៀបចំលំនាំនៃការបង្រៀនឱ្យបានល្អ ហើយសមស្របទៅនឹងចំណេះ ដឹង

ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស ដើម្បីឱ្យសិស្សទទួលយល់ដឹងបាន ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរឹងមាំ ច្បាស់លាស់។ ចំណេះដឹងទាំងនោះ ដែលត្រូវបានបង្រៀនរួចមកហើយ តម្រូវឱ្យសិស្សនឹកឃើញឡើងវិញ និងអនុវត្តបានក្នុងការបន្តដំណោះស្រាយ ដើម្បីទទួលបាននូវលទ្ធផលល្អលើភារកិច្ច ឬកិច្ចការប្រតិបត្តិចំណេះដឹងនៅក្នុងស្ថានភាពបញ្ហា ដែលមានកម្រិតផ្សេងៗគ្នា។

លោក កូមិនស្គី (១៥៩២-១៦៧០) បានលើកឡើង ពីមូលដ្ឋានរបស់គោលការណ៍ ដែលជានាបាននូវចរិតរឹងមាំក្នុងការក្តាប់បានចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់របស់សិស្ស។ ចរិតរឹង មាំនេះមានតួនាទីសំខាន់ណាស់។ តម្រូវការ តែងតែមានមូលហេតុច្បាស់លាស់ ។ ដើមឈើ ដែលត្រូវ ចិញ្ចឹមខ្លួនដោយឬស ឬជំរ បានរីកដុះដាលធំឡើងជាបណ្តើរៗ រួចកើតមានផ្លែផ្កាដែលលទ្ធផលចុងក្រោយ គឺផ្លែផ្កានេះឯងដែលនឹងបានទៅជាតំណពូជ។ក្រោយលោក កូមិនស្គី មានគរុវិទូជឿនលឿនជាច្រើនបាន ធ្វើឱ្យគោលការណ៍នេះកាន់តែសុក្រិតឡើងថែមទៀត។ ស្នាដៃនៃការសិក្សាស្រាវជ្រាវជាច្រើន កាន់តែមាន អត្ថន័យក៏សកម្មនៅក្នុងលំនាំនៃការបង្រៀនសព្វថ្ងៃនេះ។ ការចងចាំ ការយល់ច្បាស់លាស់ គឺជាមូលដ្ឋាន នៃការធានាបាននូវការពង្រឹងចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់។ ការចងចាំសម្រេចបានដោយ ការយល់ច្បាស់ពីអត្ថន័យ ខ្លឹមសារ និងការគួបផ្សំគ្នារវាងលំនឹកតាមបែបមេកានិច ឬលំនឹកដ៏សមហេតុផល។ សព្វថ្ងៃនេះ ទំហំដ៏ធំមាំនៃចំណេះដឹងដ៏ទំនើបៗ ដែលបានផ្សព្វផ្សាយត្រូវបាន មនុស្សបង្កើតបានជាគ្រឿងម៉ាស៊ីនសម្រាប់ចងចាំជាច្រើនប្រកបដោយប្រសិទ្ធភាពខ្ពស់។ ដូចនេះហើយ បានជាការចងចាំតាមបែបម៉ាស៊ីនត្រូវបានបន្ថយ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ការចងចាំតាមបែប ម៉ាស៊ីនមិនអាចផ្លាស់ប្តូរបានទាំងស្រុងឱ្យមនុស្សបានឡើយ។ដូចនេះបញ្ហាពង្រឹងចំណេះដឹងត្រូវបានគេ យកចិត្តទុកដាក់យ៉ាងខ្លាំង។

- ការក្តាប់បាននូវចំណេះដឹងដ៏រឹងមាំ គឺជាលក្ខខ័ណ្ឌមួយដ៏ចាំបាច់ ដើម្បីឱ្យការសិក្សារបស់សិស្ស អភិវឌ្ឍឡើងបាន។ បើសិស្ស រៀនឯមុខភ្លេចឯក្រោយ នោះសិស្សក៏មិនអាចប្រមូលផ្តុំទុននៃចំណេះដឹង ហើយក៏មិនអាចក្តាប់បញ្ហាថ្មី នៅក្នុងការសិក្សាបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ចំណេះដឹងថ្មី ក៏ត្រូវតែឈរលើមូលដ្ឋាននៃចំណេះដឹងចាស់ដែរ។ក្តាប់ចំណេះដឹងបានរឹងមាំ មានន័យថាក្តាប់បាននូវលក្ខខណ្ឌមួយដ៏សំខាន់បំផុតដើម្បីចូលបម្រើការងារក្នុងថ្ងៃអនាគតឱ្យបានល្អ។រីឯចំណេះដឹងដែលបានសិក្សានៅក្នុងសាលារៀនចំណេះទូទៅសុទ្ធតែជាចំណេះដឹងជាមូលដ្ឋានចាំបាច់ ឱ្យដល់ផ្នែកនីមួយៗនៃសកម្មភាពប្រតិបត្តិ។បើសាស្ត្រាចារ្យនិងសិស្សមិនបានយកចិត្តទុកដាក់ដល់គោលដៅនិងសំណូមពរក្នុង ការពង្រឹងចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ នោះនឹងឈានដល់លទ្ធផលប្រកបដោយគ្រោះថ្នាក់គឺៈ

- សិស្សមានការច្របូកច្របល់ក្នុងការយល់ជ្រួតជ្រាប និងក្តាប់បានចំណេះដឹង
  - ✓ សិស្សធ្លាក់ចុះខ្សោយក្នុងការសិក្សា
  - ✓ សិស្សមិនអាចសិក្សាតាមកម្មវិធីសិក្សាបានទាន់ពេលវេលា ។ល។

- ដើម្បីអនុវត្តគោលការណ៍នេះឱ្យបានល្អ សាស្ត្រាចារ្យត្រូវយកចិត្តទុកដាក់ដល់ៈធ្វើឱ្យសិស្សអាចក្តាប់បានចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ដ៏រឹងមាំជាក់ស្តែង ដូចជាៈ

- ✓ ទូន្មានសិស្សឱ្យខិតខំសិក្សាផ្ទាល់ខ្លួន
- ✓ ណែនាំសិស្សឱ្យពិនិត្យសង្កេត ចាប់អារម្មណ៍ នឹកគិត និងពិចារណាឱ្យបានសមហេតុផលទៅលើវត្ថុបាតុភូត ហេតុការណ៍ដែលត្រូវបង្រៀន។

✓ ពង្រឹងសមត្ថភាពសិស្ស ក្នុងការអនុវត្តចំណេះដឹង
✓ ដាក់លំហាត់ សំណួរ ឬកិច្ចការត្រួតពិនិត្យឱ្យសមនឹងសមត្ថភាពសិស្ស
✓ លំហាត់ សំណួរ កិច្ចការត្រួតពិនិត្យ ដែលធ្វើបានច្រើនដង និងទៀងទាត់តាមផែនការកំណត់កាន់តែល្អ។

សាស្ត្រាចារ្យម្នាក់ៗ ត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាព នូវគោលការណ៍នៃការបង្រៀនផ្សេងទៀត ជាពិសេស ក្នុងគោលការណ៍នីមួយៗ ត្រូវយកចិត្តទុកដាក់ធ្វើឱ្យសិស្សមានចរិតសកម្ម និងភ្ញាក់រលឹកខ្ពស់ក្នុង ការក្តាប់យកចំណេះដឹង។ សាស្ត្រាចារ្យ ត្រូវបកស្រាយពន្យល់ទៅលើចំណេះដឹង ដែលលើកយកមកបង្រៀនឱ្យបានច្បាស់លាស់ ហើយមានលក្ខណៈផ្សារភ្ជាប់គ្នាជាប្រព័ន្ធកម្មនៅក្នុងការអនុវត្ត។

- ការពង្រឹងចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ ត្រូវបានដំណើរការនៅក្នុងលំនាំនៃការបង្រៀន។

នៅដើមឆ្នាំសិក្សានីមួយៗសាស្ត្រាចារ្យម្នាក់ៗត្រូវរៀបចំការសិក្សាសារឡើងវិញ ទៅលើកម្មវិធីសិក្សាពីឆ្នាំមុនដើម្បីឱ្យសិស្សរំលឹកនិងក្តាប់សារឡើងវិញនូវប្រព័ន្ធនៃកម្មវិធីសិក្សានិងសញ្ញាណសំខាន់ជាមូលដ្ឋានមុននឹងចាប់ផ្តើមសិក្សាកម្មវិធីសិក្សាតាមឆ្នាំសិក្សាថ្មី។ក្នុងមួយម៉ោងសិក្សានៅក្នុងថ្នាក់រៀន សាស្ត្រាចារ្យ ត្រូវចេះគួបផ្សំឱ្យបានជិតស្និទ្ធ និងយ៉ាងប៉ិនប្រសប់ទៅលើដំណាក់កាលនីមួយៗ នៅក្នុង បំណកស្រាយពន្យល់មេរៀនដូចជា ត្រួតពិនិត្យ មេរៀនចាស់ ពង្រឹងមេរៀនថ្មី ដាក់លំហាត់ ឬកិច្ចការ ឱ្យសិស្សអនុវត្ត។ ការរំលឹកផ្ទួនៗ នូវមេរៀនដែលបានរៀនរួចមកហើយ គឺជាវិធីមួយដ៏សំខាន់បំផុតក្នុង ការពង្រឹងចំណេះដឹង។ប៉ុន្តែសាស្ត្រាចារ្យ ត្រូវប៉ិនប្រសប់ និងឈ្លាសវៃក្នុងការធ្វើការរំលឹកឡើងវិញនេះ ឱ្យបានទាន់ពេលវេលា និងឱ្យបានត្រឹមត្រូវច្បាស់លាស់បំផុត តាមរូបភាពថ្មី និងក្រោមទិដ្ឋភាពថ្មី។

កិច្ចការត្រួតពិនិត្យ ក៏គឺជាល្បិចមួយដ៏ល្អ ក្នុងការពង្រឹងចំណេះដឹង។ កិច្ចការត្រួតពិនិត្យ ជួយសិស្សឱ្យខិតខំសិក្សាយ៉ាងសកម្ម និងចងចាំបានយ៉ាងច្បាស់លាស់ទៅលើចំណេះដឹងដែលបានរៀនរួច មកហើយ ហើយសិស្សអាចវាយតម្លៃសបានដោយខ្លួនឯង ទៅលើការចងចាំចំណេះដឹងនោះ។

ការសិក្សាសារឡើងវិញទូទៅ ការសិក្សាសរុប ចំណុចសំខាន់ៗនៃមេរៀន ការធ្វើទូទៅកម្ម ប្រព័ន្ធកម្មនៅពេលបង្រៀនចប់ជំពូកមេរៀននីមួយៗនៅបំណាច់ខែ បំណាច់ត្រីមាស ឬនៅពេលចប់មុខវិជ្ជាសិក្សានីមួយៗ ជួយសិស្សឱ្យក្តាប់បាននូវចំណេះដឹងទាំងឡាយដ៏ច្បាស់លាស់រឹងមាំ ហើយរង្វើលៗពីគ្នា តែមានលក្ខណៈផ្សារភ្ជាប់គ្នា ជាប្រព័ន្ធកម្មនៃជំពូកមេរៀនទាំងមូល។ ការសិក្សាសារឡើងវិញនេះ នឹងធ្វើឱ្យចំណេះដឹងរបស់សិស្ស ត្រូវបានពង្រឹងយ៉ាងមាំផង និងលើកកម្ពស់បានផង។

- បំពាក់បំប៉នឱ្យដល់សិស្សនូវស្មារតីភ្ញាក់រលឹក និងសុធន្ទៈក្នុងការសិក្សា និងក្នុងវិធីសិក្សា សារឡើងវិញដូចជា៖

✓ នាំសិស្សឱ្យធ្វើប្រព័ន្ធកម្ម ទៅលើចំណេះដឹងដែលបានរៀនរួចមកហើយ
✓ ឱ្យសិស្សយកចិត្តទុកដាក់ ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវតាមគំនិតនៃការចងចាំទាំងពីរ គឺរូបភាពនៃការចងចាំប្រកបដោយអត្ថន័យ និងរូបភាពនៃការចងចាំតាមបែបមេកានិច។

សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ដល់ការអភិវឌ្ឍខាងផ្នែកលំនឹករបស់សិស្ស ហើយកំណត់ឱ្យបានច្បាស់នូវឯកសារដែលត្រូវចងចាំ និងត្រូវរៀនបានចេះស្ទាត់ដូចជា មេរៀនដែលចាំបាច់ក្នុង ការយល់ស៊ីជម្រៅមេរៀនដែលត្រូវមើល ឯកសារដែលត្រូវមើលបន្ថែម ឬវចនានុក្រម។

## ៥.៤.៧.គោលការណ៍នៃការបង្រៀនត្រូវយកចិត្តទុកដាក់ដល់ភាពដោយឡែករបស់សិស្សម្នាក់ៗ

ក/យកចិត្តទុកដាក់ដល់ភាពដោយឡែកនៃកម្មវត្ថុបង្រៀនគឺបម្រើបម្រាស់និងជម្រើសខ្លឹមសារវិធី និងរូបភាពចាត់តាំងលំនាំនៃការបង្រៀនឱ្យបានសមស្របទៅនឹងកម្រិតយល់ដឹងកម្រិតអភិវឌ្ឍ និងបទពិសោធន៍ដែលសិស្សមានរួចមកហើយ ហើយម្យ៉ាងទៀត ឈរលើមូលដ្ឋាននេះ យកចិត្តទុកដាក់សមូហភាពសិស្សក្នុង ថ្នាក់ដូចជា៖

- យកចិត្តទុកដាក់ភាពដោយឡែកចំពោះសិស្សម្នាក់ៗ
- ចេះគួបផ្សំការខិតខំប្រឹងប្រែងរបស់សិស្សម្នាក់ៗ ជាមួយនឹងការជួយគ្នាទៅវិញទៅមក នៅក្នុងរង្វង់សមូហភាពសិស្ស។

ខ/យកចិត្តទុកដាក់ដល់លក្ខណៈពិសេសនៃវ័យសិក្សា និងអត្តចរិតរបស់សិស្សម្នាក់ៗ

– សាស្ត្រាចារ្យ យកចិត្តទុកដាក់ដល់ភាពដោយឡែក ក្នុងកម្មវត្ថុសិក្សាដូចដែលបានពោលខាងលើ គឺបំណកស្រាយពន្យល់មេរៀន ត្រូវឱ្យបានច្បាស់លាស់ ហើយសមស្របទៅនឹងកម្រិតយល់ដឹងរបស់ សមូហភាពសិស្ស និងសិស្សម្នាក់ៗ ហើយពឹងផ្អែកលើចំណុចនេះ ធ្វើឱ្យសិស្សម្នាក់ៗ ទទួលបានលទ្ធផលល្អ ប្រសើរក្នុងការសិក្សា។ យើងជាសាស្ត្រាចារ្យ គប្បីយល់ដឹង និងស៊ីជម្រៅទៅលើអត្តចរិត និងចំណង់ ចំណូលចិត្តសិស្សម្នាក់ៗ។ សិស្សម្នាក់ៗ តែងតែមានអត្តចរិត សុខភាព ទំនោរ សមត្ថភាព កិរិយា មាយាទឬកពារខុសប្លែកគ្នា។នៅក្នុងលំនាំនៃការបង្រៀនចាំបាច់ត្រូវយកចិត្តទុកដាក់ដល់ចំណុចពិសេស ទាំងនេះរបស់សិស្សម្នាក់ៗ។ ការបោះបង់ចោល ឬការមិនបានយកចិត្តទុកដាក់ការថែរក្សាសិស្សជំពូកនេះគឺ ជាបុព្វហេតុ ឬជាមូលដ្ឋានដែលធ្វើឱ្យសមូហភាពសិស្សអន់ថយ ឥតសណ្តាប់ធ្នាប់ កាន់តែចុះខ្សោយ ទៅពីមួយថ្ងៃទៅមួយថ្ងៃ។ ហើយដោយសារមូលហេតុនេះ ភាពលំបាកក្នុងការបង្រៀន និងអប់រំសិស្ស ក៏កើតមានឡើង។

- ការយកចិត្តទុកដាក់ដល់ភាពដោយឡែករបស់សិស្សម្នាក់ៗ នៅក្នុងលំនាំនៃការបង្រៀន គឺស្តែងចេញឱ្យឃើញច្បាស់នូវភក្តីភាពរបស់សាស្ត្រាចារ្យចំពោះសិស្ស ហើយនោះ ក៏គឺជាការដែលស្តែងឱ្យឃើញច្បាស់នូវភាពដ៏ប្រសើរថ្លៃថ្លារបស់សាស្ត្រាចារ្យផងដែរ៖ «អ្វីៗទាំងអស់ ដើម្បីសិស្សជាទីស្រលាញ់»។

លោក Howard Gardner បានអះអាងថាបញ្ញារបស់មនុស្សម្នាក់ៗរីកដុះដាល់ពុំស្មើគ្នាទេ។ ឧទាហរណ៍៖ សិស្សខ្លះពូកែខាងវោហារបានជាងកម្លាំងកាយ ពោលគឺបញ្ញាផ្នែកខាងពាក្យសម្តី និងភាសាខ្លាំងជាងបញ្ញាខាងរាងកាយ និងចលនារាងកាយ។ មនុស្សម្នាក់ៗអាចមានសមត្ថភាពពង្រឹងពង្រីកពហុបញ្ញារបស់គេបាន។ ហេតុនេះហើយបានជាអ្នកអប់រំជឿជាក់ គេអាចបង្រៀន និងអប់រំសិស្សឱ្យពង្រឹងពង្រីកបញ្ញារបស់ពួកគេ។

១. វិធីបង្រៀនដោយប្រើពហុបញ្ញារបស់សិស្ស៖

វិធីបង្រៀនដោយសិស្សប្រើពហុបញ្ញារបស់ពួកគេមានបួន ដំណាក់កាល៖

ក/ ដំណាក់កាលដាស់បញ្ញា

ខ/ ដំណាក់កាលពង្រឹងបញ្ញា

គ/ ដំណាក់កាលបង្រៀន

ឃ/ ដំណាក់កាលយកបញ្ញាទៅប្រើប្រាស់ក្នុងជីវភាពរស់នៅ

ក/ ដំណាក់កាលទី១៖ ការដាស់បញ្ញា

គ្រូជឿថាសិស្សម្នាក់ៗមានពហុបញ្ញា។ គ្រូត្រូវប្រើបច្ចេកទេសផ្សេងៗដើម្បីដាស់បញ្ញានោះដោយឱ្យសិស្សប្រុងប្រៀបខ្លួនដើម្បីធ្វើសកម្មភាពដែលត្រូវបានគ្រោងទុកក្នុងមេរៀន។

ដូច្នេះគ្រូត្រូវប្រើវិធីសាស្ត្របង្រៀនផ្សេងៗដើម្បីដាស់អារម្មណ៍ខួរក្បាលរាងកាយ និងចលនារាងកាយរបស់សិស្ស។

ខ/ ដំណាក់កាលទី២៖ ការពង្រឹងបញ្ញា

គ្រូត្រូវដឹងថា តើបញ្ញាប្រភេទនិមួយៗតម្រូវ "របៀបបង្រៀនបែបណា" ដើម្បីឆ្លើយតបបានទៅនឹង

មុខងារ និងសកម្មភាពរបស់បញ្ញានោះ? ឧទាហរណ៍ គ្រូពុំគួរចាប់ផ្តើមមេរៀនដោយឱ្យសិស្សដែលមានបញ្ញាខាងសំដី និងភាសាដីកដីដាំកូនឈើ មុនពេលដែលឱ្យកូនសិស្សនោះអានអត្ថបទអំពីរបៀបដាំកូនឈើឡើយ។ ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលបញ្ញាណាមួយ ទៅតាមគំរោងមេរៀនរបស់ខ្លួន គ្រូត្រូវចេះ និងយល់ឱ្យបានច្បាស់លាស់ជាមុនសិននូវ "ភាសារបស់បញ្ញា" បំនិនប្រសប់ និងសម្បទាផ្សេងៗសំរាប់យកមកប្រើក្នុងការអប់រំបញ្ញានីមួយៗ។ឧទាហរណ៍៖ ភាសារបស់បញ្ញាផ្នែកខាងរាងកាយ និងចលនារាងកាយគឺចលនាដែលទាក់ទងទៅនឹងរាងកាយដូចជា រត់ ធ្វើពិសោធន៍....ពុំមែនពាក្យសម្តី ឬសន្ទរកថាទេ។

គ/ ដំណាក់កាលទី៣៖ ការបង្រៀន

គ្រូត្រូវបង្រៀនសិស្សអំពីខ្លឹមសារមេរៀនទៅតាមសកម្មភាពផ្សេងៗដែលបញ្ញានីមួយៗអាចមានសមត្ថភាពអភិវឌ្ឍបាន។ លោកបានសន្និដ្ឋានពីរយ៉ាងថា៖

យើងអាចបង្រៀនសិស្សឱ្យកាន់តែមានប្រាជ្ញាឡើងតាមមធ្យោបាយប្រើបញ្ញាច្រើនយ៉ាងរួមគ្នាដូចជា ប្រើបញ្ញាផ្នែកខាងសំដីភាសាផង ផ្នែកខាងចិត្តវិទ្យា គណិតវិទ្យាផង និងបញ្ញាតូរ្យតន្ត្រីចង្វាក់ចុងជួនផង។

យើងអាចប្រើវិធីសាស្ត្របង្រៀនបែបណាក៏បានដែរឱ្យតែសិស្សរៀនតាមពហុបញ្ញារបស់គេ។

ឃ/ ដំណាក់កាលទី៤៖ យកបញ្ញាទៅប្រើប្រាស់ក្នុងជីវភាពរស់នៅ

គ្រូត្រូវបង្រៀនសិស្សគ្រប់គ្នាឱ្យចេះ៖

- ប្រើប្រាស់គ្រប់បញ្ញាទាំងអស់
- ដោះស្រាយបញ្ហាទាំងឡាយដោយខ្លួនឯង
- ប្រឈមមុខនឹងការលំបាក។

## សំណួរ

1. ហេតុអ្វីសាលារៀនគួរបង្រៀនសិស្សឲ្យមានការគិតកម្រិតខ្ពស់ និងការដោះស្រាយបញ្ហា?
2. តើអ្នកមានការគិតលំដាប់ខ្ពស់មានលក្ខណៈដូចម្តេច?
3. ដើម្បីឲ្យអំណះអំណាងមួយទទួលបានជោគជ័យ តើត្រូវពឹងផ្អែកលើអ្វីខ្លះ។
4. តើបញ្ញាជាអ្វី?
5. តាមទ្រឹស្តីពហុបញ្ញាតើបញ្ញាមានប៉ុន្មានប្រភេទ?អ្វីខ្លះ?ចូរពន្យល់។
6. តើគោលការណ៍ទូទៅនៃការអភិវឌ្ឍពុទ្ធិមានប៉ុន្មាន? អ្វីខ្លះ?
7. ចូរបង្ហាញពីមុខងាររបស់អឌ្ឍគោលខួរក្បាលឱ្យបានច្បាស់លាស់។
8. តើទ្រឹស្តីបញ្ញា Triarchic របស់លោក Sternberg ផ្តោតលើទិដ្ឋិភាពអ្វីខ្លះ? ចូរបកស្រាយ។
9. យោងតាមទ្រឹស្តីពហុបញ្ញា និងមុខងាររបស់ខួរក្បាល តើគ្រូបង្រៀនត្រូវបង្រៀនដូចម្តេចដើម្បីឱ្យសិស្សមានបញ្ញាល្អ?

**ឯកសារយោង**

-Educational Psychology 2019

-Think Smarter

-Critical Thinking to Improve Problem-Solving and Decision-Making Skills By Michael Kallet, Mike Kallet · 2014

## ជំពូកទី III

## មេរៀនទី៧ ការគ្រប់គ្រងថ្នាក់រៀន ( Classroom Management )

### ៧.១. វត្ថុបំណងមេរៀន

នៅចុងបញ្ចប់នៃមេរៀននេះ គរុនិស្សិតនឹងមានសមត្ថភាព៖

- កំណត់បានពីគោលដៅសំខាន់ៗក្នុងការគ្រប់គ្រងថ្នាក់រៀន
- រៀបចំនិតិវិធី និងរក្សាបាននូវបរិយាកាសសិក្សាជាវិជ្ជមាននៅក្នុងថ្នាក់រៀន និងមានទំនាក់ទំនងល្អជាមួយអ្នកជាប់ពាក់ព័ន្ធ
- ស្វែងរកនិតិវិធីដើម្បីការពារ គ្រប់គ្រង និងដោះស្រាយបញ្ហាចំពោះសិស្សដែលមានអាកប្បកិរិយាមិនសមរម្យ
- ប្រើប្រាស់យុទ្ធវិធី និងបទពិសោធទាំងនេះទៅអនុវត្តក្នុងការបង្រៀនជាក់ស្តែង។

### ៧.២. គោលដៅនៃការគ្រប់គ្រងថ្នាក់រៀន

ការគ្រប់គ្រងថ្នាក់រៀនគឺ ជាពាក្យដែលគ្រូប្រើដើម្បីពិពណ៌នាអំពីដំណើរការដើម្បីធានាថា មេរៀនក្នុងថ្នាក់ដំណើរការដោយរលូន ដោយគ្មានអាកប្បកិរិយារំខានពីសិស្សដែលប៉ះពាល់ដល់ការបង្រៀន និងរៀន។ ពាក្យនេះក៏បង្កប់នូវការការពារអាកប្បកិរិយារំខានទុកជាមុន ព្រមទាំងការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពបន្ទាប់ពីវាកើតឡើង។ ការគ្រប់គ្រងថ្នាក់រៀនរួមមានសកម្មភាពទាំងអស់ដែលគ្រូធ្វើដើម្បីបង្កើតបរិយាកាស គាំទ្រសកម្មភាពរៀនសូត្រ ការគ្រប់គ្រងខ្លួនឯង សង្គម និងការអភិវឌ្ឍន៍ផ្លូវចិត្តផងដែរ។ គោលបំណងនៃការគ្រប់គ្រងថ្នាក់រៀនគឺ ដើម្បីរក្សាបរិយាកាសសិក្សាប្រកបដោយផលិតភាព និងវិជ្ជមាន។

គោលដៅនៃការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពគឺ ត្រូវធ្វើឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការសិក្សា ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការប្រើប្រាស់ពេលវេលា ឱ្យសិស្សចូលរួមយ៉ាងសកម្ម និងត្រូវប្រាកដថា ការចូលរួម រចនាសម្ព័ន្ធ គឺច្បាស់លាស់ ជាក់ស្តែង និងជាប់លាប់ រួមនិងការលើកទឹកចិត្តសិស្សឱ្យចេះគ្រប់គ្រងខ្លួនឯង និងការទទួលខុសត្រូវផងដែរ។

## ៧.៣. ការបង្កើតបរិយាកាសសិក្សាវិជ្ជមាន

ពេលខ្លះសិស្សក្លាយទៅជាអ្នករំខានគេ ដោយសារតែការងារដែលបានកំណត់ គឺស្មុគស្មាញ និងពិបាកពេក។ សិស្សដែលធុញទ្រាន់នឹងមេរៀនក៏ដោយសារកម្រិតសមត្ថភាពរបស់ពួកគេស្ថិតនៅទាបពេក។ ដូច្នេះគេអាចស្វែងរកសកម្មភាពផ្សេងៗគួរឱ្យរំភើបដើម្បីបំពេញពេលវេលារបស់ពួកគេ។

គ្រូបង្រៀនត្រូវតែ ការពារបញ្ហាវិន័យ ដើម្បីឱ្យពួកគេខិតខំប្រឹងប្រែង និងលើកទឹកចិត្តពួកគេឱ្យចូលរួម។ សិស្សដែលចូលរួមក្នុងការសិក្សាជាធម្មតាមិនជាប់ពាក់ព័ន្ធនឹងការប៉ះទង្គិចជាមួយគ្រូ ឬអ្នកផ្សេងទៀតឡើយ។ គ្រូក៏ត្រូវមានផែនការសម្រាប់ការលើកទឹកចិត្តសិស្ស និងជាជំហានឆ្ពោះទៅរកការទប់ស្កាត់បញ្ហាផងដែរ។ ហេតុដូចនេះ គ្រូបង្រៀនគួរតែរៀបចំនិតិវិធី ឬច្បាប់ទម្លាប់មួយចំនួនដើម្បីការពារនិងគ្រប់គ្រងសិស្សដែលមិនអាកប្បកិរិយាមិនសមរម្យដូចជា៖

1) **ទម្លាប់ និងនីតិវិធី៖**

- តើសម្ភារៈ និងកិច្ចការនឹងត្រូវចែកចាយយ៉ាងដូចម្តេច? ហើយតើការប្រមូលមកវិញបានដោយរបៀបណា?
- តើសិស្សអាចចេញពីបន្ទប់ក្រោមលក្ខខណ្ឌអ្វីខ្លះ?
- តើចំណាត់ថ្នាក់នឹងត្រូវបានកំណត់យ៉ាងដូចម្តេច?
- តើត្រូវធ្វើដូចម្តេចដើម្បីគ្រប់គ្រង និងផ្គត់ផ្គង់ឧបករណ៍ប្រើប្រាស់ឱ្យបានល្អ?

នីតិវិធី និងទម្លាប់មួយចំនួនខាងក្រោមនឹងពណ៌នាអំពីរបៀបដែលសកម្មភាពត្រូវបានធ្វើឡើង នៅក្នុងថ្នាក់រៀនប៉ុន្តែវាកម្រត្រូវបានសរសេរចូលណាស់ វាគ្រាន់តែជាវិធីធ្វើកិច្ចការក្នុងថ្នាក់តែប៉ុណ្ណោះ។ Carol Weinstein និងសហការីរបស់នាង (Weinstein & Novodvorsky, 2015; Weinstein & Romano, 2015) ផ្តល់យោបល់ថា គ្រូបង្កើតទម្លាប់ដើម្បីគ្របដណ្តប់លើផ្នែកខាងក្រោម៖

1. ទម្លាប់រដ្ឋបាលមួយចំនួន ដូចជាការចូលរួមជាដើម
2. សកម្មភាពរបស់សិស្ស ដូចជាចូល និងចេញក្រៅថ្នាក់ ឬចូលបន្ទប់ទឹក
3. ការងារគេហដ្ឋាន ដូចជាស្រោចទឹករុក្ខជាតិ ឬទុកដាក់របស់របរផ្ទាល់ខ្លួន
4. ទម្លាប់នៃការប្រគល់កិច្ចការមេរៀន ដូចជារបៀបប្រមូលកិច្ចការផ្ទះ ឬកិច្ចការស្រាវជ្រាវ
5. អន្តរកម្មរវាងគ្រូនិងសិស្ស ដូចជារបៀបប្រាស្រ័យទាក់ទងជាមួយគ្រូនៅពេលត្រូវការជំនួយ
6. និយាយទៅកាន់សិស្សក្នុងថ្នាក់ទាំងមូល ដូចជាការផ្តល់ជំនួយ ឬគាំទ្រ ឬការជួយសង្គម

អ្នកអាចនឹងប្រើទម្លាប់ទាំងប្រាំមួយនេះជាក្របខ័ណ្ឌសម្រាប់រៀបចំផែនការទម្លាប់ក្នុងថ្នាក់របស់អ្នក។ ការបង្កើតទម្លាប់ល្អក្នុងថ្នាក់រៀនអាចជួយយើងរៀបចំផែនបានត្រឹមត្រូវទៅថ្ងៃមុខ។

2) **ច្បាប់៖** មិនដូចទម្លាប់ទេ ច្បាប់ច្រើនតែត្រូវបានសរសេរចុះ ហើយបង្ហោះ ព្រោះច្បាប់បញ្ជាក់សកម្មភាពដែលរំពឹងទុក និងការហាមឃាត់នៅក្នុងថ្នាក់។ វាគឺជារឿងដែលគួរធ្វើ និងមិនគួរធ្វើនៃជីវិតក្នុងថ្នាក់រៀន ។ ក្នុងការបង្កើតច្បាប់ អ្នកគួរតែពិចារណាថា តើបរិយាកាសបែបណាដែលអ្នកចង់បង្កើត។ អាកប្បកិរិយារបស់សិស្សបែបណានឹងជួយអ្នកក្នុងការបង្រៀនប្រកបដោយប្រសិទ្ធភាព? តើអាកប្បកិរិយាសិស្សកម្រិតណាដែលយើងត្រូវធ្វើការណែនាំ?

ច្បាប់ដែលអ្នកបានកំណត់គួរតែស្របតាមច្បាប់របស់សាលា និងក៏ត្រូវរក្សាទុកផងដែរជាមួយនឹងគោលការណ៍នៃការរៀនសូត្រ។ ជាឧទាហរណ៍ យើងដឹងពីការស្រាវជ្រាវលើការសិក្សាជាក្រុមតូចដែលសិស្សទទួលបានអត្ថប្រយោជន៍នៅពេលពួកគេពន្យល់ការងារដល់មិត្តភក្តិ។ ពួកគេរៀនច្បាប់ដូចដែលពួកគេបង្រៀនច្បាប់នោះ។ ការហាមសិស្សមិនឱ្យចេះជួយគ្នាទៅវិញទៅមកអាចនឹងមិនស្របតាមគោលការណ៍សិក្សាល្អ ឬច្បាប់មួយដែលនិយាយថា "គ្មានការលុបនៅពេលសរសេរ" អាចធ្វើឱ្យសិស្សផ្តោតលើការការពារកំហុសជាងការប្រាស្រ័យទាក់ទងធ្វើយ៉ាងច្បាស់នៅក្នុងការសរសេររបស់ពួកគេ (Burden, 1995; Emmer & Stough, 2001; C. S. Weinstein & Romano, 2015) ។

ច្បាប់គួរតែមានលក្ខណៈវិជ្ជមាន និងអាចសង្កេតបាន (លើកដៃរបស់អ្នកដើម្បីទទួលស្គាល់)។ មានច្បាប់ទូទៅខ្លះដែលគ្របដណ្តប់លើចំណុចជាក់លាក់ជាច្រើន គឺប្រសើរជាងការរាយការណ៍ពីបញ្ជីអ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ។ ប៉ុន្តែសកម្មភាពជាក់លាក់មួយចំនួនត្រូវបានហាមឃាត់ ដូចជាការចាកចេញពីបរិវេណសាលា ឬការជក់បារីនៅក្នុងបន្ទប់ទឹក នោះច្បាប់គួរតែធ្វើឱ្យបានច្បាស់លាស់ (Emmer & Gerwels, 2006) ។

**3) កំណត់នីតិវិធីសម្រាប់ការថែទាំបរិក្ខារក្នុងថ្នាក់រៀន និងសម្ភារៈផ្សេងៗទៀត៖**

**ឧទាហរណ៍៖**

ការសម្អាតតុ កៅអី ទូរ ធ្នើ ម៉ូនីទ័រ និងសម្ភារៈបង្រៀនផ្សេងៗទៀតដែលមាននៅក្នុងបន្ទប់។ម្យ៉ាងទៀតត្រូវរៀបចំទុកដាក់សម្ភារៈដែលប្រើប្រាស់រួចតាមកន្លែង អនាម័យ និងមានរបៀបរៀបរយផងដែរ។

**4) កំណត់និតិវិធីសម្រាប់ការចូល និងចេញពីបន្ទប់រៀនរបស់សិស្ស**

**ឧទាហរណ៍៖**

ក. គ្រូត្រូវមាននិតិវិធីសម្រាប់សិស្សអនុវត្តមុនពេលចូលថ្នាក់រៀន។ គ្រូខ្លះមានស្តង់ដារកិច្ចការ (សិស្សត្រូវបង្ហាញកិច្ចការផ្ទះរបស់ពួកគេឱ្យគ្រូមើលសិន ទើបគ្រូអនុញ្ញាតិឱ្យចូលបន្ទប់រៀន)។

ខ. ជូនដំណឹងដល់សិស្សនៅក្រោមលក្ខខណ្ឌអ្វី ដែលពួកគេអាចសុំចេញពីបន្ទប់រៀនមុនបាន ដោយត្រូវប្រាកដថា ពួកគេយល់ពីមេរៀន ឬធ្វើកិច្ចការបាន ពេលដែលគេធ្វើដូច្នេះ។

គ. ប្រាប់សិស្សពីរបៀបដែលពួកគេគួរទទួលបានការចូលបន្ទប់ ប្រសិនបើពួកគេយឺត។

ឃ. រៀបចំគោលការណ៍អំពីការបណ្តេញចេញពីថ្នាក់។ គ្រូបង្រៀនជាច្រើនទាមទារសិស្សត្រូវអង្គុយនៅកន្លែងអង្គុយ ហើយស្ងាត់សិន មុនគេអាចចាកចេញនៅចុងបញ្ចប់នៃថ្នាក់រៀនបាន។ គ្រូមិនមែនជាកណ្តឹង ឬបណ្តេញសិស្សចេញពីថ្នាក់ឡើយ។

**5) បង្កើតសញ្ញាសម្រាប់ការចាប់អារម្មណ៍របស់សិស្ស ហើយបង្រៀនដល់សិស្សរបស់អ្នក៖**

ដូចការចុចកណ្តឹង ឬនិយាយថា សូមមើលមកនេះ ឬ សូមស្ងាត់ ជាដើម

**6) កំណត់ទម្លាប់សម្រាប់ការចូលរួមរបស់សិស្សនៅក្នុងថ្នាក់៖**

អាចឱ្យសិស្សលើកដៃ ឬទះដៃជាដើម

7) **កំណត់ពីរបៀបដែលអ្នកនឹងទំនាក់ទំនង ប្រមូល និងប្រគល់ភារកិច្ចមកវិញ៖** គ្រូអាចកំណត់ទីតាំង ឬកន្លែងសម្រាប់ឱ្យសិស្សជួបដើម្បីពិគ្រោះ ឬប្រមូលកិច្ចការ។

**8) ច្បាប់សម្រាប់សាលាមធ្យមសិក្សា៖**

លោកEmmer and Evertson(2009)ណែនាំ ឧទាហរណ៍គោលការណ៍ទាំង៦សម្រាប់សិស្សមធ្យមសិក្សា៖

1. យកសម្ភារៈដែលត្រូវប្រើការទាំងអស់មករៀនដូចជា ប្រភេទប៊ិច ខ្មៅដៃ ក្រដាស សៀវភៅកត់ត្រាអត្ថបទ ឬសម្ភារសម្រាប់រៀនធរណីមាត្រ ជាដើម។

2. អង្គុយនៅកន្លែងអង្គុយរៀងៗខ្លួនមុនពេលជួង ឬកណ្ដឹងរោទ៍ដើម្បីចាប់ផ្ដើមធ្វើវិញ្ញាសា។

៣.គោរព និងគួរសមចំពោះមនុស្សគ្រប់រូប។ នេះគ្របដណ្ដប់លើការវាយតប់ ការបំពានពាក្យសំដី និងការបង្កបញ្ហាទូទៅ ចំពោះមនុស្សទាំងអស់ រួមទាំងគ្រូផងដែរ។

4. ស្ដាប់ និងអង្គុយខណៈពេលដែលអ្នកផ្សេងកំពុងនិយាយ។ នេះអនុវត្តនៅពេលដែលគ្រូ ឬអ្នកដទៃពីសិស្សកំពុងនិយាយ។

5. គោរពទ្រព្យសម្បត្តិអ្នកដទៃ មានន័យថា ទ្រព្យសម្បត្តិជារបស់សាលា គ្រូ ឬសិស្សផ្សេងទៀត

6. គោរពបទបញ្ជាផ្ទៃក្នុងសាលាទាំងអស់ គ្របដណ្ដប់លើអាកប្បកិរិយា និងស្ថានភាពជាច្រើន។

## ប្រភេទទាំង៧យ៉ាងសម្រាប់ការពិន័យសិស្ស៖

1. បង្ហាញពីការមិនពេញចិត្ត។ ប្រសិនបើសិស្សចូលចិត្ត និងគោរពគ្រូរបស់ពួកគេ នោះគេនឹងមានការខកចិត្ត និងសោកស្ដាយចំពោះទង្វើទាំងនោះ និងអាចឱ្យគេបញ្ឈប់ និងគិតឡើងវិញ។

2. ការបាត់បង់ឯកសិទ្ធិ។ សិស្សអាចបាត់បង់ពេលទំនេររបស់គេ ប្រសិនបើពួកគេមិនបានបញ្ចប់កិច្ចការផ្ទះ។ ឧទាហរណ៍ សិស្សអាចត្រូវធ្វើវាឡើងវិញ ក្នុងអំឡុងពេលទំនេរ ឬឈប់សម្រាក។

3. Time-Out: ការដកចេញពីក្រុម។ សិស្សដែលរំខានមិត្តភក្តិរបស់ពួកគេ ឬបរាជ័យក្នុងការសហការ អាចត្រូវបានបំបែកចេញពីក្រុមរហូតដល់ពួកគេអាចសហការគ្នាឡើងវិញបាន។ គ្រូខ្លះផ្ដល់ឱកាសឱ្យសិស្សពី 10 ទៅ 15 នាទី។ សិស្សត្រូវទៅថ្នាក់ផ្សេង ឬសាលសិក្សាដែលជាកន្លែងដែលសិស្ស និងគ្រូផ្សេងទៀតមិនអើពើសិស្សដែលបំពានសម្រាប់ពេលនោះ។

4. ការឆ្លុះបញ្ចាំងជាលាយលក្ខណ៍អក្សរលើបញ្ហា។ សិស្សអាចសរសេរក្នុងទិនានុប្បវត្តិ សរសេរអត្ថបទអំពីអ្វីពួកគេបានធ្វើ និងរបៀបដែលវាប៉ះពាល់ដល់អ្នកដទៃ ឬសរសេរសំបុត្រសុំទោស ប្រសិនបើទង្វើនេះសមស្រប។ លទ្ធភាពមួយទៀតគឺ សួរសិស្សឱ្យពណ៌នាអំពីអ្វីដែលពួកគេបានធ្វើ បន្ទាប់មកគ្រូ ហើយសិស្សអាចចុះហត្ថលេខា និងកាលបរិច្ឆេទនៃកំណត់ត្រានេះ។ កំណត់ត្រាទាំងនេះអាចរកបានប្រសិនបើឪពុកម្ដាយ ឬអ្នកគ្រប់គ្រងត្រូវការភស្តុតាងពីអាកប្បកិរិយារបស់សិស្ស។

5. ទៅការិយាល័យរបស់នាយកសាលា។ គ្រូជំនាញកម្រប្រើការពិន័យនេះណាស់ ប៉ុន្តែពួកគេប្រើវានៅពេលដែលស្ថានភាពជានា។ សាលាខ្លះតម្រូវឱ្យបញ្ជូនសិស្សទៅការិយាល័យបទល្មើស ដោយការបំពានធ្ងន់ធ្ងរ។ ប្រសិនបើអ្នកប្រាប់សិស្សឱ្យទៅការិយាល័យ ហើយសិស្សបដិសេធ គ្រូអាចទូរស័ព្ទទៅការិយាល័យ ដោយនិយាយថា សិស្សត្រូវបានបញ្ជូនទៅហើយ។ បន្ទាប់មកសិស្សមានជម្រើសទាំងទៅការិយាល័យ ឬប្រឈមមុខនឹងការពិន័យរបស់នាយកសាលាចំពោះការ "បាត់ខ្លួន" នៅតាមផ្លូវ។

6. ការដាក់ខ្លួននៅមួយកន្លែង។ អាចជាការជួបរយៈពេលខ្លីក្រោយម៉ោងសិក្សា អំឡុងពេលទំនេរ ឬនៅពេលអាហារថ្ងៃត្រង់។ គោលបំណងសំខាន់គឺ និយាយអំពីអ្វីដែលបានកើតឡើង។

7. ទាក់ទងទៅឪពុកម្តាយ។ ប្រសិនបើបញ្ហាក្លាយជាលំនាំដដែលៗ គ្រូភាគច្រើនទាក់ទងទៅអាណាព្យាបាល ឬឪពុកម្តាយសិស្សតែម្តង។ ទង្វើនេះគឺ ដើម្បីស្វែងរកការជួយដល់សិស្ស មិនមែនជាការបន្ទោសឪពុកម្តាយ ឬដាក់ទណ្ឌកម្មសិស្សទេ។

9) **និតិវិធី (គោលការណ៍)មួយចំនួន ដើម្បីការពារសិទ្ធិរបស់យើង៖**

1. ជាដំបូងត្រូវធ្វើតាមនិតិវិធី ឬបទបញ្ជាផ្ទៃក្នុងសាលាសិន។

២.និយាយគួរសម ទន់ភ្លន់ និងគោរពដល់អារម្មណ៍ និងបញ្ហារបស់គេ។

3. សើចឱ្យបានត្រឹមត្រូវតាមពេលវេលា។

4. គោរពសិទ្ធិរបស់អ្នកដទៃ កុំរំខានអ្នកដទៃ កុំឡូឡា ឬស្រែក។ ចងចាំថា ភាពស្ងប់ស្ងាត់អាចធ្វើឱ្យអ្នករាប់ថយក្រោយបាន។

5. និយាយនៅពេលដែលត្រូវនិយាយ ដោយសម្លេងស្រទន់ និងកម្រិតល្មមអាចស្តាប់គ្នាបាន

6. ការផ្លាស់ប្តូរ និងចលនាមានភាពស្ងៀមស្ងាត់ ស្ងប់ស្ងាត់ ប្រុងប្រយ័ត្ន និងធើតឆាយ។

7. អនុវត្តតាមនីតិវិធីទាំងអស់ក្នុងថ្នាក់រៀន និងសាលា ដូចជា៖ បន្ទប់ទឹក; ខ្មៅដៃ; អាហារថ្ងៃត្រង់និងសម្រាក; ព្រឹក; ការបណ្តេញចេញ; និង . . .

## ៧.៤. ការរក្សាបរិយាកាសល្អសម្រាប់ការសិក្សា

ការចាប់ផ្តើមដោយរលូនគឺ ជាទង្វើល្អបំផុតរបស់គ្រូបង្រៀនដែលមានប្រសិទ្ធភាព។ គ្រូអាចរក្សាប្រព័ន្ធនៃការគ្រប់គ្រងដោយទប់ស្កាត់បាននៅរាល់បញ្ហាដែលនឹងកើតឡើង និងធ្វើឱ្យសិស្សអាចចូលរួមក្នុងសកម្មភាពនៃការរៀនដើម្បីឈានទៅទទួលបានលទ្ធផលពីការសិក្សានៅចុងបញ្ចប់នៃមេរៀន។ លើការលើកទឹកចិត្ត ជាឧទាហរណ៍មួយដែលយើងបានចាត់ទុកជា ការជំរុញការចង់ដឹងចង់ឃើញ ទំនាក់ទំនងនឹងមេរៀនទៅនឹងចំណាប់អារម្មណ៍របស់សិស្ស ការបង្កើតគោលដៅសិក្សា គោលដៅប្រតិបត្តិ និងមានការរំពឹងទុកជាវិជ្ជមាន។ តើអ្វីដែលគ្រូអាចធ្វើបានទៀត?

### ក. រក្សាឱ្យមានការចូលរួមរបស់សិស្ស

1) **កិច្ចការជាមូលដ្ឋានត្រូវមានភាពច្បាស់លាស់**

**ឧទាហរណ៍៖**

1. បញ្ជាក់ និងរំលឹកពីសម្ភារៈសិក្សាដែលត្រូវប្រើប្រចាំថ្ងៃ ដូចជា សៀវភៅ ប៊ិច ឬខ្មៅដៃជាដើម

2. បញ្ជាក់ និងរំលឹកអំពីវិន័យ ការងារយឺត ឬមិនពេញលេញ និងអវត្តមាន។ អាចនិយាយជាមួយឪពុកម្តាយប្រសិនបើចាំបាច់។

3. កំណត់កាលបរិច្ឆេទសមហេតុផលមួយ អាចឱ្យសិស្សមានពេលវេលាគ្រប់គ្រាន់ធ្វើវាបានល្អ

2) **ការប្រាស្រ័យទាក់ទងសម្រាប់ធ្វើកិច្ចការបានសម្រេច**

**ឧទាហរណ៍៖**

1. ជាមួយសិស្សដែលមានវ័យក្មេង ត្រូវមាននិតិវិធីក្នុងការផ្តល់ឱ្យកិច្ចការ ដូចជាការសរសេរនៅលើក្តារខៀនកន្លែងដដែលជារៀងរាល់ថ្ងៃ។ ជាមួយសិស្សធំ កិច្ចការអាចត្រូវបានសរសេរជាលាយលក្ខ័អក្សរ ឬតាមរយៈការបង្ហោះ ឬផ្តល់ឱ្យតាមការគ្រោងទុក។

2. រំលឹកសិស្សអំពីកិច្ចការនាពេលខាងមុខ។

3. ជាមួយនឹងកិច្ចការដ៏ស្មុគស្មាញ អាចឱ្យសិស្សពិពណ៌នាអ្វីដែលត្រូវធ្វើ ធនធានណាដែលមាន កាលបរិច្ឆេទកំណត់យក.... រួមនឹងលក្ខណៈវិនិច្ឆ័យការដាក់ពិន្ទុជាដើម។

4. បង្ហាញពីរបៀបធ្វើកិច្ចការ ដោយណែនាំជាឧទាហរណ៍មួយពីរ ឬផ្តល់សន្លឹកកិច្ចការគម្រូ។

3) **ការត្រួតពិនិត្យកិច្ចការដែលកំពុងដំណើរការ**

**ឧទាហរណ៍៖**

1. នៅពេលអ្នកផ្តល់កិច្ចការក្នុងថ្នាក់ សូមប្រាកដថា សិស្សម្នាក់ៗអាចចាប់ផ្តើមដោយត្រឹមត្រូវ។ ប្រសិនបើអ្នកពិនិត្យតែសិស្សដែលលើកដៃ អ្នកនឹងមិនបានដឹងពីអ្នកដែលមិនបានលើកដៃដោយពួកគាត់មិនយល់ ខ្មាស់មិនហ៊ានសួរ និងអ្នកដែលមិនចង់ធ្វើការងារទាល់តែសោះ។

2. ពិនិត្យវឌ្ឍនភាពកិច្ចការជាប្រចាំ។ នៅក្នុងការពិភាក្សាត្រូវប្រាកដថា គ្រប់គ្នាមានឱកាសឆ្លើយឆ្លងគ្នា។

4) **ការផ្តល់មតិកែលម្អការសិក្សាឱ្យបានញឹកញាប់**

**ឧទាហរណ៍៖**

1. ជាការល្អសិស្សគួរទទួលបានឯកសារត្រឡប់មកវិញនៅថ្ងៃបន្ទាប់ពីពួកគេត្រូវបានប្រគល់ឱ្យ

2. ការងារល្អអាចត្រូវបានបង្ហាញនៅក្នុងថ្នាក់រៀន និងដាក់ចំណាត់ថ្នាក់ ហើយក៏អាចផ្ញើទៅឱ្យឪពុកម្តាយរៀងរាល់សប្តាហ៍ផងដែរ។

3. សិស្សគ្រប់វ័យអាចរក្សាកំណត់ត្រានៃថ្នាក់ ការបញ្ចប់គម្រោង និងទទួលបានឥណទានបន្ថែម

4. សម្រាប់សិស្សចាស់ យើងអាចបំបែកកិច្ចការរយៈពេលវែងចូលទៅក្នុងដំណាក់កាលជាច្រើនដើម្បីងាយស្រួលផ្តល់មតិ និងកែលម្អនៅចំណុចនីមួយៗឱ្យបានច្បាស់។

## ខ. ការបង្កើតទំនាក់ទំនងនិងយកចិត្តទុកដាក់ជាមួយសិស្ស

### 1. ស្គាល់សិស្សជាបុគ្គល៖

**ឧទាហរណ៍**

1. ញ៉ាំអាហារថ្ងៃត្រង់ជាមួយសិស្សមួយក្រុមផ្សេងគ្នាជារៀងរាល់ថ្ងៃ។

2. ធ្វើការជាមួយក្លឹប សកម្មភាពក្រៅកម្មវិធីសិក្សា ឬក្រុមកីឡា និងចូលរួមសកម្មភាពសិស្ស។

3. បង្ហាញចំណាប់អារម្មណ៍របស់អ្នកចំពោះសិស្សរបស់អ្នកជាបុគ្គល។

4. កំណត់ពេលសន្និសីទបុគ្គលជាមួយសិស្ស។

### 2. ទំនាក់ទំនងការគោរពរបស់អ្នកចំពោះសមត្ថភាពរបស់សិស្ស៖

**ឧទាហរណ៍**

1. «ការគោរពគំរូចំពោះភាពចម្រុះ—ដោយបង្ហាញការកោតសរសើរ សម្រាប់សមត្ថភាពពីរភាសារបស់សិស្ស ដោយការបញ្ចេញមតិដោយរីករាយ អំពីចំនួនភាសាផ្សេងៗគ្នា ត្រូវបានតំណាងនៅក្នុងថ្នាក់ និងដោយរួមបញ្ចូលឧទាហរណ៍ និងខ្លឹមសារពីវប្បធម៌ផ្សេងៗគ្នា" (C. S. Weinstein, Curran & Tomlinson-Clarke, 2003, ទំ។ ២៧២)។

2. ផ្តល់យោបល់ដល់សិស្សជាឯកជនអំពីការសង្កេតរបស់អ្នក។ ការសម្តែងរបស់ពួកគេនៅក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា។

3. លើកទឹកចិត្តសិស្សឱ្យប្រើផលប្រយោជន៍ផ្ទាល់ខ្លួន ប្រធានបទសម្រាប់ការសរសេររបស់ពួកគេ។

4. ស្វាគមន៍សិស្សនៅមាត់ទ្វារចូលថ្នាក់រៀនជារៀងរាល់ថ្ងៃ។

3. **រក្សាទំនាក់ទំនងពិតប្រាកដ ប៉ុន្តែប្រកបដោយវិជ្ជាជីវៈ៖**

**ឧទាហរណ៍**

1. ផ្ញើកំណត់ចំណាំផ្ទាល់ខ្លួនខ្លីៗដល់សិស្សដែលទទួលស្គាល់ ការងារល្អលើការងារ ឧស្សាហ៍ព្យាយាម និងតស៊ូ ថ្ងៃកំណើត ឬបារម្ភអំពីអវត្តមាន។ រួមបញ្ចូលកន្លែងសំរាកកាតរួមជាមួយនឹងកិច្ចការផ្ទះផ្ញើទៅសិស្សដែលឈឺ។

2. ចែករំលែករឿងខ្លះពីជីវិតផ្ទាល់ខ្លួនរបស់អ្នកជាឧទាហរណ៍ រំភើប អំពីប្រធានបទមួយ ការធ្វើខុស (និងរៀនពីពួកគេ) និងការតស៊ូ និងការជំនះការលំបាក។

៣.កុំមិត្តសិស្សតាមបណ្តាញសង្គម ហើយត្រូវប្រយ័ត្នខ្លាំង អំពីភាសា និងការបង្ហោះរូបភាពរបស់អ្នកនៅលើអេឡិចត្រូនិកទាំងអស់។ ទំនាក់ទំនង - រឿងជាច្រើនអាចត្រូវបានបកស្រាយខុស។ បង្កើតគណនីអ៊ីមែលដែលទាក់ទងនឹងសាលារៀនដែលខុសគ្នាពីគណនីផ្ទាល់ខ្លួន។

4. ពិនិត្យមើលគោលការណ៍សាលារបស់អ្នកអំពីការចែករំលែកព័ត៌មានផ្ទាល់ខ្លួន ដូចជាសាសនា ទំនោរផ្លូវភេទ ឬនយោបាយ ទស្សនៈ។

5. ប្រសិនបើអ្នកជួបតែឯងជាមួយសិស្ស ធ្វើដូច្នេះនៅក្នុងតំបន់មួយ។ អាចមើលឃើញដោយអ្នកដ៏ទៃ គួរឲ្យសោកស្តាយ គ្រូបង្រៀនសព្វថ្ងៃនេះត្រូវតែការពារ ប្រឆាំងនឹងការមានទំនាក់ទំនងវិជ្ជមានរបស់ពួកគេជាមួយសិស្ស បកស្រាយខុសដោយអ្នកដទៃ ឬដោយសិស្ស។

4. **ស្វែងរកការបញ្ចូលរបស់សិស្ស ហើយគោរពវា ប៉ុន្តែកុំយកវាផងដែរផ្ទាល់ខ្លួន៖**

**ឧទាហរណ៍**

1. ពិចារណាប្រអប់ផ្តល់យោបល់ ឬការប្រជុំសហគមន៍សម្រាប់សិស្សវ័យក្មេង។

2. ស្តាប់កង្វល់ និងពាក្យបណ្តឹងរបស់សិស្សដោយមិនទទួលបានការពារ។ សុំយោបល់ ប៉ុន្តែសូមចែករំលែកហេតុផលរបស់អ្នកផងដែរ។ សម្រាប់កិច្ចការ និងថ្នាក់។

3. សួរសិស្សដោយផ្ទាល់សម្រាប់មតិកែលម្អអនាមិកអំពីថា តើពួកគេមានអារម្មណ៍គោរព និងយកចិត្តទុកដាក់ក្នុងថ្នាក់របស់អ្នក។ ប្រើកម្រងសំណួរសាមញ្ញ ដែលមិនបង្ហាញអត្តសញ្ញាណរបស់សិស្សតាមរយៈការសរសេរដោយដៃ។

## ៧.៥. ដំណោះស្រាយបញ្ហាវិន័យ

មុននឹងយើងពិភាក្សាអំពីការដោះស្រាយបញ្ហាវិន័យ សូមចាំថាគ្រប់សាលាមានគោលការណ៍ បទបញ្ជាផ្ទៃក្នុង ឬនីតិវិធីសម្រាប់ដោះស្រាយបញ្ហាអាកប្បកិរិយារបស់សិស្សរៀងៗខ្លួន ជាពិសេសចំពោះបញ្ហាធ្ងន់ធ្ងរ។ ត្រូវប្រាកដថា យើងត្រូវមាននីតិវិធី និងដឹងពីតម្រូវការទាំងនេះមុនពេលយើងបង្កើតផែនការគ្រប់គ្រងអាកប្បកិរិយាបែបណាមួយនោះ។ សូមរក្សាទុកនៅក្នុងចិត្តថា ការធ្វើជាអ្នកគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពមិនមែនមានន័យថា អ្នកត្រូវកែតម្រូវជាសាធារណៈរាល់ការរំលោភបំពានទោះតិចតួចនោះទេ។ សំខាន់អ្នកត្រូវដឹងពីអ្វីដែលកំពុងកើតឡើង និងដឹងពីមធ្យោបាយចាំបាច់សម្រាប់ទប់ទល់នឹងបញ្ហាទាំងនោះ។ ដូច្នេះអ្នកអាចការពាររាល់បញ្ហាបានហើយ។ សិស្សភាគច្រើនធ្វើតាមយ៉ាងឆាប់រហ័សនៅពេលដែលគ្រូផ្តល់ពាក្យបដិសេធ "ឈប់ធ្វើវា" ឬបញ្ជូនបន្តទៅថ្នាក់លើដើម្បីបញ្ឈប់បញ្ហា «អាកប្បកិរិយាសិស្សមិនប្រក្រតី» បានយ៉ាងឆាប់រហ័ស ។ ប៉ុន្តែសិស្សខ្លះក៏មិនងាយនឹងបោះបង់អាកប្បកិរិយារបស់ពួកគេភ្លាមៗដែ

រ។ ការសិក្សាមួយបានរកឃើញថា សិស្សដែលរំខានទាំងនេះកម្រធ្វើតាមសំណើរបស់គ្រូទីមួយណាស់។ Emmer និង Evertson (2009) និង Levin and Nolan (2000) ណែនាំវិធីសាមញ្ញចំនួនប្រាំពីរដើម្បីបញ្ឈប់អាកប្បកិរិយាមិនសមរម្យយ៉ាងលឿន ពីតូចទៅធំ៖

- ប្រើក្រសែភ្នែកមើលឱ្យចំ ឬខិតទៅជិតសិស្សនោះ។ អាចចង្អុលគាត់។ ត្រូវប្រាកដថា សិស្សពិតជាបញ្ឈប់អាកប្បកិរិយាមិនសមរម្យ ហើយត្រឡប់ទៅរកសិក្សាវិញ។ បើអ្នកមិនធ្វើចឹង ទេសិស្សនឹងមិនធ្វើតាមទេ។
- សាកល្បងណែនាំដោយប្រើពាក្យសំដីដូចជា "លប់ឈ្មោះចោល" ឬសួរសំណួរទៅគាត់
- សួរសិស្សថា តើពួកគេដឹងពីផលប៉ះពាល់អវិជ្ជមាននៃសកម្មភាពរបស់ពួកគេដែរឬទេ?
- ប្រសិនបើពួកគេអនុវត្តនីតិវិធីក្នុងថ្នាក់មិនបានត្រឹមត្រូវ សូមរំលឹកសិស្សអំពីនីតិវិធីនោះ ហើយឱ្យពួកគេធ្វើតាមវាឱ្យបានត្រឹមត្រូវ។ យើងអាចជូនដំណឹងដល់សិស្សជាមុនថានឹងមិនអនុញ្ញាត្តិឱ្យប្រើប្រាស់ប្រដាប់កម្សាន្តផ្សេងៗ ឬទូរស័ព្ទដៃក្នុងថ្នាក់រៀនឡើយ។ ទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវដកហូត និងប្រគល់វិញបន្ទាប់ពីថ្នាក់ចប់។
- ក្នុងរបៀបស្ងប់ស្ងាត់ និងគ្មានអរិភាព សូមឲ្យសិស្សនិយាយពីច្បាប់ ឬនីតិវិធីត្រឹមត្រូវ ហើយបន្ទាប់មកធ្វើតាមវា។ Glasser (1969) ស្នើសំណួរបី: "តើអ្នកកំពុងធ្វើអ្វី? តើវាផ្ទុយនឹងច្បាប់ទេ? តើអ្នកគួរធ្វើអ្វីវិញ?
- ប្រាប់សិស្សឱ្យបានច្បាស់ អះអាង និងគ្មានអរិភាព ដើម្បីបញ្ឈប់អាកប្បកិរិយាមិនសមរម្យរបស់គេ។ ប្រសិនបើសិស្ស «និយាយតបវិញ» គ្រាន់តែនិយាយឡើងវិញនូវពាក្យសំដីរបស់អ្នក។
- ផ្តល់ជូនគាត់នូវជម្រើសមួយ។ ជាឧទាហរណ៍ គាត់អាចលើកដៃឡើងឆ្លើយ ឬដើរទៅខាងក្រោយបន្ទប់ដើម្បីជួបជាឯកជនជាមួយគ្រូ (Levin & Nolan, 2000, p. 177)។

## ៧.៥.១ ការដាក់ទណ្ឌកម្ម

**ក. ពន្យារពេលការពិភាក្សាអំពីស្ថានការណ៍រហូតដល់អ្នក និងសិស្សដែលចូលរួមមានភាពស្ងប់ស្ងាត់ និងមានគោលដៅបន្ថែម៖**

**ឧទាហរណ៍៖**

1. និយាយដោយស្ងាត់ស្ងៀមទៅកាន់សិស្សថា "អង្គុយនៅហ្នឹងហើយ ហើយគិតអំពីអ្វីដែលបានកើតឡើង។ ខ្ញុំនឹងនិយាយជាមួយអ្នកក្នុងរយៈពេលពីរបីនាទីទៀត" ឬ "ខ្ញុំមិនចូលចិត្តអ្វីដែលខ្ញុំទើបតែបានឃើញ។ ប្រាប់ខ្ញុំក្នុងអំឡុងពេលទំនេររបស់អ្នកនៅថ្ងៃនេះ។»
2. និយាយថា "ខ្ញុំពិតជាខឹងនឹងអ្វីដែលបានកើតឡើង។ ទាំងអស់គ្នាយកទិនានុប្បវត្តិមក យើងនឹងសរសេរអំពីរឿងនេះ»។ បន្ទាប់ពីពីរបីនាទីនៃការសរសេរមក យើងអាចពិភាក្សាអំពីឧប្បត្តិហេតុនេះ។

**ខ. ដាក់ពិន័យចំពោះបុគ្គល៖**

**ឧទាហរណ៍៖**

1. រៀបចំជំនួបជាមួយសិស្សជាលក្ខណៈឯកជន។ ឈរយ៉ាងរឹងមាំ ដើម្បីត្រៀមរៀបចំជាស្រេច។
2. ទប់អារម្មណ៍ដោយ "រំលឹក" សិស្សទាំងអស់ថា នឹងមិនស្ថិតនៅខាងណាមួយទេ។

3. ដើរទៅជិតសិស្សដែលត្រូវពិន័យ និងនិយាយទៅកាន់គាត់តែម្នាក់ឯង។

**គ. បន្ទាប់ពីការដាក់ពិន័យរួម សូមបង្កើតទំនាក់ទំនងជាវិជ្ជមានជាមួយសិស្សភ្លាមៗឡើងវិញ**

**ឧទាហរណ៍៖**

1. ផ្តល់កិច្ចការអ្វីមួយឱ្យគាត់ធ្វើ ឬសុំឱ្យគាត់ជួយធ្វើការងារអ្វីមួយ។

2. សរសើរការងាររបស់គាត់ ឬផ្តល់សញ្ញាដោយ "អង្អែលខ្នងគាត់តិចៗ" នៅពេលដែលអាកប្បកិរិយារបស់គាត់ល្អ។ ពិនិត្យមើលឱ្យបានល្អិតល្អន់លើឱកាសបែបនេះ។

3. រយៈពេល 2 នាទី ជារៀងរាល់ថ្ងៃ សម្រាប់រយៈពេល 10 ថ្ងៃជាប់ៗគ្នា យើងអាចជជែកលេងផ្ទាល់ជាមួយគាត់ អំពីអ្វីមួយដែលគាត់ចំណាប់អារម្មណ៍ដូចជា កីឡា ហ្គេម ភាពយន្ត និងរកឱ្យឃើញពីចំណុចដែលគាត់ពេញចិត្ត។ ទង្វើនេះអាចធ្វើឱ្យគាត់បែរមកការសិក្សារបស់គាត់វិញ។

**ឃ. រៀបចំតារាងចំណាត់ថ្នាក់នៃការពិន័យស្របតាមស្ថានភាពនីមួយៗ៖**

**ឧទាហរណ៍៖**

ចំពោះការដែលគាត់មិនប្រគល់កិច្ចការផ្ទះ៖

(1)ធ្វើការរំលឹក

(2)ទទួលបានការព្រមាន

(3)ប្រគល់កិច្ចការផ្ទះមុនថ្ងៃបិទសាលា

(4)ប្រគល់កិច្ចការក្រោយថ្ងៃបិទសាលា

(5)ចូលរួមនៅក្នុងការប្រជុំគ្រូ-សិស្ស-មាតាបិតាដើម្បីបង្កើតផែនការសកម្មភាព។

**ង. ជានិច្ចកាលបង្រៀនពីយុទ្ធសាស្ត្រដោះស្រាយបញ្ហាជាមួយការពិន័យដើម្បីជួយសិស្សឱ្យរៀនពីអ្វីដែលត្រូវធ្វើនៅពេលក្រោយ** (M. J. Elias & Schwab, 2006)

**ឧទាហរណ៍៖**

1. ប្រើកំណត់ហេតុបញ្ហា ដែលសិស្សកត់ត្រានូវអ្វីដែលពួកគេចាប់អារម្មណ៍ កំណត់បញ្ហា និងកំណត់គោលដៅរបស់ពួកគេ បន្ទាប់មកគិតអំពីលទ្ធភាពដែលអាចដោះស្រាយបញ្ហាបាន និងដើម្បីសម្រេចបានដល់គោលដៅ។

2. ព្យាយាមអនុវត្តរូបមន្តភាពស្ងាត់ស្ងៀម 5–2–5៖ បន្ទាប់ពីដឹងខ្លួនឯងថា មានអារម្មណ៍ខឹងសម្បារ សិស្សអាចនិយាយទៅកាន់ខ្លួនឯងថា៖ «ឈប់ ហើយរក្សាភាពស្ងប់ស្ងាត់" បន្ទាប់មកធ្វើចលនាដង្ហើមយឺតៗដោយ ដកដង្ហើមចូលយឺតៗរាប់ដល់៥ សង្កត់ដង្ហើម២ និងបញ្ចេញដង្ហើម៥វិញ។

## ៧.៥.២ ការដោះស្រាយស្ថានភាពដែលអាចផ្ទុះឡើង

**ក. ធ្វើដោយសន្សឹមៗ និងចេតនាផ្តោះរកស្ថានភាពធូរស្រាលនៃបញ្ហា៖**

**ឧទាហរណ៍៖**

1. ដើរយឺតៗ បន្ទាប់មករក្សាជំហរដែលអាចធ្វើទៅបាន។

2. រក្សាគោលជំហរឱ្យបានល្អប្រសើរ។

**ខ. ត្រូវគោរព៖**

**ឧទាហរណ៍៖**

1. រក្សាចម្ងាយសមរម្យ។
2. កុំប្រឡោតទៅរកសិស្ស។ កុំប្រឈមមុខជាមួយសិស្ស
3. និយាយដោយគោរព។ ប្រើឈ្មោះសិស្ស។
4. ជៀសវាងការចង្អុល ឬបង្ហាញកាយវិការប្រចង់ប្រចាង។

**គ. ធ្វើការសង្ខេប៖**

**ឧទាហរណ៍៖**

1. ជៀសវាងការនិយាយវែងឆ្ងាយ ឬនិយាយញុះញង់។
2. ប្រកាន់ខ្ជាប់ជាមួយនឹងរបៀបវារៈ។ ផ្តោតលើបញ្ហានៅដៃ។ កុំឲ្យវង្វេង
3. ដោះស្រាយបញ្ហាមិនសូវធ្ងន់ធ្ងរនៅពេលក្រោយ។

**ឃ. ជៀសវាងការប្រើកម្លាំង៖**

**ឧទាហរណ៍៖**

1. និយាយជាឯកជនសិនបើអាចធ្វើទៅបាន កុំគំរាមកំហែង។
2. កុំតាំងចិត្តដោយការប្រើពាក្យ "ខ្ញុំនឹងមិនទេ បើអ្នកនឹង" ។
3. កុំគំរាមកំហែង ឬតម្លើងសំឡេងរបស់អ្នក។

**ង. ផ្តល់ជម្រើសឱ្យសិស្សអំពីអាកប្បកិរិយាដែលអ្នកចង់បាន និងផលវិបាកអវិជ្ជមាន ឬការសម្រេចចិត្តណាមួយសម្រាប់សិស្ស។ បន្ទាប់មកដកខ្លួនចេញពីសិស្ស ហើយទុកពេលឲ្យសិស្សសម្រេចចិត្ត**

**ឧទាហរណ៍៖**

1. "សារណាក់ អ្នកត្រូវត្រឡប់ទៅតុរបស់អ្នកវិញ បើមិនដូច្នោះទេ ខ្ញុំនឹងបញ្ជូនអ្នកទៅជួបនាយកសាលា។ អ្នកមានពេលពីរបីនាទីដើម្បីសម្រេចចិត្ត។" បន្ទាប់មកគ្រូក៏ដើរចេញទៅ គាត់អាចទៅជួបជាមួយសិស្សផ្សេងទៀត។
2. ប្រសិនបើ សារណាក់ មិនជ្រើសរើសអាកប្បកិរិយាសមរម្យផ្តល់លទ្ធផលជាវិជ្ជមានទេ។ អ្នកនឹងត្រូវមានជម្រើស ទូរសព្ទ័ទៅនាយកសាលា។

## ៧.៦. ភាពចាំបាច់ក្នុងការប្រាស្រ័យទាក់ទង

ភាពជាដៃគូរវាងគ្រួសារ និងសហគមន៍ជាការប្រាស្រ័យទាក់ទងចាំបាច់។

**ក. ត្រូវប្រាកដថាគ្រួសារសិស្សដឹងពីការរំពឹងទុក និងវិន័យក្នុងថ្នាក់និងសាលារៀន**

**ឧទាហរណ៍៖**

1. នៅរាត្រីរីករាយជាលក្ខណៈគ្រួសារ សូមឲ្យសិស្សរបស់អ្នកបង្ហាញពីវិន័យ - អ្នកដែលគោរពវិន័យសាលា និងអ្នកដែលមិនគោរពវិន័យសាលា។
2. សរសេរលើក្រដាស់ផ្ទាំងធំ ពណ៌នាពីចំណុចសំខាន់ៗ និងការរំពឹងទុក។
3. សម្រាប់សិស្សធំ អាចជូនដំណឹងមាតាបីតានូវបញ្ជីកាលបរិច្ឆេទកំណត់ចំពោះកិច្ចការសំខាន់ៗមួយចំនួន រួមជាមួយនឹងការណែនាំអំពីរបៀបធ្វើ ការលើកទឹកចិត្តប្រកបដោយគុណភាពដោយការព្យាយាម និងជៀសវាងការភ័យស្លន់ស្លោនៅនាទីចុងក្រោយ។ សាលារៀនខ្លះតម្រូវឱ្យសមាជិកគ្រួសារចុះហត្ថលេខាលើក្រដាសកិច្ចការពីកាលបរិច្ឆេទផុតកំណត់ផងដែរ។

4. ប្រើមធ្យោបាយទាក់ទងសមស្រប—ដំបូងអាចប្រើភាសាទាក់ទងជាមួយមាតាបីតាសិស្ស

**ខ. បង្កើតជាដៃគូស្និទ្ធស្នាលជាមួយគ្រួសារដើម្បីស្គាល់គ្នាច្បាស់៖**

**ឧទាហរណ៍៖**

1. ធ្វើរបាយការណ៍សិក្សាជូនមាតាបិតាចំពោះលទ្ធផលសិក្សាសិស្ស ជាពិសេសសិស្សដែលមានបញ្ហានឹងការសិក្សា បញ្ហាក្នុងការគ្រប់គ្រង ឬធ្វើការងារបានល្អនៅក្នុងថ្នាក់រៀន។

2. ផ្តល់ជាគំនិតសម្រាប់គ្រួសារ ទោះជាអ្នកមានធនធានសេដ្ឋកិច្ចមានកម្រិតក៏ដោយ អាចអបអរនឹងសមិទ្ធិផល និងសំណូមពរផ្សេងៗដូចជា អាហារដែលពេញចិត្ត ការជ្រើសរើសហ្គេមលេងផ្សេង ៗ ឬការបញ្ចេញមតិយោបល់របស់ មាតាបិតា សាច់ញាត ឬពីអ្នកគ្រប់គ្រងសាលា។

**គ. កំណត់រកសប្បុរសជនក្នុងសហគមន៍ដើម្បីជួយពង្រឹងការសិក្សា និងបរិស្ថាននៅក្នុងសាលារៀនរបស់អ្នក**

**ឧទាហរណ៍៖**

1. ឱ្យសិស្សសរសេរសំបុត្រទៅពាណិជ្ជករ អាជីករ សិប្បករ មន្ត្រីរាជការ ឬស្ថាប័នណាមួយស្នើសុំជំនួយឧបត្ថម្ភផ្សេងៗជាសម្ភារៈ ឬថវិកាសម្រាប់កសាង ឬជួសជុលសាលារៀន។

**ឃ. ស្វែងរកកិច្ចសហការពីក្រុមគ្រួសារចំពោះសិស្សមានបញ្ហាអាកប្បកិរិយាមិនប្រក្រតីកើតឡើង។**

**ឧទាហរណ៍៖**

1. និយាយជាមួយក្រុមគ្រួសារតាមទូរស័ព្ទ ឬទៅដល់ផ្ទះសិស្សផ្ទាល់។ រក្សាទុកកំណត់ត្រាអំពីបញ្ហាឥរិយាបថដែលកើតមានឡើងឱ្យបានល្អ ។

2. ស្តាប់សមាជិកគ្រួសារ និងដោះស្រាយបញ្ហាជាមួយពួកគាត់។

# មេរៀនទី ៨ វិធីសាស្ត្រក្នុងការលើកទឹកចិត្តសិស្ស

( Methods for motivating students )

## ៨.១. វត្ថុបំណងមេរៀន

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

- ប្រាប់បានពីនិយមន័យ “ ការលើកទឹកចិត្ត ” រូបភាព និងវិធីសាស្ត្រនៃការលើកទឹកចិត្ត
- កំណត់បានការលូតលាស់ផ្លូវចិត្តវិជ្ជមាន ដែលបាននឹងកំពុងអភិវឌ្ឍ
- មានស្មារតីក្នុងការលើកទឹកចិត្ត និងអាចផ្ទេរចំណេះដឹង ក្នុងគ្រួសារ សាលា និងសហគមន៍ ។

## ៨.២. និយមន័យ និងគោលបំណងនៃការលើកទឹកចិត្ត

### ៨.២.១. និយមន័យ:

ការលើកទឹកចិត្ត ជាគំនិតដ៏ទូលំទូលាយ ដែលជាប់ទាក់ទងជាមួយអាកប្បកិរិយា មហិច្ឆិតា ចំណាប់អារម្មណ៍ និងការប្រឹងប្រែង។ ការលើកទឹកចិត្ត ជះឥទ្ធិពលលើអត្តចរិត និងការរៀនសូត្រ ទាំង ក្នុងនិងក្រៅសាលាទាំងវិស័យសិក្សានិងវិស័យផ្សេងៗទៀត ព្រមទាំងស្ទើរតែទាំងអស់ នៃតំណាក់ កាលលូតលាស់ និងការអភិវឌ្ឍរបស់មនុស្ស។ដោយសារ តែមានការជំរុញសិស្សដែលមាន សមត្ថភាពខ្សោយ អាចទទួលបានជោគជ័យលើការសិក្សាបានយ៉ាងល្អ( overachievers )ហើយសិស្សដែលពូកែអាច ទទួលបានជ័យជម្នះទាបជាងការរំពឹងទុកនៅពេលដែលគ្មាការលើកទឹកចិត្ត ( underachievers )។

ដូចនេះ ការលើកទឹកចិត្តជាទង្វើ ឬវត្ថុផ្តល់ដល់បុគ្គលណាម្នាក់ ឱ្យធ្វើសកម្មភាពដោយពេញចិត្ត ដើម្បី ឈានដល់លទ្ធផលសម្រេច។

### ៨.២.២. គោលបំណងនៃការលើកចិត្ត:

ការលើកទឹកចិត្ត មានគោលបំណងជំរុញ គាំទ្រ ផ្តល់ទំនុកចិត្ត និងផ្តល់ក្តីសង្ឃឹម ដើម្បីឱ្យសិស្សក្លាហាន និងមាន ឆន្ទះចង់រៀនព្រមទាំងជួយពង្រឹងការលូតលាស់ផ្លូវចិត្តដល់សិស្ស។

## ៨.៣. ទ្រឹស្តីកម្លាំងជំរុញតាមបែបប្រពៃណី ( Traditional Motivational Theories )

-ទ្រឹស្តីកម្លាំងជំរុញបែបប្រពៃណីជាប់ទាក់ទងជាមួយអត្តចរិត ចំណេះដឹង និងការសិក្សារបស់ មនុស្ស។តាមទ្រឹស្តីអាកប្បកិរិយារបស់លោក Skinner កត្តានៃកម្លាំងជំរុញមានឥទ្ធិពលធ្វើ ឱ្យមានកម្លាំង ជំរុញលើអ្នកអាកប្បកិរិយានិយមបែបបូរាណកាន់តែខ្លាំង។ឧទាហរណ៍ះផ្កាយមាសមួយឬយោបល់វិជ្ជមាន អាចធ្វើឱ្យការងារដ៏អស្ចារ្យមួយរបស់អ្នកសិក្សាក្មេងខ្ចីអាចអភិវឌ្ឍ។

-ទ្រឹស្តីចំណេះដឹងបានពណ៌នា ពីការលើកទឹកចិត្តជាចលករក្នុង ( intrinsic ) និងចលករក្រៅ ( extrinsic )។ អ្នកស្រាវជ្រាវជាច្រើនបានអះអាងថា កម្លាំងចលករខាងក្នុង គឺជាកម្លាំងជំរុញប្រកបដោយថាមពលខ្លាំង ជាងកម្លាំងចលករខាងក្រៅ។ទោះបីយ៉ាងណាក៏ដោយការប្រកួតប្រជែងហួសពេក ឬការប្រើរង្វាន់ជាកម្លាំងជំរុញ លើសលុបពេក អាចធ្វើឱ្យកម្លាំងចលករក្នុងចុះខ្សោយ។

-នៅមានមធ្យោបាយនៃការគិតផ្សេងៗទៀតអំពីកម្លាំងជំរុញគឺការពិចារណាទៅលើតម្រូវការ ជាមូលដ្ឋាន តាមឋានានុក្រមរបស់លោក Abraham Maslow។ តម្រូវការចុងក្រោយរបស់មនុស្សម្នាក់ៗគឺសមត្ថភាព សក្តានុពល និងសុខភាពក្នុងការទំនាក់ទំនងក្នុងសង្គម។នៅក្នុងតម្រូវការដំបូង ឬតម្រូវការជា

មូលដ្ឋាន គឺ ជាប់ទាក់ទងជាមួយនឹងតម្រូវការសរីរាង្គ(physiological need) ដូចជា៖ អាហារ ទឹក ការសម្រាក។ បន្ទាប់មកមនុស្សមានតម្រូវការសុវត្ថិភាព(safety need) តម្រូវការក្ដីស្រលាញ់(love and belonging need) តម្រូវការតម្លៃ ឬគោរព(esteem need) និងតម្រូវការចុងក្រោយគឺតម្រូវការសត្តានុពលភាព និងសមត្ថភាព(self actualization)។ប្រសិនបើ គ្រូយល់ស្របតាមទ្រឹស្ដីលោក Abraham Maslow ឬក៏ផ្នែកណាមួយនៃទ្រឹស្ដីនេះគ្រូត្រូវពិចារណាលើការជាប់ជំពាក់ជំពិននៅពេលដែលតម្រូវការទាំងនោះ មិនត្រូវបានបំពេញជាពិសេសនៅក្នុងបរិបទនៃការបង្រៀនដែលជាគ្រោះថ្នាក់ដល់សិស្ស។ ពេលដែលក្មេង និងយុវវ័យមកកាន់សាលារៀនជាមួយតម្រូវការមូលដ្ឋាន ដែលមិនបានបំពេញដូចជា ឃ្លាន ឬអស់កម្លាំង ឬពួកគេ មកសាលារៀនដោយការស្ដីបន្ទោស ឬដោយគ្មានគំនិតចង់ចេះ ចង់ដឹងដោយខ្លួនឯងនោះ វាជាការលំបាក ក្នុងការជំរុញឱ្យពួកគេរៀន។ពួកគេមានតម្រូវការ កង្វល់ និងចំណាប់អារម្មណ៍ផ្សេងៗប្រកួតជាមួយតម្រូវ ការស្មារតីនិងតម្រូវការសោភ័ណ។នៅពេលដែលគ្រូយើងធ្វើការជាមួយសិស្សមួយកម្រិតដោយការប៉ាន់ ស្មានថាសិស្សរបស់យើងមានតម្រូវការមូលដ្ឋានគ្រប់គ្រាន់នៅផ្ទះនោះកង្វះខាតរបស់សិស្សបង្កើតនូវបញ្ហា ចំណេះដឹងដែលនាំឱ្យលទ្ធផលនៃការសិក្សា បរាជ័យ និងបាត់បង់សក្ដានុពលរបស់សិស្ស។

## ៨.៤. វិធីសាស្ត្រក្នុងការជម្រុញទឹកចិត្តសិស្ស

លោកគ្រូ អ្នកគ្រូត្រូវមានទំនួលខុសត្រូវ ដើម្បីជួយសិស្សឱ្យមានចំណាប់អារម្មណ៍ក្នុងការសិក្សារៀនសូត្រ និងការទទួលបានជោគជ័យ។ គ្រូមិនត្រូវធ្វើឱ្យសិស្សធុញទ្រាន់ឡើយ ប៉ុន្តែត្រូវធ្វើឱ្យសិស្សចាប់មានការអារម្មណ៍លើកិច្ចការសាលា។ ខាងក្រោមនេះ គឺជាមូលដ្ឋាននៃការឆ្លើយតបទៅនឹងទ្រឹស្ដីកម្លាំងជំរុញសម្រាប់ណែនាំអ្នកសិក្សាឱ្យទទួលបានជោគជ័យៈ

១. ត្រូវដឹងឱ្យច្បាស់ថា សិស្សអាចបំពេញតម្រូវការមូលដ្ឋានរបស់សាលា។ ផ្ដល់ពេលវេលាគ្រប់គ្រាន់ដើម្បីឱ្យសិស្សពិភាក្សាលើការសិក្សា និងសេចក្ដីរំពឹងទុករបស់សង្គម មានទំនួលខុសត្រូវ និងអាកប្បកិរិយាត្រឹមត្រូវ។

២.ធ្វើឱ្យថ្នាក់រៀនមានផាសុខភាព របៀបរៀបរយ និងរីករាយ។ អារម្មណ៍របស់សិស្សម្នាក់ៗ និងភាពកក់ក្ដៅខាងផ្លូវចិត្តរបស់ពួកគេត្រូវបានទទួលរងនូវឥទ្ធិពលពីកត្តាជាច្រើនដូចជាៈ សីតុណ្ហភាព ពន្លឺ ការរៀប ចំគ្រឿងសង្ហារឹម រូបភាព តារាងព្រឹត្តិបត្រ និងភាពស្អាត។

៣.ជួយឱ្យសិស្សចេះសង្កេតតាមដានកិច្ចការមានតម្លៃក្នុងថ្នាក់។អ្នកសិក្សាត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យពួកគេជឿថា កិច្ចការដែលពួកគេបានធ្វើគឺទាក់ទងនឹង តម្រូវការ ចំណាប់អារម្មណ៍ និងគោលបំណងរបស់ពួកគេ។

៤. ត្រូវប្រាកដក្នុងចិត្តថា កិច្ចការដែលដាក់ទៅឱ្យសិស្សគឺសមស្របតាមកម្រិតសមត្ថភាព យល់ដឹងរបស់សិស្ស។ប្រសិនបើកិច្ចការលំបាកពេក នោះសិស្សនឹងរុញរា អាក់អន់ចិត្ត យ៉ាងឆាប់រហ័ស និងបោះបង់នូវជំនឿចិត្តលើខ្លួនឯង។ប្រសិនបើកិច្ចការងាយស្រួលពេកនោះនាំឱ្យសិស្សធុញទ្រាន់ និងបាត់ បង់នូវចំណាប់អារម្មណ៍លើកិច្ចការដោយថាហេតុ។

៥. ចូរចាំថា សិស្សមានកម្រិតនៃក្ដីបារម្ភ និងតម្រូវការនៃការរីកចម្រើនមិនដូចគ្នាទេ។ សិស្សខ្លះត្រូវការពេលវេលា ការគាំទ្រ ឬការជួយជ្រោមជ្រែងលើសគេ ពីព្រោះពួកគេ ហាក់ដូចជាមិនត្រូវបានគេជួយលើកទឹកចិត្ត។ភាគច្រើននៃអាកប្បកិរិយានេះ គឺជាយន្តការការពារមួយ ដែលនាំមកដោយការបរាជ័យ

ភាពខ្វះខាតនៃការដាស់តឿន ឬភាពខ្សត់ខ្សោយ នៃការគោរពខ្លួនឯង។សិស្សដ៏ទៃទៀតត្រូវបានគេចិញ្ចឹម អប់រំនៅក្នុងបរិស្ថានដែលលទ្ធផល ក្នុងសំពាធគ្មានទុក្ខព្រួយនិងតម្រូវការដែលល្អជាងនេះ។

៦.ជួយសិស្ស ឱ្យមានទំនួលខុសត្រូវយ៉ាងត្រឹមត្រូវ លើភាពជោគជ័យ និងបរាជ័យរបស់ពួកគេ សិស្សត្រូវការឱ្យគេបង្រៀនព្រោះពួកគេ មិនអាចធ្វើបានល្អលើសលប់លើគ្រប់សកម្មភាពទេ។ សិស្សខ្លះដែលមិនអាចធ្វើការសម្តែងចេញបានល្អលើចំណុចមួយ អាចអភិវឌ្ឍដោយការខិតខំប្រឹងប្រែងហើយក៏អាច ធ្វើបានល្អលើចំណុចផ្សេងៗទៀតផងដែរ។បង្កើតភាពខ្លាំងរបស់សិស្សធ្វើការជំរុញភាពទន់ខ្សោយរបស់សិស្ស និងជំរុញលើក ទឹកចិត្តដោយមិនបំភ្លេចចោលឡើយ។

៧. ជួយសិស្សបង្កើតគោលដៅសមហេតុផល។ ជំរុញ និងលើកទឹកចិត្តសិស្សឱ្យគេបង្កើត គោលបំណងខ្លី ប្រាកដនិយម។ពិភាក្សា ពីតម្រូវការសម្រាប់ផែនការអនុវត្ត និងការតស៊ូ។

៨. ផ្តល់នូវសកម្មភាពរៀនដ៏សម្បូរបែប ខុសៗគ្នា។ ផ្លាស់ប្តូរសកម្មភាពណែនាំ ដើម្បីជួយឱ្យសិស្សផ្តោតបម្រុងប្រយត្ន័ និងបង្កើតការចាប់អារម្មណ៍ជាថ្មី។ សិស្សក្មេងៗ និងសិស្សដែលខ្សោយត្រូវការសកម្មភាពខុសៗគ្នា ច្រើនប្រភេទ ដើម្បីជៀសវាងភាពធុញទ្រាន់។

៩. ប្រើវិធីបង្រៀនថ្មី និងវិធីណែនាំអន្តរអំពើ។ គំនិតនេះ គឺធ្វើឱ្យសិស្សសួរ "ហេតុអ្វី" "តើវាកើតឡើងយ៉ាងដូចម្តេច?""តើនឹងមានអ្វីកើតឡើង ប្រសិនបើខ្ញុំធ្វើ X, Y or Z?" គោលបំណង គឺចង់នាំសិស្ស ឱ្យចាប់អារម្មណ៍ រួចហើយពិចារណា។ ជាងនេះទៅទៀត គ្រូនិយាយច្រើនពេកនាំឱ្យសិស្សអផ្សុក ឬអសកម្ម។

១០. ប្រើ វិធីរៀន ដោយសហការ។គ្រូ នាំសិស្សឱ្យចូ លរួមធ្វើការងារជាមួ យគ្នា ពួកគេធ្វើការងារជាក្រុម។ ដូច នេះជ័យជម្នះរបស់សិស្សម្នាក់ ជួយឱ្យសិស្សដ៏ទៃទៀតទទួលបានជោគជ័យ។ ការរៀនសូត្របែបសហការ កាត់បន្ថយភាពតានតឹង និងការថប់បារម្ភផងដែរ ពិសេសចំពោះសិស្ស ដែលសម្រេចកិច្ចការបានតិចតួច។

១១.ពិនិត្យតាមដានការងាររបស់សិស្ស និងផ្តល់ពត៌មានត្រឡប់ដល់សិស្ស។ លទ្ធផល នៃចំណេះដឹង ការកត់ត្រាអំពីកិច្ចការផ្ទះ ឬការងារស្រាវជ្រាវ ទោះបីគ្រូគ្រាន់តែ ងក់ក្បាល ឬការសរសើរដោយពាក្យសំដីក៏សុទ្ធតែជាពត៌មានត្រឡប់ដែលសិស្សទទួលបាន និងត្រូវការចាំបាច់សម្រាប់គោលបំណងនៃការគាំទ្រ និងការទទួលស្គាល់។

១២.ផ្តល់នូវរបៀបសម្រាប់បង្កើនសមត្ថភាព។ ការពន្យល់ ពីបំណិននៃការសម្តែង និងរបៀប បង្កើនសមត្ថភាព គឺសំខាន់ណាស់ ព្រោះវាជាការអនុញ្ញាតឱ្យសិស្សធ្វើការកែប្រែជៀសវាងទម្លាប់អាក្រក់ និងការយល់ខ្លឹមសារបានល្អលើមុខវិជ្ជានិមួយៗ។

## ៨.៥. ការបំផុសគំនិតសិស្សអោយចង់រៀន (Motivation)

### ៨.៥.១. វិធីធ្វើការសិក្សារបស់សិស្សឱ្យមានលក្ខណៈសកម្ម (Ways to make learning active)

តើខ្ញុំផ្តល់អោយសិស្សខ្ញុំនូវជោគវាសនាល្អមអោយគេមានចរិតសកម្មក្នុងការសិក្សាដែរ ឬទេ ។

*សេចក្តីណែនាំ:*

ពិនិត្យមើលឧទាហរណ៍ស្តីពីចរិតសកម្មភាពរបស់សិស្សក្នុងការសិក្សា ហើយរៀបចំជាគម្រោងប្រើប្រាស់វិធីណាមួយឬវិធីខ្លះនៅក្នុងរយៈពេលពីរ បីថ្ងៃក្រោយមក ។

### ៨.៥.២. វិធីលើកកំពស់ការសិក្សាស្រាវជ្រាវរបស់សិស្ស (Ways to promotes investigation)

តើមានវិធីផ្សេងៗដែលខ្ញុំអាចផ្តល់ឱកាសដ៏ច្រើនអោយសិស្សខ្ញុំបានសិក្សាស្រាវជ្រាវឬទេ ។

*សេចក្តីណែនាំ:*

ពិនិត្យពិច័យមើលលទ្ធភាពនៃការបង្កើតអោយមានមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនៅក្នុងបន្ទប់រៀន ។ នាំសមូហភាពសិស្សទាំងមូលចូលទៅក្នុងបណ្ណាល័យ ហើយប្រាប់ពួកគេអោយរើសសៀវភៅដែលគេចូលចិត្តដាក់មួយជុំ ។ សួរសមូហភាពសិស្សអោយលើកឡើងពីលទ្ធភាពនៃការសិក្សាស្រាវជ្រាវឬការធ្វើបាឋកកថា ។

**៨.៥.៣. វិធីលើកឡើងពីការសិក្សាតាមបែបផ្សងព្រេង**: ( Ways to make learning seem adventurous )

តើខ្ញុំមានវិធីណាដែលខ្ញុំអាចយកមកប្រើប្រាស់ស្របច្បាប់ និង ប្រកបដោយប្រសិទ្ធភាពហើយជាបច្ចេកវិធីប្លែក ចំពោះសមូហភាពសិស្សនៅក្នុងរៀនរបស់ខ្ញុំឬទេ ។

*សេចក្តីណែនាំ* : នៅក្នុងពេលដែលខ្ញុំធ្វើកិច្ចតែងការបង្រៀន នៅក្នុងជំពូកថ្មីនៃនៃមេរៀនណាមួយ ខ្ញុំត្រូវគិតពីវិធីដែលធ្វើអោយសិស្សរំភើបខ្លាំង ឬក៏វិធីណាមួយដែលមិនធ្វើអោយ សិស្សមានការរង់ចាំក្នុងការបង្ហាញពីវត្ថុបំណងនៃមេរៀន ពិនិត្យសង្កេតមើលវិធីដែលបែងចែកដោយលោក គូឡាំ ដើម្បីអោយដឹងថាតើសកម្មភាពបញ្ជាក់ពីលក្ខណៈផ្សេងៗ ឬ សកម្មភាពដដែលៗ សក្តិសម ទៅនឹងគំរោងកិច្ចតែងការបង្រៀនដែរ ឬទេ ។

**៨.៥.៤. វិធីជំរុញអោយសិស្សសិក្សាពីសង្គម** : ( Ways to make learning social )

តើខ្ញុំផ្តល់ឱកាសអោយសិស្សខ្ញុំចូលរួមនៅក្នុងអន្តរកម្មក្នុងសង្គមដែរ ឬទេ នៅពេលដែលពួកគេកំពុងរៀនតាមកម្មវិធីក្នុងសាលារៀន ។

*សេចក្តីណែនាំ* : ចែកសិស្សជាក្រុមហើយចែកពួកគេអោយសិក្សា ដើម្បីត្រៀមប្រលង ឬក៏ប្រាប់ពួកគេអោយធ្វើរបាយការណ៍។ ពិនិត្យសង្កេតមើលទៅលើការចាត់តាំងតួនាទីអោយសិស្សម្នាក់ៗ ឬការដកពិសោធន៍ពីគ្នាទៅវិញទៅមក ។

**៨.៥.៥. វិធីជំរុញអោយសិស្សយល់ពីអត្ថប្រយោជន៍ក្នុងការសិក្សា**: Ways to make learning Useful

ខ្ញុំកំពុងធ្វើអោយប្រាកដប្រជាចំពោះសិស្សរបស់ខ្ញុំអោយគេយល់ដឹងថាអ្វីៗ ដែលពួកគេកំពុងរៀនមាន

ប្រយោជន៍និងមានសក្តានុពលចំពោះពួកគេ ។

*សេចក្តីណែនាំ* : ជារឿយៗគ្រូគប្បីបង្ហាញសិស្សថា តើគេត្រូវរៀនអំពីអ្វី ហើយត្រូវរៀនយ៉ាងដូចម្តេច ដើម្បីអោយពួកគេមើលឃើញអត្ថប្រយោជន៍។ ចែកលំហាត់អោយសិស្សធ្វើនេះជាការបង្ហាញអោយដឹងពីតម្លៃនៃសក្តានុពលចំពោះអ្វីៗ ដែលគេកំពុងរៀន ។

**៨.៥.៦. វិធីកែអាកប្បកិរិយានៅក្នុងបច្ចេកវិធីបំផុសគំនិតសិស្សអោយចេះចង់រៀន:**

( Using behavior modification techniques to motivate )

តើខ្ញុំកំពុងតែកែប្រែអាកប្បកិរិយានៅក្នុងបច្ចេកវិធីដើម្បីជួយសិស្សអោយមានទំនាក់ទំនងជាមួយខ្លឹមសារមេ

រៀនដែលមិនធ្វើអោយសិស្សចាប់អារម្មណ៍នៅក្នុងការបំផុសគំនិតនៅក្នុងខ្លួនសិស្សអោយរៀនយកស្នាដៃ ឬទេ។

*សេចក្តីណែនាំ*: ពិនិត្យសង្កេតមើល ចំពោះការបង្កើតអោយមានភារកិច្ចមួយចំនួន ដើម្បីអោយសិស្សយល់ដឹងពី វឌ្ឍនភាពរបស់ខ្លួន ។ បំពាក់បំប៉ននូវការពង្រឹងជាវិជ្ជមានទៅតាមរូបភាពនៃការធ្វើអត្ថាធិប្បាយផ្ទាល់មាត់ ឬដោយការសរសេរ។ លើកទឹកចិត្តសិស្សអោយចេះប្រើប្រាស់បច្ចេកទេសកែប្រែអាកប្បកិរិយាផ្ទាល់ខ្លួនទៅតាមនីតិវិធីស្រដៀងគ្នា ដូចបានពិពណ៌នាស្រាប់ ។

**៨.៥.៧. វិធីសម្របសម្រួលគោលបំណងសិក្សាសំរាប់រយៈពេលខ្លី** (Ways to arrange short-term goals)

តើខ្ញុំមានរំពឹងទុកថា សិស្សរបស់ខ្ញុំសិក្សាឆ្ពោះទៅរកគោលបំណងមួយដែលគេមានភាពធុញទ្រានដែរ ឬទេ ។ *សេចក្តីណែនាំ:* ព្យាយាមបង្កើតអោយមានជម្រើសបណ្ណាល័យសិក្សាដូចៗគ្នា ឬក៏ប្រើប្រាស់ប្រព័ន្ធសិក្សាប្លែកៗពីគ្នា ទៅតាមសិស្សម្នាក់ៗ ។

**៨.៥.៨. វិធីវិភាគពីបញ្ហានៃកំណែប្រែអាកប្បកិរិយា** (Ways to analyze motivation problem)

តើខ្ញុំកំពុងប្រើប្រាស់ប្រព័ន្ធកម្មក្នុងការវិភាគទៅលើបញ្ហានៃការបំផុសគំនិតសិស្ស អោយចង់រៀនដែរ ឬទេ ។

*សេចក្តីណែនាំ:* ធ្វើការកត់ចំណាំសម្រាប់យកមកពិនិត្យ សង្កេតអោយដឹងថា តើសិស្សឆ្លើយតបយ៉ាងដូចម្តេច ចំពោះភារកិច្ចដែលដាក់អោយវាធ្វើ រួចមកត្រូវប្រមើលមើលពីមូលហេតុដែលធ្វើអោយសិស្សបាត់បង់ការបំផុសគំនិតចង់រៀនរបស់ពួកគេ ដោយសំអាងទៅលើរបៀបជួយដោះស្រាយបញ្ហា ដូចមានពិពណ៌នាស្រាប់ ។

**៨.៥.៩. វិធីអោយសិស្សពេញចិត្ត និងតម្រូវការផ្នែកសរីរៈ** (Ways to satisfy physiological need)

តើខ្ញុំកំពុងលើកយកមកពិចារណាអំពីតម្រូវការផ្នែកសេរីរៈរបស់សិស្សខ្ញុំដែរឬទេ ។

*សេចក្តីណែនាំ:* ធ្វើជាតារាងស្តីពីវិធីពិសេសៗដើម្បីអោយដឹងប្រាកដប្រជាថា សិស្សមានការពេញចិត្តចំពោះតម្រូវការផ្នែកសរីរៈ ឧទាហរណ៍ : សិស្សចូលបង្គន់ បន្ទប់ទឹក ជាញឹកញយដង គឺជាការដ៏ត្រឹមត្រូវរបស់ពួកគេ ។ យូរម្តងៗ គប្បីសួរសិស្ស តើបន្ទប់បង្គន់ ឬ បន្ទប់ទឹកនោះក្តៅពេក ឬ ត្រជាក់ពេក ។ ពិនិត្យតាមដានសិស្សនៅពេលម៉ោងស្រស់ស្រូបអាហារ ឬបង្ខំសិស្សអោយចុះ ទៅស្រស់ស្រូបអាហារនៅចន្លោះម៉ោងរៀន ។

**៨.៥.១០. វិធីធ្វើអោយសិស្សមានតម្រូវការផ្នែកសុវត្ថិភាព** (Ways to satisfy safety needs)

តើខ្ញុំកំពុងធ្វើអ្វីៗ ដើម្បីបង្កជំរុញសិស្សរបស់ខ្ញុំ អោយមានការព្រួយបារម្ភអំពីសុវត្ថិភាពជាផ្លូវកាយឬផ្លូវចិត្តដែរឬទេ ?

*សេចក្តីណែនាំ:* ធ្វើជាបញ្ជីមួយលើកឡើងអំពីអ្វីដែលសិស្សត្រូវការ និងអ្វីដែលសិស្សមិនត្រូវការផ្នែកសុវត្ថិភាព ឧទាហរណ៍ ចៀសវាងការជំរុញសិស្សអោយធ្វើសកម្មភាពបែបណាមួយ ប្រសិនបើសិស្សវាបញ្ចេញអាកប្បកិរិយា អោយឃើញថា គេយល់ដឹងពីសកម្មភាពនោះរួចហើយ ។ កត់ត្រាចំណុចទាំងនោះដើម្បីសំដែងនូវសមានចិត្តជួយគាំទ្រ សិស្សក្រោយពេលដែលសិស្សមានបទពិសោធន៍ហើយ ។

**៨.៥.១១. វិធីធ្វើអោយសិស្សពេញចិត្តនឹងតម្រូវការផ្នែកកម្មសិទ្ធ** (Ways to satisfy

belonging needs )

តើសិស្សរបស់ខ្ញុំបញ្ចេញនូវអារម្មណ៍ស្វាគមន៍ មានទឹកមុខរីករាយនឹងទទួលរាក់ទាក់នឹងខ្ញុំឬទេនៅពេលដែលខ្ញុំ ដើរមកក្នុងថ្នាក់រៀន ។

*សេចក្តីណែនាំ* : នៅខែក្រោយកាលវិភាគខ្លះក្នុងការរៀបចំសកម្មភាពរបស់សិស្ស ការរៀបចំ ផែនការប្រជុំខ្លីៗ ជាមួយសិស្សម្នាក់ៗ ដែលធ្វើអោយខ្ញុំមានអន្តរកម្មដោយផ្ទាល់ជាមួយសិស្សរបស់ខ្ញុំម្នាក់ៗ ។

**៨.៥.១២. វិធីធ្វើអោយសិស្សពេញចិត្តនឹងតម្រូវការផ្ទាល់ខ្លួន** ( Ways to satisfy esteen needs )

តើខ្ញុំបានបង្ក្រាបដោយចៃដន្យទៅលើសតិអារម្មណ៍សិស្សរបស់ខ្ញុំបានដែរ ឬទេ ។

*សេចក្តីណែនាំ* : ស្វែងរកវិធីសម្រាប់ជួយសម្រាលដល់ស្ថានភាពនៃការប្រៀបធៀបគ្នាជាទូទៅ ។ ចាត់ទុកការប្រើប្រាស់ប្រព័ន្ធអប់រំបុគ្គលិកលក្ខណៈអោយបានសមស្រប ។ ព្យាយាមដាក់កិច្ចការអោយសិស្សធ្វើជាបុគ្គល ដើម្បីអោយសិស្សទាំងអស់អាចលើកកំពស់កម្រិតយល់ដឹងរបស់ខ្លួនបាន ។

**៨.៥.១៣. វិធីលើកទឹកចិត្តសិស្សម្នាក់ៗអោយមានគំនិតប្រកួតប្រជែង** ( Ways to encourage self-competition )

តើខ្ញុំមាននឹកឃើញដល់ការបាត់បង់ផលប្រយោជន៍របស់សិស្សនៅក្នុងរចនាសម្ព័ន្ធក្នុងការសិក្សាដែរឬទេ។ *សេចក្តីណែនាំ :* ត្រូវធ្វើជាបញ្ជីរក្សាទុកនូវវឌ្ឍនភាពរបស់សិស្សម្នាក់ៗ ។ ជួយផ្តល់អោយសិស្សនូវចំណេះដឹង នូវការបញ្ចេញ បាននូវស្នាដៃល្អទៅតាមសកម្មភាពប្លែកៗ ពីគ្នាអនុវត្តតាមសេចក្តីណែនាំ ដែលអាចជួយលើកទឹកចិត្តសិស្សអោយចេះ បង្កើតបាននូវគោលបំណងផ្ទាល់ខ្លួន និង រកអោយឃើញនូវវិធីផ្សេងៗគ្នា សំដៅគាំទ្រអោយមានព័ត៌មានត្រឡប់ជាវិជ្ជមាន ។

encourage to said their own objective

**៨.៥.១៤.តើខ្ញុំកំពុងអនុញ្ញាតិអោយសិស្សរបស់ខ្ញុំចូលរួមក្នុងការបង្កើតបាននូវគោលបំណងផ្ទាល់ខ្លួនក្នុងការសិក្សាដែរ ឬទេ** ?

*សេចក្តីណែនាំៈ* ជំរុញសិស្សអោយចេះបង្កើតបាននូវគោលបំណងផ្ទាល់ខ្លួន ដោយផ្តើមចេញពីវត្ថុបំណងទៅតាមពេលវេលាជាកំណត់ចំនួនសមាមាត្រនៃចម្លើយដ៏ត្រឹមត្រូវ ឬតំណាងទង្វើទាំងឡាយដែលត្រូវធ្វើអោយបានសម្រេច

**៨.៥.១៥. វិធីទ្រទ្រង់អោយមានការផ្តល់ព័ត៌មានត្រឡប់ជាវិជ្ជមាន** ( Ways to supply positive feedback )

តើខ្ញុំកំពុងរៀបចំអោយសិស្សខ្ញុំផ្តល់ព័ត៌មានត្រឡប់ដ៏សំបូរបែប ទៅតាមវិធីប្រកបដោយប្រសិទ្ធភាពដែរឬទេ។ កាលណាខ្ញុំប្រើប្រាស់ការលើកសរសើរ តើខ្ញុំបានប្រើបច្ចេកវិធីដ៏មានប្រសិទ្ធភាពដែលលោក ប្រូហ្វីបានណែនាំដែរឬទេ ។

*សេចក្តីណែនាំៈ*កាលណាចប់ការងារបង្រៀនសិស្សពេញមួយថ្ងៃខ្ញុំត្រូវរក្សាទុកនូវកំនត់ត្រារបស់ថាតើខ្ញុំត្រូវលើកសរ សើរសិស្សខ្ញុំយ៉ាងដូចម្តេច។ រួចមកខ្ញុំធ្វើវិភាគលើចម្លើយរបស់សិស្សចំពោះការលើកសរសើរនោះដោយបញ្ជាក់ទៅ តាមចំណុចដែលលោក ប្រូហ្វីបានលើកឡើង និងតាមព័ត៌មានសង្ខេប ។

**៨.៥.១៦. វិធីរៀបចំអោយសិស្សដឹកនាំការសិក្សាផ្ទាល់ខ្លួន** ( Ways to permit students to

direct their own learning )

**តើខ្ញុំប្រើអំណាចផ្តាច់ការពេកឬ ក្នុងការកំណត់ពីអ្វីៗ ដែលសិស្សត្រូវរៀន ហើយតើខ្ញុំត្រូវកំណត់អោយ**សិស្ស រៀនយ៉ាងដូចម្តេច : ពិនិត្យពិច័យមើលអំពីការប្រើប្រាស់នីតិវិធីសម្រាប់ចងក្រងប្រធានបទអោយសិស្សសិក្សា ដែលលើកឡើងដោយលោកហូវ វិធីសម្រាប់បង្កើតអោយមានកិច្ចសន្យាផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ ដែលរៀបចំឡើងដោយលោករ៉ូលកូស្គី ឬក៏ពិនិត្យមើលបញ្ជីដែលគាត់តែងឡើងដោយលោក សូរិនសុង លោកស្មិន និង លោកបារី អំពីការអប់រំអាកប្បកិរិយាសិស្សឱ្យចុះសម្រុងក្នុងសង្គម ។

**៨.៥.១៧.វិធីលើកទឹកចិត្តសិស្សអោយមានតម្រូវការនៅក្នុងការសម្រេចស្នាដៃសិក្សា** ( **Encouraging a need for achievement** )

តើខ្ញុំកំពុងលើកទឹកចិត្ត ធ្វើអោយសិស្សបាក់ទឹកចិត្តនៅក្នុងការធ្វើអោយអភិវឌ្ឍនូវអត្ថន័យនៃមុខងារផ្ទាល់ខ្លួនរបស់គេម្នាក់ៗ ។

*សេចក្តីណែនាំ* : ត្រូវប្រាប់ដល់សិស្សដែលធ្វើការបានលទ្ធផលខ្សត់ខ្សោយថាពួកគេអាចលើកកំពស់ការសិក្សារបស់ពួកគេបាន ។ រួចមកត្រូវលើកទឹកចិត្តពួកគេអោយព្យាយាមសិក្សាដោយផ្ទាល់ អោយគេនូវកិច្ចការមួយ ចំនួនពីងាយស្រួលទៅលំបាក រួចជំរុញពួកគេអោយចេះបង្កើតនូវគោលបំណងនៃការសិក្សាផ្ទាល់ខ្លួន ត្រូវពិនិត្យពិច័យមើលពីគោលបំណង នៃការពង្រឹងសញ្ចេតនាក្នុងការចេះអោយតម្លៃលើខ្លួនឯងដោយប្រើប្រាស់បច្ចេកវិធីប្រហាក់ប្រហែលគ្នាទៅនឹងបច្ចេកវិជ្ជាដែលពិពណ៌នាដោយលោក ឆាម ។

**៨.៥.១៨. វិធីប្រើប្រាស់កិច្ចការគំរូ ដើម្បីលើកទឹកចិត្តសិស្សអោយចង់រៀន** ( Way to use modeling toencourage motivation to learn )

តើខ្ញុំបង្កើតអោយមានគំរូដ៏ល្អហើយទាក់ទងទឹកចិត្តសិស្សអោយទាញយកអត្ថប្រយោជន៍យ៉ាងយកចិត្តទុកដាក់ ក្នុងការសិក្សាដែលនាំឆ្ពោះទៅរកបានការសម្រេចបានស្នាដៃគួរជាទីចាប់អារម្មណ៍ដែរ ឬទេ ។

*សេចក្តីណែនាំ* : បង្ហាញអោយសិស្សមើលឃើញនូវអត្ថប្រយោជន៍ និង បរិយាកាសដ៏រីករាយនៅក្នុងការសិក្សាទៅតាម ការដែលអាចធ្វើទៅបាន ។ ចេះទាក់ទាញស្មារតីរបស់សិស្ស អោយចេះយល់ពីវីរៈភាពរបស់វីរៈជន ក្នុងទំព័រប្រវត្តិសាស្ត្រ ដែលបានធ្វើសម្បទានដ៏មានអត្ថន័យទៅតាមមុខវិជ្ជាផ្សេងៗគ្នា ។

## ៨.៦.គោលការណ៍ណែនាំៈ ពីការលើកទឹកចិត្តដើម្បីរៀនសូត្រភាពជាដៃគូក្នុងគ្រួសារ និងសហគមន៍

- **យល់ពីគោលបំណងគ្រួសារសម្រាប់កុមារ**

*ឧទាហរណ៍*

1. នៅតាមកន្លែងជួបជុំគ្នាក្រៅផ្លូវការ នៅតាមហាងកាហ្វេ ឬពេលញ៉ាំអាហារសម្រន់ ជួបជុំជាមួយគ្រួសាររៀងៗខ្លួន ឬជាក្រុមតូចៗដើម្បីស្តាប់គោលបំណងរបស់គេសម្រាប់កូនៗរបស់គេ។
2. ផ្ញើកម្រងសំណួរឬផ្ញើកាតឆ្លើយតបនៅតាមផ្ទះទុកឱ្យសិស្ស ដោយសួរថាតើជំនាញអ្វីដែលក្រុមគ្រួសារជឿថាកូនៗ របស់ពួកគេត្រូវការប្រើច្រើនជាងគេ។ ជ្រើសរើសគោលដៅមួយសម្រាប់កុមារម្នាក់ៗ ហើយបង្កើតផែនការសម្រាប់ធ្វើការឆ្ពោះទៅរកគោលដៅទាំងក្នុងនិងក្រៅសាលា។ ចែករំលែកផែនការជាមួយក្រុមគ្រួសារនិងសុំយោបល់ត្រឡប់។

- **កំណត់ចំណាប់អារម្មណ៍របស់សិស្សនិងក្រុមគ្រួសារដែលអាចទាក់ទងទៅនឹងគោលដៅ**

*ឧទាហរណ៍*

1. សុំឱ្យសមាជិកគ្រួសារចែករំលែកជំនាញឬសកម្មភាពកម្សាន្ត
2. កំណត់ "ចំណង់ចំណូលចិត្តគ្រួសារ" ដូចជា អាហារដែលចូលចិត្ត តន្ត្រី វិស្សមកាល កីឡា សកម្មភាព ចម្រៀង ខ្សែភាពយន្ត ហ្គេម អាហារសម្រន់ រូបមន្តធ្វើម្ហូប ការចងចាំ។ ចងភ្ជាប់មេរៀនក្នុងថ្នាក់ទៅនឹងចំណាប់អារម្មណ៍។

- **ផ្តល់ឱ្យគ្រួសារនូវវិធីដើម្បីមួយតាមដានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅ**

*ឧទាហរណ៍*

1. ផ្តល់ជូន "គំនូសតាងស្តីពីវឌ្ឍនភាព" ឬកាតគោលដៅសាមញ្ញដែលអាចដាក់លើទូទឹកកក
2. សុំយោបល់ពីឪពុកម្តាយឬអ្នកថែទាំ ( និងបញ្ជាក់វា )អំពីប្រសិទ្ធភាពរបស់អ្នកក្នុងការជួយកូនៗរបស់ពួកគេ។

- **ធ្វើការជាមួយក្រុមគ្រួសារដើម្បីកសាងទំនុកចិត្តនិងការរំពឹងទុកវិជ្ជមាន**

*ឧទាហរណ៍*

1. ចៀសវាងប្រៀបធៀបកុមារម្នាក់នៅក្នុងគ្រួសារទៅនឹងកុមារម្នាក់ទៀតអំឡុងពេលសន្និសីទនិងពិភាក្សាជាមួយសមាជិកគ្រួសារ។
2. សុំឱ្យសមាជិកគ្រួសារលើកឡើងពីចំណុចខ្លាំងនៃកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។ ពួកគេអាចភ្ជាប់កំណត់ត្រាទៅនឹងកិច្ចការដែលពិពណ៌នាអំពីទិដ្ឋភាពល្អបំផុតទាំងបីនៃការងារ និងធាតុមួយដែលអាចត្រូវបានកែលម្អ។

- **ធ្វើឱ្យដៃគូក្នុងគ្រួសារបង្ហាញតម្លៃនៃការរៀនសូត្រ។**

*ឧទាហរណ៍*

1. អញ្ជើញសមាជិកគ្រួសារចូលក្នុងថ្នាក់ដើម្បីបង្ហាញពីរបៀបដែលពួកគេប្រើគណិតវិទ្យាឬការសរសេរនៅក្នុងការងាររបស់ពួកគេ។
2. ទាក់ទងឪពុកម្តាយ ឬ អ្នកថែទាំក្នុងការកំណត់ជំនាញ និង ចំណេះដឹងដែលអាចត្រូវបានអនុវត្តនៅផ្ទះហើយបង្ហាញថាមានប្រយោជន៍ដល់គ្រួសារនាពេលបច្ចុប្បន្ននេះ ឧទាហរណ៍៖ការរក្សាទុកកំណត់ហេតុទីភ្នាក់ងារភ្នាក់ងារ សរសេរលិខិតបណ្តឹងទៅកាន់ហាងនាយកដ្ឋានឬម្ចាស់ដីឬស្រាវជ្រាវទិសដៅវិស្សមកាល។

- **ផ្តល់ធនធានដែលកសាងជំនាញនិងឆន្ទៈសម្រាប់គ្រួសារ**

*ឧទាហរណ៍*

1. ផ្តល់ឱ្យសមាជិកគ្រួសារនូវយុទ្ធសាស្ត្រងាយៗសម្រាប់ជួយកូនៗរបស់ពួកគេបង្កើនជំនាញសិក្សា។
2. ទាក់ទងសិស្សដែលមានអាយុច្រើនឱ្យធ្វើ "កិច្ចការផ្ទះ" តាមបណ្តាញទូរស័ព្ទសម្រាប់ជួយដល់សិស្សក្មេងៗ។

- **ប្រារព្ធពិធីឱ្យបានញឹកញាប់ស្តីពីការរៀនសូត្រ**

*ឧទាហរណ៍*

1. អញ្ជើញក្រុមគ្រួសារទៅកាន់ "សារមន្ទីរ" នៅចុងបញ្ចប់នៃមេរៀនស្តីពីសត្វដាយណូស័រ។ សិស្សបង្កើតសារមន្ទីរនៅសាវនដ្ឋាន បណ្ណាល័យ ឬ ហាងកាហ្វេ។បន្ទាប់ពីបានទស្សនា សារមន្ទីរ ក្រុមគ្រួសារបានចូលទៅកាន់ថ្នាក់រៀនដើម្បីពិនិត្យមើលផលប័ត្រ (បណ្តុំឯកសារ) របស់កូនៗរបស់គេសម្រាប់មួយមេរៀន។
2. ដាក់តាំងពិព័រណ៍ខ្នាតតូចនៃការងាររបស់សិស្ស នៅតាមហាងលក់គ្រឿងទេសក្នុងស្រុក បណ្ណាល័យ ឬមជ្ឈមណ្ឌលសហគមន៍។

## ៨.៧. ការលើកទឹកចិត្តនៅក្នុងថ្នាក់រៀន ( Motivation in the classroom )

សព្វថ្ងៃនេះគ្រូៗនិងអ្នកស្រាវជ្រាវជាច្រើនយល់ស្របថា ការលើកទឹកចិត្តសិស្ស គឺមានសារៈសំ ខាន់ខ្លាំងណាស់ សម្រាប់ការសម្តែងសកម្មភាពរបស់សាលា រួមបញ្ចូលទាំងកម្លាំងជំរុញ ដើម្បីធ្វើឱ្យ សម្រេចបាននូវគោលបំណងនៃការសិក្សា។ ចំណាប់អារម្មណ៍ និងការប្រឹងប្រែងក្នុងការងារសិក្សា ការព្យា យាមធ្វើកិច្ចការក្នុងថ្នាក់ កិច្ចការផ្ទះ បទបញ្ជាខ្លួនឯង ការប្រថុយ ទទួលរងគ្រោះថ្នាក់ និងការសិក្សា ដោយឯករាជ្យ។ល។

សូម្បីតែគ្រូដ៏មានបទពិសោធន៍ ជាញឹកញាប់គាត់ប្រើវិធីសាស្ត្របង្រៀនប្លែកៗ និងសម្ភារៈសម្បូរបែបដើម្បីជំរុញ និងលើកទឹកចិត្តសិស្ស ប៉ុន្តែក៏នៅមានសិស្សមួយចំនួន ដែលត្រូវការការដាស់តឿន ឬការលើកទឹកចិត្តបន្តិចបន្តួច ពីគ្រូរបស់ពួកគេ។ សិស្សនឹងខិតខំរៀនដោយខ្លួនឯងដូចជាការធ្វើកិច្ចការស្រាវជ្រាវដែលគ្រូផ្តល់ឱ្យ។ពួកគេម្ចាស់ការទទួល ខុសត្រូវលើការសិក្សា ផ្តល់កិច្ចការឱ្យគ្រូទាន់ពេលវេលា។ ជាពិសេស ពួកគេលែងមានបញ្ហាដូចជា ធុញទ្រាន់ ការភាន់ច្រឡំ និងភាពរុញរា ក្នុងការរៀនសូត្រទៀតឡើយ។ ទោះ បីយ៉ាងណាក៏ដោយ សិស្សភាគច្រើនត្រូវការការលើកទឹកចិត្ត ដើម្បីកាត់បន្ថយការបកស្រាយភ័ន្តច្រឡំ និង ភាពធុញទ្រាន់ របស់ពួកគេក្នុងការរៀនសូត្រ ហើយក៏ដើម្បីសម្រុះសម្រួលការអាក់អន់ចិត្តបានយ៉ាងច្បាស់ ច្រើនជាងការទុកឱ្យសិស្សគិតរវើរវាយ គូសលើតុមើលចេញទៅក្រៅបង្អួចឬក្លាយជាគ្មានសណ្តាប់ធ្នាប់។

## សន្និដ្ឋាន

ដើម្បីបង្កឱ្យការបង្រៀននិងរៀនប្រព្រឹត្តិទៅបានសមស្រប ទាំងគ្រូ ទាំងសិស្ស ត្រូវមានមូលហេតុនៃការបង្រៀន និងរៀនឱ្យបានច្បាស់លាស់ ងាយស្រួលក្នុងការរៀបចំ សកម្មភាពបង្រៀន និងសកម្មភាពរៀនផងដែរ។ ជាពិសេស គឺងាយក្នុងការប្រើវិធីសាស្ត្រ ដើម្បីជួយជំរុញ និងលើកទឹកចិត្តសិស្សឱ្យបាន សមស្របតាមវ័យសិក្សាពេលវេលា និងស្ថានភាពជាក់ស្តែង។ ការពេញចិត្តនឹងអ្វីមួយ ជួយឱ្យបុគ្គលធ្វើកិច្ច ការដោយយកចិត្តទុកដាក់។នេះជាកម្លាំងជំរុញមួយ ដែលធ្វើឱ្យមនុស្សបង្កើនសមត្ថភាព ក្នុងការ បំពេញការងារ ពិសេស គ្រូបង្រៀនត្រូវមានវិធីសាស្ត្រក្នុងការលើកទឹកចិត្ត ជួយឱ្យសិស្សទទួលបាន ជោគ ជ័យក្នុងការសិក្សា។

# ឯកសារយោង


– សៀវភៅគរុកោសល្យរបស់ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ឆ្នាំ ២០០២
– សៀវភៅគរុកោសល្យរបស់លោក បណ្ឌិត ចាន់ រដ្ឋសុផា ឆ្នាំ ២០០៤
– សៀវភៅគរុកោសល្យរបស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ឆ្នាំ ២០០៤
– សៀវភៅចិត្តវិទ្យាអប់រំភាគ២ របស់លោក បណ្ឌិត ចាន់ រដ្ឋសុផា ឆ្នាំ ២០១២
- វិទ្យាស្ថានជាតិអប់រំ (២០២០) គរុកោសល្យទូទៅ
- ចិត្តវិទ្យា គរុកោសល្យ ដោយបណ្ឌិតចាន់ រដ្ឋសុផា ឆ្នាំ២០០៨
- កំណែទម្រង់សាលារៀននៅកម្ពុជា ដោយបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឆ្នាំ២០២០
- ការអប់រំបរិយាបន្នមធ្យមសិក្សាទុតិយភូមិ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២០
- សៀវភៅសិក្សា ការអប់រំភាពជាពលរដ្ឋសកល វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៣
- Onn-Seang, T. et al. (2016). *Educational psychology*. an Asia edition.
- https://images.app.goo.gl/VQnXGxtcSqf3CAfA6
- Educational Psychology 2019
- Think Smarter
- Critical Thinking to Improve Problem-Solving and Decision-Making Skills By Michael Kallet, Mike Kallet • 2014